សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច

Université Royale de Droit et des Sciences Economies'

Royal University of Law and Economics

# សារណាបញ្ចប់ការសិក្សា

# ការព្យួរទោស

ស្រាវជ្រាវចាប់ពីថ្ងៃទី ០៨ ខែ មេសា ដល់ថ្ងៃទី ១០ ខែ សីហា ឆ្នាំ២០២៤

ស្រាវជ្រាវដោយ

និស្សិតឈ្មោះ: **កញ្ញា ផា ស៊ីឡៃ**

**លោក ស្រួន សុភ័ស**

ណែនាំដោយ

**លោកស្រី ឆែ វិជ្ជតា**

ថ្នាក់បរិញ្ញាបត្រ **នីតិសាស្ត្រ**

ជំនាន់ទី២៤

ឆ្នាំចូលសិក្សា ២០២០

ឆ្នាំសរសេរសារណា ២០២៤

# សេចក្តីថ្លែងអំណរគុណ

យើងខ្ញុំជានិស្សិតថ្នាក់បរិញ្ញាបត្រជំនាន់ទី២៤ ផ្នែកនីតិសាស្ត្រ នៃសាកលវិទ្យាល័យភូមិន្ទ នីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច ក្នុងឆ្នាំសិក្សា ២០២០-២០២៤ ដែលមានយើងខ្ញុំទាំងពីររូប រួមមានឈ្មោះ **ផា ស៊ីឡែ** និងឈ្មោះ **ស្រួន សុភ័ស** ។

**យើងខ្ញុំទាំងពីររូប សូមគោរពលំឱនកាយវាចារចិត្ត សូមធ្វើការសម្តែងនូវមហាកតញ្ញូតាធម៌ដឹងគុណយ៉ាងជ្រាលជ្រៅបំផុតជូនចំពោះ ៖**

- **លោកឪពុក កែវ ផា** និង **អ្នកម្តាយ កែវ ស៊ូខេង**
- **លោកឪពុក ប្អូន សុភា** និង **អ្នកម្តាយ អ៊ិន ស្រីអេន**

ដែលបានផ្តល់កំណើត និងបានចិញ្ចឹមបីបាច់ថែរក្សាទូន្មាន ប្រៀនប្រដៅ ជួយទំនុកបម្រុង ដល់រូបកូនៗទាំងស្មារតី និងសម្ភារៈគ្រប់បែបយ៉ាង ជាពិសេស ថែមទាំងការផ្តល់នូវដំបូន្មានល្អៗរបស់លោកទាំងពីរ ដែលបានផ្តល់ឱ្យរូបកូនចាប់តាំងពីពេលដែលកូននៅជាកុមារភាព រហូតដល់ធំដឹងក្តី និងបានទទួលនូវការបណ្តុះបណ្តាលថ្នាក់ឧត្តមសិក្សា ដោយបានបញ្ចប់ការសិក្សាជាស្ថាពរជាមួយនឹងការទទួលបាននូវលទ្ធផលជាទីគាប់ចិត្តថែមទៀត។ ដោយលោកទាំងពីរ បានយកអស់ទាំងកម្លាំងកាយ និងទាំងកម្លាំងចិត្តដោយឥតមានរុញរា ហើយក៏មិនគិតអំពីទុក្ខវេទនារបស់ខ្លួនឡើយ។ លើសពីនេះ លោកទាំងពីរបានខិតខំពុះពារទាំងយប់ទាំងថ្ងៃ ធ្វើយ៉ាងណាឱ្យកូនទទួលបាននូវលទ្ធផលដូចសព្វថ្ងៃនេះ។ លើសពីនេះទៅទៀត កូនក៏ពុំដែលបានឮម្តងណាឡើយពីការនឿយហត់ ដែលកើតចេញពីការខិតខំរបស់លោកទាំងពីរ។ ដោយតាមរយៈការខិតខំអស់ពីកម្លាំងចិត្តរបស់លោកទាំងពីរនេះហើយ ដែលបានធ្វើឱ្យកូនមិនអាចបំភ្លេចបានជារៀងរហូត លោកទាំងពីរបានធ្វើ ឱ្យកូនមានការគោរពកោតសរសើរជាខ្លាំងចំពោះអំពើដ៏ល្អប្រពៃ ដើម្បីឱ្យកូនយកមកធ្វើជាគំរូ និងមិនអាចធ្វើការបំភ្លេចបានឡើយនូវពាក្យពេចន៍ទូន្មានដ៏ល្អៗ ជាពិសេសគុណូបការៈដ៏សែនធំ ដែលរកអ្វីមកប្រៀបប្រដូចពុំបាន។ ហើយកូនមានថ្ងៃនេះក៏ព្រោះតែព្រហ្មវិហារធម៌របស់លោកឪពុក និងអ្នកម្តាយកូនចងចាំជានិច្ចរហូតដល់វិនាទីនៃដង្ហើមចុងក្រោយរបស់កូន ។

- រាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា នៅក្រោមការដឹកនាំដ៏ឈ្លាសវៃប្រកបដោយគតិបណ្ឌិតរបស់ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន** និង**សម្តេចកិត្តិព្រឹទ្ធបណ្ឌិត ប៊ុន រ៉ានីហ៊ុនសែន** និង **សម្តេចមហាបវរធិបតី ហ៊ុន ម៉ាណែត** និង**លោកជំទាវ ពេជ ចន្ទមុន្នី ហ៊ុនម៉ាណែត** ដែលជាអគ្គមគ្គុទេសន៍ដ៏ឆ្នើម រួមជាមួយសេនាធិការរបស់ រាជរដ្ឋាភិបាលកម្ពុជាគ្រប់ជាន់ថ្នាក់ ដែលបានបង្កើតឱ្យមានកាលានុវត្តភាពដ៏ប្រសើរ និង ជម្រុញឱ្យសង្គមកម្ពុជាមានការអភិវឌ្ឍន៍គ្រប់វិស័យ

និយាយជារួម និង និយាយដោយឡែក សម្រាប់វិស័យអប់រំ និង ការសិក្សាស្រាវជ្រាវ។ កាលានុវត្តភាពនេះហើយ ដែលបានផ្តល់ឲ្យយើងខ្ញុំមានឱកាសទទួល បាននូវការបណ្តុះបណ្តាលដែលពោរពេញទៅដោយក្តីសង្ឃឹមសម្រាប់អនាគត ។

– ឯកឧត្តម **លុយ ចណ្ណា** សាកលវិទ្យាធិការ ព្រមទាំងសាកលវិទ្យាធិការរង ព្រឹទ្ធបុរស ព្រមទាំងអស់ លោក-លោកស្រីសាស្ត្រាចារ្យ នៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្រ្ត និងវិទ្យាសាស្ត្រសេដ្ឋកិច្ច ដែលមានសមត្ថភាពដ៏ខ្ពង់ខ្ពស់ និងថែមទាំងជួយតម្រង់ទិសដល់យើងខ្ញុំ ចាប់តាំងពីឆ្នាំសិក្សាថ្នាក់មូលដ្ឋាន រហូតដល់បញ្ចប់ថ្នាក់បរិញ្ញាបត្រនេះ ប្រកបដោយក្រមសីលធម៌វិជ្ជាជីវៈ ។

– លោកស្រីសាស្ត្រាចារ្យ **នៃ វិជ្ជតា** បានធ្វើការដឹកនាំ និងបង្ហាត់បង្ហាញពីគំនិត និងវិធីសាស្រ្តល្អៗ ដែលទាក់ទងទៅនឹងប្រធានបទ រួមទាំងការចំណាយពេលវេលាដ៏មានតម្លៃរបស់ លោកស្រី តាំងពីដើមរហូតដល់បញ្ចប់ការសិក្សាស្រាវជ្រាវនូវប្រធានបទមួយនេះ ហើយស្នាដៃ ដែលកើតចេញពីការសិក្សាស្រាវជ្រាវមួយនេះ គឺពិតជាមិនមានអត្ថិភាពឡើយបើមិនមានការជួយ ជ្រោមជ្រែងពីលោកស្រីនោះទេ ។

– លោកស្រីចៅក្រម **ចាំង ស៊ីណាត** ចៅក្រមតុលាការកំពូល ដែលបានសម្រួលដល់ រូបយើងខ្ញុំទាំងពីរនាក់ ឱ្យបានចុះកម្មសិក្សានៅកំឡុងពេលនៃការស្រាវជ្រាវសារណាទៅលើ ប្រធានបទ **ការព្យួរទោស**។

– កញ្ញា **ប្រង់ ពេជ្រមាលា** ក្រឡាបញ្ជីសាលាដំបូងរាជធានីភ្នំពេញ ដែលបានជួយ សម្រួលក្នុងការរៀបចំឯកសារដល់យើងខ្ញុំ ។

– លោក **តាំង ឡៃអៀង** និង កញ្ញា **សំ វិជ្ជរ៉ា** និស្សិតរៀមច្បងដែលបាន ធ្វើការគាំទ្រផ្តល់ជាគំនិតនូវយោបល់ ដែលជម្រុញឱ្យកិច្ចការស្រាវជ្រាវនេះកាន់តែមានភាពប្រសើរឡើង ដើម្បីជាវិភាគទានក្នុងការសិក្សាស្រាវជ្រាវផ្សេងៗ ។ មុននឹងបញ្ចប់ យើងខ្ញុំសូមគោរពជូនពរ លោកអ្នកដែលមានគុណ ដែលបានរៀបរាប់ខាងលើទាំងអស់ សូមឲ្យជួបប្រទះនូវពុទ្ធពរទាំងបួន ប្រការគឺ អាយុ វណ្ណៈ សុខៈ ពលៈ កុំបីឃ្លៀងឃ្លាតឡើយ។

# អារម្ភកថា

នៅក្នុងប្រព័ន្ធសិក្សាធិការថ្នាក់សាកលវិទ្យាល័យ មិនថានៅប្រទេសអភិវឌ្ឍន៍ ឬ ប្រទេសកំពុងអភិវឌ្ឍន៍ឡើយ នៅមុនពេលទទួលសញ្ញាបត្រដើម្បីបញ្ចប់ការសិក្សាត្រូវធ្វើសារណា ឬ និក្ខេបបទដើម្បីបញ្ជាក់នូវការយល់ដឹងរបស់ខ្លួន ដែលបានឆ្លងកាត់រយៈពេលសិក្សា និងការធ្វើកម្មសិក្សាកន្លងមក និងដើម្បីទុកដាក់ជាឯកសារដល់អ្នកសិក្សាជំនាន់ក្រោយៗទៀត ។

ដោយអនុវត្តន៍តាមគោលការណ៍របស់ក្រសួងអប់រំយុវជន និងកីឡា សាកលវិទ្យាល័យ ភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច យើងខ្ញុំក៏បានទទួលការអនុញ្ញាតពី សាកលវិទ្យាល័យ ដើម្បីសរសេរសារណាដោយគិតពីថ្ងៃទី ០៨ ខែ មេសា ឆ្នាំ ២០២៤ ដល់ ថ្ងៃទី ១០ ខែ សីហា ឆ្នាំ ២០២៤ ក្រោមប្រធានបទ **ការព្យួរទោស** ដែលកើតចេញពីការខិតខំ ប្រឹងប្រែង និងការស្រលាញ់ការសិក្សានេះ។ ក្នុងន័យដើម្បីបំពេញសារណាដែលមានលក្ខខណ្ឌពេញលេញប្រកបដោយខ្លឹមសារ និងអត្ថន័យសមស្របតាមច្បាប់នោះ តម្រូវឲ្យយើងខ្ញុំខិតខំប្រឹងប្រែងព្យាយាម និងយកចិត្តទុកដាក់ក្នុងការសិក្សាស្រាវជ្រាវ នូវបណ្តាអត្ថបទជាច្រើនលើសពីនេះទៅទៀត ជាការឆ្លើយតបទៅនឹងសណ្តានចិត្តដ៏ល្អប្រពៃពីសំណាកលោកស្រីសាស្ត្រាចារ្យ **ឆៃ ទិព្វតា** ក្នុងន័យដែលលោកស្រីបាន ចំណាយពេលវេលាយ៉ាងមានតម្លៃក្នុងការចែករំលែកនូវចំណេះដឹង និងបទពិសោធន៍សម្រាប់ជាពុទ្ធិដល់រូបយើងខ្ញុំ។ឆ្លើយ តបទៅនឹងលក្ខខណ្ឌខាងលើនេះ ជាមួយក្តីសង្ឃឹមរួមជាមួយកិច្ចខិតខំប្រឹងប្រែងរបស់ លោកស្រីសាស្ត្រាចារ្យ **ឆៃ ទិព្វតា** ក្នុងការបណ្តុះបណ្តាលសម្របសម្រួលដល់រូបយើងខ្ញុំ រួមទាំងការយកចិត្តទុកដាក់ និងការខិតខំប្រឹងប្រែង សិក្សាស្រាវជ្រាវដោយផ្ទាល់ខ្លួន។ ទីបំផុតសារណាមួយនេះ ក៏បានចាប់បដិសន្ធិឡើងលេចចេញជារូបរាងយ៉ាងពិតប្រាកដដែលឆ្លុះបញ្ចាំងអំពីចំណេះដឹងជាក់ស្តែងដែលយើងខ្ញុំបានសិក្សាកន្លងមក ។

យើងខ្ញុំជឿជាក់ថា ស្នាដៃនេះប្រាកដជាមានការខុសឆ្គងដោយប្រការណាមួយជាក់ជាពុំខានទាំងអក្ខរាវិរុទ្ធ ទាំងអត្ថន័យក្នុងវិស័យច្បាប់ ព្រោះថានេះជាស្នាដៃដំបូងរបស់យើងខ្ញុំ ដែលទទួលបានក្រោយពីការសិក្សាក្នុងសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច។ ជាថ្មីម្តងទៀត យើងខ្ញុំក្នុងនាមជាអ្នករៀបរៀងផ្ទាល់ក្នុងសារណានេះរង់ចាំទទួលនូវការរិះគន់ និងការកែ លម្អក្នុងន័យស្តាបនានូវបណ្តាការខ្វះខាត និងកំហុសឆ្គងទាំងអស់ ដើម្បីឲ្យស្នាដៃនេះក្លាយជា ចំណែកមួយជាជំនួយខាងផ្នែកស្មារតី និងចំណេះដឹងសម្រាប់និស្សិតជំនាន់ក្រោយៗជាបន្តបន្ទាប់ ទៀត។

ជាចុងក្រោយយើងខ្ញុំទាំងពីរនាក់ ក៏សូមជូនពរដល់អស់លោក លោកស្រី ដែលកំពុងអាន សៀវភៅនេះ សូមជួបប្រទះនូវពុទ្ធពរទាំងបួនប្រការគឺ អាយុ វណ្ណៈ សុខៈ ពលៈ កុំបីឃ្លៀងឃ្លាតឡើយ។

# មាតិកា

**ទំព័រ**


**សេចក្ដីផ្ដើម** ....... ១

## ជំពូកទី១
## សញ្ញាណទូទៅនៃទោសព្រហ្មទណ្ឌ

**ផ្នែកទី ១. អត្ថន័យនៃទោស** ....... ៤

**១.១.អត្ថន័យតាមបែបអក្សរសាស្ត្រ** ....... ៤

**១.២. អត្ថន័យតាមបែបនីតិសាស្ត្រ** ....... ៤

**ផ្នែកទី ២. ប្រភេទនៃទោសព្រហ្មទណ្ឌ** ....... ៥

**២.១. មូលទោស** ....... ៥

២.១.១. ទោសដាក់ពន្ធនាគារ ....... ៥

២.១.២. ទោសពិន័យជាប្រាក់ ....... ៦

**២.២. ទោសបន្ថែម** ....... ៧

២.២.១. ប្រភេទនៃទោសបន្ថែម ....... ៧

**២.៣. ទោសជំនួស** ....... ៨

២.៣.១. ទោសការងារសហគមន៍ ....... ៨

២.៣.២. ការស្ដីបន្ទោស ....... ៩

**២.៤. គោលបំណងនៃទោស** ....... ១០

## ជំពូកទី២
## ការព្យួរទោសធម្មតា

**ផ្នែកទី១ . ការចោទប្រកាន់ចំពោះបទឧក្រិដ្ឋ ឬ បទមជ្ឈិម** ....... ១២

**១.១ .លក្ខខណ្ឌនៃការព្យួរទោសធម្មតាចំពោះ បទឧក្រិដ្ឋ ឬ បទមជ្ឈិម** ....... ១២

១.១.១.លក្ខខណ្ឌទាក់ទងជាមួយនឹងការផ្ដន្ទាទោសពីមុន ....... ១២

១.១.២. លក្ខខណ្ឌទាក់ទងនឹងទោសដែលអាចនាំឱ្យមានការព្យួរទោស ....... ១៣

**១.២. ការសម្រេចសេចក្ដីអំពីការព្យួរទោសធម្មតា** ....... ១៤

**១.៣. អានុភាពនៃការព្យួរទោសធម្មតា** ....... ១៩

១.៣.១. ការទុកជាអសារបង់នូវការផ្ដន្ទាទោស ....... ១៩

១.៣.២. ការដកហូតការព្យួរទោសជាអញ្ញត្រកម្ម ....... ២០

**ផ្នែកទី២ . ការចោទប្រកាន់ចំពោះបទលហុ**.......................................................... .២១
**២.១ . លក្ខខណ្ឌនៃការព្យួរទោសធម្មតាចំពោះបទលហុ** ................................. .២១
២.១.១. លក្ខខណ្ឌទាក់ទងជាមួយនឹងការផ្តន្ទាទោសពីមុន ................................... .២២
២.១.២. លក្ខខណ្ឌទាក់ទងជាមួយនឹងទោសដែលអាចនាំឱ្យមានការព្យួរទោស........ .២២
**២.២. ការសម្រេចសេចក្តីអំពីការព្យួរទោសធម្មតា**....................................... ២៣
**២.៣. អានុភាពនៃការព្យួរទោសធម្មតា**...........................................................២៣
២.៣.១. ការចាត់ទុកជាអសារបង់នូវការផ្តន្ទាទោស..............................................២៣
២.៣.២. ការដកហូតការព្យួរទោស ........................................................................ .២៤

## ជំពូកទី៣

## ការព្យួរទោសសាកល្បង

**ផ្នែកទី១. លក្ខខណ្ឌនៃការព្យួរទោសសាកល្បង** ............................................. .២៦
**១.១. អវត្តមានលក្ខខណ្ឌជាមួយនឹងការផ្តន្ទាទោសពីមុន** ....................................... .២៦
**១.២. លក្ខខណ្ឌទាក់ទងនឹងទណ្ឌកម្មដែលអាចធ្វើការព្យួរទោសសាកល្បង**.... .២៧
**ផ្នែកទី២. ការសម្រេចសេចក្តីអំពីការព្យួរទោសសាកល្បង** ........................................ .២៨
**ផ្នែកទី៣. អានុភាពនៃការព្យួរទោសសាកល្ប**.............................................................៣៣
**៣.១. ការអនុវត្តការសាកល្បង**...........................................................................៣៣
៣.១.១. រយៈពេលសាកល្បង...................................................................................៣៣
៣.១.២. វិធានការសាកល្បង.....................................................................................៣៣
៣.១.២.១. វិធានការត្រួតពិនិត្យ........................................................... .៣៤
៣.១.២.២. កាតព្វកិច្ចដោយឡែកដែលអាចដាក់ទៅលើទណ្ឌិត ................ .៣៤
៣.១.២.៣. ការកែប្រែកាតព្វកិច្ចដោយឡែកដោយយុត្តាធិការ.................. .៣៦
**៣.២.ការដកហូតការព្យួរទោសសាកល្បង**............................................. ៣៧
**៣.៣.ការផ្តន្ទាទោសដែលត្រូវចាត់ទុកជាអសារបង់**......................................... .៣៨
**សេចក្តីសន្និដ្ឋាន**...........................................................................................................៤០
**អនុសាសន៍**................................................................................................................. .៤២
**ឯកសារយោង**
**ឧបសម្ព័ន្ធ**

# សេចក្តីផ្តើម

# សេចក្តីផ្តើម

## ១. លំនាំនៃការស្រាវជ្រាវ

ប្រទេសកម្ពុជាយើងជាប្រទេសមួយដែលធ្លាប់បានឆ្លងកាត់នូវភ្នក់ភ្លើងនៃសង្គ្រាមស៊ីវិលអស់ជាច្រើនសតវត្ស ដែលធ្វើឲ្យបាត់បង់នូវសណ្តាប់ធ្នាប់ សន្តិសុខសង្គម ខូចខាតហេដ្ឋារចនាសម្ព័ន្ធយ៉ាងធ្ងន់ធ្ងរ រួមទាំងការជាន់ឈ្លី ធ្វើបាប ការគៀបសង្កត់ពីសំណាក់អ្នកមានអំណាចផ្សេងៗ។ បន្ទាប់ពីសង្គ្រាមត្រូវបានបញ្ចប់ ប្រទេសកម្ពុជាយើងបាននឹងកំពុងខិតខំស្តារនូវរាល់ហេដ្ឋារចនាសម្ព័ន្ធ កសាងអភិវឌ្ឍសណ្តាប់ធ្នាប់សង្គមជាតិទាំងមូលមិនតែប៉ុណ្ណោះ រាជរដ្ឋាភិបាលក៏បានខិតខំប្រឹងប្រែងកសាងមុខមាត់របស់ប្រទេសកម្ពុជាយើងឡើងវិញលើឆាកអន្តរជាតិទាំងថ្នាក់តំបន់ និងថ្នាក់សកល។ ក្នុងកំឡុងពេលនោះប្រទេសកម្ពុជាយើងបានអនុវត្តនូវច្បាប់រដ្ឋធម្មនុញ្ញដែលត្រូវបានអនុម័តដោយព្រះរាជាណាចក្រកម្ពុជាផ្ទាល់ ហើយបានប្រកាសឲ្យប្រើនៅក្នុងឆ្នាំ ១៩៩៣ មកម្ល៉េះ។ រាជរដ្ឋាភិបាលបានចាត់ទុកវិស័យច្បាប់ជាទិសដៅអាទិភាព ក្នុងការអភិវឌ្ឍដោយបានបញ្ចូលវិស័យនេះទៅក្នុងយុទ្ធសាស្ត្រចតុកោណ ពោលគឺគោលនយោបាយរបស់ជាតិ ដែលត្រូវបានគេស្គាល់ថាជាកំណែទម្រង់ច្បាប់ និងប្រព័ន្ធយុត្តិធម៌ ដែលមានកំណត់នៅក្នុងស្នូលនៃយុទ្ធសាស្ត្រចតុកោណ និងផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ប្រទេសជាតិសព្វថ្ងៃ។ អត្ថបទច្បាប់ជាច្រើនត្រូវបានតាក់តែងឡើងដោយផ្អែកលើតម្រូវការសង្គមសព្វថ្ងៃ ដែលជួយសម្រួលដល់បញ្ហាចំណេះដឹងបទពិសោធន៍ក្នុងជីវភាពរស់នៅរបស់បងប្អូនប្រជាពលរដ្ឋជាច្រើនដែលកំពុងជួបប្រទះការលំបាក ព្រមទាំងជាចក្ខុវិស័យក្នុងការអភិវឌ្ឍជាតិនាពេលអនាគតផងដែរ។

បើយោងទៅតាមរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា ចែងយ៉ាងច្បាស់អំពីអំណាចតុលាការក្នុងការគ្រប់គ្រងទៅលើរឿងក្តីទាំងអស់ រួមទាំងផ្នែករដ្ឋបាលផងដែរ។ អំណាចតុលាការមានសិទ្ធិក្នុងការសម្រេចសេចក្តីពាក់ព័ន្ធជាមួយនឹងវិវាទដែលកើតមានឡើងនៅក្នុងស្ថាប័ន ក្នុងការរកយុត្តិធម៌ជូនប្រជាពលរដ្ឋដែលជាជនរងគ្រោះតាមនីតិវិធីដែលច្បាប់បានកំណត់ ហើយចៅក្រមគឺជាអ្នកដែលមានសិទ្ធិនៅក្នុងការជម្រះក្តីដោយគោរពទៅតាមច្បាប់ និងសម្បជញ្ញៈរបស់ខ្លួន។ តុលាការព្រហ្មទណ្ឌ គឺជាអ្នកទទួលបន្ទុកដោះស្រាយបញ្ហាដែលពាក់ព័ន្ធទៅនឹងរឿងក្តីព្រហ្មទណ្ឌតែប៉ុណ្ណោះ ពោលគឺតុលាការមានសិទ្ធិក្នុងការដាក់ទណ្ឌកម្ម ឬអនុវត្តការព្យួរទោសទៅលើជនណាមួយដែលបានប្រព្រឹត្តល្មើស និងក្រមព្រហ្មទណ្ឌ ឬបទប្បញ្ញត្តិព្រហ្មទណ្ឌ។

ជាគោលការណ៍ នៅពេលមានបទល្មើសមួយកើតមានឡើងមុននឹងឈានដល់ការជំនុំជម្រះ គឺទាមទារឲ្យបំពេញនីតិវិធីជាច្រើនតាមដំណាក់កាលជាមុនសិនដូចជាកិច្ចស៊ើបអង្កេត កិច្ចចោទប្រកាន់ និងកិច្ចស៊ើបសួរជាដើម ដើម្បីស្វែងរកភស្តុតាង និងការពិតនៃរឿងក្តីទាំងនោះមុននឹងចេញសេចក្តីសម្រេច។ នៅពេលតុលាការប្រកាសពីការផ្តន្ទាទោស ទោសអាចត្រូវបានអនុវត្ត ឬមិនត្រូវបានអនុវត្ត អាស្រ័យដោយតុលាការពិនិត្យមើលទៅលើស្ថានភាពនៃបទល្មើស និងលក្ខណៈសម្បត្តិរបស់ជនជាប់ចោទ ឬជនដែលត្រូវផ្តន្ទាទោសនោះ។ ទោសព្រហ្មទណ្ឌដែលអាចយកមកអនុវត្តមាន៣ គឺមូលទោស ទោសបន្ថែម និងទោសជំនួស ដែលការអនុវត្តទោសទាំង៣នេះមានលក្ខខណ្ឌខុសៗពីគ្នា។

## ២. ចំណោទបញ្ហា

ទោសព្រហ្មទណ្ឌមានសារៈសំខាន់ចំពោះចារីទាំងឡាយណាដែលមានពិរុទ្ធភាពពីបទល្មើសព្រហ្មទណ្ឌណាមួយ ដែលត្រូវបានចោទប្រកាន់ហើយឈានដល់ការសម្រេចសេចក្តីដោយតុលាការព្រហ្មទណ្ឌនូវទណ្ឌកម្មចំពោះពិរុទ្ធជន។ ម្យ៉ាងវិញទៀត ទណ្ឌកម្មព្រហ្មទណ្ឌអាចនាំឲ្យមាននូវទោសទណ្ឌចំពោះជនដែលបានប្រព្រឹត្តល្មើសនឹងបទប្បញ្ញត្តិដែលមានចែងក្នុងច្បាប់ព្រហ្មទណ្ឌ ហើយក្នុងការប្រកាសសេចក្តីសម្រេច គឺមានតែតុលាការនោះទេ ដែលមានសមត្ថកិច្ចក្នុងការសម្រេចផ្តន្ទាទោសដល់ជនដែលបានប្រព្រឹត្តបទល្មើសព្រហ្មទណ្ឌ។

ហេតុនេះហើយ ទើបយើងខ្ញុំលើកយកប្រធានបទអំពី **ការព្យួរទោស** មកសរសេរនៅក្នុងសារណានេះ គឺដើម្បីចង់បង្ហាញដល់អ្នកអាន ដូចជានិស្សិតជំនាន់ក្រោយៗទៀតឲ្យយល់ដឹងបន្ថែមថា អ្វីទៅជាការព្យួរទោស? តើការនីតិវិធីនៃការព្យួរទោសត្រូវអនុវត្តយ៉ាងដូចម្តេច? មានផលប៉ះពាល់អ្វីខ្លះដល់ការព្យួរទោស? ហើយលក្ខខណ្ឌនៃការព្យួរទោសមានអ្វីខ្លះ?

## ៣. គោលបំណងនៃការស្រាវជ្រាវ

ការសិក្សាស្រាវជ្រាវសារណានេះឡើងគឺក្នុងគោលបំណងដើម្បីធ្វើការពង្រឹង និងពង្រីកនូវសមត្ថភាពបន្ថែមពីសារៈសំខាន់នៃទោសព្រហ្មទណ្ឌ នៃព្រះរាជាណាចក្រកម្ពុជាដែលទាក់ទងជាមួយនឹងនីតិវិធីរបស់តុលាការក្នុងការព្យួរទោសណាមួយ ដែលជាចំណេះដឹង និងបទពិសោធន៍ដ៏ល្អមួយដល់យើងខ្ញុំទាំងពីរ និងជាទុនមួយសម្រាប់ទុកជាឯកសារដល់និស្សិតជំនាន់ក្រោយៗទៀត។ លើសពីនេះទៅទៀត អ្នកសិក្សាក៏អាចស្វែងយល់បន្ថែមអំពីសេចក្តីសម្រេចរបស់តុលាការក្នុងអនុវត្តនៃការព្យួរទោសបែបណាចំពោះទណ្ឌិតដែលមានបញ្ញត្តិនៅក្នុងច្បាប់ជាធរមាន។

## ៤. ដែនកំណត់ និងវិសាលភាពនៃការសិក្សាស្រាវជ្រាវ

ដើម្បីឆ្លើយតបទៅនឹងប្រធានបទដែលបានលើកឡើងនៅក្នុងចំណោទបញ្ហាខាងលើយើងខ្ញុំទាំងពីរបានខិតខំធ្វើការសិក្សាស្រាវជ្រាវដោយផ្អែកទៅលើឯកសារតាមច្បាប់ និងបទប្បញ្ញត្តិដែលចូលជាធរមានរបស់ព្រះរាជាណាចក្រកម្ពុជាមានដូចជាក្រមព្រហ្មទណ្ឌឆ្នាំ២០០៩ ក្រមនីតិវិធីព្រហ្មទណ្ឌឆ្នាំ២០០៧ និងលិខិតបទដ្ឋានគតិយុត្តនានា ព្រមទាំងកម្រងឯកសារ ស្នាដៃ សៀវភៅ បទឧបទ្ទេសរបស់សាស្ត្រាចារ្យ និងអ្នកជំនាញវិស័យច្បាប់នានាផ្នែកនីតិឯកជនផងដែរ ទើបសរសេរនូវសារណានេះឡើងបានចំនួន ០៣ ជំពូក។ នៅក្នុងសារណានេះនឹងបង្ហាញអំពីប្រភេទនៃព្យួរទោស ក៏ដូចជាលក្ខខណ្ឌនៃការព្យួរទោសដែលជាផ្នែកមួយនៃទោសព្រហ្មទណ្ឌផងដែរ។

## ៥. វិធីសាស្ត្រនៃការស្រាវជ្រាវ

ការសិក្សាស្រាវជ្រាវក្នុងការសរសេរសារណានេះឡើង យើងខ្ញុំបានដកស្រង់ និងប្រមូលឯកសារមួយចំនួនចេញពីក្រមព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា(ឆ្នាំ២០០៩) ក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា(ឆ្នាំ២០១០) ច្បាប់ពន្ធនាគារ សៀវភៅមេរៀនដែលសាស្ត្រាចារ្យផ្នែកច្បាប់ព្រហ្មទណ្ឌបានចងក្រង

ព្រមទាំងបទពិសោធន៍ក្នុងវិស័យនេះ និងតាមប្រព័ន្ធអ៊ីនធើណេតចេញពីព័ត៌មានមួយចំនួន រួមទាំងការសាកសួរពិគ្រោះជាមួយសាស្ត្រាចារ្យដឹកនាំ និងសាស្ត្រាចារ្យច្បាប់នៅសាកលវិទ្យាល័យផ្ទាល់។

## ៦.សារៈសំខាន់នៃការស្រាវជ្រាវ

សារណានេះ គឺអាចនាំឱ្យបងប្អូន ក៏ដូចជាមិត្តនិស្សិតដទៃទៀតទុកជាជំនួយស្មារតីក្នុងការស្រាវជ្រាវរបស់ខ្លួន ហើយក៏អានបានយល់ដឹងនូវអ្វីទៅដែលជាការព្យួរទោស? ហើយលក្ខខណ្ឌណាខ្លះដែលនាំឱ្យមានការព្យួរទោស? ការព្យួរទោសមានប៉ុន្មានប្រភេទ? អ្វីខ្លះ?

## ៧. រចនាសម្ព័ន្ធនៃការស្រាវជ្រាវ

ខ្លឹមសារនៃប្រធានបទនេះ បានបែងចែកដូចខាងក្រោម ៖

សេចក្តីផ្តើម

- ជំពូកទី ១ ស្តីអំពី សញ្ញាណទូទៅនៃទោសព្រហ្មទណ្ឌ
- ជំពូកទី ២ ស្តីអំពី ការព្យួរទោសធម្មតា
- ជំពូកទី៣ ស្តីអំពី ការព្យួរទោសសាកល្បង

# ជំពូកទី១
# សញ្ញាណទូទៅនៃ
# ទោសព្រហ្មទណ្ឌ

# ជំពូកទី១
# សញ្ញាណទូទៅនៃទោសព្រហ្មទណ្ឌ

នៅក្នុងច្បាប់ព្រហ្មទណ្ឌ ការកំណត់នូវបទល្មើសនីមួយៗទៅតាមបញ្ញត្តិដែលមានចែង គឺមានច្រើនប្រភេទដែលទាក់ទងនឹងឆន្ទានុសិទ្ធិរបស់ចៅក្រមក្នុងការកាត់ក្តីបទល្មើសនីមួយៗ។ ក្នុងនោះចៅក្រមត្រូវផ្តន្ទាទោសចារីដែលបានប្រព្រឹត្តបទល្មើសផ្ទុយនឹងច្បាប់ទៅតាមទោសរបស់ជននោះ។ ដូច្នេះការស្វែងយល់ពីនិយមន័យ គឺជាការចាំបាច់មុនឈានទៅដល់ប្រភេទនៃទោសព្រហ្មទណ្ឌ។

## ផ្នែកទី ១. អត្ថន័យនៃទោស

### ១.១. អត្ថន័យតាមបែបអក្សរសាស្ត្រ

យោងតាមវចនានុក្រមសម្តេច ជួន ណាត ទោសគឺជាពាក្យបាលីសំក្រឹត មានន័យថា ការប្រទូស្ត កំហឹង សម្អប់ កំហុស៖ មនុស្សមានទោស ចិត្តប្រកបដោយទោស។[1]

### ១.២. អត្ថន័យតាមបែបនីតិសាស្ត្រ

ទោស គឺសំដៅដល់ទោសព្រហ្មទណ្ឌ ជាទណ្ឌកម្មដែលកំណត់ដោយច្បាប់រដ្ឋ ដែលផ្តល់អំណាចដល់អង្គការតុលាការជាអ្នកមានសមត្ថកិច្ចក្នុងការប្រកាសផ្តន្ទាទៅលើបុគ្គលណាដែលបានប្រព្រឹត្តផ្ទុយនឹងក្រមព្រហ្មទណ្ឌ ឬបទប្បញ្ញត្តិព្រហ្មទណ្ឌជាធរមានណាមួយ ដោយផ្អែកទៅលើទម្ងន់នៃបទល្មើស និងបុគ្គលិកលក្ខណៈរបស់បុគ្គលដែលប្រព្រឹត្តបទល្មើស។[2]

ម្យ៉ាងវិញទៀត ទោសព្រហ្មទណ្ឌពុំមានមូលដ្ឋានណាដែលផ្អែកទៅលើលក្ខខណ្ឌសង្គមនោះទេ មិនថា (រូបសម្បត្តិ, ឋានៈ និងទ្រព្យធន, អ្នកមាន, អ្នកក្រ, អ្នកដែលមានឋានៈ ឬគ្មានឋានៈនោះទេ សុទ្ធតែត្រូវផ្តន្ទាទោសដូចគ្នា) ប្រសិនបើបុគ្គលនោះបានប្រព្រឹត្តនូវបទល្មើស ដែលខុសពីច្បាប់ព្រហ្មទណ្ឌបានចែង។

ជាការពិតទោសព្រហ្មទណ្ឌ គឺសំដៅលើទោសដាក់ពន្ធនាគារ និងទោសពិន័យជាប្រាក់ហើយគេចាត់ទុកទោសទាំងនោះ គឺជាបទល្មើសដែលចេញមកពីកំហុស ឬអំពើរបស់ចារីផ្ទាល់ ឬសហចារីដែលចារីបានប្រព្រឹត្តអំពើដែលល្មើសនឹងច្បាប់ ហើយបានជះឥទ្ធិពលអាក្រក់ដល់សណ្តាប់ធ្នាប់ និងសន្តិសុខសង្គម។ តួនាទីនៃទោសគឺដើម្បីបង្ក្រាប កែប្រែ និងបង្ការនូវអំពើដែលជាបទល្មើស។ ចំពោះការដាក់ទោសជនដែលបានប្រព្រឹត្តអំពើខុសច្បាប់ទាំងនោះ ត្រូវចាំបាច់រកឲ្យឃើញនូវពិរុទ្ធភាព និងធាតុផ្សំនៃបទល្មើសរបស់ជននោះសិន ដើម្បីកំណត់អំពីប្រភេទនៃបទល្មើស ឬទោសនោះ។ ប្រសិនបើរកមិនឃើញនូវបទល្មើសទេ នោះពុំមានកម្មវត្ថុក្នុងការផ្តន្ទាទោសឡើយ ព្រោះបើយោងតាមគោលការណ៍នីត្យានុកូលភាពនៃទោស និងគោលការណ៍នីត្យានុកូលភាពនៃបទល្មើសដែលត្រូវបានចាត់ទុកថាគ្មានទោស គ្មានបទល្មើស បើគ្មានច្បាប់ចែង។តាមគោលការណ៍នីត្យានុកូលភាពនៃបទល្មើសព្រហ្មទណ្ឌនេះ អំពើណាមួយដែលអាចជាបទល្មើសបាន លុះត្រាតែអំពើនោះមានចែងក្នុងច្បាប់ជា

---

[1] វចនានុក្រមសម្តេចសង្ឃរាជ ជួន ណាត បោះពុម្ពផ្សាយ ឆ្នាំ២០២២

[2] ស្លាយមេរៀនរបស់របស់លោកគ្រូ ម៉ម ចាន់ណែត (នីតិព្រហ្មទណ្ឌទូទៅ )

ធរមានហើយទោសដែលអាចប្រកាសបាន លុះត្រាតែទោសនោះបានចែងនៅក្នុងច្បាប់ផងដែរ។[3] ហេតុដូច្នេះហើយបានជានៅក្នុងក្រមព្រហ្មទណ្ឌខ្មែរឆ្នាំ ២០០៩ បានចែងអំពីនិយមន័យ, ជាតុផ្សំនៃបទល្មើស និងអំពីទោសជាច្រើន ដើម្បីឲ្យមានភាពងាយស្រួលក្នុងការអនុវត្តទោសទាំងនោះស្របទៅតាមបទដ្ឋានគតិយុត្ត ក៏ដូចជាស្របតាមបទប្បញ្ញត្តិនិងគោលការណ៍នៃច្បាប់ផងដែរ។

## ផ្នែកទី ២. ប្រភេទនៃទោសព្រហ្មទណ្ឌ

ក្រមព្រហ្មទណ្ឌបានចែងទោសជា ៣ ប្រភេទដូចជា៖

- មូលទោស
- ទោសបន្ថែម
- ទោសជំនួស។

### ២.១. មូលទោស

មូលទោស គឺជាទោសចម្បងដែលតុលាការតែងតែយកមកប្រើប្រាស់ក្នុងការកាត់ក្តីដាក់ទោស និងប្រកាសទោសចំពោះជនជាប់ចោទដែលបានប្រព្រឹត្តបទល្មើស។ រាល់អំពើដែលចាត់ទុកជាបទល្មើសត្រូវតែមានជាប់មូលទោសជានិច្ច ក៏ប៉ុន្តែក្នុងករណីខ្លះតុលាការអាចប្រើប្រាស់ទោសជំនួស ឬ ទោសបន្ថែមជំនួសឲ្យមូលទោសបាន។

មូលទោស ត្រូវបានគេធ្វើការបែងចែកជាពីរប្រភេទរួមមាន ដូចជាទោសដាក់ពន្ធនាគារ និងទោសពិន័យជាប្រាក់។[4] ការពិន័យត្រូវគិតជាប្រាក់រៀល។[5]

#### ២.១.១. ទោសដាក់ពន្ធនាគារ

ទោសដាក់ពន្ធនាគារ គឺជាទោសដែលលុបបំបាត់នូវសិទ្ធិសេរីភាពទាំងអស់ជាមូលដ្ឋានហើយជាប្រភេទទោសដែលមានរយៈពេលយូរ ចាប់ពី១ថ្ងៃ រហូតដល់៣០ឆ្នាំ ឬអស់មួយជាជីវិត អាស្រ័យទៅតាមបទល្មើសដែលជននោះបានប្រព្រឹត្ត។ ទោសដាក់ពន្ធនាគារ អាចត្រូវបន្ថែមនូវទោសពិន័យជាប្រាក់ផងដែរ។[6]ទោសដាក់ពន្ធនាគារត្រូវគិតចិរវេលា ១ (មួយ) ថ្ងៃត្រូវគិត ២៤ (ម្ភៃបួន) ម៉ោង ១(មួយ) ខែ ត្រូវគិត ៣០ (សាមសិប) ថ្ងៃ និង១ (មួយ) ឆ្នាំ ត្រូវគិត ១២ (ដប់ពីរ) ខែ ហើយរយៈពេលនៃទោសគឺត្រូវគិតចាប់ពីថ្ងៃដែលបានកាត់ទោសតទៅ។[7]

---

[3] ក្រមព្រហ្មទណ្ឌ,លេខ នស/រកម/១១០៩/០២២ ,៣០ វិច្ឆិកា ២០០៩,មាត្រា ៣

[4] ក្រមព្រហ្មទណ្ឌ,លេខ នស/រកម/១១០៩/០២២ ,៣០ វិច្ឆិកា ២០០៩,មាត្រា ៤៣ កថាខណ្ឌទី១

[5] ក្រមព្រហ្មទណ្ឌ,លេខ នស/រកម/១១០៩/០២២ ,៣០ វិច្ឆិកា ២០០៩,មាត្រា ៤៣ កថាខណ្ឌទី១

[6] ក្រមព្រហ្មទណ្ឌ,លេខ នស/រកម/១១០៩/០២២ ,៣០ វិច្ឆិកា ២០០៩,មាត្រា ៤៦ កថាខណ្ឌទី២

[7] ក្រមព្រហ្មទណ្ឌ,លេខ នស/រកម/១១០៩/០២២ ,៣០ វិច្ឆិកា ២០០៩,មាត្រា ៤៩

នៅពេលដែលតុលាការបានប្រកាសឲ្យជនណាម្នាក់ជាប់ពន្ធនាគារហើយ នោះថិរវេលានៃការឃុំខ្លួនបណ្ដោះអាសន្នត្រូវដកទាំងស្រុងចេញពីថិរវេលានៃទោសជាប់ពន្ធនាគារដែលត្រូវទទួលរងនោះ។ ចំពោះទណ្ឌិតដែលបានទទួលទោសនៅក្នុងពន្ធនាគារចប់សព្វគ្រប់ហើយ ជននោះនឹងត្រូវបានដោះលែងឲ្យមានសេរីភាពសារជាថ្មីវិញ ក៏ប៉ុន្តែចំពោះទណ្ឌិតដែលទោសរបស់ខ្លួនត្រូវបញ្ចប់នៅថ្ងៃសៅរ៍ ថ្ងៃអាទិត្យ ឬ ថ្ងៃឈប់សម្រាកផ្សេងៗទៀតដែលច្បាប់ ឬ បទដ្ឋានគតិយុត្តបានកំណត់ត្រូវតែដោះលែងឲ្យមានសេរីភាពវិញនៅមុនថ្ងៃឈប់សម្រាកនោះ។[8]

### ២.១.២. ទោសពិន័យជាប្រាក់

ទោសពិន័យជាប្រាក់ គឺតម្រូវឲ្យទណ្ឌិតបង់នូវចំនួនប្រាក់ដែលច្បាប់បានកំណត់ទៅតាមការប្រកាសទោសរបស់ចៅក្រម ហើយទឹកប្រាក់ត្រូវកំណត់ជាប្រាក់រៀល។ ចំនួនទឹកប្រាក់ដែលបានបង់ ហៅបានថាជាប្រាក់ពិន័យ គឺត្រូវបង់ចូលថវិការដ្ឋ។[9] ប្រាក់ពិន័យដែលទទួលបានត្រូវរក្សាទុកនូវក្នុងធនាគារជាតិដោយចូលជាប្រាក់របស់រដ្ឋ មិនមែនជាប្រាក់សំណងដែលត្រូវបង់ទៅឲ្យជនរងគ្រោះនោះទេ។

ឧទាហរណ៍ ៖ ក្នុងករណីបង្ករបួសស្នាមដោយចេតនា ប្រសិនបើចៅក្រមរកឃើញថាមានពិរុទ្ធភាពពិតមែន ជនល្មើសអាចត្រូវទទួលទោសដាក់ពន្ធនាគារពី ១ (មួយ) ឆ្នាំ ទៅ ៣ (បី) ឆ្នាំ និងពិន័យជាប្រាក់ពី ២ លានរៀល ទៅ៦លានរៀល។[10] ២លានរៀល ទៅ ៦លានរៀលនេះ គឺជាទោសព្រហ្មទណ្ឌដែលត្រូវបង់ទៅឲ្យរដ្ឋទោះបីមាន ឬក៏គ្មានដើមបណ្ដឹងរដ្ឋប្បវេណី ក៏ជនល្មើសត្រូវតែបង់ដែរ។ ក៏ប៉ុន្តែការបង្ករបួសស្នាមតែងតែមានជនរងគ្រោះ ដូច្នេះបើសិនជនរងគ្រោះទាមទារសំណងជំងឺចិត្ត ចៅក្រមអាចសម្រេចឲ្យជនល្មើសបង់សំណងជំងឺចិត្តឲ្យជនរងគ្រោះបន្ថែមពីលើប្រាក់ពិន័យដែលត្រូវបង់ទៅឲ្យរដ្ឋ។[11]

### ២.២. ទោសបន្ថែម

ទោសបន្ថែម គឺជាទោសដែលតុលាការយកមកប្រើនៅក្នុងការប្រកាសបន្ថែមទៅលើមូលទោស ដោយសំដៅដល់ទោសដែលត្រូវដាក់បញ្ចូល ឬដាក់ជំនួសទៅក្នុងមូលទោស។ ក្នុងករណីខ្លះទោសបន្ថែម ដែលត្រូវបានបន្ថែមលើមូលទោសដោយចៅក្រម ពុំមានការប្រកាសទោសច្បាស់លាស់នោះទេ។ ទោសបន្ថែមត្រូវបានបង្កើតឡើងក្នុងគោលបំណងកម្រិតនូវទណ្ឌកម្មឲ្យសមស្របទៅតាម បទល្មើសដែលបានប្រព្រឹត្តជាក់ស្ដែង ដើម្បីធានាដល់ការអនុវត្តដែលគេហៅថា **គោលការណ៍ឯកត្តកម្មនៃទោស។**[12] ចំពោះទោសនេះផងដែរ ចៅក្រម

---

[8] ក្រមព្រហ្មទណ្ឌ,លេខ នស/រកម/១១០៩/០២២ ,៣០ វិច្ឆិកា ២០០៩,មាត្រា ៥០

[9] ក្រមព្រហ្មទណ្ឌ,លេខ នស/រកម/១១០៩/០២២ ,៣០ វិច្ឆិកា ២០០៩,មាត្រា ៥២

[10] ក្រមព្រហ្មទណ្ឌ,លេខ នស/រកម/១១០៩/០២២ ,៣០ វិច្ឆិកា ២០០៩,មាត្រា ២១៧

[11] នាទីយល់ដឹងអំពីច្បាប់ និងជំនួញ, ក្រមព្រហ្មទណ្ឌខ្មែរ ៖ ប្រភេទនៃទោសព្រហ្មទណ្ឌ និងការអនុវត្ត រៀបរៀងដោយ សេង ឌីណា

[12] ទំព័រស្វែងយល់ពីច្បាប់ , ប្រភេទនៃទោស រៀបរៀងដោយ ន.ស.រ មករា ឆ្នាំ២០១៧ ទំព័រទី១០

អាចធ្វើការបប្រកាសមួយ ឬច្រើនទៅតាមឆន្ទានុសិទ្ធិរបស់ចៅក្រមដោយផ្អែកតាមច្បាប់ ហើយការប្រកាសទោសត្រូវតែមានភាពច្បាស់លាស់។[13]

ជាការពិតណាស់ ទោសនេះត្រូវស្ថិតនៅក្រោមគោលការណ៍នីត្យានុកូលភាព ពោលគឺទោសនេះនៅតត្រូវបានប្រកាសឡើងដរាបណាទោសនេះ ត្រូវបានចែងដោយច្បាប់ព្រហ្មទណ្ឌផ្អែកទៅលើកាលៈទេសៈ និងស្ថានទម្ងន់នៃបទល្មើសទៅលើបុគ្គលិកលក្ខណៈនៃជនជាប់ចោទ ទៅលើសភាពផ្លូវចិត្ត ឬកិរិយាមាយាទរបស់ជនល្មើសក្រោយពេលប្រព្រឹត្តបទល្មើសចំពោះជនរងគ្រោះជាដើម។[14] ទោសបន្ថែមមាននៅក្នុងនីតិកម្មខ្មែរពីបុរាណ ដោយនៅក្នុងនោះមានទោសជាច្រើនដែលទាក់ទងនឹងទោសខាងផ្លូវចិត្ត និងទោសនាំឲ្យខូចកិត្តិយស។[15]

### ២.២.១. ប្រភេទនៃទោសបន្ថែម

ប្រភេទនៃទោសបន្ថែមមាន ៖ [16]

១ - ការដកសិទ្ធិខ្លះជាពលរដ្ឋ។

២ - ការហាមឃាត់ចំពោះការប្រកបវិជ្ជាជីវៈណា ដែលបទល្មើសនោះបានប្រព្រឹត្តនៅក្នុងពេលដែលប្រកបវិជ្ជាជីវៈនេះ។

៣ - ការហាមឃាត់ចំពោះការបើកបរយានយន្តគ្រប់ប្រភេទ។

៤ - ការព្យួរលិខិតបើកបរ។

៥ - ការហាមឃាត់ចំពោះការស្នាក់នៅ។

៦- ការហាមឃាត់ចំពោះការចាកចេញពីដែនដីនៃព្រះរាជាណាចក្រកម្ពុជា ។ ទណ្ឌិតត្រូវតែប្រគល់លិខិត-ឆ្លងដែនរបស់ខ្លួនទៅក្រឡាបញ្ជីនៃតុលាការ ហើយលិខិតឆ្លងដែននោះត្រូវបានរក្សាទុកតាមលក្ខខណ្ឌដែលកំណត់ដោយការរបស់រដ្ឋមន្ត្រីក្រសួងយុត្តិធម៌។[17]

៧ - ការហាមឃាត់ចំពោះការចូល និងការស្នាក់នៅលើដែនដីនៃព្រះរាជាណាចក្រកម្ពុជាចំពោះទណ្ឌិតដែលជាជនបរទេស។

៨ - ការរឹបអូសឧបករណ៍សម្ភារៈ ឬវត្ថុដែលប្រើប្រាស់ក្នុងពេលប្រព្រឹត្តបទល្មើស ឬដែលទុកសម្រាប់ប្រព្រឹត្តបទល្មើស។

៩ - ការរឹបអូសវត្ថុ ឬមូលនិធិដែលជាកម្មវត្ថុនៃបទល្មើស។

---

[13] ក្រមព្រហ្មទណ្ឌ,លេខ នស/រកម/១១០៩/០២២ ,៣០ វិច្ឆិកា ២០០៩,មាត្រា ១០០

[14] ក្រមព្រហ្មទណ្ឌ,លេខ នស/រកម/១១០៩/០២២ ,៣០ វិច្ឆិកា ២០០៩,មាត្រា ៩៦

[15] មេរៀននីតិព្រហ្មទណ្ឌ , ខែធ្នូ ឆ្នាំ២០០៧ , ទំព័រទី៥៤

[16] ក្រមព្រហ្មទណ្ឌ,លេខ នស/រកម/១១០៩/០២២ ,៣០ វិច្ឆិកា ២០០៩,មាត្រា ៥៣

[17] ក្រមព្រហ្មទណ្ឌ,លេខ នស/រកម/១១០៩/០២២ ,៣០ វិច្ឆិកា ២០០៩,មាត្រា ៦០

១០ - ការរឹបអូសផលទុន ឬ ទ្រព្យសម្បត្តិដែលជាផលកើតចេញពីបទល្មើស។

១១ - ការរឹបអូសឧបភោគភណ្ឌ សម្ភារៈ ឬ ចលនវត្ថុ ដែលនៅក្នុងទីកន្លែងដែលបទល្មើសត្រូវបានប្រព្រឹត្ត។

១២ - ការរឹបអូសយានជំនិះដែលជារបស់ទណ្ឌិត។

១៣ - ការហាមឃាត់ចំពោះការកាន់កាប់ ឬការយកតាមខ្លួននូវអាវុធគ្រឿងផ្ទុះនិងគ្រាប់រំសេវគ្រប់ប្រភេទ។

១៤ - ការបណ្តេញចេញពីលទ្ធកម្មសាធារណៈ។

១៥ - ការបិទគ្រឹះស្ថានដែលប្រើប្រាស់ ដើម្បីត្រៀម ឬប្រព្រឹត្តបទល្មើស។

១៦ - ការហាមឃាត់ចំពោះការធ្វើអាជីវកម្មនៅក្នុងគ្រឹះស្ថាន ដែលបើកចំហសម្រាប់សាធារណជន ឬដែលប្រើប្រាស់ដោយសាធារណជន។

១៧ - ការបិទផ្សាយសេចក្តីសម្រេចផ្តន្ទាទោស។

១៨ - ការផ្សាយសេចក្តីសម្រេចផ្តន្ទាទោសនៅក្នុងសារព័ត៌មាន។

១៩ - ការផ្សាយសេចក្តីសម្រេចផ្តន្ទាទោស តាមគ្រប់មធ្យោបាយទូរគមនាគមន៍សោតទស្សន៍។

ក្រៅពីទោសបន្ថែមដែលបានរៀបរាប់ខាងលើ ក៏មានទោសបន្ថែមដែលមានចែងក្នុងច្បាប់ដោយឡែកដែរ។ ទោសបន្ថែមទាំងឡាយ ដែលមានចែងនៅក្នុងចំណុច ១, ២, ៣, ៤, ៥, ៦ និង ៧ ខាងលើនេះត្រូវអនុវត្តនៅពេលផុតទោសពន្ធនាគារ លើកលែងតែមានសេចក្តីសម្រេចផ្ទុយរបស់តុលាការ។[18]

**២.៣. ទោសជំនួស**

ទោសជំនួស គឺសំដៅទៅលើទោសដែលតុលាការយកមកប្រកាសជំនួសមូលទោស ប្រសិនបើតុលាការយល់ឃើញថាទោសនោះមិនអាចប្រកាសផ្តន្ទាទោសដាក់ពន្ធនាគារ ឬ ពិន័យជាប្រាក់បាននោះទេ។[19] នៅពេលមានករណីនេះកើតឡើង តុលាការនឹងប្រើទោសការងារសហគមន៍ ឬការស្តីបន្ទោសមកប្រកាសជំនួសឲ្យមូលទោសវិញ។ តុលាការដែលប្រកាសទោសការងារសហគមន៍ ឬការស្តីបន្ទោស ពុំអាចប្រកាសទោសពន្ធនាគារ ឬទោសពិន័យបានទេ[20] ព្រោះតុលាការពុំអាចប្រកាសទោសជំនួសទាំងពីរនេះ ត្រួតគ្នាឡើយ។ មូលហេតុដែលសម្រេចអំពីទោសជំនួសបាន គឺដោយផ្អែកទៅលើគោលការណ៍មនុស្សធម៌ គេអាចពិនិត្យទៅលើស្ថានភាពកាលៈទេសៈនៃការប្រព្រឹត្តបទល្មើស ដើម្បីមិនអនុវត្តទោសដែលជាមូលដ្ឋានដោយយកទោសជំនួសមកអនុវត្តវិញ។[21]

**២.៣.១. ទោសការងារសហគមន៍**

ទោសការងារសហគមន៍ គឺជាកាតព្វកិច្ចដែលជនជាប់ចោទត្រូវបំពេញនៅការងារមួយដែលគ្មានប្រាក់កម្រៃនិងបានជាប្រយោជន៍ដល់រដ្ឋ រដ្ឋបាលថ្នាក់ក្រោមជាតិ ឬនីតិបុគ្គលនៃនីតិបុគ្គល សាធារណៈផ្សេងៗទៀតដល់សហគមន៍ ឬដល់អង្គការមិនមែនរដ្ឋាភិបាល។[22] ការងារដែលជននោះត្រូវបានដាក់ឲ្យធ្វើអាចប្រែប្រួលរយៈ

[18] សំណួរចម្លើយសម្រាប់ត្រៀមប្រឡងរៀបចំឡើងដោយបណ្ណាគារភក្តីឡដំ, ចេញថ្ងៃទី២៦/១២/២០១៦

[19] ក្រមព្រហ្មទណ្ឌ,លេខ នស/រកម/១១០៩/០២២ ,៣០ វិច្ឆិកា ២០០៩,មាត្រា ៩៨

[20] ក្រមព្រហ្មទណ្ឌ,លេខ នស/រកម/១១០៩/០២២ ,៣០ វិច្ឆិកា ២០០៩,មាត្រា ៩៨

[21] សំណួរចម្លើយសម្រាប់ត្រៀមប្រឡងរៀបចំឡើងដោយបណ្ណាគារភក្តីឡដំ, ចេញថ្ងៃទី២៦/១២/២០១៦

[22] ក្រមព្រហ្មទណ្ឌ,លេខ នស/រកម/១១០៩/០២២ ,៣០ វិច្ឆិកា ២០០៩,មាត្រា ៧២ កថាខណ្ឌទី២

ពេលចាប់ពី ៣០ (សាមសិប) ម៉ោង រហូតដល់២០០ (ពីររយ) ម៉ោង។[23] ការងារនេះមិនមែនជាប្រយោជន៍នៃរូបវន្តបុគ្គលនោះទេ ព្រោះជនដែលត្រូវអនុវត្តទោសនេះអាចជួយជាប្រយោជន៍រួមដល់រដ្ឋ និងសង្គមទាំងមូល។

ម្យ៉ាងវិញទៀត ការងារសហគមន៍ ត្រូវតែស្ថិតនៅក្រោមបទប្បញ្ញត្តិនៃច្បាប់ស្តីពីការងារជាអាទិ៍ ការងារនៅពេលយប់ អនាម័យ សន្តិសុខ និងការងាររបស់ស្ត្រីជាដើម។ ការងារសហគមន៍អាចត្រួតគ្នាជាមួយនឹងការអនុវត្តសកម្មភាពវិជ្ជាជីវៈ។[24] រដ្ឋជាអ្នករ៉ាប់រងចេញសោហ៊ុយជួសជុលសំណងការខូចខាតនានា ដែលបង្កឡើងដោយទណ្ឌិតនៅពេលកំពុងអនុវត្តការងារសហគមន៍។[25] លើសពីនេះទៅទៀតព្រះរាជអាជ្ញាមានតួនាទីជាអ្នកកំណត់នូវទោសការងារសហគមន៍នេះចំពោះទណ្ឌិត នៅពេលដែលតុលាការសម្រេចសេចក្តីឲ្យជននោះទទួលទោសនេះ។

### ២.៣.២. ការស្តីបន្ទោស

ការស្តីបន្ទោស តុលាការគ្រាន់តែធ្វើការស្តីបន្ទោសដល់ជនល្មើស ដែលបានប្រព្រឹត្តបទល្មើស ប៉ុន្តែមិនផ្តន្ទាទោសដាក់ពន្ធនាគារ ឬ ទោសពិន័យជាប្រាក់ឡើយ កាលបើជនល្មើសបានសងការខូចខាតរួចរាល់ហើយ។ ការស្តីបន្ទោសទាំងនោះភាគច្រើន តុលាការប្រើទៅលើអនីតិជនណាដែលមានអាយុចាប់ពី ១៤ឆ្នាំឡើង និងក្រោម១៨ឆ្នាំ ព្រោះជននោះត្រូវបានគេយល់ឃើញថាខ្វះសមត្ថភាពក្នុងការប្រព្រឹត្តបទល្មើសដោយឯកឯង។ តុលាការអាចប្រកាសទោសនេះទៅលើអនីតិជនបាន ដោយការព្រមានហើយ ប្រដៅអំពីទោសកំហុសឆ្គងដែលគាត់បានប្រព្រឹត្តហើយព្រមានថាកុំឲ្យគាត់ប្រព្រឹត្តបទល្មើសតទៅទៀត។[26]

តុលាការអាចធ្វើការប្រកាសការស្តីបន្ទោស កាលបើជនជាប់ចោទរងទោសដាក់ពន្ធនាគារ ដែលមានអតិបរមាតិចជាង ឬស្មើនឹង ០៣ឆ្នាំ ហើយប្រសិនបើបានបំពេញលក្ខខណ្ឌបីយ៉ាងដូចខាងក្រោម៖[27]

- ភាពចលាចលដល់សណ្តាប់ធ្នាប់សាធារណៈបង្កដោយបទល្មើសបានបញ្ចប់។
- ការខូចខាតត្រូវបានជួសជុលហើយ និង
- ជនជាប់ចោទបង្ហាញការជានាក្នុងការចូលរួមរស់ក្នុងសង្គមវិញ។

## ២.៤. គោលបំណងនៃទោស

ទោសត្រូវបានប្រកាសដោយតុលាការ គ្មានទោសណាមួយដែលអាចយកមកអនុវត្តបានឡើយ ប្រសិនបើទោសនោះមិនត្រូវបានប្រកាសដោយតុលាការ ។ ម្យ៉ាងវិញទៀត ទោសត្រូវបានគេសំដៅដល់ទណ្ឌកម្មមួយ

[23] ក្រមព្រហ្មទណ្ឌ,លេខ នស/រកម/១១០៩/០២២ ,៣០ វិច្ឆិកា ២០០៩,មាត្រា ៧២ កថាខណ្ឌទី២

[24] ក្រមព្រហ្មទណ្ឌ,លេខ នស/រកម/១១០៩/០២២ ,៣០ វិច្ឆិកា ២០០៩,មាត្រា ៧៤

[25] ក្រមព្រហ្មទណ្ឌ,លេខ នស/រកម/១១០៩/០២២ ,៣០ វិច្ឆិកា ២០០៩,មាត្រា ៧៥

[26] យោងតាមប្រសាសន៍របស់ ឯកឧត្តម **កើត រិទ្ធ** អនុប្រធានក្រុមការងារចូលរួមតាក់តែង និងការពារសេចក្តីព្រាងក្រមព្រហ្មទណ្ឌនៅក្នុងកម្មវិធីផ្សព្វផ្សាយច្បាប់ស្តីពី ក្រមព្រហ្មទណ្ឌ ដែលរៀបចំឡើងដោយក្រសួងយុត្តិធ៌សហការជាមួយក្រសួងព័ត៌មានតាមរយៈទូរទស្សន៍ជាតិ ឆ្នាំ២០១០

[27] ក្រមព្រហ្មទណ្ឌ,លេខ នស/រកម/១១០៩/០២២ ,៣០ វិច្ឆិកា ២០០៩,មាត្រា ៧៩

ដែលត្រូវបានប្រកាសដោយតុលាការសម្រាប់ធ្វើការអនុវត្តចំពោះបុគ្គលណា ដែលបានប្រព្រឹត្តបទល្មើសដូចមានចែងនៅក្នុងក្រមព្រហ្មទណ្ឌ ហើយទោសត្រូវបានប្រកាសដោយឈរលើមូលដ្ឋានព្យសនកម្មនៃបទល្មើស ដែលបានបង្កឲ្យមានការខូចខាតដល់ជនរងគ្រោះ ឬសណ្តាប់ធ្នាប់សង្គម។[28]

គោលបំណងនៃទោសមានដូចខាងក្រោម៖[29]

- ជួយរកយុត្តិធម៌ឲ្យជនរងគ្រោះ ឬ អ្នកទទួលរងព្យសនកម្ម
- ការពារសិទ្ធិសេរីភាព កិត្តិយស សេចក្តីថ្លៃថ្នូរ ផលប្រយោជន៍ស្របច្បាប់របស់ប្រជាពលរដ្ឋ ជាពិសេសផលប្រយោជន៍សាធារណៈ
- បង្រៀនឲ្យមនុស្សមានការទទួលខុសត្រូវខ្លួនឯង
- ដាក់ទោសទណ្ឌកម្មដល់ជនណាដែលបានល្មើសនឹងច្បាប់ ឲ្យសមទៅនឹងកំហុសទៅលើអំពើដែលខ្លួនបាន
- ទប់ស្កាត់ ព្រមានដល់ជនមិនល្អគ្រប់រូប និងបញ្ឈប់ជាបន្ទាន់នូវការប្រព្រឹត្តបទល្មើសទាំងបច្ចុប្បន្ននិងអនាគត
- ជួយផ្តល់នូវចំណេះដឹង ការអប់រំ និងដំបូន្មាន ដែលអាចយកមកប្រើប្រាស់នឹងអនុវត្តដល់ជនល្មើស ឬទណ្ឌិតពេលចូលទៅរស់នៅក្នុងសង្គមវិញ។

[28] ក្រមព្រហ្មទណ្ឌ,លេខ នស/រកម/១១០៩/០២២ ,៣០ វិច្ឆិកា ២០០៩,មាត្រា ៦

[29] (ចូលទស្សនាថ្ងៃទី២៥ ខែមេសា ឆ្នាំ២០២៤ )

# ជំពូកទី២

# ការព្យួរទោសជម្លតា

# ជំពូកទី២
# ការព្យួរទោសធម្មតា

ការព្យួរទោសធម្មតា គឺចង់សំដៅទៅលើការព្យួរទោស ដែលមិនមានការដាក់ឱ្យទណ្ឌិតស្ថិតនៅក្រោមវិធានការត្រួតពិនិត្យ និង គោរពនូវកាតព្វកិច្ចដោយឡែកណាមួយ ឬ ក៏ច្រើននោះទេ។

ហើយការព្យួរទោសធម្មតានេះ គឺត្រូវធ្វើការអនុវត្តទៅលើទោសដូចជា ៖

- ទោសដាក់ពន្ធនាគារ កាលបើទោសនោះតិចជាង ឬ ស្មើនឹង ៥ (ប្រាំ) ឆ្នាំ នៃបទឧក្រិដ្ឋ ឬ បទមជ្ឈិម និង តិចជាង ឬស្មើនឹង ១ (មួយ) ឆ្នាំ នៃបទលហុ
- ទោសពិន័យជាប្រាក់។[30]
- តុលាការ អាចសម្រេចថា ការព្យួរទោសធម្មតានេះអាចនឹងអនុវត្តទៅលើមួយផ្នែក នៃទោសពន្ធនាគារ ដែលតុលាការជាអ្នកកំណត់ថិរវេលា ឬ ក៏មួយផ្នែកនៃប្រាក់ពិន័យ ដែលតុលាការជាអ្នកកំណត់នូវចំនួនទឹកប្រាក់ដែលត្រូវធ្វើការពិន័យនោះ ។[31]

ក្នុងករណីនេះ ប្រសិនបើរយៈពេល ៥ (ប្រាំ) ឆ្នាំ បន្ទាប់ពីមានការផ្តន្ទាទោសជាស្ថាពររួចហើយ ពីបទឧក្រិដ្ឋ ឬ បទមជ្ឈិម ហើយដោយមានការព្យួរទោសធម្មតានោះ ប៉ុន្តែគ្មានការផ្តន្ទាទោសថ្មីជាស្ថាពរមួយផ្សេងទៀត ពីបទឧក្រិដ្ឋ ឬ បទមជ្ឈិមទេនោះ គឺការផ្តន្ទាទោសដោយមានការព្យួរទោសនេះ ត្រូវបានចាត់ទុកជាអសារបង់ ហើយទោសក៏មិនអាចងាកយកមកធ្វើការអនុវត្តបានទៀតដែរ។ ប៉ុន្តែប្រសិនបើក្នុងករណីរយៈពេល ៥ (ប្រាំ) ឆ្នាំ បន្ទាប់ពីមានការផ្តន្ទាទោសជាស្ថាពរពីបទឧក្រិដ្ឋ ឬ បទមជ្ឈិម ដោយមានការផ្តន្ទាទោសធម្មតា បែរជាមានការផ្តន្ទាទោសនូវបទល្មើសថ្មីមួយទៀត នោះត្រូវធ្វើការដកហូតការព្យួរទោសចេញ ដោយយកទោសចាស់មកបូកបញ្ចូលជាមួយទោសថ្មី ដែលតុលាការបានធ្វើការប្រកាសនៅក្នុងសាលក្រម ឬក៏សាលដីកានោះ ។ ហើយលក្ខខណ្ឌនៃការព្យួរទោសធម្មតានេះ គេក៏អាចធ្វើការសង្កេតឃើញថា ការប្រែប្រួលរបស់វា គឺទៅតាមប្រភេទនៃបទល្មើសចោទប្រកាន់ ថាតើបទឧក្រិដ្ឋ[32] បទមជ្ឈិម[33] ឬ បទលហុ ។ ដូច្នេះ បានសេចក្តីថា គឺច្បាប់បានដាក់

---

[30]មាត្រា ១០៧ (ទោសអាចនាំឱ្យមានការព្យួរទោស) នៃក្រមព្រហ្មទណ្ឌ ឆ្នាំ២០០៩

[31]មាត្រា ១០៨ (ការព្យួរទោសមួយផ្នែក) នៃក្រមព្រហ្មទណ្ឌ ឆ្នាំ២០០៩ បានចែងថា តុលាការអាចសម្រេចថា ការព្យួរទោសធម្មតានេះអាចនឹងអនុវត្តទៅលើមួយផ្នែកនៃទោសពន្ធនាគារ ដែលតុលាការជាអ្នកកំណត់ថិរវេលា ឬ លើមួយផ្នែកនៃប្រាក់ពិន័យដែលតុលាការជាអ្នកកំណត់ចំនួនទឹកប្រាក់ ។

[32]បទឧក្រិដ្ឋ គឺជាបទល្មើសដែលមានទណ្ឌកម្មធ្ងន់ធ្ងរបំផុត ។ បទល្មើសនេះត្រូវផ្តន្ទាទោសដាក់ពន្ធនាគារមានរយៈពេលលើសពី ៥ (ប្រាំ) ឆ្នាំ និងក្រោម ឬស្មើនឹង ៣០ (សាមសិប) ឆ្នាំ ឬដាក់ពន្ធនាគារអស់មួយជីវិត ។ ហើយមាត្រា៤៦ នៃក្រមព្រហ្មទណ្ឌ ក៏បានចែងអំពីនិយមន័យនៃបទឧក្រិដ្ឋដែរ ។( English : Felony , Crime /France : Crime) សន្ទានុក្រមពាក្យច្បាប់ (ដកស្រង់ពីច្បាប់ និង លិខិតបទដ្ឋានគតិយុត្តជាធរមាន) ពីឆ្នាំ១៩៩៤ ដល់ ឆ្នាំ២០១២

[33]បទមជ្ឈិម គឺជាបទល្មើសដែលមានទណ្ឌកម្មមធ្យមនៃទោស ដែលត្រូវដាក់ពន្ធនាគារមានរយៈពេលលើសពី ៦ (ប្រាំមួយ) ថ្ងៃ ដល់ ៥ (ប្រាំ) ឆ្នាំ ។ ហើយមាត្រា៤៧ នៃក្រមព្រហ្មទណ្ឌ ក៏បានចែងអំពីនិយមន័យនៃបទមជ្ឈិមដែរ ។

លក្ខខណ្ឌទៅលើអត្ថិភាព[34]នៃការផ្តន្ទាទោសពីមុន និង កំណត់អំពីទោស ដែលត្រូវបានអនុញ្ញាតឱ្យចៅក្រមអាចធ្វើការព្យួរទោសបាន ។

**ផ្នែកទី១ : ការចោទប្រកាន់ចំពោះបទឧក្រិដ្ឋ ឬ បទមជ្ឈិម**

ចំពោះការចោទប្រកាន់ចំពោះបទឧក្រិដ្ឋ ឬ បទមជ្ឈិម នេះទៅបាន គឺលុះត្រាតែចៅក្រមត្រូវពិនិត្យមើលឱ្យបានច្បាស់លាស់នូវការចោទប្រកាន់នោះ ដោយត្រូវបំពេញនូវ ៣(បី)កថាខណ្ឌ គឺ(កថាខណ្ឌទី១)លក្ខខណ្ឌនៃការព្យួរទោសធម្មតាចំពោះបទឧក្រិដ្ឋ ឬ បទមជ្ឈិម(កថាខណ្ឌទី២)ការសម្រេចសេចក្តីអំពីការព្យួរទោស និង (កថាខណ្ឌទី៣) អានុភាពនៃការព្យួរទោសជាមុនសិន។

**១.១ .លក្ខខណ្ឌនៃការព្យួរទោសធម្មតាចំពោះ បទឧក្រិដ្ឋ ឬ បទមជ្ឈិម**

លក្ខខណ្ឌនៃការព្យួរទោសធម្មតា ចំពោះបទឧក្រិដ្ឋ ឬ បទមជ្ឈិម អាចប្រព្រឹត្តទៅបាន ដោយត្រូវបំពេញនូវលក្ខខណ្ឌចំនួន ២ គឺៈ (ក) លក្ខខណ្ឌទាក់ទងជាមួយនឹងការផ្តន្ទាទោសពីមុន និង(ខ) លក្ខខណ្ឌទាក់ទងជាមួយនឹងទោសដែលអាចនាំឱ្យមានការព្យួរទោស។

**១.១.១.លក្ខខណ្ឌទាក់ទងជាមួយនឹងការផ្តន្ទាទោសពីមុន**

ចំពោះលក្ខខណ្ឌទាក់ទងជាមួយនឹងការផ្តន្ទាទោសពីមុន[35] គឺជាការទាក់ទងទៅនឹងការចោទប្រកាន់ពីបទឧក្រិដ្ឋ ឬ ក៏បទមជ្ឈិមណាមួយ ដែលតុលាការអាចធ្វើការប្រកាសព្យួរទោសបាន គឺលុះត្រាតែជនជាប់ចោទនោះមិនធ្លាប់មានការផ្តន្ទាទោសជាស្ថាពរពីមុនមក នៅក្នុងរយៈពេល ៥ (ប្រាំ) ឆ្នាំ ។ នៅក្នុងន័យនេះ គឺចង់បកស្រាយថា រហូតមកដល់ថ្ងៃដែលគាត់បានប្រព្រឹត្តបទល្មើសនេះ គឺគាត់ពុំដែលត្រូវបានតុលាការធ្វើការសម្រេចផ្តន្ទាទោសណាមួយពីមុនមកជាស្ថាពរនោះទេ ដោយនៅក្នុងរយៈពេល ៥ (ប្រាំ) ឆ្នាំនេះ។ ប៉ុន្តែ ប្រសិនបើជាគិតតាំងពីលើកមុនមក គាត់មានសាលក្រម ឬ សាលដីកាស្ថាពរពីចៅក្រម ក្នុងកំឡុងពេលដែលមិនទាន់ផុត ៥ (ប្រាំ) ឆ្នាំផង ពេលនោះស្រាប់តែមានការប្រព្រឹត្តនូវបទល្មើសថ្មីមួយផ្សេងទៀតនោះ បានសេចក្តីថា តុលាការមិនអាចលើកយកករណីដែលគាត់បានប្រព្រឹត្តបទល្មើសថ្មីមួយទៀតនោះ មកធ្វើការព្យួរទោសបានទៀតទេ។ ប៉ុន្តែ បើក្នុងករណីមានការប្រកាសការផ្តន្ទាទោសពីចៅក្រមនៅក្នុងសាលក្រម ឬ សាលដីកានោះ ដោយចូលជាស្ថាពរ ហើយក៏ត្រូវទទួលបាននូវការព្យួរទោសពីចៅក្រមផងដែរ ប៉ុន្តែរយៈពេល ៥ (ប្រាំ) ឆ្នាំ ត្រូវបានកន្លងហួស

[34]អត្ថិភាព គឺជាការកើតមាន ។ ឧទាហរណ៍ : អត្ថិភាពនៃបទល្មើសគឺការកើតមាននៃបទល្មើស ។ ( English : Existence / France : Existence ) សន្ទានុក្រមពាក្យច្បាប់ (ដកស្រង់ពីច្បាប់ និង លិខិតបទដ្ឋានគតិយុត្តជាធរមាន) ពីឆ្នាំ១៩៩៤ ដល់ ឆ្នាំ២០១២

[35]មាត្រា ១០៦ (លក្ខខណ្ឌទាក់ទងនឹងការផ្តន្ទាទោសពីមុន) នៃក្រមព្រហ្មទណ្ឌ ឆ្នាំ២០០៩ បានចែងថា ក្នុងករណីដែលមានការចោទប្រកាន់ពីបទឧក្រិដ្ឋ ឬ បទមជ្ឈិមនោះ ការព្យួរទោសធម្មតាអាចត្រូវផ្តល់ឱ្យបាន ប្រសិនបើជនជាប់ចោទមិនទាន់មានការផ្តន្ទាទោសជាស្ថាពរឱ្យជាប់ពន្ធនាគារក្នុងរយៈពេល ៥ (ប្រាំ) ឆ្នាំ មុនអំពើល្មើស ។

ក្រោយមកទើបមានការប្រព្រឹត្តនូវបទល្មើស[36]ចោទប្រកាន់ថ្មីមួយទៀត ហេតុនេះ ជនល្មើសនោះនៅតែអាចទទួលបាននូវអត្ថប្រយោជន៍ដដែរ។ ហើយរយៈពេលនេះគឺត្រូវគិតពីថ្ងៃដែលសេចក្ដីសម្រេចផ្ដន្ទាទោសពីមុនត្រូវបានចូលជាស្ថាពរ ។

### ១.១.២. លក្ខខណ្ឌទាក់ទងនឹងទោសដែលអាចនាំឱ្យមានការព្យួរទោស

ដោយផ្អែកទៅតាមមាត្រា ១០៧ នៃក្រមព្រហ្មទណ្ឌ ឆ្នាំ២០០៩ បានចែងថា ទោសដែលអាចនាំឱ្យមានការព្យួរទោស ដែលបានកំណត់ថា ការព្យួរទោសធម្មតា គឺត្រូវអនុវត្តទៅលើទោសដូចតទៅ ៖

- ទោសដាក់ពន្ធនាគារ កាលបើទោសដែលប្រកាសនោះតិចជាង ឬ ស្មើនឹង ៥ (ប្រាំ) ឆ្នាំ
- ទោសពិន័យជាប្រាក់ ។

បានសេចក្ដីថា ចំណុចខាងលើនេះ គឺចង់សំដៅទៅលើទោសដែលមានការផ្ដន្ទាទោសឱ្យជាប់ពន្ធនាគារ[37] ដែលមានរយៈពេលតិចជាង ឬ ក៏ស្មើនឹង ៥ (ប្រាំ) ឆ្នាំ មានន័យថា ត្រឹម ៥ (ប្រាំ) ឆ្នាំតុលាការបានប្រកាសនៅក្នុងសាលក្រម ឬ សាលដីកា ថា ជននោះមានទោសត្រូវដាក់ពន្ធនាគារត្រឹម ៥ (ប្រាំ) ឆ្នាំ ចុះក្រោមហ្នឹង គឺចៅក្រមអាចធ្វើការជ្រើសរើសយកនូវការព្យួរទោសនេះបាន ។ ហើយបើក្នុងករណីទោសនោះជាទោសពិន័យជាប្រាក់វិញនៅពេលដែលតុលាការបានកំណត់ដោយធ្វើការប្រកាសនៅក្នុងសាលក្រម ឬ សាលដីកានោះប្រសិនបើជាជននោះមិនចង់ឱ្យមានការអនុវត្តនូវទោសពិន័យជាប្រាក់ទេនោះ ជននោះក៏អាចសុំឱ្យតុលាការធ្វើការប្រកាសនូវការព្យួរទោសក៏បានដែរ ។

ប៉ុន្តែ នៅក្នុងចំណុចខាងលើនេះ តុលាការក៏អាចធ្វើការប្រកាសនូវការព្យួរទោសតែមួយផ្នែកនៃមូលទោស[38]ក៏បានដែរ ដោយតុលាការត្រូវបញ្ជាក់អំពីថិរវេលា និងចំនួនទឹកប្រាក់ដែលត្រូវពិន័យ ដែលអាចធ្វើការព្យួរទោសមួយផ្នែកបាន ឬ ក៏ទាំងស្រុងក៏បានដែរ ។ បានសេចក្ដីថា បើសិនជាចៅក្រមគាត់ចង់ប្រកាសឱ្យមានការព្យួរទោសមួយផ្នែកនោះ គឺត្រូវតែកំណត់ឱ្យបានច្បាស់លាស់នូវផ្នែកនៃទោសដែលត្រូវព្យួរ ដូចជាការប្រកាស

[36]បទល្មើស គឺជាអំពើប្រឆាំងនឹងរដ្ឋ អំពើដែលនាំឱ្យមានគ្រោះថ្នាក់ដល់សង្គម អំពើប្រឆាំងនឹងច្បាប់ព្រហ្មទណ្ឌជាធរមាន និងត្រូវផ្ដន្ទាទោសក្នុងបទឧក្រិដ្ឋ បទមជ្ឈិម ឬ បទលហុ ។( English : Offence / France : Infraction ) សទ្ទានុក្រមពាក្យច្បាប់ (ដកស្រង់ពីច្បាប់ និង លិខិតបទដ្ឋានគតិយុត្តជាធរមាន) ពីឆ្នាំ១៩៩៤ ដល់ ឆ្នាំ២០១២

[37]ពន្ធនាគារ គឺជាកន្លែងប្រើសម្រាប់ធ្វើការឃុំឃាំងជនជាប់ឃុំ តាមលិខិតឃុំខ្លួនចេញដោយអាជ្ញាធរតុលាការ រួមមាន មណ្ឌលឃុំខ្លួន និងមណ្ឌលអប់រំកែប្រែផង ។ សទ្ទានុក្រមពាក្យច្បាប់ (ដកស្រង់ពីច្បាប់ និង លិខិតបទដ្ឋានគតិយុត្តជាធរមាន) ពីឆ្នាំ១៩៩៤ ដល់ ឆ្នាំ២០១២

[38]មាត្រា ៤៣ (មូលទោស) នៃក្រមព្រហ្មទណ្ឌ ឆ្នាំ២០០៩ បានចែងថា មូលទោសរួមមាន ទោសដាក់ពន្ធនាគារ និងទោសពិន័យ ។ ការពិន័យត្រូវគិតជាប្រាក់រៀល ។

ទោស[39]ទៅលើទោសដាក់ពន្ធនាគារ[40]ហើយបើចៅក្រមគាត់ចង់ធ្វើការព្យួរទោសមួយផ្នែកនោះ គឺចៅក្រមត្រូវតែកំណត់នូវរយៈពេលថាប៉ុន្មានដែលគាត់ឱ្យអនុវត្ត ហើយរយៈពេលប៉ុន្មានថ្ងៃ ខែ ឆ្នាំ ទៀតដែលចៅក្រមត្រូវឱ្យព្យួរដោយមិនឱ្យមានជាប់ពន្ធនាគារនោះ ។ ដោយយោងទៅតាមមាត្រា ១០៨ (ការព្យួរទោសមួយផ្នែក) នៃក្រមព្រហ្មទណ្ឌ ឆ្នាំ២០០៩ បានចែងថា តុលាការអាចសម្រេចថា ការព្យួរទោសធម្មតានេះអាចនឹងអនុវត្តទៅលើមួយផ្នែកនៃទោសពន្ធនាគារ ដែលតុលាការជាអ្នកកំណត់ចិរវេលា ឬ លើមួយផ្នែកនៃប្រាក់ពិន័យ ដែលតុលាការជាអ្នកកំណត់ចំនួនទឹកប្រាក់ ។ ប៉ុន្តែ បើក្នុងករណីការប្រព្រឹត្តនេះ ដោយ អនីតិជនវិញ គឺការផ្តន្ទាទោសដោយចៅក្រមមានដូចគ្នា ខុសត្រង់ថា មូលទោសរបស់អនីតិជនគឺត្រូវបានកំណត់ផ្សេង ដោយយោងទៅតាមមាត្រា ១៦០ (មូលទោសអនុវត្តចំពោះអនីតិជនអាយុចាប់ពី ១៤ ឆ្នាំ ឡើងទៅ) នៃក្រមព្រហ្មទណ្ឌ ឆ្នាំ២០០៩ បានចែងថា កាលណាតុលាការសម្រេចផ្តន្ទាទោសព្រហ្មទណ្ឌទៅលើអនីតិជនអាយុចាប់ពី ១៤ (ដប់បួន) ឆ្នាំ ឡើងទៅ មូលទោសលើបទល្មើសដែលចោទប្រកាន់ ត្រូវបានបន្ថយក្នុងលក្ខខណ្ឌដូចតទៅ ៖

- អតិបរមានៃទោសដាក់ពន្ធនាគារត្រូវបន្ថយពាក់កណ្តាល ។
- ប្រសិនបើអតិបរមានៃទោសនោះ គឺជាទោសដាក់ពន្ធនាគារអស់មួយជីវិតអតិបរមាត្រូវបន្ថយមកដាក់ពន្ធនាគារ ២០ (ម្ភៃ) ឆ្នាំ ។
- អប្បបរមានៃទោសដាក់ពន្ធនាគារ ត្រូវបន្ថយពាក់កណ្តាល ប្រសិនបើអប្បបរមានេះលើសពី ១ (មួយ) ឆ្នាំ ។
- អប្បបរមា និងអតិបរមានៃទោសពិន័យជាប្រាក់ ត្រូវបន្ថយពាក់កណ្តាល ។

ក្នុងករណីចោទប្រកាន់ពីបទឧក្រិដ្ឋ ប្រសិនបើបទប្បញ្ញត្តិនៃមាត្រានេះមានអានុភាពបន្ថយអតិបរមានៃទោសដាក់ពន្ធនាគារមកត្រឹមចិរវេលាមួយស្មើ ឬ តិចជាង ៥ (ប្រាំ) ឆ្នាំនោះ បទល្មើសដែលចោទប្រកាន់នៅតែជាបទឧក្រិដ្ឋដដែល។

<u>**ឧទាហរណ៍**</u>:

ចៅក្រមបានធ្វើការប្រកាសទោសចំពោះទណ្ឌិតម្នាក់ ក្នុងករណីប្រព្រឹត្តបទលួច ដោយចៅក្រមបានប្រកាសផ្តន្ទាទោសដាក់ពន្ធនាគាររយៈពេល ២(ពីរ) ឆ្នាំ ប៉ុន្តែចៅក្រមគាត់មិនចង់ឱ្យមានការព្យួរទោសទាំងស្រុងនោះទេ ដូច្នេះ ចៅក្រមក៏ធ្វើការប្រកាសនៅក្នុងសាលក្រម ឬ ក៏សាលដីកាថា ១ (មួយ) ឆ្នាំ ត្រូវអនុវត្តក្នុងពន្ធនាគារ និង ១ (មួយ) ឆ្នាំ ទៀត ត្រូវធ្វើការព្យួរទោស ។ ដោយចំណុចនេះ ចៅក្រមត្រូវតែធ្វើការប្រកាស

---

[39]ការប្រកាសទោស គឺជាការប្រកាសដោយតុលាការនូវទោសណាមួយ ដើម្បីអាចយកទោសនោះមកអនុវត្តបាន ។ ( English : Denouncement of a penalty ) សន្ទានុក្រមពាក្យច្បាប់ (ដកស្រង់ពីច្បាប់ និង លិខិតបទដ្ឋានគតិយុត្តជាធរមាន) ពីឆ្នាំ១៩៩៤ ដល់ ឆ្នាំ ២០១២

[40]ទោសដាក់ពន្ធនាគារ គឺជាទោសគុក ទោសដែលបំបាត់សេរីភាពមានកំណត់កាល ដែលត្រូវបានផ្តន្ទាទោសដោយដាក់ពន្ធនាគារ ។ ( English : Jail punishment )

ដោយកំណត់ឱ្យបានច្បាស់លាស់នៅក្នុងសាលក្រម ឬ សាលដីកា សម្រាប់ផ្តន្ទាទោសដាក់ពន្ធនាគារ ២ (ពីរ) ឆ្នាំ ប៉ុន្តែ ១ (មួយ) ឆ្នាំ ត្រូវព្យួរ ដោយត្រូវតែកំណត់ឱ្យបានជាក់លាក់ ។

ទាក់ទងទៅនឹងការពិន័យជាប្រាក់វិញក៏ដូចគ្នាដែរ គឺថានៅក្នុងករណីណាដែលចៅក្រមគាត់ចង់ប្រកាសទោសពិន័យជាប្រាក់នោះហើយ បើនៅក្នុងករណីដែលចៅក្រមយល់ឃើញថាមិនគប្បីឱ្យមានការព្យួរទោសទាំងស្រុងទេនោះ ហើយក៏មិនគួរឱ្យមានការអនុវត្តទោសទាំងស្រុងផងដែរ ហេតុនេះតុលាការអាចធ្វើការព្យួរទោសមួយផ្នែកណាមួយនៃមូលទោសឱ្យសមស្របទៅនឹងអំពើដែលជនជាប់ចោទបានប្រព្រឹត្ត ។ បានសេចក្តីថា ចៅក្រមក៏អាចធ្វើការប្រកាសឱ្យព្យួរទោសតែមួយផ្នែកក៏បានដែរ ដូចករណីដាក់ទោសពន្ធនាគារអញ្ចឹងដែរ ។ ដូច្នេះប្រសិនមានការព្យួរទោសមួយផ្នែកចៅក្រមត្រូវតែកំណត់នូវចំនួនទឹកប្រាក់ប៉ុន្មានទៅតាមអ្វីដែលត្រូវធ្វើការព្យួរ ។ ចំណុចនេះហើយ គឺទាក់ទងទៅនឹងការព្យួរទោសពិន័យមួយផ្នែក ។

## ១.២. ការសម្រេចសេចក្តីអំពីការព្យួរទោសធម្មតា

ចំពោះការសម្រេចសេចក្តីអំពីការព្យួរទោសធម្មតា អាចប្រព្រឹត្តទៅបាននោះ គឺមានតែចៅក្រមដែលធ្វើការជំនុំជម្រះក្តីជាសាធារណៈ ឬ ពិសេស ដោយបញ្ជាក់អំពីបុគ្គលដែលបានប្រព្រឹត្តបទល្មើសនោះ នៅក្នុងសាលក្រម ឬ សាលដីកា។ ហើយដើម្បីអនុវត្តបទបញ្ញត្តិស្តីពីការព្យួរទោសបាននោះត្រូវគិតអំពីការផ្តន្ទាទោសជាស្ថាពរខាងបណ្តឹងអាជ្ញាប៉ុណ្ណោះ។[41]

<u>ឧទាហរណ៍:</u>

ជនម្នាក់ត្រូវបានផ្តន្ទាទោសឱ្យជាប់ពន្ធនាគាររយៈពេល ២ (ពីរ) ឆ្នាំ ហើយទោសនេះត្រូវព្យួរទោស ១ (មួយ) ឆ្នាំ។ នេះបានសេចក្តីថា ថ្វីត្បិតតែជនខាងលើត្រូវទទួលទោសជាប់ពន្ធនាគារ ២ (ពីរ) ឆ្នាំ ពិតមែន ប៉ុន្តែជននោះត្រូវអនុវត្តទោសតែ ១ (មួយ) ឆ្នាំ ប៉ុណ្ណោះ ពីព្រោះទោស ១ (មួយ) ឆ្នាំ ទៀតត្រូវបានធ្វើការព្យួរទោស។

សូមក្រឡេកមើលការបកស្រាយដែលទាក់ទងទៅនឹងសាលក្រម និងសាលដីកា ដែលទាក់ទងទៅនឹងការព្យួរទោសធម្មតា(បទឧក្រិដ្ឋ ឬបទមជ្ឈិម) ៖

-<u>**ការពិភាក្សាលើសាលក្រមទី១៖**</u>

យោងទៅតាមសាលក្រមដែលចេញដោយសាលាដំបូងខេត្តកំពង់ស្ពឺ លេខៈ ៧៣ "គ" ចុះថ្ងៃទី ២៥ ខែមករា ឆ្នាំ២០២២ ដែលអាចឲ្យយើងយល់ដឹងអំពីករណីដែលមានក្នុងសាលក្រមនេះ។ ដោយនៅក្នុងអង្គហេតុដែលបានរៀបរាប់នៅក្នុងសាលក្រមនេះ គឺលោក **ក** ដែលជាជនជាប់ចោទ ត្រូវបានជាប់ចោទពីបទ **បើកបរដោយធ្វេសប្រហែស ខ្ជីខ្ជា មិនប្រុងប្រយ័ត្នបណ្តាលឲ្យរបួសអ្នកដទៃ** ដោយមូលហេតុថាកាលពីថ្ងៃទី១២ ខែ

[41]មាត្រា ១០៥ (របបនៃការព្យួរទោស) នៃក្រមព្រហ្មទណ្ឌ ឆ្នាំ២០០៩ បានចែងថា ដើម្បីអនុវត្តបទបញ្ញត្តិស្តីពីការព្យួរទោស ត្រូវគិតតែអំពីការផ្តន្ទាទោសជាស្ថាពរខាងបណ្តឹងអាជ្ញាប៉ុណ្ណោះ ។

កុម្ភៈ ឆ្នាំ២០២១ វេលាម៉ោង៤ និង២០នាទី នៅលើផ្លូវជាតិលេខ៤ ត្រង់ចំណុចភូមិចំបក់ ខេត្តកំពង់ស្ពឺ មានករណីគ្រោះថ្នាក់ចរាចរណ៍មួយបានកើតឡើង។ លោក ក បានបើកបររថយន្តមួយគ្រឿង ក្នុងទិសដៅពីលិចទៅកើត បានបើកចូលចំណែកផ្លូវម្ខាងទៀត ខុសនឹងច្បាប់ស្តីពីចរាចរណ៍ផ្លូវគោក ជ្រុលទៅបុករថយន្តមួយគ្រឿងបើកបរដោយបុរស **ខ** និង លោកស្រី **គ** អ្នករួមដំណើរម្នាក់ ដែលកំពុងបើកបញ្ច្រាស់ទិសគ្នា បន្ទាប់មកលោក **ក** បានបើកជ្រុលទៅបុកបង្គោលភ្លើងចំនួន០១ដើម និងផ្ទះមួយខ្នងរបស់លោក **ស**។ គ្រោះថ្នាក់មួយនេះបណ្តាលអោយលោក **ខ** របួសធ្ងន់ និង លោកស្រី **គ** ជាអ្នករួមដំណើរម្នាក់រងរបួសស្រាល និងធ្វើឲ្យខូចខាតរថយន្ត០២គ្រឿង បង្គោលភ្លើងមួយដើម ផ្ទះមួយខ្នង និងសម្ភារៈក្នុងផ្ទះមួយចំនួន។ ដើមបណ្តឹងដែលមានលោក **ខ** និងលោកស្រី **គ** ក៏បានដាក់ពាក្យបណ្តឹងទៅសាលាដំបូងខេត្តកំពង់ស្ពឺ។ ហេតុនេះ សេចក្តីសម្រេចរបស់សាលាដំបូងខេត្តកំពង់ស្ពឺ ដែលមាននៅក្នុងសាលក្រមលេខៈ ៧៣ "គ" ចុះថ្ងៃទី២៥ ខែមករា ឆ្នាំ២០២២ ដោយធ្វើការប្រកាសជាសាធារណៈអំពីការផ្តន្ទាទោស លោក **ក** ពីបទ **បើកបរដោយធ្វេសប្រហែស ខ្ជីខ្ជា មិនប្រុងប្រយ័ត្នបណ្តាលឲ្យរបួសអ្នកដទៃ** ដោយកំណត់ដាក់ពន្ធនាគាររយៈពេល ០១ (មួយ)ឆ្នាំ និង ០៦(ប្រាំមួយ)ខែ តាមមាត្រា៨៣ នៃច្បាប់ចរាចរណ៍ផ្លូវគោក តែទោសនេះត្រូវព្យួរធម្មតា តាមមាត្រា១០៦ និងមាត្រា១០៧ នៃក្រមព្រហ្មទណ្ឌ និងឲ្យអ្នកទទួលខុសត្រូវរដ្ឋប្បវេណីសងសំណងការខូចខាត និងជម្ងឺចិត្តទៅឲ្យលោក **ខ** និងលោក **ស** ដែលជាដើមបណ្តឹងរដ្ឋប្បវេណី។ ដោយវត្ថុចាប់យកមាន៖ រថយន្តមួយគ្រឿងរបស់លោក **ខ** (ប្រគល់ឲម្ចាស់ដើម), រថយន្តមួយគ្រឿងរបស់លោក **ក** (ប្រគល់ឲម្ចាស់ដើម) និងសណ្តោងរ៉ឺម៉ក់(ប្រគល់ឲម្ចាស់ដើម)។ មូលហេតុ ដែលសាលាដំបូងខេត្តកំពង់ស្ពឺ សម្រេចផ្តន្ទាទោសបែបនេះ ពីព្រោះ តំណាងអយ្យការមានមូលហេតុ និងមូលដ្ឋានគ្រប់គ្រាន់ និងមានធាតុផ្សំគ្រប់គ្រាន់ ដែលជាបទល្មើស បើកបរដោយធ្វេសប្រហែស ខ្ជីខ្ជា មិនប្រុងប្រយ័ត្នបណ្តាលឲ្យរបួសអ្នកដទៃ តាមមាត្រា ៨៣ នៃច្បាប់ស្តីពីចរាចរណ៍ផ្លូវគោក។ ដោយចម្លើយសារភាពរបស់លោក **ក** នាពេលសវនាការក៏ស៊ីចង្វាក់ជាមួយគ្នាផងដែរ គ្រប់គ្រាន់នៅក្នុងការផ្តន្ទាទោស។ ហើយការបើកបររបស់ជនជាប់ចោទបានធ្វើឲ្យប៉ះពាល់ដល់របៀបរៀបរយសារធារណៈ និងសន្តិសុខសង្គម ព្រមទាំងធ្វើឲ្យគ្រោះថ្នាក់ដល់អ្នកដទៃ រងរបួសផងដែរ។

បានសេចក្តីថា បទ **បើកបរដោយធ្វេសប្រហែស ខ្ជីខ្ជាមិនប្រុងប្រយ័ត្នបណ្តាលឲ្យរបួសអ្នកដទៃ** គឺថាតំណាងអយ្យការបានធ្វើការប្រកាសសាលក្រមនេះដោយអនុវត្តទៅតាមច្បាប់ ដែលទាក់ទងទៅនឹង ការបើកបរដោយធ្វេសប្រហែស ខ្ជីខ្ជា មិនប្រុងប្រយ័ត្នបណ្តាលឲ្យរបួសអ្នកដទៃ តាមមាត្រា ៨៣ នៃច្បាប់ស្តីពីចរាចរណ៍ផ្លូវគោក ហើយមានការប្រកាសអំពីការព្យួរទោសធម្មតានៅក្នុងសាលក្រមនេះផងដែរ ដែលមានចែងក្នុងក្រមព្រហ្មទណ្ឌ ២០០៩។ ចំពោះមូលហេតុដែលចៅក្រមសម្រេចព្យួរទោសមួយផ្នែកដូចខាងលើនេះ ក៏ព្រោះតែជននោះបានប្រព្រឹត្ត ហើយមានព្យសនៈកម្ម បង្កឲ្យមានរបួសដល់អ្នកដទៃ ប៉ុន្តែមិនគ្រោះថ្នាក់ដល់ជីវិត ហេតុនេះហើយទើបតំណាងអយ្យការសម្រេចអោយមានការព្យួរទោសទៅលើជននោះ[42]។

**-<u>ការពិភាក្សាលើសាលដីកាទី២</u>៖**

យោងទៅតាមសាលដីកាដែលចេញដោយសាលាឧទ្ធរណ៍លេខៈ ១៦៧(ខ)ចុះថ្ងៃទី១៣ខែមីនា

[42] ឧបសម្ព័ន្ធទី៤, សាលាដំបូងខេត្តកំពង់ស្ពឺ, សាលក្រម លេខៈ ៧៣ "គ" ចុះថ្ងៃទី២៥ ខែមករា ឆ្នាំ២០២២ ។

ឆ្នាំ២០២៤ ដែលអាចឲ្យយើងយល់ដឹងអំពីករណីដែលមាននៅក្នុងសាលដីកានេះ។ ដោយនៅក្នុងអង្គហេតុដែលបានរៀបរាប់នៅក្នុងសាលដីកានេះគឺលោក **ក** ជាជនជាប់ចោទ ត្រូវបានជាប់ពីបទ **ជួញដូរ និងប្រើប្រាស់ដោយខុសច្បាប់នូវសារធាតុញៀន** ដោយមូលហេតុនៅថ្ងៃទី១៣ ខែ ឧសភា ឆ្នាំ២០២៣ កម្លាំងប្រឆាំងគ្រឿងញៀននៃអធិការនគរបាលក្រុងប៉ៃលិនបានចុះបង្ក្រាបករណីជាក់ស្តែង ជួញដូរ និងប្រើប្រាស់ដោយខុសច្បាប់នូវសារធាតុញៀន ដោយបានឃាត់ខ្លួនលោក **ក** ដែលជាជនសង្ស័យព្រមទាំងបានដកហូតម្សៅក្រាមពណ៌សថ្លាចំនួន ០២កញ្ចប់តូច ទម្ងន់ ២,២៥ ក្រាម, ជញ្ជីងថ្លឹងថ្នាំញៀនចំនួន ០១ និងទូរស័ព្ទចំនួន ០១គ្រឿង។ ក្រោយពីបានសាកសួរជនសង្ស័យរួច សមត្ថកិច្ចបានកសាងសំណុំរឿងបញ្ជូនទៅអយ្យការអមសាលាដំបូងខេត្តប៉ៃលិន ដើម្បីចាត់ការតាមនីតិវិធី។ ហេតុនេះ សេចក្តីសម្រេចរបស់សាលាដំបូងខេត្តប៉ៃលិន ដែលមាននៅក្នុងសាលក្រមលេខៈ ៨៣ "ខ" ចុះថ្ងៃទី៦ ខែតុលា ឆ្នាំ២០២៣ ដោយធ្វើការប្រកាសជាសាធារណៈអំពីការផ្តន្ទាទោស លោក **ក** ពីបទជួញដូរ និងប្រើប្រាស់ដោយខុសច្បាប់នូវសារធាតុញៀន ដោយកំណត់ដាក់ពន្ធនាគាររយៈពេល ០២ (ពីរ)ឆ្នាំ តាមមាត្រា ៤០ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន។ ដោយវត្ថុចាប់យកមានៈ ម្សៅក្រាមពណ៌សថ្លាចំនួន ២,២៧ ក្រាម, ទូរស័ព្ទម៉ាក IPHONE 6 ពណ៌ទឹកប្រាក់ចំនួន ០១គ្រឿង, សម្រេចរឹបអូសបំផ្លាញចោល លើកលែងតែទូរស័ព្ទម៉ាក IPHONE 6 ពណ៌ទឹកប្រាក់ ០១គ្រឿង សម្រេចប្រគល់ឲ្យម្ចាស់ដើមវិញ។ ក៏ប៉ុន្តែ លោក **ក** មិនសុខចិត្តទៅនឹងសេចក្តីសម្រេចរបស់សាលាដំបូងខេត្តប៉ៃលិន ក៏បានធ្វើបណ្តឹងឧទ្ធរណ៍។ ហេតុនេះ សាលាឧទ្ធរណ៍ទទួលពាក្យបណ្តឹងឧទ្ធរណ៍របស់លោក **ក** ទុកជាត្រឹមត្រូវតាមទម្រង់ច្បាប់ ហើយក៏បានចេញនូវសាលដីកាលេខៈ ១៦៧(ខ) ចុះថ្ងៃទី១៣ ខែមីនា ឆ្នាំ២០២៤ ដែលប្រកាសជាសារធាណៈ ដោយបានតម្កល់សាលក្រមព្រហ្មទណ្ឌលេខៈ ៨៣ "ខ" ចុះថ្ងៃទី៦ ខែតុលា ឆ្នាំ២០២៣ ទុកជាបានការដដែល ដោយគ្រាន់តែកែប្រែរយៈពេលនៃការផ្តន្ទាទោសលើ លោក **ក** ក្នុងចំណុចទី១ នៃសេចក្តីសម្រេច ពីទោសដាក់ពន្ធនាគារកំណត់ ២ (ពីរ) ឆ្នាំ មកជា ទោសដាក់ពន្ធនាគារកំណត់ ២ (ពីរ) ឆ្នាំ តែត្រូវអនុវត្តក្នុងពន្ធនាគារកំណត់ចំនួន ១ (មួយ) ឆ្នាំ ទោសនៅសល់ពីនេះ ត្រូវព្យួរទោសធម្មតាវិញ យោងតាមមាត្រា១០៧ និងមាត្រា ១០៨ នៃក្រមព្រហ្មទណ្ឌ។ ដោយមូលហេតុថា សាលាឧទ្ធរណ៍បានធ្វើការពិនិត្យទៅលើអង្គហេតុ ភស្តុតាង និងចម្លើយរបស់ជនជាប់ចោទមានលក្ខណៈសមរម្យ ព្រោះជនជាប់ចោទបានសហការជាមួយសមត្ថកិច្ច មិនបង្កការលំបាកដល់នីតិវិធីតុលាការ មានសារភាពទទួលស្គាល់កំហុស និងមានការសោកស្តាយចំពោះកំហុស ដែលបានធ្វើខុសកន្លងមក។ ហេតុនេះ ទើបសាលាឧទ្ធរណ៍តម្កល់សាលក្រមសាលាដំបូងទុកជាបានការ ដោយគ្រាន់តែកែប្រែការផ្តន្ទាទោសលើជនជាប់ចោទ ដោយអនុវត្តក្នុងពន្ធនាគារកំណត់ចំនួន ១ (មួយ)ឆ្នាំ ទោសនៅសល់ពីនេះ ត្រូវព្យួរធម្មតាវិញ យោងតាមមាត្រា ១០៧ និងមាត្រា ១០៨ នៃក្រមព្រហ្មទណ្ឌ។

បានសេចក្តីថា បទល្មើស ជួញដូរ និងប្រើប្រាស់ដោយខុសច្បាប់នូវសារធាតុញៀន គឺថាទាំងសាលក្រម

និងសាលដីកា របស់តុលាការគ្រប់ជាន់ថ្នាក់ តំណាងអយ្យការធ្វើការប្រកាសទៅតាមបទល្មើសដែលមានចែងនៅក្នុងក្រមព្រហ្មទណ្ឌ និងអនុវត្តនូវការព្យួរទោសធម្មតា ដែលមានចែងក្នុងក្រមព្រហ្មទណ្ឌផងដែរ។ ចំពោះមូលហេតុដែលចៅក្រមសម្រេចព្យួរទោសមួយផ្នែកដូចខាងលើនេះ ក៏ព្រោះតែជននោះបានសារភាពទទួលស្គាល់នូវកំហុសរបស់ខ្លួន គឺខ្លួនពិតជាបានប្រព្រឹត្តអំពើជួញដូរ និងរក្សាទុកដោយខុសច្បាប់នូវសារធាតុញៀនពិតប្រាកដមែន។ ហេតុនេះ ទើបតុលាការសម្រេចឱ្យមានការព្យួរទោសទៅលើជននោះតែម្តង[43]។

-**<u>ការពិភាក្សាលើសាលដីកាទី៣</u>**៖

យោងទៅតាមសាលដីកាដែលចេញដោយសាលាឧទ្ធរណ៍ភ្នំពេញលេខៈ ៥១ "ក្រ.III.ច" ចុះថ្ងៃទី២៩-០៤-២០២៤ ដែលអាចឱ្យយើងយល់ដឹងអំពីករណីដែលមានក្នុងសាលដីកានេះ។ ដោយនៅក្នុងអង្គហេតុដែលបានរៀបរាប់នៅក្នុងសាលដីកានេះ គឺលោកស្រី **ក** ដែលជាជនជាប់ចោទពីបទ **ឆបោក និងមិនបំពេញកាតព្វកិច្ចចំពោះឧបករណ៍អាចជួញដូរបាន** និង លោកស្រី **ខ** លោក **គ** និងលោកស្រី **ឃ** ជាជនជាប់ចោទពីបទឆបោក និងលោក **ឆ** ជាដើមបណ្តឹង ដោយមូលហេតុថា កាលពីអំឡុងឆ្នាំ២០១៩ ដល់ឆ្នាំ២០២០ លោកស្រី **ក** លោកស្រី **ខ** លោក **គ** និងលោកស្រី **ឃ** បានសុំខ្ចីប្រាក់ពី លោក **ឆ** ដើម្បីយកទៅរកស៊ីទិញដី នៅខេត្តព្រះសីហនុ ទិញគ្រឿងចក្រ និងឡានដឹកខ្សាច់ ដោយមានការជឿជាក់ លោក ឆ ក៏បានប្រគល់ប្រាក់ជាបន្តបន្ទាប់សរុប ១៤៣,៥០០$ (ដប់បួនម៉ឺនបីពាន់ប្រាំរយដុល្លារអាមេរិក) ដោយលោកស្រី **ក** លោក **គ** និងលោកស្រី **ឃ** បានដាក់ធានា កាតគ្រីឡានដឹកដី លិខិតស្នាមពាក់ព័ន្ធដីធ្លីមួយចំនួន លុះដល់ថ្ងៃកំណត់ទូទាត់ប្រាក់ជំពាក់លោកស្រី **ក** បានចេញមូលប្បទានប័ត្រចំនួន៤សន្លឹក ដែលមានលេខ ២៧២៩៧៩, លេខ២៧២៩៨០, លេខ ២៧២៩៨១, លេខ២៧២៩៨២ របស់ធនាគារវិនិយោគ និងអភិវឌ្ឍន៍កម្ពុជា ភីអិលស៊ី ប្រគល់ឱ្យលោក **ឆ** ប៉ុន្តែពេលលោក **ឆ** យកទៅបើកប្រាក់ត្រូវធនាគារបង្វិលត្រឡប់ ព្រោះមិនមានសាច់ប្រាក់ក្នុងគណនី។ ក្រោយមកលោក **ឆ** បានធ្វើការស៊ើបសួរទើបដឹងថា កាតគ្រីឡានដឹកដី លិខិតស្នាមពាក់ព័ន្ធដីធ្លី ដែលពួកគេបានដាក់ធានានេះ មិនមែនជាកម្មសិទ្ធរបស់លោកស្រី **ក** លោកស្រី **ខ** លោក **គ** និងលោកស្រី **ឃ** នោះទេ។ ដើមបណ្តឹងដែលមានលោក **ឆ** ក៏បានដាក់ពាក្យបណ្តឹងទៅសាលាដំបូងរាជធានីភ្នំពេញ ។ ហេតុនេះ សេចក្តីសម្រេចរបស់សាលាដំបូងរាជធានីភ្នំពេញ ដែលមាននៅក្នុងសាលក្រមលេខៈ ៣៤៧២ "ត" ចុះថ្ងៃទី១៥ ខែវិច្ឆិកា ឆ្នាំ២០២២ ដោយឲ្យលោកស្រី **ក** រួចខ្លួនពីបទចោទខាងលើ ពីបទ ឆបោក និងមិនបំពេញកាតព្វកិច្ចចំពោះឧបករណ៍អាចជួញដូរបាន ប្រព្រឹត្តនៅរាជធានីភ្នំពេញ កាលពីអំឡុងឆ្នាំ២០១៩ ដល់ឆ្នាំ២០២០ និងលោកស្រី ខ លោក គ និងលោកស្រី **ឃ** រួចផុតពីបទ **ឆបោក**។ សាលក្រមនេះប្រកាសជាសាធារណៈនៅថ្ងៃទី១៥ ខែវិច្ឆិកា ឆ្នាំ២០២២។ ប៉ុន្តែអគ្គព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍ភ្នំពេញ និងដើមបណ្តឹងរដ្ឋប្បវេណីលោក **ឆ** មិនសុខចិត្ត ក៏បានធ្វើបណ្តឹងឧទ្ធរណ៍ផងដែរ។ ហេតុនេះ សាលាឧទ្ធរណ៍ទទួលពាក្យបណ្តឹងឧទ្ធរណ៍របស់ដើមបណ្តឹងរដ្ឋប្បវេណីលោក **ឆ**

[43]ឧបសម្ព័ន្ធទី៥, សាលាឧទ្ធរណ៍ភ្នំពេញ, សាលដីកាលេខ ១៦៧(ខ) ចុះថ្ងៃទី១៣ ខែមីនា ឆ្នាំ២០២៤។

និងរបស់អគ្គព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍ ទុកជាត្រឹមត្រូវតាមទម្រង់ច្បាប់ ហើយក៏បានចេញនូវសាលដីកាចុះថ្ងៃទី២៩ ខែមេសា ឆ្នាំ២០២៤ ដែលប្រកាសជាសាធារណៈ ដោយបានតម្កល់សាលក្រមព្រហ្មទណ្ឌចុះថ្ងៃទី១៥ ខែវិច្ឆិកា ឆ្នាំ២០២២ ទុកជាបានការ លើកលែងចំណុចទី១ នៃសេចក្តីសម្រេចត្រូវបដិសេធចោល ដោយសម្រេចជាថ្មី៖ ដោយផ្តន្ទាទោសលោកស្រី ក ដាក់ពន្ធនាគារកំណត់ ០២ (ពីរ) ឆ្នាំ តែទោសនេះត្រូវអនុវត្តទោសព្យួរធម្មតា ពីបទ មិនបំពេញកាតព្វកិច្ចចំពោះឧបករណ៍ដែលអាចជួញដូរ យោងតាមមាត្រា ២៣១ នៃច្បាប់ស្តីពីឧបករណ៍អាចជួញដូរបាន និងប្រតិតបត្តិការទូទាត់ប្រាក់ និងមាត្រា ១០៧ នៃក្រមព្រហ្មទណ្ឌ និងបង្គាប់ឲ្យលោកស្រី **ក** សងប្រាក់ និងសំណងជម្ងឺចិត្តទៅឲ្យដើមបណ្តឹងរដ្ឋប្បវេណីលោក **ឆ**។[44] ដោយមូលហេតុថា សាលាឧទ្ធរណ៍បានធ្វើការពិនិត្យទៅលើអង្គហេតុ ភស្តុតាង (បូលប្បទានបត្រ) និងចម្លើយរបស់ដើមបណ្តឹងរដ្ឋប្បវេណី ឃើញថា ពិតជាមានពិរុទ្ធភាព និងភស្តុតាងគ្រប់គ្រាន់ទៅលើលោកស្រី **ក** ពីបទ មិនបំពេញកាតព្វកិច្ចចំពោះឧបករណ៍ដែលអាចជួញដូរ ពិតប្រាកដមែន ។ ហេតុនេះ ទើបសាលាឧទ្ធរណ៍តម្កល់សាលក្រមសាលាដំបូងទុកជាបានការ ដោយគ្រាន់តែកែប្រែទោសដាក់ពន្ធនាគារ ២ (ពីរ) ឆ្នាំ ដោយអនុវត្តព្យួរទោសធម្មតា តាមមាត្រា ១០៧ នៃក្រមព្រហ្មទណ្ឌ។

បានសេចក្តីថា បទល្មើស **មិនបំពេញកាតព្វកិច្ចចំពោះឧបករណ៍ដែលអាចជួញដូរ** គឺថានៅក្នុងសាលដីកា ចៅក្រមបានធ្វើការប្រកាសដោយអនុវត្តទៅតាមច្បាប់ដែលទាក់ទងទៅនឹងបទល្មើស ដែលបានកើតឡើងដោយមានចែងនៅក្នុងច្បាប់ស្តីពី ឧបករណ៍អាចជួញដូរបាន និងប្រតិតបត្តិការទូទាត់ប្រាក់ ហើយចៅក្រមក៏បានប្រកាសអំពីការព្យួរទោសធម្មតានៅក្នុងសាលក្រមនេះផងដែរ។ ចំពោះមូលហេតុ ដែលចៅក្រមសម្រេចព្យួរមួយផ្នែកខាងលើនេះ ក៏ព្រោះតែមេធាវីដើមបណ្តឹងរដ្ឋប្បវេណីបាននិយាយថា សុំទាមទារឲ្យសងនូវប្រាក់របស់ដមបណ្តឹងរដ្ឋប្បវេណីតែប៉ុណ្ណោះ។ ហេតុនេះ ទើបចៅក្រមសម្រេចឲ្យមានការព្យួរទោសទៅលើជននោះតែម្តង ដោយគ្រាន់តែឲ្យសងប្រាក់ និងជម្ងឺចិត្តទៅដើមបណ្តឹងរដ្ឋប្បវេណីវិញតែប៉ុណ្ណោះ។

### ១.៣. អានុភាពនៃការព្យួរទោសធម្មតា

ការព្យួរទោសធម្មតាមានអានុភាព នៅក្នុងករណីដែលជនណាមួយបានប្រព្រឹត្តបទឧក្រិដ្ឋ ឬ បទមជ្ឈិមដែលត្រូវបានចៅក្រមធ្វើការប្រកាសទោសដាក់ពន្ធនាគារ ឬ ក៏ពិន័យជាប្រាក់ នៅក្នុងសាលក្រម[45] ឬ ក៏សាល

[44] ឧបសម្ព័ន្ធទី៦, សាលាឧទ្ធរណ៍ភ្នំពេញ, សាលដីកាលេខ ៥១ "ក្រ.III.ច" ចុះថ្ងៃទី២៩ ខែមេសា ឆ្នាំ២០២៤។

[45]សាលក្រម គឺជាសេចក្តីសម្រេចរបស់តុលាការជាន់ទាប មានលក្ខណៈគ្រប់គ្រាន់ទៅតាមទម្រង់ដែលច្បាប់បានកំណត់ ដោយផ្អែកតាមការទាញហេតុផលដោយផ្ទាល់មាត់ ។ ( English : Judgment / France : Jugement )សន្ទានុក្រមពាក្យច្បាប់ (ដកស្រង់ពីច្បាប់ និងលិខិតបទដ្ឋានគតិយុត្តជាធរមាន) ពីឆ្នាំ១៩៩៤ ដល់ ឆ្នាំ២០១២

ដីកា[46] ទៅតាមលក្ខខណ្ឌនៃការចោទប្រកាន់ចំពោះបទឧក្រិដ្ឋ ឬ បទមជ្ឈិម ដែលលក្ខខណ្ឌទាំងនោះមានការបកស្រាយនៅក្នុងកថាខណ្ឌទី១ ។

### ១.៣.១. ការទុកជាអសារបង់នូវការផ្តន្ទាទោស

ទាក់ទងទៅនឹងការព្យួរទោសខាងលើ នៅក្នុងចំណុចនេះ យើងសូមបញ្ជាក់ជូនបន្ថែមទៀតផងដែរថា ប្រសិនបើក្នុងករណីដែលផុតចិរវេលា ៥ (ប្រាំ) ឆ្នាំ ហើយបន្ទាប់ពីមានសាលក្រម ឬ សាលដីកា ដែលបានកំណត់អំពីការព្យួរទោសនេះ គឺទោសនោះត្រូវតែចាត់ទុកជាអសារបង់ បានសេចក្តីថា គឺគេលែងយកមកធ្វើការអនុវត្តតទៅទៀតនោះហើយ បើទោះបីជាទោសដាក់ពន្ធនាគារក៏ដោយ ឬ ក៏ទោសពិន័យជាប្រាក់ក៏ដោយ ។ ដោយផ្អែកទៅតាមមាត្រា ១១១ (ការទុកជាអសារបង់នូវការផ្តន្ទាទោស) នៃក្រមព្រហ្មទណ្ឌ ឆ្នាំ២០០៩ បានចែងថា ប្រសិនបើរយៈពេល ៥ (ប្រាំ) ឆ្នាំ បន្ទាប់ពីផ្តន្ទាទោសជាស្ថាពរពីបទឧក្រិដ្ឋ ឬ បទមជ្ឈិម ដោយមានការព្យួរទោសធម្មតា ហើយក៏គ្មានការផ្តន្ទាទោសថ្មីជាស្ថាពរមួយទៀតពីបទឧក្រិដ្ឋ ឬ បទមជ្ឈិមនោះទេ ការផ្តន្ទាទោសដោយមានព្យួរនេះត្រូវចាត់ទុកថាជាអសារបង់ ។ ទោសក៏មិនអាចយកមកអនុវត្តបានទៀតឡើយ ។

កាលណា បើការព្យួរទោសត្រូវបានប្រកាសទៅលើតែផ្នែកមួយនៃទោសនោះ ការ ផ្តន្ទាទោសត្រូវចាត់ទុកជាអសារបង់ទាំងស្រុង ។ ទោសក៏មិនអាចយកមកអនុវត្តបានទៀតដែរ ។ ដូច្នេះ ចំណុចខាងលើនេះ គឺចង់សំដៅទៅលើបើក្នុងករណីផុតរយៈពេលដែលបានកំណត់ (៥ ឆ្នាំ) ដែលមានសាលក្រម ឬ សាលដីកា ចូលជាស្ថាពរហើយនោះ ទោសនេះក៏ត្រូវបានទុកជាអសារបង់ផងដែរ ។

### ១.៣.២. ការដកហូតការព្យួរទោសជាអញ្ញត្រកម្ម

កាលណាក្នុងរយៈពេល ៥ (ប្រាំ) ឆ្នាំ បន្ទាប់ពីមានការផ្តន្ទាទោសជាស្ថាពរពីបទឧក្រិដ្ឋ ឬ បទមជ្ឈិមរួចមក ហើយដោយមានការព្យួរទោសធម្មតាហើយនោះ រួចក៏មានការផ្តន្ទាទោសថ្មីជាស្ថាពរមួយទៀតកើតឡើងពីបទឧក្រិដ្ឋ ឬ បទមជ្ឈិមផងដែរនោះ ហេតុនេះហើយការព្យួរទោសធម្មតានោះ ត្រូវតែធ្វើការដកហូតដោយពេញច្បាប់ បើនិយាយឱ្យសាមញ្ញ គឺត្រូវធ្វើការដកហូតដោយស្វ័យប្រវត្តិតែម្តង ។ ហើយដោយទោសទី១ ត្រូវតែអនុវត្តដោយមិនអាចធ្វើការស្រូបចូលជាមួយនឹងទោសទី២ បាននោះទេ បើយោងទៅតាមអត្ថន័យខាងលើនេះបានន័យថា ទាក់ទងទៅនឹងការព្យួរទោសធម្មតា ប្រសិនបើក្នុងរយៈពេល ៥(ប្រាំ) ឆ្នាំ មិនទាន់ហួស ហើយជននោះក៏បានប្រព្រឹត្តបទល្មើសឧក្រិដ្ឋ ឬ បទមជ្ឈិមណាផ្សេងទៀតនោះ បើក្នុងករណីនេះ ប្រសិនជាមានសាលក្រម ឬ សាលដីកា ក្រោយពីមានការផ្តន្ទាទោសជាស្ថាពរ ធ្វើឱ្យមានការដកហូតនូវការព្យួរទោសដែលត្រូវផ្តន្ទាទោសនោះ ហើយបើមានកំណត់នៅក្នុងសាលក្រម ឬ សាលដីកាមុននឹងត្រូវធ្វើការដកហូតដោយពេញច្បាប់តែ

[46]សាលដីកា គឺជាសេចក្តីសម្រេចរបស់សាលាជម្រះក្តីជាន់ខ្ពស់ ( សាលាឧទ្ធរណ៍តុលាការ ) ដែលមានលក្ខណៈគ្រប់គ្រាន់ទៅតាមទម្រង់ដែលច្បាប់បានកំណត់ ដោយផ្អែកតាមការទាញហេតុផលដោយផ្ទាល់មាត់ ។ ( English : Judgment ) សន្ទានុក្រមពាក្យច្បាប់ (ដកស្រង់ពីច្បាប់ និង លិខិតបទដ្ឋានគតិយុត្តជាធរមាន) ពីឆ្នាំ១៩៩៤ ដល់ ឆ្នាំ២០១២

ម្តង ឬ ក៏ដោយស្វ័យប្រវត្តិ ។ ចំណុចនេះគឺចង់និយាយថា បើសាលក្រមទី១ ដែលមានកំណត់នូវទោសដាក់ពន្ធនាគារមានរយៈពេលប៉ុន្មាន នោះត្រូវធ្វើការដកហូតយកមកអនុវត្តទោសដោយពេញលេញទៅនឹងសាលក្រមទី២ ដែលមានកំណត់នូវរយៈពេលប៉ុន្មាននោះ ដែលត្រូវយកមកអនុវត្ត ដោយត្រូវធ្វើការបូកបញ្ចូលគ្នា គឺមិនត្រូវធ្វើការស្រូបបញ្ចូលគ្នានោះទេ ។

ហេតុនេះ បើកាលណាមានការដកហូតការព្យួរទោសបែបនេះ គឺសាលក្រមទី១ និង សាលក្រមទី២ ត្រូវយកទៅអនុវត្តដោយធ្វើការបូកបញ្ចូលគ្នាតែម្តង ដោយពុំមានការស្រូបទោសនោះទេ ។ហើយជាអញ្ញត្រកម្ម តុលាការក៏អាចប្រកាសពីភាពមិនអាចដកហូតបានដែរ ចំពោះការព្យួរទោសពីមុន ដោយត្រូវបញ្ជាក់ហេតុផលពិសេស ។ ដោយយោងទៅតាមមាត្រា ១១០ (ការមិនដកហូតការព្យួរទោស) នៃក្រមព្រហ្មទណ្ឌ ឆ្នាំ២០០៩ បានចែងថា ជាបដិប្បញ្ញត្តិទៅនឹងមាត្រា ១០៩ (ការដកហូតការព្យួរទោស) នៃក្រមនេះ តុលាការអាចសម្រេចថា ការផ្តន្ទាទោសថ្មីមិននាំឱ្យមានការដកហូតនូវការព្យួរទោសធម្មតា ដែលបានសម្រេចពីមុននោះទេ ។សេចក្តីសម្រេចរបស់តុលាការត្រូវតែមានសំអាងហេតុជាពិសេស ។ បើយោងទៅតាមអត្ថន័យខាងលើនេះ គឺអាចបញ្ជាក់ឱ្យកាន់តែយល់អំពីខ្លឹមសារយ៉ាងលម្អិត ដែលទាក់ទងទៅនឹងការមិនដកហូតការព្យួរទោសឱ្យកាន់តែច្បាស់ថែមទៀតថា នៅក្នុងក្រមនេះ គឺគេទុកសិទ្ធិសម្រាប់ចៅក្រមដែរ ប្រសិនបើគាត់យល់ឃើញថា ការផ្តន្ទាទោសក្រោយនេះ ទោះបីជាស្ថិតនៅក្នុងកម្រិតនៃរយៈពេល ៥ (ប្រាំ) ឆ្នាំ ដែលជននោះបានប្រព្រឹត្តចំពោះសាលក្រមទី១ ដែលត្រូវបានកំណត់ព្យួររួចហើយក៏ដោយ បើសិនជាធ្វើការពិនិត្យមើលទៅលើបទប្បញ្ញត្តិនៃមាត្រា ១០៩ គឺថាត្រូវតែមានការដកហូតការព្យួរទោសដោយស្វ័យប្រវត្តិពិតមែន ។ ប៉ុន្តែ ចំពោះមាត្រា ១១០ (ការមិនដកហូតការព្យួរទោស) នៃក្រមព្រហ្មទណ្ឌ ឆ្នាំ២០០៩ គឺបានចែងឱ្យចៅក្រមមានសិទ្ធិសម្រេចដោយមិនឱ្យមានការដកហូតការព្យួរទោសនោះបាន ដោយមានចែង និងកំណត់យ៉ាងច្បាស់លាស់នៅក្នុងសាលក្រម ឬ សាលដីកា ហើយត្រូវតែមានសំអាងហេតុ[47]ជាពិសេស។ ប្រសិនបើចៅក្រមយល់ឃើញថា មិនគួរដកហូតការព្យួរទោសទេ នោះចៅក្រមត្រូវតែចែងនៅក្នុងសាលក្រម ឬ សាលដីកានោះឱ្យបានច្បាស់លាស់ថា ពុំមានការដកហូតការព្យួរទោសនោះទេ ហើយក៏ត្រូវបញ្ជាក់អំពីសំអាងហេតុដែរ ថាហេតុអ្វីបានជាមិនដកហូតការព្យួរទោសនេះ ។

<u>**ឧទាហរណ៍**</u>:

បើក្នុងករណីជនម្នាក់ជាជនដែលទីទាល់ក្រ គ្មានអាហារហូបចុក ស្រាប់តែថ្ងៃមួយ ជននោះក៏បានទៅប្រព្រឹត្តបទល្មើសលួច ។ នៅពេលនោះ ក៏ត្រូវបានមន្ត្រីនគរបាលយុត្តិធម៌ចាប់ខ្លួន ដោយបានធ្វើការបញ្ជូនមកកាន់តុលាការ ដើម្បីធ្វើការជំនុំជម្រះទៅលើរឿងក្តីរបស់គាត់ ។ ប៉ុន្តែ នៅពេលធ្វើការជំនុំជម្រះរួច ចៅក្រមក៏បាន

[47]សំអាងហេតុ គឺជាអំណះអំណាងដែលជួយដល់តុលាការ ក្នុងការសម្រេចសេចក្តី ឬ អាចជាផ្នែកមួយនៃសាលក្រមដែលបង្ហាញអំពីយោបលរបស់ចៅក្រម ក្នុងក្របខណ្ឌនៃអង្គហេតុក្នុងដំណើរការវិនិច្ឆ័យសេចក្តី ។ ( English : Motive /France : Motif ) សទ្ទានុក្រមពាក្យច្បាប់ (ដកស្រង់ពីច្បាប់ និង លិខិតបទដ្ឋានគតិយុត្តជាធរមាន) ពីឆ្នាំ១៩៩៤ ដល់ ឆ្នាំ២០១២

សម្រេចដោយប្រកាសព្យួរទោសទៅលើជននោះ ។ ក្រោយមក ជននោះក៏ខិតខំអប់រំ និងកែប្រែខ្លួនឯង ប៉ុន្តែ នៅថ្ងៃដែលជិតផុតរយៈពេលដែលបានកំណត់ដោយច្បាប់ហើយនោះ (រយៈពេល ៥ ឆ្នាំ) ជននោះក៏បានទៅលួចគេម្តងទៀត ដោយមូលហេតុគ្មានអាហារសម្រាប់ហូប ណាមួយឃ្លានខ្លាំងពេក ។ ដូច្នេះ ក្នុងករណីមួយនេះ គឺថាចៅក្រមអាចមិនដកហូតការព្យួរទោសទៅលើជននោះទេ ។

## ផ្នែកទី២ : ការចោទប្រកាន់ចំពោះបទលហុ

ទាក់ទងទៅនឹងការព្យួរទោសចំពោះបទលហុវិញ គឺវាមានលក្ខណៈខុសប្លែកពីគ្នាខ្លះត្រង់ចិរវេលា ដែលទាក់ទងជាមួយនឹងការផ្តន្ទាទោសពីមុន ។ ហើយវាក៏ជាលក្ខខណ្ឌ ដែលចាំបាច់សម្រាប់ផ្តល់ឱ្យតុលាការអាចធ្វើការសម្រេចអំពីការព្យួរទោសធម្មតាដែរ ។ ចំពោះលក្ខខណ្ឌដែលមាននៅក្នុងការចោទប្រកាន់អំពីបទលហុនេះ គឺវាមាន២ (ពីរ) ចំណុចដែរ ប៉ុន្តែក៏នៅមានចំណុចដែលសំខាន់ផ្សេងទៀត ហើយក៏ដូចគ្នាទៅនឹងការចោទប្រកាន់ចំពោះបទឧក្រិដ្ឋ ឬក៏បទមជ្ឈិម ហើយចំពោះការខុសគ្នារបស់វាវិញ គឺខុសគ្នាត្រង់តែចិរវេលានៃការផ្តន្ទាទោសដាក់ពន្ធនាគារតែប៉ុណ្ណោះ ។ ហើយលក្ខខណ្ឌ២ (ពីរ) ចំណុចដែលមាននៅក្នុងការចោទប្រកាន់ចំពោះបទលហុនេះមានដូចជា ៖

- លក្ខខណ្ឌទាក់ទងជាមួយនឹងការផ្តន្ទាទោសពីមុន
- លក្ខខណ្ឌទាក់ទងជាមួយនឹងទោសដែលអាចនាំឱ្យមានការព្យួរ

### ២.១ : លក្ខខណ្ឌនៃការព្យួរទោសធម្មតាចំពោះបទលហុ

ចំពោះលក្ខខណ្ឌនៃការព្យួរទោសធម្មតាចំពោះបទលហុអាចប្រព្រឹត្តទៅបាន ចៅក្រមត្រូវពិនិត្យលើលក្ខខណ្ឌចំនួន ២ (ពីរ) គឺ (ក) លក្ខខណ្ឌទាក់ទងជាមួយនឹងការផ្តន្ទាទោសពីមុន និង(ខ) លក្ខខណ្ឌទាក់ទងជាមួយនឹងទោស ដែលអាចនាំអោយមានការព្យួរទោស។

#### ២.១.១. លក្ខខណ្ឌទាក់ទងជាមួយនឹងការផ្តន្ទាទោសពីមុន[48]

ចំពោះលក្ខខណ្ឌដែលទាក់ទងជាមួយនឹងការផ្តន្ទាទោសពីមុន គឺជាការទាក់ទងមួយ បើក្នុងករណីណាមួយជននោះមិនធ្លាប់ត្រូវបានទទួលការប្រកាសពីចៅក្រម អំពីការផ្តន្ទាទោសណាមួយពីបទល្មើស ដែលមានរយៈពេល ១ (មួយ) ឆ្នាំ នោះទេ ។ ហើយប្រសិនបើមានការផ្តន្ទាទោសពីមុន ដែលមាននៅក្នុងរយៈពេល ១ (មួយ) ឆ្នាំ គឺមិនអាចយកមកធ្វើការព្យួរទោសចំពោះបទលហុនេះក្នុងការយកមកប្រើប្រាស់បាននោះឡើយ ដោយហេតុថា នៅក្នុងក្រមព្រហ្មទណ្ឌ មាត្រា ១១២ (លក្ខខណ្ឌទាក់ទងជាមួយនឹងការផ្តន្ទាទោសពីមុន) ឆ្នាំ ២០០៩ បានចែងថា ក្នុងករណីចោទប្រកាន់ពីបទលហុ ការព្យួរទោសធម្មតាអាចត្រូវបានប្រកាសប្រសិនបើជនជាប់ចោទមិនទាន់ត្រូវបានផ្តន្ទាទោសដាក់ពន្ធនាគារជាស្ថាពរនៅឡើយ នៅក្នុងរយៈពេល ១ (មួយ) ឆ្នាំ មុនបទ

[48]យោងតាមមាត្រា ១១២ (លក្ខខណ្ឌទាក់ទងទៅនឹងការផ្តន្ទាទោសពីមុន) នៃក្រមព្រហ្មទណ្ឌ ឆ្នាំ២០០៩

ល្មើសនេះ ។ ហេតុនេះបានសេចក្ដីថា មុនពេលដែលជននោះបានប្រព្រឹត្តបទល្មើសនេះ គឺជននោះមិនធ្លាប់ត្រូវបានតុលាការធ្វើការសម្រេចនូវការផ្ដន្ទាទោសណាមួយពីមុន ដែលបានចូលជាស្ថាពរនោះទេ ដោយនៅក្នុងរយៈពេល ១ (មួយ) ឆ្នាំ នេះ ។ ក៏ប៉ុន្តែ បើលើកមុននោះជននេះមានការផ្ដន្ទាទោសនៅក្នុងសាលក្រម ឬ សាលដីកា ដែលបានចូលជាស្ថាពរពីចៅក្រមវិញនោះ ដោយពុំទាន់ផុតនូវកំឡុងពេល ១ (មួយ) ឆ្នាំ ផង ស្រាប់តែមានការប្រព្រឹត្តនូវបទល្មើសថ្មីមួយទៀត នោះតុលាការមិនអាចយកករណីដែលជននោះបានប្រព្រឹត្តថ្មីទៀតនោះ មកធ្វើការព្យួរទោសបានឡើយ ។ ប៉ុន្តែ ចំពោះករណីដែលមានការប្រកាសការផ្ដន្ទាទោសពីចៅក្រមនៅក្នុងសាលក្រម ឬ សាលដីកា នោះចូលជាស្ថាពរ ហើយមានការប្រកាសនូវការព្យួរទោសពីចៅក្រមផងដែរ តែរយៈពេល ១ (មួយ) ឆ្នាំ នោះក៏ត្រូវបានកន្លងហួស ក្រោយមកទើបមានការប្រព្រឹត្តបទល្មើសចោទប្រកាន់ថ្មីមួយនេះ ដូចនេះបានសេចក្ដីថា ជននោះនៅតែអាចទទួលបាននូវអត្ថប្រយោជន៍បានដដែរ ។

### ២.១.២. លក្ខខណ្ឌទាក់ទងជាមួយនឹងទោសដែលអាចនាំឱ្យមានការព្យួរទោស

នៅក្នុងចំណុចនេះ បើយោងទៅតាមមាត្រា ១១៣ (ទោសអាចនាំឱ្យមានការព្យួរទោស) នៃក្រមព្រហ្មទណ្ឌ ឆ្នាំ២០០៩ បានចែងថា ក្នុងករណីចោទប្រកាន់ពីបទលហុ ការព្យួរទោសធម្មតាត្រូវអនុវត្តទៅលើទោសដូចតទៅនេះ ៖

- ទោសដាក់ពន្ធនាគារ
- ទោសពិន័យជាប្រាក់

ទាក់ទងទៅនឹងនិយមន័យខាងលើនេះ គឺចង់សំដៅទោសដាក់ពន្ធនាគារដែលមានរយៈពេលតិចជាង ឬស្មើនឹង ១ (មួយ) ឆ្នាំ បានន័យថា ត្រឹម ១ (មួយ) ឆ្នាំ ដែលតុលាការបានធ្វើការប្រកាសនៅក្នុងសាលក្រមឬក៏សាលដីកាដោយថាជននោះត្រូវមានទោសដាក់ពន្ធនាគារត្រឹម ១ (មួយ) ឆ្នាំ ចុះក្រោម ហើយចៅក្រមអាចធ្វើការជ្រើសរើសយកនូវការព្យួរទោសបាន ។ បើក្នុងករណីទោសពិន័យជាប្រាក់វិញ គឺនៅពេលដែលតុលាការបានធ្វើការប្រកាសនៅក្នុងសាលក្រម ឬ សាលដីកា ហើយប្រសិនបើជននោះមិនចង់ឱ្យមានការអនុវត្តទោសពិន័យជាប្រាក់នោះទេ ជននោះអាចសុំឱ្យតុលាការធ្វើការប្រកាសការព្យួរទោសបាន ។

### ២.២. ការសម្រេចសេចក្ដីអំពីការព្យួរទោសធម្មតា

ការសម្រេចសេចក្ដីអំពីការព្យួរទោសធម្មតានេះ អាចប្រព្រឹត្តទៅបាននោះ គឺចៅក្រមត្រូវពិចារណាលើបុគ្គលនោះដែលបានប្រព្រឹត្តនូវអំពីល្មើសដែលមានចែងក្នុងច្បាប់ ឬ បទដ្ឋានគតិយុត្តទាំងឡាយណាថាជាបទល្មើស។ ហើយការសម្រេចនោះ ត្រូវតែគោរពទៅតាមវិធានដែលមានចែង និងកំណត់ថាបុគ្គលនោះមានពិតជាបានប្រព្រឹត្តបទល្មើសមែន ។ ជាពិសេសដែលមានបញ្ជាក់អំពីការសម្រេចសេចក្ដីនៅក្នុងសាលក្រម ឬ សាលដីកា។

**ឧទាហរណ៍:**

ជនម្នាក់ត្រូវបានតុលាការប្រកាសផ្ដន្ទាទោសពីបទជេរប្រមាថជាសាធារណៈ ដែលមានចែងនៅក្នុងក្រម

ព្រហ្មទណ្ឌ មាត្រា ៣០៧ ត្រូវពិន័យជាប្រាក់ពី ១០០.០០០ (មួយសែន) រៀល ទៅ ១០.០០០.០០០ (ដប់លាន) រៀល ។ ប៉ុន្តែ តុលាការបានប្រកាសផ្តន្ទាទោសដោយពិន័យជាប្រាក់ចំនួន២.០០០.០០០ (ពីរលាន) រៀលនៅក្នុងសាលក្រម ហើយទោសនេះក៏ត្រូវកំណត់ឱ្យព្យួរទោសផងដែរ ។ នេះបានសេចក្តីថា ថ្វីត្បិតតែជនខាងលើត្រូវទទួលទោសពិន័យជាប្រាក់ក៏ពិតមែនក៏ប៉ុន្តែជននោះត្រូវបានតុលាការប្រកាសអំពីការព្យួរទោសពិន័យជាប្រាក់ដែលមាននៅក្នុងសាលក្រម ឬសាលដីការួចទៅហើយដោយមូលហេតុការពិន័យជាប្រាក់នេះត្រូវបានទទួលការព្យួរទោសពីតុលាការ។

### ២.៣. អានុភាពនៃការព្យួរទោសធម្មតា

អានុភាពនៃការព្យួរទោសធម្មតា គឺទាក់ទងទៅនឹងករណីដែលជននោះបានប្រព្រឹត្តនូវបទលហុ ហើយដែលត្រូវបានតុលាការធ្វើការប្រកាសនូវទោសដាក់ពន្ធនាគារ ឬ ពិន័យជាប្រាក់ ដែលបានកំណត់នៅក្នុងសាលក្រម ឬ សាលដីកា តាមលក្ខខណ្ឌនៃការចោទប្រកាន់ចំពោះបទលហុ ។

#### ២.៣.១. ការចាត់ទុកជាអសារបង់នូវការផ្តន្ទាទោស[49]

នៅក្នុងចំណុចនេះ ក្នុងករណីដែលរយៈពេល ១ (មួយ) ឆ្នាំ បន្ទាប់ពីមានការផ្តន្ទាទោសត្រូវបានចូលជាស្ថាពររួចហើយពីបទលហុនោះ ហើយដែលសាលក្រមនោះក៏ត្រូវបានចៅក្រមប្រកាសឱ្យមានការព្យួរទោសធម្មតាដែរ ។ ហេតុនេះ បើពុំមានការផ្តន្ទាទោសពីបទល្មើសថ្មីណាមួយដែលបានកើតឡើងពីបទឧក្រិដ្ឋ បទមជ្ឈិម ឬក៏បទលហុទេនោះ ការផ្តន្ទាទោសដែលមានការព្យួរទោសនោះត្រូវចាត់ទុកជាអសារបង់ ចំណែកឯទោសក៏មិនអាចយកទៅអនុវត្តបន្តទៀតបានដែរ ។ ដូចនេះ បើក្នុងករណីដែលហួសរយៈពេល ១ (មួយ) ឆ្នាំ ហើយផុតពីសាលក្រមដែលត្រូវបានកំណត់អំពីការព្យួរទោសស្តីអំពីបទលហុនោះ ដែលត្រូវបានកន្លងផុតទៅ គឺទោសនោះត្រូវបានចាត់ទុកជាអសារបង់បានសេចក្តីថា គឺគេលែងយកទោសនោះមកធ្វើការអនុវត្តបន្តទៀតបានឡើយ ។ ហើយនៅក្នុងក្រមព្រហ្មទណ្ឌមាត្រា ១១៦(ការចាត់ទុកជាអសារបង់នូវការផ្តន្ទាទោស) បានចែងថា ប្រសិនបើក្នុងរយៈពេល ១ (មួយ) ឆ្នាំ បន្ទាប់ពីការផ្តន្ទាទោសជាស្ថាពរពីបទលហុ ដែលមានការព្យួរទោសធម្មតា គ្មានការផ្តន្ទាទោសថ្មីណាមួយបានកើតឡើងពីបទឧក្រិដ្ឋ បទមជ្ឈិម ឬ បទលហុ ការផ្តន្ទាទោសដែលព្យួរនោះ ត្រូវទុកជាអសារបង់ ។ ទោសក៏មិនអាចយកមកអនុវត្តបានទៀតឡើយ ។

#### ២.៣.២. ការដកហូតការព្យួរទោស

យោងទៅតាមមាត្រា ១១៤ នៃក្រមព្រហ្មទណ្ឌ ឆ្នាំ២០០៩ បានចែងថា ប្រសិនបើក្នុងរយៈពេល ១ (មួយ) ឆ្នាំ ក្រោយការផ្តន្ទាទោសជាស្ថាពរពីបទលហុ ដោយមានការព្យួរទោសធម្មតាផង រួចកើតមានការផ្តន្ទាទោសថ្មីជាស្ថាពរពីបទឧក្រិដ្ឋ បទមជ្ឈិម ឬ បទលហុ ការព្យួរទោសធម្មតានេះ ត្រូវដកហូតចេញដោយពេញ

---

[49]យោងតាមមាត្រា ១១៦ (ការចាត់ទុកជាអសារបង់នូវការផ្តន្ទាទោស) នៃក្រមព្រហ្មទណ្ឌ ឆ្នាំ២០០៩

ច្បាប់ ។ ទោសទី១ ត្រូវអនុវត្តដោយគ្មានស្រូបជាមួយទោសទី២នោះឡើយ ។បានសេចក្តីថា បើការព្យួរទោសនៅក្នុងបទលហុ ហើយជននោះបានប្រព្រឹត្តនូវបទល្មើសថ្មីផ្សេងទៀត ដែលទាក់ទងទៅនឹងបទឧក្រិដ្ឋក្តី បទមជ្ឈិមក្តី ឬ បទលហុដដែរក្តី នៅក្នុងរយៈពេល ១ (មួយ) ឆ្នាំ គឺគិតតាំងពីពេលដែលសាលក្រមលើកមុនបានចូលជាស្ថាពរ ដែលមានប្រកាសពីការព្យួរទោសបទលហុនេះ ។ ដោយហេតុថា ការដកហូតការព្យួរទោសនៃសាលក្រមមុន គឺត្រូវតែដកហូតដោយពេញច្បាប់ ឬក៏ដោយស្វ័យប្រវត្តិ ។ ត្រង់ចំណុចនេះចង់និយាយថា បើសាលក្រមទី១ ដែលបានកំណត់នូវទោសដាក់ពន្ធនាគារប៉ុន្មាន គឺត្រូវធ្វើការដកហូតដោយយកមកអនុវត្តនូវទោសដោយពេញលេញជាមួយនឹងសាលក្រមទី២ដែលបានកំណត់នូវរយៈពេលដាក់ពន្ធនាគារប៉ុន្មាននោះដែលត្រូវយកមកអនុវត្តដោយធ្វើការបូកបញ្ចូលគ្នា តែមិនត្រូវធ្វើការស្រូបបញ្ចូលគ្នាជាទោសតែមួយនោះទេ ។

ហើយនៅក្នុងមាត្រា ១៤០ (ការបូកបញ្ចូលគ្នានៃទោសពិន័យ) នៃក្រមព្រហ្មទណ្ឌ ឆ្នាំ២០០៩ បានចែងថា ជាបដិប្បញ្ញត្តិទៅលើបទប្បញ្ញត្តិមុន ការពិន័យដែលបានប្រកាសឡើង ចំពោះបទលហុច្រើននោះ ត្រូវបូកបញ្ចូលគ្នា ហើយត្រូវបូកផងដែរជាមួយទោសពិន័យ ដែលប្រកាសឡើងចំពោះបទឧក្រិដ្ឋ ឬ បទមជ្ឈិម ។ ដូចនេះ បើកាលណាមានការដកហូតការព្យួរទោសបែបនេះ គឺត្រូវយកសាលក្រមទី១ និងសាលក្រមទី២ ទៅអនុវត្តជាមួយគ្នាដោរយត្រូវធ្វើការបូកបញ្ចូលទោសចូលគ្នាតែម្តង ផ្ទុយទៅវិញគឺអត់ធ្វើការស្រូបបញ្ចូលទោសចូលគ្នានោះទេ ។ ប៉ុន្តែនៅក្នុងការចោទប្រកាន់ចំពោះបទលហុនេះ តុលាការក៏អាចធ្វើការមិនដកហូតការព្យួរទោស[50]បានដែរ ហើយលក្ខណៈរបស់វាគឺដូចគ្នាទៅនឹងការចោទប្រកាន់ពីបទឧក្រិដ្ឋ និង បទមជ្ឈិមដែរ ។ ទាក់ទងទៅនឹងការមិនដកហូតការព្យួរទោសនេះ គឺថាប្រសិនបើចៅក្រមយល់ឃើញថា បើទោះបីជាទណ្ឌិតនោះបានប្រព្រឹត្តបទល្មើសនៅក្នុងចិរវេលា ១ (មួយ) ឆ្នាំ ក៏ដោយ បន្ទាប់ពីមានសាលក្រមស្ថាពរដែលមានការព្យួរទោសលើកទី១ក៏ដោយ បើតុលាការយល់ឃើញថាមិនត្រូវធ្វើការដកហូតការព្យួរទោសធម្មតានោះទេ គឺចៅក្រមត្រូវតែធ្វើការចែងឱ្យបានច្បាស់លាស់នៅក្នុងសាលក្រម និងត្រូវមានចែងបញ្ជាក់អំពីសំអាងហេតុជាពិសេសផងដែរ ដោយហេតុនៅក្នុងក្រមព្រហ្មទណ្ឌ មាត្រា ១១៥ (ការមិនដកហូតការព្យួរទោស) ក៏បានចែងបញ្ជាក់ដែរថា ជាបដិប្បញ្ញត្តិនៃមាត្រា ១១៤ (ការដកហូតការព្យួរទោស) នៃក្រមនេះ តុលាការអាចសម្រេចថា ការផ្តន្ទាទោសថ្មីមិនអាចនាំឱ្យមានការដកហូតការព្យួរទោសធម្មតានេះដែលសម្រេចពីមុននោះទេ ។ សេចក្តីសម្រេចនេះត្រូវតែមានសំអាងហេតុជាពិសេស ។

**<u>ឧទាហរណ៍</u>:**

បុរសម្នាក់តែងតែស្រវឹងជារៀងរាល់ថ្ងៃ ហើយថ្ងៃមួយបុរសម្នាក់នោះក៏បានប្រព្រឹត្តបទល្មើសមួយ ដែលបទល្មើសនោះក៏មានចែងនៅក្នុងក្រមព្រហ្មទណ្ឌ ត្រង់មាត្រា ២៩៧ (បទស្រវឹងជាក់ស្តែង) ។ ហើយនៅពេលនោះចៅក្រមក៏បានធ្វើការផ្តន្ទាទោសពិន័យជាប្រាក់ទៅលើបុរសម្នាក់នោះប៉ុន្តែទោសនោះត្រូវបានព្យួរ។ ស្រាប់តែ

[50]យោងតាមមាត្រា១១៥ (ការមិនដកហូតព្យួរទោស) នៃក្រមព្រហ្មទណ្ឌ ឆ្នាំ២០០៩

ក្រោយមក បុរសម្នាក់នោះគាត់ខិតខំប្រឹងប្រែងដើម្បីកែខ្លួនគាត់ដែរ ប៉ុន្តែនៅតែកែមិនបាន ដោយសារតែបុរសនោះបានផុសមេស្រាបាត់ទៅហើយ ទើបបុរសនោះគាត់ទៅប្រព្រឹត្តបទស្រវឹងជាក់ស្តែងម្តងទៀត ហើយក៏បានដើរស្រែកឡូឡាពេញផ្លូវថ្នល់សាធារណៈតែម្នាក់ឯង ដោយក្នុងស្ថានភាពស្រវឹងជោគជាំ ។ ហេតុនេះហើយ បើក្នុងករណីបែបនេះមែនចៅក្រមអាចសម្រេចមិនដកហូតការព្យួរទោសរបស់បុរសម្នាក់នោះបាន ។ បានសេចក្តីថា បើក្នុងសាលក្រមទី២ តុលាការបានកំណត់ឱ្យមានការដកហូតនូវសាលក្រមទី១ នោះបានន័យថា ការអនុវត្តដែលមាននៅក្នុងសាលក្រមទី១ ត្រូវបានដកហូតដោយមិនឱ្យមានការអនុវត្តតទៅនោះទេ ។ ប៉ុន្តែ បើក្នុងករណីសាលក្រមទី២ តុលាការមិនបានកំណត់ឱ្យមានការដកហូតនូវសាលក្រមទី១ទេនោះ ការអនុវត្តដែលមាននៅក្នុងសាលក្រម ទៅលើជនជាប់ចោទនោះនៅតែមានអានុភាពទៅលើជននោះដដែរ។

# ជំពូកទី៣

# ការព្យួរទោសសាកល្បង

# ជំពូកទី៣

# ការព្យួរទោសសាកល្បង

ការព្យួរទោសសាកល្បង គឺជាការព្យួរទោសដែលអាចផ្តល់ឱ្យទណ្ឌិតដែលត្រូវទទួលរងទោសដាក់ពន្ធនាគារមានរយៈពេលពី ៦(ប្រាំមួយ) ខែទៅ ៥ (ប្រាំ) ឆ្នាំដោយដាក់ឱ្យទណ្ឌិតស្ថិតនៅក្រោមវិធានការត្រួតពិនិត្យ និងគោរពកាតព្វកិច្ចដោយឡែកមួយ ឬ ច្រើន នៅក្នុងរយៈពេលសាកល្បង ដោយមិនអាចតិចជាង១ (មួយ) ឆ្នាំ និងមិនឱ្យលើសពី ៣ (បី)ឆ្នាំ នោះទេ ។ ហើយបើយោងទៅតាមមាត្រា ១១៧ នៃក្រមព្រហ្មទណ្ឌ បានចែងថា តុលាការអាចសម្រេចព្យួរសាកល្បងនូវទោសដែលបានសម្រេចដាក់ពន្ធនាគារដែលមានរយៈពេលពី៦ (ប្រាំមួយ) ខែ ទៅ ៥ (ប្រាំ) ឆ្នាំ ។ ការព្យួរទោសសាកល្បងមានអានុភាពដាក់ឱ្យទណ្ឌិតស្ថិតនៅក្រោមវិធានការត្រួតពិនិត្យ និងគោរពកាតព្វកិច្ចដោយឡែកមួយ ឬ ច្រើនក្នុងរយៈពេលសាកល្បង ។ ហើយនឹងយោងទៅតាមមាត្រា ១១៨ នៃក្រមព្រហ្មទណ្ឌ បានចែងថា តុលាការកំណត់រយៈពេលនៃការសាកល្បង ។ រយៈពេលនេះមិនអាចតិចជាង ១ (មួយ) ឆ្នាំ និងមិនលើសពី ៣ (បី) ឆ្នាំ ទេ ។ បានន័យថា ការព្យួរទោសសាកល្បងនេះ គឺតុលាការត្រូវដាក់ទណ្ឌិតឱ្យស្ថិតនៅក្រោមវិធានការត្រួតពិនិត្យ និងត្រូវដាក់ឱ្យទណ្ឌិតបំពេញនូវកាតព្វកិច្ចដោយឡែកមួយ ឬ ច្រើនដែលមាននៅក្នុងចិរវេលាដែលតុលាការបានកំណត់ឱ្យធ្វើការសាកល្បងទៅតាមច្បាប់ ។

## ផ្នែកទី១: លក្ខខណ្ឌនៃការព្យួរទោសសាកល្បង

ការព្យួរទោសសាកល្បងនេះ ដើម្បីអាចធ្វើការព្យួរទោសសាកល្បងបាន លុះត្រាតែទណ្ឌិតនោះត្រូវបានតុលាការប្រកាសទោសឱ្យនៅចន្លោះពី ៦ (ប្រាំមួយ) ខែ ទៅ ៥ (ប្រាំ) ឆ្នាំ បានសេចក្តីថា ទោសដែលទណ្ឌិតនោះត្រូវទទួលរងគឺដូចជា តុលាការបានធ្វើការយល់ឃើញថា ដាក់គុកទណ្ឌិតនេះរយៈពេល ១ (មួយ) ឆ្នាំ ឬក៏ ៤ (បួន) ឆ្នាំ បែបនេះគឺនៅចន្លោះពី ៦ (ប្រាំមួយ) ខែ ទៅ ៥ (ប្រាំ) ឆ្នាំ ។ ហេតុដូច្នេះ តុលាការអាចធ្វើការជ្រើសរើសយកនូវការព្យួរទោសសាកល្បងបាន ពីព្រោះនៅក្នុងមាត្រា ១១៧ កថាខណ្ឌទី១ នៃក្រមព្រហ្មទណ្ឌ បានចែងថា តុលាការអាចសម្រេចព្យួរទោសសាកល្បងនូវទោសដែលបានសម្រេចដាក់ពន្ធនាគារដែលមានរយៈពេលពី ៦ (ប្រាំមួយ) ខែ ទៅ ៥ (ប្រាំ) ឆ្នាំ ។ ដូចនេះ លក្ខខណ្ឌនៃការព្យួរទោសសាកល្បង គឺជាលក្ខខណ្ឌដើម្បីឱ្យការព្យួរទោសសាកល្បងមានអានុភាព ។

### ១.១. អវត្តមានលក្ខខណ្ឌជាមួយនឹងការផ្តន្ទាទោសពីមុន

ចំពោះចំណុចខាងលើនេះ ការព្យួរទោសសាកល្បង គឺនៅក្នុងក្រមព្រហ្មទណ្ឌពុំបានចែងអំពីការផ្តន្ទាទោសពីមុននោះទេ ។ ហេតុនេះ ក្នុងករណីដែលជនណាម្នាក់បានប្រព្រឹត្តបទល្មើសពីមុនមក ហើយមានសាលក្រម ឬ សាលដីកាណាដែលបានចូលជាស្ថាពរហើយនោះ ជននោះក៏អាចទទួលបានការសម្រេចការព្យួរទោស

សាកល្បងពីចៅក្រមបានដដែរ ដោយពុំចាំបាច់ធ្វើការពិនិត្យទៅលើបញ្ជីថ្កោលទោសថាតើជននោះធ្លាប់មានដែលប្រព្រឹត្តនូវបទល្មើសណាមួយ ឬក៏អត់នោះទេ ។

ដូចនេះទាក់ទងទៅនឹងការព្យួរទោសសាកល្បង គឺវាមានលក្ខណៈមិនដូចគ្នាទៅនឹងការព្យួរទោសធម្មតា ត្រង់ថា ការព្យួរទោសធម្មតា គឺត្រូវធ្វើការពិនិត្យទៅលើការផ្តន្ទាទោសពីមុនជាមុនសិន ពីព្រោះថា នៅក្នុងក្រមព្រហ្មទណ្ឌ បានកំណត់អំពីការផ្តន្ទាទោសពីមុននៅក្នុងការព្យួរទោសធម្មតា ដោយហេតុថា បើក្នុងករណីជនណាម្នាក់បានប្រព្រឹត្តនូវបទល្មើសណាមួយ ដែលមានការសម្រេចផ្តន្ទាទោសពីចៅក្រមដោយមានការប្រកាសនៅក្នុងសាលក្រម ឬ ក៏សាលដីកាជាស្ថាពរហើយនោះ ដោយទទួលបានការព្យួរទោសពីចៅក្រមផងដែរ នៅក្នុងរយៈពេល ៥ (ប្រាំ) ឆ្នាំ ។ ប៉ុន្តែ បើនៅក្នុងរយៈពេល ៥ (ប្រាំ) ឆ្នាំ មិនទាន់បានកន្លងផុតទេនោះ ហើយជននោះក៏បានប្រព្រឹត្តនូវបទល្មើសថ្មីមួយទៀត ជននោះនឹងមិនអាចត្រូវបានតុលាការធ្វើការប្រកាសការព្យួរទោសធម្មតាម្តងទៀតនោះទេ ហើយក៏ត្រូវបានតុលាការធ្វើការដកហូតការព្យួរទោសផងដែរ ។ ក៏ប៉ុន្តែបើក្នុងរយៈពេល ៥ (ប្រាំ) ឆ្នាំ បានកន្លងផុតទៅវិញនោះ ហើយជននោះបានប្រព្រឹត្តនូវបទល្មើសថ្មីមួយទៀត ជននោះក៏នៅតែអាចទទួលបាននូវការព្យួរទោសធម្មតាពីចៅក្រមដដែរ ។ ហើយបើចំពោះការព្យួរទោសសាកល្បងវិញនោះ គឺថាពុំចាំបាច់ធ្វើការត្រួតពិនិត្យទៅលើចំណុចដែលទាក់ទងនឹងការផ្តន្ទាទោសពីមុននោះទេ ពីព្រោះថា ច្បាប់ពុំបានចែងនូវចំណុចនេះនោះទេ ហេតុនេះហើយ ទោះបីជាជនណាម្នាក់ធ្លាប់បានប្រព្រឹត្តនូវបទល្មើសពីមុនមកក៏ដោយ ដោយមានសាលក្រម ឬ សាលដីកាចូលជាស្ថាពរហើយក៏ដោយ ក៏ជននោះនៅតែអាចទទួលបាននូវការព្យួរទោសសាកល្បងពីចៅក្រមបានដដែរ ឱ្យតែការសម្រេចផ្តន្ទាទោសនេះស្ថិតនៅក្នុងរយៈពេលពី ៦ (ប្រាំមួយ) ខែ ទៅ ៥ (ប្រាំ) ឆ្នាំ ហើយដោយការកំណត់រយៈពេលសាកល្បងនេះគឺមិនតិចជាង ១ (មួយ) ឆ្នាំ និងមិនលើសពី ៣ (បី) ឆ្នាំ នោះទេ ។ ដូចនេះបានសេចក្តីថា ប្រវត្តិនៃការផ្តន្ទាទោសពីមុនរបស់ជនជាប់ចោទ គឺមិនមែនជាឧបសគ្គដើម្បីអនុញ្ញាតឱ្យមានការព្យួរទោសសាកល្បងនោះទេ ។ បានន័យថា នៅក្នុងចំណុចនេះ គឺវាផ្ទុយពីការព្យួរទោសធម្មតា ដែលត្រូវធ្វើការពិចារណាអំពីប្រវត្តិនៃការផ្តន្ទាទោសពីមុន ។ ក្នុងករណីនេះ បើជនជាប់ចោទធ្លាប់ត្រូវបានផ្តន្ទាទោសស្ថាពររួចហើយក៏ដោយក៏ការព្យួរទោសសាកល្បងអាចត្រូវបានអនុញ្ញាតឱ្យធ្វើការប្រកាសបានដែរ ។

## ១.២. លក្ខខណ្ឌទាក់ទងនឹងទណ្ឌកម្មដែលអាចធ្វើការព្យួរទោសសាកល្បង

នៅក្នុងចំណុចនេះ តុលាការអាចធ្វើការសម្រេចព្យួរទោសសាកល្បងនូវទោស ដែលបានសម្រេចដាក់ពន្ធនាគារ ដែលមានរយៈពេលពី ៦ (ប្រាំមួយ) ខែ ទៅ ៥ (ប្រាំ) ឆ្នាំ ។ ហើយទោសដែលអាចព្យួរសាកល្បងបាន គឺអាចជាបទឧក្រិដ្ឋ ឬ បទមជ្ឈិម នៃបទល្មើសព្រហ្មទណ្ឌទូទៅ ។ ទាក់ទងទៅនឹងបទល្មើសដែលចំពោះ

បទឧក្រិដ្ឋនៃបទល្មើសគ្រឿងញៀនវិញ គឺមិនអាចធ្វើការព្យួរទោសសាកល្បងបាននោះឡើយ ពីព្រោះមាត្រា ៣៣ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន មិនអនុញ្ញាតឱ្យមានការផ្តល់ស្ថានសម្រាលសម្រាប់បទឧក្រិដ្ឋដែលជាបទល្មើសគ្រឿងញៀននោះទេ ។ ប៉ុន្តែមានករណីលើកលែងចំពោះមាត្រា ៣២ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន ។ ហេតុនេះ នៅត្រង់ចំណុចនេះគឺវាមានលក្ខណៈខុសគ្នាទៅនឹងការព្យួរទោសធម្មតាត្រង់ថា ការព្យួរទោសធម្មតាអាចធ្វើការព្យួរទោសទៅលើទោសដាក់ពន្ធនាគារផង និងទោសពិន័យជាប្រាក់ផង[51] ។ ប៉ុន្តែចំពោះការព្យួរទោសសាកល្បងវិញ គឺថាការព្យួរទោសនេះ គឺធ្វើតែទៅលើការដាក់ទោសផ្នែកពន្ធនាគារតែប៉ុណ្ណោះ ដោយពុំមានទាក់ទងទៅនឹងការព្យួរទោសទៅលើប្រាក់ពិន័យនោះទេ ។ ដូចនេះ បានសេចក្តីថា ការព្យួរទោសសាកល្បង គឺតុលាការធ្វើការព្យួរទោសតែទៅលើទោសដាក់ពន្ធនាគារតែប៉ុណ្ណោះ ដោយពុំធ្វើការព្យួរទោសទៅលើទោសពិន័យជាប្រាក់នោះឡើយ ។

## ផ្នែកទី២: ការសម្រេចសេចក្តីអំពីការព្យួរទោសសាកល្បង

ចំពោះការសម្រេចសេចក្តីអំពីការព្យួរទោសសាកល្បងនេះ គឺចៅក្រមត្រូវពិនិត្យមើល ថាតើបុគ្គលនោះពិតជាមានសារៈប្រយោជន៍ទៅដល់សង្គម ឬ អាចឱ្យបុគ្គលនោះអាចធ្វើការកែប្រែខ្លួនឡើងវិញ ដោយធ្វើជាបុគ្គលដ៏ល្អនៅក្នុងការអភិវឌ្ឍន៍សង្គមជាតិ។ ជាពិសេសគឺ មិនត្រូវបានចំណាយប្រាក់កាក់(រដ្ឋ)មួយចំនួនទៅលើបុគ្គលនោះ ដោយដាក់ឱ្យនៅជាប់ក្នុងពន្ធនាគារ ។

សូមក្រឡេកមើលការបកស្រាយដែលទាក់ទងទៅនឹងសាលក្រម និងសាលដីកា ដែលទាក់ទងទៅនឹងការព្យួរទោសសាកល្បង ៖

-**<u>ការពិភាក្សាលើសាលក្រមទី១</u>**៖

យោងតាមសាលក្រម ដែលចេញដោយសាលាដំបូងរាជធានីភ្នំពេញ ចុះថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០២០ ដែលអាចធ្វើឱ្យយើងបានយល់ដឹងអំពីករណីដែលមាននៅក្នុងសាលក្រមនៃសាលាដំបូងរាជធានីភ្នំពេញនេះ ។ ដោយនៅក្នុងអង្គហេតុបានរៀបរាប់នូវអ្វីដែលមាននៅក្នុងសាលក្រមនេះ នៅថ្ងៃទី១៤ ខែមករា ឆ្នាំ២០២០ វេលាម៉ោង០៩ និង១៥នាទី នៅចំណុចផ្លូវ ១១០ កែងនិងផ្លូវ១៣២ ខណ្ឌទួលគោក រាជធានីភ្នំពេញ កងកម្លាំងសមត្ថកិច្ចបានចុះល្បាតតាមមូលដ្ឋាន ដោយប្រទះឃើញជនជាប់ចោទចំនួន ០៣នាក់ គឺ១. ឈ្មោះ ក ២. ឈ្មោះក និង៣.ឈ្មោះ គ ដោយមានការសង្ស័យ បានហៅត្រួតពិនិត្យ និងឆែកឆេរឃើញ ក្រមពណ៌សថ្លា

[51]យោងតាមមាត្រា ១០៧ (ទោសអាចនាំឱ្យមានការព្យួរទោស) នៃក្រមព្រហ្មទណ្ឌ ឆ្នាំ២០១១ បានចែងថា ការព្យួរទោសធម្មតា ត្រូវអនុវត្តទៅលើទោសដូចតទៅ ៖ (១) ទោសដាក់ពន្ធនាគារ កាលបើទោសដែលប្រកាសនោះតិចជាង ឬស្មើនឹង ៥ (ប្រាំ) ឆ្នាំ ។ (២) ទោសពិន័យជាប្រាក់ ។

សង្ស័យជាគ្រឿងញៀនចំនួន០២កញ្ចប់ ។ ក្រោយឃាត់ខ្លួនជនជាប់ចោទ និងដកហូតបានវត្ថុតាង រួចកសាងសំណុំរឿងបញ្ជូនមកអយ្យការអមសាលាដំបូងរាជធានីភ្នំពេញតែម្តង់។ ក្រោយពីធ្វើការសាកសួរបានដឹងថាឈ្មោះ **គ** ពុំមានពាក់ព័ន្ធនឹងបទល្មើសអ្វីទេ ទើបតំណាងអយ្យការសម្រេចឱ្យត្រឡប់ទៅលំនៅដ្ឋានវិញ ។ហេតុនេះ សេចក្តីសម្រេចរបស់សាលាដំបូងរាជធានីភ្នំពេញ ដែលមាននៅក្នុងសាលក្រមចុះថ្ងៃទី៣០ ខែមិថុនា ឆ្នាំ ២០២០ ដោយបានធ្វើការប្រកាសអំពីការកំណត់ផ្តន្ទាទោសទៅលើឈ្មោះ **ក** ឈ្មោះ **ខ** ពីបទ **រក្សាទុកដោយខុសច្បាប់នូវសារធាតុញៀន** ដោយកំណត់ដាក់ពន្ធនាគារលើឈ្មោះ **ក** រយៈពេល ២ (ពីរ) ឆ្នាំ តែឱ្យអនុវត្តទោសក្នុងពន្ធនាគាររយៈពេល០៨ (ប្រាំបី )ខែ ទោសដែលនៅសល់ព្យួរសាកល្បង និងដាក់ពន្ធនាគារលើឈ្មោះ **ខ** រយៈពេល ១ (ពីរ) ឆ្នាំ តែឱ្យអនុវត្តទោសក្នុងពន្ធនាគាររយៈពេល០៦ (ប្រាំមួយ )ខែ ទោសដែលនៅសល់ព្យួរសាកល្បង តាមបញ្ញត្តិមាត្រា ១១៧ និងមាត្រា ១២២ នៃក្រមព្រហ្មទណ្ឌ ឆ្នាំ២០០៩ ។ដោយវត្ថុចាប់យកមានដូចជា៖ ស្រោមសំបុត្រពណ៌ស ដែលមានសរសេរថា ៖ កញ្ចប់រក្សាវត្ថុតាង ក្រាមសថ្លា ចំនួន០២កញ្ចប់ មានតម្រុយសង្ស័យជាសារធាតុញៀនមានទម្ងន់ ០,៤៦g ដោយមានស្នាមមេដៃរបស់ជនជាប់ចោទឈ្មោះ ក និងឈ្មោះ ខ ចូលរួមចុះហត្ថលេខាដោយមន្ត្រីនគរបាលយុត្តិធម៌ គប្បីសម្រេចរឹបអូសតាមមាត្រា ៩៣ និងមាត្រា ៩៤ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន។ មូលហេតុ ដែលសាលាដំបូងរាជធានីភ្នំពេញ សម្រេចផ្តន្ទាទោសបែបនេះ ពីព្រោះថាដោយសារតែការពិនិត្យទៅលើអង្គហេតុខាងលើឃើញថា ឈ្មោះ **ក** និងឈ្មោះ **ខ** ពិតជាមានករណី **រក្សាទុកដោយខុសច្បាប់នូវសារធាតុញៀន** ពិតប្រាកដមែន ។ ហើយឈ្មោះ **ក** និងឈ្មោះ **ខ** ក៏បានសារភាពនាពេលសវនាការថាខ្លួនពិតជាបានប្រព្រឹត្តអំពើ **រក្សាទុកដោយខុសច្បាប់នូវសារធាតុញៀន** នេះដែរ ។ ដោយចម្លើយសារភាពនេះមានលក្ខណៈស៊ីចង្វាក់ទៅនឹងរបាយការណ៍សំយោគ និងលទ្ធផលកោសលវិច័យព្រមទាំងវត្ថុតាងនានា ហេតុនេះ សំណុំរឿងនេះអាចឱ្យតុលាការកំណត់បានថាឈ្មោះ **ក** និងឈ្មោះ **ខ** ជាជនជាប់ចោទពិតប្រាកដមែន ពីព្រោះថាមានពិរុទ្ធភាពគ្រប់គ្រាន់ក្នុងការផ្តន្ទាទោស ហើយការប្រព្រឹត្តរបស់ជនជាប់ចោទ គឺមានចេតនាទុច្ចរិត និងបានធ្វើឱ្យប៉ះពាល់ដល់របៀបរៀបរយសាធារណៈ និងសន្តិសុខសង្គម ព្រមទាំងស្មារតីរបស់អ្នកដទៃ ។

បានសេចក្តីថា បទល្មើស **រក្សាទុកដោយខុសច្បាប់នូវសារធាតុញៀន** គឺថាចៅក្រមនៃសាលាដំបូងរាជធានីភ្នំពេញបានធ្វើការប្រកាសសាលក្រមនេះដោយអនុវត្តទៅតាមច្បាប់ដែលទាក់ទងទៅនឹងច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន ហើយនឹងមានការប្រកាសអំពីការព្យួរសាកល្បង នៅក្នុងសាលក្រមនេះផងដែរ ដែលមានចែងនៅក្នុងក្រមព្រហ្មទណ្ឌឆ្នាំ២០០៩ ។ចំពោះមូលហេតុដែលចៅក្រមសម្រេចព្យួរទោសសាកល្បង ដូចខាងលើនេះក៏ព្រោះតែជននោះបានសារភាពនូវទង្វើដែលខ្លួនបានប្រព្រឹត្ត មិនតែប៉ុណ្ណោះព្យសនៈកម្មនៃបទល្មើស

នេះមានលក្ខណៈតូច ហេតុនេះហើយ ទើបចៅក្រមសម្រេចឱ្យមានការព្យួរទោសសាកល្បងទៅលើជនទាំងពីរនោះ[52]។

-**ការពិភាក្សាលើសាលដីកាទី២៖**

យោងទៅតាមសាលដីកាដែលចេញដោយតុលាការកំពូល លេខ: ៦០IV ចុះថ្ងៃទី១១ ខែមីនា ឆ្នាំ ២០២០ គឺអាចឱ្យយើងបានយល់ដឹងអំពីអង្គហេតុដែលមាននៅក្នុងសាលដីកានេះ ។ ដោយនៅក្នុងអង្គហេតុដែលមាននៅក្នុងសាលដីកានេះ បើ គឺថាកាលពីខែមិថុនា ឆ្នាំ២០១៥ ស្ថិតនៅភូមិក្រាំងទ្រា ឃុំនិពាន្ធ ស្រុកគងពិសី ខេត្តកំពង់ស្ពឺ ឈ្មោះ **ស** មិនបំពេញកាតព្វកិច្ចចំពោះឧបករណ៍អាចជួញដូរបានដល់ឥណប្រតិទានដោយបំណង និងដោយមានចេតនាធ្វើឱ្យខូចខាតប្រយោជន៍អ្នកដទៃមួយបានកើតឡើង ដែលបង្កឡើងដោយឈ្មោះ **ស** ពិតប្រាកដមែន ។ សាលាដំបូងខេត្តកំពង់កំពង់ស្ពឺ ក៏បានចេញនូវសាលក្រមលេខៈ ១៦១ "ខ" ចុះថ្ងៃទី១០ ខែឧសភា ឆ្នាំ២០១៨ ដោយបានធ្វើការប្រកាសជាសាធារណៈអំពីការផ្តន្ទាទោសទៅលើឈ្មោះ **ស** ពីបទ **មិនបំពេញកាតព្វកិច្ចចំពោះឧបករណ៍ដែលអាចជួលដូរបាន** ដោយកំណត់ដាក់ពន្ធនាគារ ០១ (មួយ) ឆ្នាំ តែទោសត្រូវព្យួរសាកល្បងរយៈពេលសាកល្បង ០៣ (បី) ឆ្នាំ ដោយគិតចាប់ពីថ្ងៃប្រកាសសាលក្រមស្ថាពរ ការផ្តន្ទាទោសនេះដោយយោងតាមមាត្រា ២៣១ នៃច្បាប់ស្តីពីឧបករណ៍ដែលអាចជួញដូរបាន និងប្រតិបត្តិការទូទាត់សងប្រាក់ និងមាត្រា ១១៨ នៃក្រមព្រហ្មទណ្ឌ ឆ្នាំ២០០៩ និងបង្គាប់ឱ្យឈ្មោះ **ស** សងប្រាក់ចំនួន$ ៨,០០០ (ប្រាំបីពាន់ដុល្លា ) ទៅដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ **វ**។ ប៉ុន្តែ ឈ្មោះ **ស** និងដើមបណ្តឹងរដ្ឋប្បវេណី មិនសុខចិត្ត ក៏បានប្តឹងឧទ្ធរណ៍ទៅនឹងសាលក្រមព្រហ្មទណ្ឌ លេខៈ ១៦១ "ខ" ចុះថ្ងៃទី១០ ខែឧសភា ឆ្នាំ២០១៨ របស់សាលាដំបូងខេត្តកំពង់ស្ពឺ ត្រង់ចំណុចសេចក្តីសម្រេចទាំងមូល ។ ហេតុនេះ សាលាឧទ្ធរណ៍ក៏បានទទួលពាក្យបណ្តឹងឧទ្ធរណ៍នេះ ប៉ុន្តែត្រូវបានបដិសេធចោលដោយទាស់គតិច្បាប់ ហើយក៏បានប្រកាសជាសាធារណៈថា នឹងតម្កល់សាលក្រមព្រហ្មទណ្ឌ លេលេខៈ ១៦១ "ខ" ចុះថ្ងៃទី១០ ខែឧសភា ឆ្នាំ២០១៨ របស់សាលាដំបូងខេត្តកំពង់ស្ពឺ ទុកជាបានការដដែល ។ ប៉ុន្តែ ឈ្មោះ **ស** នៅតែមិនសុខចិត្តទៅនឹងសេចក្តីសម្រេចរបស់សាលាឧទ្ធរណ៍ដដែល ហេតុនេះ ឈ្មោះ **ស** ក៏បានប្តឹងសាទុក្ខទៅនឹងសាលដីកាព្រហ្មទណ្ឌ លេខៈ ៥៣ "ក្រ.សវ" ចុះថ្ងៃទី២៤ ខែឧសភា ឆ្នាំ២០១៩ របស់សាលាឧទ្ធរណ៍ ត្រង់ចំណុចនៃសេចក្តីសម្រេចទាំងមូល ។ តំណាងអយ្យាការអមតុលាការកំពូលសន្និដ្ឋានថា ជនជាប់ចោទ បានសារភាពថា ពិតជាបានចេញសែកដែលបានលើកឡើងថា មុនទៅដកប្រាក់មួយថ្ងៃឱ្យប្រាប់ផង ព្រោះមិនទាន់មានពប្រាក់ក្នុងសែកនោះទេ តែផ្ទុយទៅវិញខ្លួនមិនបានយកប្រាក់ទៅដាក់នៅពេលដើមបណ្តឹងរដ្ឋប្បវេណីទៅដក ក៏គ្មានប្រាក់ប្រាកដ ហេតុដូចន្នេះសែកនោះ គឺពិតជាបានចេញថ្លៃកក់ដីតែគ្មានប្រាក់ទេ ។ហេតុនេះ តុលាការកំពូលបានទទួលពាក្យបណ្តឹងសាទុក្ខនេះ

[52]ឧបសម្ព័ន្ធទី៧, សាលាដំបូងរាជធានីភ្នំពេញ, សាលក្រម ចុះថ្ងៃទី៣០ខែមិថុនាឆ្នាំ២០២០។

ប៉ុន្តែត្រូវបានបដិសេធនឹងបណ្តឹងសាទុក្ខនេះវិញ ដោយបានប្រកាសជាសាធារណៈ និងតម្កល់សាលដីកាព្រហ្មទណ្ឌ លេខៈ ៥៣ "ក្រ.សវ" ចុះថ្ងៃទី២៤ ខែឧសភា ឆ្នាំ២០១៩ របស់សាលាឧទ្ធរណ៍ ទុកជាបានការ ។ មូលហេតុ ដែលតុលាការកំពូលតម្កល់សាលដីកាសាលាឧទ្ធរណ៍ ពីព្រោះ ជនជាប់ចោទបានទទួលសារភាព ហើយអង្គហេតុនោះវាមានលក្ខណៈស៊ីសង្វាក់គ្នាទៅនឹងអង្គហេតុរបស់ដើមបណ្តឹងរដ្ឋប្បវេណី ហើយសបញ្ជាក់ឱ្យឃើញថា ជនជាប់ចោទនោះពិតជាមានពិរុទ្ធភាព និងមានចេតនាធ្វើឱ្យខូចខាតផលប្រយោជន៍របស់ដើមបណ្តឹងរដ្ឋប្បវេណីពិតប្រាកដមែន ។

បានសេចក្តីថា បទល្មើស **មិនបំពេញកាតព្វកិច្ចចំពោះឧបករណ៍ដែលអាចជួលដូរបាន** គឺថាទាំងសាលក្រម និងសាលដីកា របស់តុលាការគ្រប់ជាន់ថ្នាក់ គឺចៅក្រមសុទ្ធតែធ្វើការប្រកាសទៅតាមបទល្មើសដែលមានចែងក្នុងច្បាប់ស្តីពីឧបករណ៍ដែលអាចជួញដូរបាន និងប្រតិបត្តិការទូទាត់សងប្រាក់ និងអនុវត្តនូវការព្យួរទោសសាកល្បងទៅលើបទល្មើស ដែលមានចែងនៅក្នុងក្រមព្រហ្មទណ្ឌផងដែរ។ ចំពោះមូលហេតុដែលនាំឱ្យមានព្យួរទោសសាកល្បង ពីព្រោះដោយសារតែព្យសនៈកម្មនៃបទល្មើសនេះតូច ម្យ៉ាងវិញទៀតដើម្បីឱ្យជននោះបានដឹងពីទោសកំហុសដែលខ្លួនបានប្រព្រឹត្តនូវអំពើនោះផង បើក្នុងករណីដែលជននោះបានបំពាននូវកាតព្វកិច្ចណាមួយក្នុងកំឡុងពេលដែលមានការសាកល្បងនេះ ជននោះនឹងត្រូវតុលាការធ្វើការដកហូតនូវការព្យួរទោសសាកល្បងនោះមកវិញ ។ ហេតុនេះ ទើបតុលាការប្រកាសឱ្យមានការព្យួរទោសសាកល្បងទៅលើជនល្មើសនោះដោយឱ្យស្ថិតនៅក្នុងការតាមដានរបស់តុលាការ ។[53]

**-<u>ការពិភាក្សាលើសាលដីកាទី៣</u>៖**

បើយោងតាមសាលដីកាដែលចេញដោយតុលាការកំពូល លេខៈ ៣៥១ I ចុះថ្ងៃទី២៩ ខែកក្កដា ឆ្នាំ២០២២ គឺអាចឱ្យយើងបានយល់ដឹងអំពីអង្គហេតុដែលមាននៅក្នុងសាលដីកានេះ ។ ដោយនៅក្នុងអង្គហេតុដែលមាននៅក្នុងសាលដីកានេះគឺកាលពីថ្ងៃទី២០ ខែកក្កដា ឆ្នាំ២០២០ ឈ្មោះ **ផ** និងបក្សពួកបានចុះទៅភូមិត្រពាំងផ្លុង ឃុំត្រពាំងផ្លុង ស្រុកពញាក្រែក ខេត្តត្បូងឃ្មុំ ជួបជាមួយប្រជាពលរដ្ឋចំនួន ១០ គ្រួសារ និងធ្វើការពិនិត្យលើបង្គោលព្រំដែនប្រទេសកម្ពុជា-វៀតណាម នៅបង្គោលលេខ១១៤ ដល់បង្គោលលេខ១១៩ ដែលដាំចន្លោះដីទំហំ ៦០ ហិកតា ។ បន្ទាប់មកឈ្មោះ **ផ** បានចេញសេចក្តីថ្លែងការណ៍ចុះថ្ងៃទី២១ ខែកក្កដា ឆ្នាំ២០២០ ដែលមានខ្លឹមសារបំផុសបំផុល និងញុះញង់ឱ្យប្រជាពលរដ្ឋខ្មែរមានភាពច្របូកច្របល់ បង្កចលាចល និងភាពរឹករវដល់សន្តិសុខសង្គម និងសណ្តាប់ធ្នាប់សាធារណៈ ដែលបានធ្វើការបំផ្លើសខុសពីការពិត និងមានការគាំទ្រពីឈ្មោះ **ត** និងឈ្មោះ **ថ** ផងដែរ សកម្មភាពរបស់ជនជាប់ចោទទាំងនេះបានធ្វើការផ្សព្វផ្សាយតាមរ

[53] ឧបសម្ព័ន្ធទី៨, តុលាការកំពូល, សាលដីកាលេខៈ៦០IVចុះថ្ងៃទី១១ខែមីនាឆ្នាំ២០២០ ។

យៈគេហទំព័ររបស់ឈ្មោះ RR ។យោងតាមភស្តុតាងជាសកម្មភាព និងខ្លឹមសារដែលបានដកស្រង់ចេញគេហទំព័ររបស់ឈ្មោះ RR បានបញ្ជាក់ឱ្យច្បាស់ថា ឈ្មោះ ផ បានធ្វើសកម្មភាពដែលប្រើឈ្មោះជាតំណាងក្រុមប្រឹក្សាឃ្លាំងមើលកម្ពុជាដោយខុសច្បាប់ គឺធ្វើឡើងដោយបង្កឱ្យមានភាពអសន្តិសុខ ហើយត្រូវបានបដិសេធ និងទាត់ចោលទាំងស្រុងនូវការផ្សាយព័ត៌មានមិនពិត បំផ្លើសការពិត របស់ឈ្មោះឈ្មោះ **ផ** តាមសេចក្តីថ្លែងការពិសេសលេខ៤ អ.ជ.ព.ជ ចុះថ្ងៃទី៣១ ខែកក្កដា ឆ្នាំ២០២០ របស់នីតិបុគ្គល **គ** ។។ ដោយមានការចោទប្រកាន់ពីអយ្យការអមសាលាដំបូងរាជធានីភ្នំពេញ ហេតុនេះ សេចក្តីសម្រេចរបស់សាលាដំបូងរាជធានីភ្នំពេញ ដែលមាននៅក្នុងសាលក្រម លេខៈ ២៥៦៣«រ» ចុះថ្ងៃទី១៨ ខែកក្កដា ឆ្នាំ២០២១ ដោយបានធ្វើការប្រកាសជាសាធារណៈអំពីការផ្តន្ទាទោសទៅលើឈ្មោះ **ផ** ដោយកំណត់ដាក់ពន្ធនាគារ ២ (ពីរ) ឆ្នាំ និងពិន័យជាប្រាក់ចំនួន ២.០០០.០០០ (ពីរលានរៀល ) ធ្វើការផ្តន្ទាទោសទៅលើឈ្មោះ **ត** ដោយកំណត់ដាក់ពន្ធនាគារ ២០ (ម្ភៃ ) ខែ និងពិន័យជាប្រាក់ចំនួន២.០០០.០០០ (ពីរលានរៀល ) និងធ្វើការផ្តន្ទាទោសទៅលើឈ្មោះ **ថ** ដោយកំណត់ដាក់ពន្ធនាគារ ២០ (ម្ភៃ )ខែ និងពិន័យជាប្រាក់ចំនួន២.០០០.០០០ (ពីរលានរៀល )ដោយយោងតាមមាត្រា ៤៩៤ និងមាត្រា ៤៩៥ នៃក្រមព្រហ្មទណ្ឌពីបទ **ញុះញង់បង្កឱ្យមានភាពវឹកវរធ្ងន់ធ្ងរដល់សន្តិសុខសង្គម** និងបង្គាប់ឱ្យឈ្មោះ **ផ** ឈ្មោះ **ត** និងឈ្មោះ **ថ** រួមគ្នាសងប្រាក់សំណងការខូចខាត ចំនួន ៤០០,០០០,០០០ (បួនរយលាន) រៀលទៅឱ្យ នីតិបុគ្គល **គ** ដែលជាដើមបណ្តឹងរដ្ឋប្បវេណី ការទាមទារលើសពីនេះច្រានចោល ។ ប៉ុន្តែ ឈ្មោះ **ផ** ឈ្មោះ **ត** និងឈ្មោះ **ថ** មិនសុខចិត្ត ក៏បានប្តឹងឧទ្ធរណ៍ទៅនឹងសាលក្រមព្រហ្មទណ្ឌ លេខៈ ២៥៦៣«រ» ចុះថ្ងៃទី១៨ ខែកក្កដា ឆ្នាំ២០២១ របស់សាលាដំបូងរាជធានីភ្នំពេញត្រង់ចំណុចសេចក្តីសម្រេចទាំងមូល ។ ហេតុនេះ សាលាឧទ្ធរណ៍ក៏បានទទួលពាក្យបណ្តឹងឧទ្ធរណ៍នេះ ហើយក៏បានប្រកាសជាសាធារណៈលើសាលដីកាព្រហ្មទណ្ឌលេខ ១១០ V«រ» ចុះថ្ងៃទី១២ ខែវិច្ឆិកា ឆ្នាំ២០២១ របស់សាលាឧទ្ធរណ៍ភ្នំពេញ ថានឹងតម្កល់សាលក្រមព្រហ្មទណ្ឌ លេខៈ ២៥៦៣«រ» ចុះថ្ងៃទី១៨ ខែកក្កដា ឆ្នាំ២០២១ របស់សាលាដំបូងរាជធានីភ្នំពេញទុកជាបានការ លើកលែងតែ ចំណុចទី១-១ផ្តន្ទាទោសទៅលើឈ្មោះ **ផ** ដោយកំណត់ដាក់ពន្ធនាគារ ២ (ពីរ) ឆ្នាំ ត្រូវកែប្រែមកជាទោសនេះត្រូវអនុវត្តក្នុងពន្ធនាគារកំណត់រយៈពេល ០១ (មួយ)ឆ្នាំ ០៣(បី)ខែ និង១១(ដប់មួយ) ថ្ងៃ។ ទោសដែលនៅសល់ត្រូវព្យួរទោសសាកល្បងដោយកំណត់រយៈពេល០៣ (បី)ឆ្នាំ។ចំណុចទី១-២ផ្តន្ទាទោសទៅលើឈ្មោះ **ត** ដោយកំណត់ដាក់ពន្ធនាគារ ២០ (ម្ភៃ)ខែ ត្រូវកែប្រែមកជាទោសនេះត្រូវអនុវត្តក្នុងពន្ធនាគារកំណត់រយៈពេល ០១ (មួយ)ឆ្នាំ ០៣(បី)ខែ និង ០៥(ប្រាំ) ថ្ងៃ។ ទោសដែលនៅសល់ត្រូវព្យួរទោសសាកល្បងដោយកំណត់រយៈពេល០៣ (បី)ឆ្នាំ។ ចំណុចទី១-៣ផ្តន្ទាទោសទៅលើឈ្មោះ **ត** ដោយកំណត់ដាក់ពន្ធនាគារ ២០ (ម្ភៃ)ខែ ត្រូវកែប្រែមកជាទោសនេះត្រូវអនុវត្តក្នុងពន្ធនាគារកំណត់រយៈពេល ០២ (ពីរ )ខែ និង២៤(ម្ភៃបួន ) ថ្ងៃ។ ទោសដែលនៅសល់ត្រូវព្យួរទោសសាកល្បងដោយកំណត់រយៈពេល០៣ (បី)ឆ្នាំ ។ ប៉ុន្តែ ឈ្មោះ **ផ** ឈ្មោះ **ត** និងឈ្មោះ **ថ** និង**ឯកឧត្តមអគ្គព្រះ**

**រាជអាជ្ញាអមសាលាឧទ្ធរណ៍ភ្នំពេញ** នៅតែមិនសុខចិត្តទៅនឹងសេចក្តីសម្រេចរបស់សាលាឧទ្ធរណ៍ដដែល ហេតុនេះ ក៏បានប្តឹងសាទុក្ខទៅនឹងសាលដីកាព្រហ្មទណ្ឌលេខ ១១០ V«វ» ចុះថ្ងៃទី១២ ខែវិច្ឆិកា ឆ្នាំ២០២១ របស់សាលាឧទ្ធរណ៍ភ្នំពេញ លើសេចក្តីសម្រេចទាំងមូល ។ហេតុនេះ តុលាការកំពូលបានទទួលពាក្យបណ្តឹងសាទុក្ខនេះ ប៉ុន្តែត្រូវបានបដិសេធនឹងបណ្តឹងសាទុក្ខនេះវិញ ដោយបានប្រកាសជាសាធារណៈ នឹងតម្កល់សាលដីកាព្រហ្មទណ្ឌលេខ ១១០ V«វ» ចុះថ្ងៃទី១២ ខែវិច្ឆិកា ឆ្នាំ២០២១ របស់សាលាឧទ្ធរណ៍ភ្នំពេញ ទុកជាបានការ ។ មូលហេតុ ដែលតុលាការកំពូលតម្កល់សាលដីកាសាលាឧទ្ធរណ៍ ពីព្រោះតាមសំអាងហេតុ បណ្តឹងសារទុក្ខរបស់បុគ្គលប្តឹងសារទុក្ខ ធ្វើឡើងពុំមានហេតុផលនៃបណ្តឹងសារទុក្ខសមស្របតាមបញ្ញត្តិមាត្រា ៤១៩ នៃក្រមនីតិវិធីព្រហ្មទណ្ឌឡើយ។

បានសេចក្តីថា បទល្មើស **ញុះញង់បង្កឱ្យមានភាពវឹកវរធ្ងន់ធ្ងរដល់សន្តិសុខសង្គម** គឺថាទាំងសាលក្រម និងសាលដីកា របស់តុលាការគ្រប់ជាន់ថ្នាក់ គឺចៅក្រមសុទ្ធតែធ្វើការប្រកាសទៅតាមបទល្មើសដែលមានចែងនៅក្នុងក្រមព្រហ្មទណ្ឌ និងអនុវត្តនូវការព្យួរទោសសាកល្បងទៅលើបទល្មើស ដែលមានចែងនៅក្នុងក្រមព្រហ្មទណ្ឌផងដែរ ។ ចំពោះទោសដែលត្រូវព្យួរសាកល្បង គឺមានរយៈពេលមិនឱ្យតិចជាង ១ (មួយ)ឆ្នាំ និងមិនឱ្យលើស៣ (បី) ឆ្នាំ នោះទេ។ ម៉្យាងវិញទៀត បើពុំមានចែងឆ្នាំនៃការសាកល្បងនោះទេ គឺវាមានលក្ខណៈខុសទៅនឹងក្រមព្រហ្មទណ្ឌដែលក្រមព្រហ្មទណ្ឌបានចែងនៅក្នុងមាត្រា១១៨ដែលបានកំណត់អំពីរយៈពេលនៃការសាកល្បង [54]។

## ផ្នែកទី៣: អានុភាពនៃការព្យួរទោសសាកល្បង

ទាក់ទងទៅនឹងអានុភាពនៃការព្យួរទោសសាកល្បង គឺថាតុលាការអាចដាក់ឱ្យទណ្ឌិតស្ថិតនៅក្រោមវិធានការត្រួតពិនិត្យ និងដាក់ឱ្យទណ្ឌិតបំពេញនូវកាតព្វកិច្ចដោយឡែកមួយ ឬ ច្រើន នៅក្នុងចិរវេលាដែលតុលាការបានកំណត់ឱ្យសាកល្បងទៅតាមច្បាប់ ។ ហើយរយៈពេលសាកល្បងនេះ គឺមិនអាចតិចជាង ១ (មួយ) ឆ្នាំ និងមិនលើសពី ៣ (បី) ឆ្នាំ បានទេ ។

### ៣.១. ការអនុវត្តការសាកល្បង

ចំពោះលក្ខខណ្ឌដែលទាក់ទងទៅនឹងការសាកល្បង គឺវាមាន២ (ពីរ) ចំណុច ៖ (ក) រយៈពេលសាកល្បង (ខ) វិធានការសាកល្បង ។ ហើយនៅក្នុងវិធានការសាកល្បងនេះ ក៏មាន៣ (បី) ចំណុចតូចៗដែរគឺ ៖

[54]ឧបសម្ព័ន្ធទី៩, តុលាការកំពូល, សាលដីកាលេខៈ៣៥១ ចុះថ្ងៃទី២៩ខែកក្កដាឆ្នាំ២០២២។

(១) វិធានការត្រួតពិនិត្យ (២) កាតព្វកិច្ចដោយឡែក ដែលអាចដាក់ទៅលើទណ្ឌិត (៣) ការកែប្រែកាតព្វកិច្ចដោយឡែកដោយយុត្តាធិការ ។

### ៣.១.១. រយៈពេលសាកល្បង

នៅក្នុងចំណុចនេះ រយៈពេលសាកល្បងគឺថាចៅក្រមជាអ្នកកំណត់ បានន័យថាការកំណត់នេះគឺមិនអាចឱ្យតិចជាង ១ (មួយ) ឆ្នាំ នោះទេ ហើយក៏មិនឱ្យលើសពី ៣ (បី) ឆ្នាំ នោះដែរ[55] ។ ដោយនៅក្នុងរយៈពេលសាកល្បង ទណ្ឌិតគឺត្រូវស្ថិតនៅក្រោមការត្រួតពិនិត្យតាមដាន និងអនុវត្តកាតព្វកិច្ចដែលបានកំណត់នៅក្នុងសេចក្តីសម្រេចរបស់តុលាការ ។ ហើយការកំណត់នេះ គឺត្រូវនៅចន្លោះពី ១ (មួយ) ឆ្នាំ ទៅ ៣ (បី) ឆ្នាំ ។ ដូចនេះ ទាក់ទងទៅនឹងការព្យួរទោសសាកល្បងនេះ គឺតុលាការត្រូវតែកំណត់នូវបិរវេលាឱ្យបានច្បាស់លាស់ថាប៉ុន្មានឆ្នាំដែលជននោះត្រូវទទួលបានរយៈពេលសាកល្បង ។ ហើយនៅក្នុងរយៈពេលនេះអាច ១ (មួយ) ឆ្នាំ ឬ ២ (ពីរ) ឆ្នាំ ឬក៏ ៣ (បី) ឆ្នាំ ដោយមិនឱ្យលើស ឬ ខ្វះនូវរយៈពេលដែលបានកំណត់ដោយច្បាប់នោះទេ ។ ដោយយោងទៅតាមមាត្រា ១១៨(រយៈពេលនៃការសាកល្បង) នៃក្រមព្រហ្មទណ្ឌ ឆ្នាំ២០០៩ បានចែងថា តុលាការកំណត់រយៈពេលនៃការសាកល្បង ។ រយៈពេលនេះមិនអាចតិចជាង ១ (មួយ) ឆ្នាំ និងមិនលើសពី ៣ (បី) ឆ្នាំ ទេ ។

### ៣.១.២. វិធានការសាកល្បង

នៅក្នុងចំណុចនេះ វិធានការសាកល្បង គឺជាវិធានការសម្រាប់អនុវត្តចំពោះទណ្ឌិតដែលទទួលបាននូវការព្យួរទោសសាកល្បង ។ ហើយគោលដៅនៃវិធានការនេះ គឺដើម្បីស្តារនីតិសម្បទារបស់ជនល្មើសឡើងវិញ ជាពិសេសវិធានការនេះគឺជួយជំរុញឱ្យទណ្ឌិតទទួលបាននូវស្មារតីប្រុងប្រយ័ត្ន និងដើម្បីជៀសវាងកុំឱ្យមានការប្រព្រឹត្តនូវបទល្មើសថ្មីមួយផ្សេងទៀតកើតឡើង ។ ប៉ុន្តែ មិនមែនតែនៅក្នុងកំឡុងពេលដែលធ្វើការសាកល្បងនោះទេ គឺត្រូវតែដល់នាពេលអនាគតតែម្តង ។ ហើយនៅក្នុងវិធានការសាកល្បងនេះ គឺមាន៣ (បី) ចំណុច ៖ (១) វិធានការត្រួតពិនិត្យ (២) កាតព្វកិច្ចដោយឡែកដែលអាចដាក់ទៅលើទណ្ឌិត (៣) ការកែប្រែកាតព្វកិច្ចដោយឡែកដោយយុត្តាធិការ ។

[55]យោងតាមមាត្រា ១១៨ (រយៈពេលនៃការសាកល្បង) នៃក្រមព្រហ្មទណ្ឌ ឆ្នាំ២០០៩ បានចែងថា តុលាការកំណត់រយៈពេលនៃការសាកល្បង ។ រយៈពេលនេះមិនអាចតិចជាង ១ឆ្នាំ និងមិនលើសពី ៣ឆ្នាំ ទេ ។

### ៣.១.២.១. វិធានការត្រួតពិនិត្យ

ទាក់ទងទៅនឹងវិធានការត្រួតពិនិត្យនេះ មាន៦ (ប្រាំមួយ) ចំណុច ដែលជាវិធានការសម្រាប់តម្រូវទៅលើទណ្ឌិតផងដែរ ។ ហើយវិធានការត្រួតពិនិត្យដែលតម្រូវទៅលើ ទណ្ឌិតដែលមាន៦ (ប្រាំមួយ) ចំណុចនេះមានដូចជា ៖

- ទណ្ឌិតត្រូវតែគោរពតាមដីកាកោះរបស់ព្រះរាជអាជ្ញា ឬ របស់បុគ្គលដែលព្រះរាជអាជ្ញាបានប្រគល់អំណាចឱ្យ ។
- ទណ្ឌិតត្រូវមកទទួលនូវការមកពិនិត្យមើលរបស់បុគ្គល ដែលព្រះរាជអាជ្ញាបានប្រគល់អំណាចឱ្យ ។
- ទណ្ឌិតត្រូវប្រគល់ដល់ព្រះរាជអាជ្ញា ឬ ដល់បុគ្គលដែលព្រះរាជអាជ្ញាបានប្រគល់អំណាចឱ្យនូវគ្រប់ឯកសារ សម្រាប់ធ្វើការផ្ទៀងផ្ទាត់ លើការបញ្ចូលឱ្យទៅរស់នៅក្នុងសង្គមវិញ ។
- ទណ្ឌិតត្រូវជូនដំណឹងដល់ព្រះរាជអាជ្ញា អំពីការផ្លាស់ប្តូរអាសយដ្ឋានរបស់ខ្លួន ។
- ទណ្ឌិតត្រូវជូនដំណឹងដល់ព្រះរាជអាជ្ញា អំពីការផ្លាស់ប្តូរមុខរបររបស់ខ្លួន ។
- ទណ្ឌិតត្រូវតែមានការអនុញ្ញាតពីព្រះរាជអាជ្ញា មុនពេលធ្វើដំណើរទៅបរទេស[56] ។

ហេតុដូច្នេះហើយ ៦ (ប្រាំមួយ) ចំណុចនៃវិធានការត្រួតពិនិត្យ ដែលក្រមព្រហ្មទណ្ឌបានកំណត់ទុកឱ្យទណ្ឌិតទទួល គឺនៅក្នុងករណីដែលទណ្ឌិតនោះ ត្រូវបានតុលាការប្រកាសនៅក្នុងសាលក្រម ឬ សាលដីកា ឱ្យទទួលបាននូវការព្យួរទោសសាកល្បង ។ ហេតុនេះ ទណ្ឌិតត្រូវតែអនុវត្តទៅតាមមាត្រា ១១៩ (វិធានការត្រួតពិនិត្យ)នៃក្រមព្រហ្មទណ្ឌ ឆ្នាំ២០០៩ដែលទណ្ឌិតនោះ ត្រូវបានតុលាការប្រកាសអំពីការព្យួរទោសសាកល្បង ។

### ៣.១.២.២. កាតព្វកិច្ចដោយឡែកដែលអាចដាក់ទៅលើទណ្ឌិត

ចំពោះកាតព្វកិច្ចដោយឡែកវិញ គឺមាន១៣ (ដប់បី) ចំណុច ដែលជាកាតព្វកិច្ចសម្រាប់ដាក់ទៅលើទណ្ឌិតឱ្យអនុវត្ត ។ ហើយកាតព្វកិច្ចដោយឡែកដែលអាចដាក់ទៅលើ ទណ្ឌិត ដែលមាន១៣ (ដប់បី) ចំណុចសម្រាប់ដាក់ឱ្យទណ្ឌិតអនុវត្តនេះគឺមានដូចជា ៖

- បំពេញសកម្មភាពខាងវិជ្ជាជីវៈ ។
- ទទួលការបង្ហាត់បង្រៀន ឬ ទទួលការបណ្តុះបណ្តាលវិជ្ជាជីវៈ ។

[56]យោងតាមមាត្រា ១១៩ (វិធានការត្រួតពិនិត្យ) នៃក្រមព្រហ្មទណ្ឌ ឆ្នាំ២០០៩

- រស់នៅក្នុងទីកន្លែងណាមួយជាកំណត់ ។
- ទទួលឱ្យពេទ្យធ្វើការពិនិត្យ ឬ ការព្យាបាល ។
- បញ្ជាក់ថាខ្លួនរួមចំណែកក្នុងការចិញ្ចឹមបីបាច់គ្រួសារ ។
- ធ្វើការជួសជុលការខូចខាតដែលបណ្ដាលមកពីបទល្មើសតាមលទ្ធភាពធនធានរបស់ខ្លួន ។
- បញ្ជាក់ថាខ្លួនបានបង់ប្រាក់ជូនរដ្ឋបន្ទាប់ពីការផ្ដន្ទាទោសតាមលទ្ធភាពធនធានរបស់ខ្លួន ។
- មិនត្រូវធ្វើសកម្មភាពខាងវិជ្ជាជីវៈ ឬ សង្គមដែលអនុញ្ញាត ឬ សម្រួលដល់ការប្រព្រឹត្តបទល្មើស ។ ក្នុងករណីនេះ តុលាការបញ្ជាក់អំពីសកម្មភាពដែលហាមឃាត់ ។
- មិនត្រូវមានមុខនៅទីកន្លែងខ្លះ ។ ក្នុងករណីនេះ តុលាការបញ្ជាក់អំពីទីកន្លែងដែលហាមឃាត់ ។
- មិនត្រូវសេពគប់បនល្បែង ។
- មិនត្រូវសេពគប់តៀមភេសជ្ជៈស្រវឹង ។
- មិនត្រូវសេពគប់ជាមួយបុគ្គលខ្លះ ពិសេស ចារី សហចារី អ្នកផ្ដើមគំនិត អ្នកសមគំនិត ឬ ជនរងគ្រោះនៃបទល្មើស ។ ក្នុងករណីនេះ តុលាការបញ្ជាក់អំពីបុគ្គលដែលមិនត្រូវសេពគប់ជាមួយ ។
- មិនត្រូវកាន់កាប់ ឬ យកតាមខ្លួននូវអាវុធ គ្រឿងផ្ទុះ និងគ្រាប់រំសេវគ្រប់ប្រភេទ ។

នៅក្នុងសេចក្ដីសម្រេចរបស់ខ្លួន តុលាការត្រូវតែចែងអំពីកាតព្វកិច្ចដោយឡែកដែលតម្រូវទៅលើទណ្ឌិត[57] ។ហេតុនេះ នៅក្នុង១៣ (ដប់បី) ចំណុចដែលជាកាតព្វកិច្ចដោយឡែកខាងលើនេះ គឺតុលាការអាចធ្វើការប្រកាសដោយយកមួយ ឬ ច្រើន ទៅតាមអ្វីដែលចៅក្រមបានយល់ឃើញសម្រាប់ដាក់ឱ្យទណ្ឌិតបំពេញតាម ។ ប៉ុន្តែ បើក្នុងករណីទណ្ឌិតនោះមិនបំពេញទៅតាមទេនោះ គឺចៅក្រមអាចនឹងធ្វើការដកហូតពីទណ្ឌិតនោះអំពីការព្យួរទោសសាកល្បងចោលវិញបាន ។ ហេតុនេះហើយមាត្រា ១២០ (កាតព្វកិច្ចដោយឡែកដែលអាចដាក់ទៅលើទណ្ឌិត) នៃក្រមព្រហ្មទណ្ឌនេះ គឺកាតព្វកិច្ចដោយឡែកដែលតុលាការអាចធ្វើការជ្រើសរើសយកមកដាក់ ហើយដោយក្នុងនោះចៅក្រមត្រូវមើលទៀតថាតើទណ្ឌិតហ្នឹងជាប់ពាក់ព័ន្ធជាមួយនឹងការប្រព្រឹត្តបទល្មើសមួយណា។

ហើយទាំងនេះក៏មិនមែនចេះតែដាក់ទាំងអស់ទៅតាមចិត្តចង់ និងទៅតាមការនឹកឃើញសម្រាប់ដាក់ទៅលើជនណាម្នាក់នោះទេ តែចៅក្រមអាចធ្វើការជ្រើសរើសដោយយកមួយ ឬ ច្រើន ដោយលើសពីមួយក៏បាន

[57]យោងតាមមាត្រា ១២០ (កាតព្វកិច្ចដោយឡែកដែលអាចដាក់ទៅលើទណ្ឌិត) នៃក្រមព្រហ្មទណ្ឌ ឆ្នាំ២០០៩

ដែរ ។ ហើយកាតព្វកិច្ចដែលមាន១៣ (ដប់បី) ចំណុចនេះ គឺសម្រាប់តែចំពោះទណ្ឌិតដែលជានីតិជនតែប៉ុណ្ណោះ ដោយហេតុថាមាត្រា ១២០ នៃក្រមព្រហ្មទណ្ឌនេះ គឺចែងតែទៅលើទណ្ឌិតដែលជានីតិជន ។ ប៉ុន្តែ បើចំពោះអនីតិជនវិញ គឺថាមាត្រា ១៦៥ (កាតព្វកិច្ចដោយឡែកក្នុងករណីនៃការព្យួរទោសសាកល្បង) នៃក្រមព្រហ្មទណ្ឌ ឆ្នាំ២០០៩ បានចែងពីកាតព្វកិច្ចដោយឡែករបស់អនីតិជន ហើយដែលវាមានលក្ខណៈខុសគ្នាពីកាតព្វកិច្ចដោយឡែកដែលដាក់ចំពោះនីតិជនដែរ ។ ទាក់ទងទៅនឹងកាតព្វកិច្ចដោយឡែករបស់អនីតិជននេះ គឺមាន៩ (ប្រាំបួន) ចំណុច ដែលចៅក្រមអាចធ្វើការដាក់ទៅលើអនីតិជនឱ្យអនុវត្ត នៅក្នុងករណីដែលអនីតិជននោះត្រូវបានចៅក្រមផ្តល់នូវការព្យួរទោសសាកល្បងនោះ ។ ហេតុនេះកាតព្វកិច្ចដោយឡែករបស់អនីតិជន គឺថានៅក្នុងករណីនៃការព្យួរទោសសាកល្បង មានតែកាតព្វកិច្ចដោយឡែកដូចតទៅនោះប៉ុណ្ណោះ ដែលអាចអនុវត្តទៅលើអនីតិជន ៖

- ទទួលការបង្ហាត់បង្រៀន ឬ ការបណ្តុះបណ្តាលវិជ្ជាជីវៈ ។
- ស្ថិតនៅទីកន្លែងមួយជាកំណត់ ។
- ដាក់ខ្លួនឱ្យពេទ្យពិនិត្យ ឬ ព្យាបាល ។
- ជួសជុលព្យសនកម្មដែលបណ្តាលមកអំពីបទល្មើស ទៅតាមធនធានរបស់ខ្លួន ។
- បង្ហាញភស្តុតា[58]បញ្ជាក់ថាខ្លួនបង់ទឹកប្រាក់ដែលជំពាក់ជូនរដ្ឋរួចហើយ តាមលទ្ធភាពនៃធនធានរបស់ខ្លួន បន្ទាប់ពីការផ្តន្ទាទោស ។
- មិនត្រូវបង្ហាញមុខនៅទីកន្លែងខ្លះ ។
- មិនត្រូវសេពគប់ ទីកន្លែងលក់ភេសជ្ជៈស្រវឹង ។
- មិនត្រូវសេពគប់ជាមួយបុគ្គលខ្លះ ដោយឡែកជាមួយសហចារី អ្នក ផ្តើមគំនិត អ្នកសមគំនិត ឬ ជនរងគ្រោះនៃបទល្មើស ។
- មិនត្រូវកាន់កាប់ ឬ យកតាមខ្លួននូវអាវុធ គ្រឿងផ្ទុះ និងគ្រាប់រំសេវគ្រប់ប្រភេទ[59] ។

ដូចនេះ ចំណុចទាំង៩ (ប្រាំបួន) ខាងលើនេះ គឺជាកាតព្វកិច្ចដោយឡែកដែលសម្រាប់ប្រើទៅលើអនីតិជន ។

---

[58]ភស្តុតាង គឺជាព័ត៌មានគ្រប់ប្រភេទ មានឯកសារ ព្រឹត្តិការណ៍ វត្ថុជាក់ស្តែង ដែលដាក់បង្ហាញនៅពេលស៊ើបអង្កេត ស៊ើបសួរ ឬ សវនាការ ដើម្បីបង្ហាញអំពីអត្ថិភាព(ការកើតមាន)នៃអង្គហេតុជាក់លាក់ ។ English : Evidence , Proof / France : Preuve . សន្ទានុក្រមពាក្យច្បាប់ (ដកស្រង់ពីច្បាប់ និង លិខិតបទដ្ឋានគតិយុត្តជាធរមាន) ពីឆ្នាំ១៩៩៤ ដល់ ឆ្នាំ២០១២

[59]មាត្រា ១៦៥ (កាតព្វកិច្ចដោយឡែកក្នុងករណីនៃការព្យួរទោសសាកល្បង) នៃក្រមព្រហ្មទណ្ឌ ឆ្នាំ២០០៩

### ៣.១.២.៣. ការកែប្រែកាតព្វកិច្ចដោយឡែកដោយយុត្តាធិការ

នៅក្នុងក្រមព្រហ្មទណ្ឌនេះ ពាក្យថាយុត្តាធិការ គឺសំដៅទៅលើតុលាការ ឬ ស្ថាប័នដែលទទួលបន្ទុកចាត់ការរឿងក្តី ។ សាលាជម្រះក្តីគ្រប់ជាន់ថ្នាក់ ។ ហេតុនេះ បើយោងទៅតាមមាត្រា ១២១ (ការកែប្រែកាតព្វកិច្ចដោយយុត្តាធិការ) នៃក្រមព្រហ្មទណ្ឌ ឆ្នាំ២០០៩ បានចែងថា នៅគ្រប់ពេលវេលា តុលាការអាចកែប្រែកាតព្វកិច្ចដោយឡែកដែលតម្រូវលើទណ្ឌិតបាន ។ តុលាការត្រូវបានទទួលបណ្តឹងនៅក្នុងលក្ខខណ្ឌដែលបានចែងដោយក្រមនីតិវិធីព្រហ្មទណ្ឌ ។ បានសេចក្តីថា នៅក្នុងករណីដែលកាតព្វកិច្ចណាមួយដែលចៅក្រមបានដាក់ទៅឱ្យទណ្ឌិតណាមួយអនុវត្តរួចហើយ ហើយស្រាប់តែចៅក្រមនោះបានយល់ឃើញវិញថា កាតព្វកិច្ចដែលបានដាក់នោះវាមិនសមស្របទៅនឹងស្ថានភាពនោះទេបែបនេះចៅក្រមអាចធ្វើការកែប្រែនូវកាតព្វកិច្ចនោះទៅតាមអ្វីដែលគាត់យល់ឃើញថាសមស្របទៅតាមស្ថានភាពជាក់ស្តែងវិញបាន ។ ប៉ុន្តែ ទាក់ទងទៅនឹងតុលាការត្រូវបានទទួលបណ្តឹងនៅក្នុងលក្ខខណ្ឌដែលបានចែងដោយក្រមនីតិវិធីព្រហ្មទណ្ឌវិញនោះគឺយោងទៅតាមមាត្រា ៥០០ (ការលំបាកទាក់ទងនឹងការអនុវត្តទោស) នៃក្រមនីតិវិធីព្រហ្មទណ្ឌ ឆ្នាំ២០១០ បានចែងថា ការលំបាកទាំងឡាយ ដែលទាក់ទងនឹងការអនុវត្តទោស ត្រូវតែលើកជូនតុលាការជាន់ដំបូង ឬ តុលាការជាន់ខ្ពស់ ដែលបានសម្រេចផ្តន្ទាទោសនោះដោះស្រាយ ។ តុលាការទទួលបណ្តឹង តាមពាក្យបណ្តឹងរបស់អយ្យការ ឬ របស់ភាគីពាក់ព័ន្ធ ។ តុលាការនេះ សម្រេចនៅពេលសវនាការសាធារណៈ ក្រោយពីបានស្តាប់អយ្យការ ភាគីពាក់ព័ន្ធ និងជាយថាហេតុ មេធាវីរបស់ភាគីនេះ ។ ការអនុវត្តទោសនេះអាចត្រូវបានព្យួរដោយតុលាការ ។ ហេតុនេះហើយទាំងនេះគឺជាលក្ខខណ្ឌនៃក្រមនីតិវិធីព្រហ្មទណ្ឌ ដែលពាក់ព័ន្ធទៅនឹងបណ្តឹង ដែលតុលាការត្រូវតែទទួលអនុវត្ត ។

## ៣.២.ការដកហូតការព្យួរទោសសាកល្បង

ទាក់ទងទៅនឹងការដកហូតការព្យួរទោសសាកល្បង គឺថាការព្យួរទោសសាកល្បងអាចធ្វើការដកហូតដោយតុលាការបាន ដោយនៅក្នុងករណីដូចខាងក្រោមនេះ ៖

- ប្រសិនបើក្នុងរយៈពេលសាកល្បង ទណ្ឌិតមិនគោរពតាមវិធានការត្រួតពិនិត្យ ឬ កាតព្វកិច្ចដោយឡែកទេ ។
- ប្រសិនបើក្នុងរយៈពេលសាកល្បង ទណ្ឌិតត្រូវបានផ្តន្ទាទោសពីបទឧក្រិដ្ឋ ឬ បទមជ្ឈិមជាថ្មីទៀត ។

តុលាការអាចបង្គាប់ឱ្យដកហូតការព្យួរទោសសាកល្បងនេះ ទាំងមូល ឬ មួយផ្នែក នៅក្នុងករណីនេះទោសត្រូវយកមកអនុវត្តទាំងមូល ឬ មួយផ្នែក ។ តុលាការត្រូវបានទទួលបណ្តឹងនៅក្នុងលក្ខខណ្ឌ ដែលមាន

ចែងដោយក្រមនីតិវិធីព្រហ្មទណ្ឌ[60] ។ ហេតុនេះ បានន័យថា នៅក្នុងការព្យួរទោសសាកល្បង គឺតុលាការអាចធ្វើការដកហូតការព្យួរទោសបាន បើក្នុងករណីមានបណ្តឹងត្រូវបានប្តឹងដោយព្រះរាជអាជ្ញា ដែលបណ្តឹងនោះទាក់ទងទៅនឹងការមិនគោរពកាតព្វកិច្ចរបស់គាត់(ទណ្ឌិត)ដោយហេតុថានៅក្នុងរយៈពេលដែលគាត់(ទណ្ឌិត) បានធ្វើកិច្ចការដែលស្ថិតនៅក្រោមវិធានការត្រួតពិនិត្យក្តី ឬក៏ការបំពេញនូវកាតព្វកិច្ចដោយឡែកក្តី គឺត្រូវតែស្ថិតនៅក្រោមការត្រួតពិនិត្យរបស់ព្រះរាជអាជ្ញាទាំងអស់ ។ ហើយបើក្នុងករណីបំពេញកាតព្វកិច្ច ជននោះមិនបានគោរពនូវកាតព្វកិច្ចណាមួយឱ្យបានត្រឹមត្រូវ ឬក៏មិនបានបំពេញនូវវិធានការត្រួតពិនិត្យណាមួយទេនោះ គឺថាពេលនោះព្រះរាជអាជ្ញាអាចធ្វើការដាក់ពាក្យបណ្តឹងដោយប្តឹងសុំទៅកាន់ចៅក្រម ដើម្បីឱ្យចៅក្រមគាត់ធ្វើការដកហូតនូវការព្យួរទោសសាកល្បងនោះចោលវិញពីព្រោះថានៅក្នុងរយៈពេលដែលធ្វើការសាកល្បងនេះទណ្ឌិតគ្រប់រូបដែលទទួលបានការព្យួរទោសសាកល្បងពីចៅក្រម គឺត្រូវតែធ្វើឱ្យអស់រាល់កាតព្វកិច្ចដោយឡែក ឬក៏វិធានការត្រួតពិនិត្យ ដែលចៅក្រមបានប្រកាសនៅក្នុងការព្យួរទោសសាកល្បងនេះ ។ហេតុដូច្នេះហើយ គឺព្រះរាជអាជ្ញាអាចធ្វើការតាមដាននៅក្នុងចិរវេលា ក៏ដូចជារយៈពេលដែលតុលាការបានធ្វើការកំណត់ឱ្យមានការសាកល្បងនោះមាន ២ (ពីរ) ឆ្នាំ ស្រាប់តែនៅក្នុងរយៈពេលនោះ ទណ្ឌិតនោះមិនបានបំពេញនូវកាតព្វកិច្ចណាមួយឱ្យបានជាក់លាក់ ឬក៏មិនបានគោរពទៅតាមវិធានការត្រួតពិនិត្យណាមួយនោះទេ ។ នៅក្នុងករណីបែបនេះហើយដែលធ្វើឱ្យព្រះរាជអាជ្ញាធ្វើការដាក់ពាក្យបណ្តឹងសម្រាប់ប្តឹងទៅកាន់ចៅក្រម ដើម្បីឱ្យចៅក្រមគាត់ធ្វើការសម្រេចដកហូតការព្យួរទោសសាកល្បងពីទណ្ឌិតដែលមិនបានបំពេញនូវកាតព្វកិច្ច និងមិនគោរពទៅតាមវិធានការត្រួតពិនិត្យទាំងអស់ដែលចៅក្រមបានដាក់ឱ្យនៅពេលធ្វើការប្រកាសការព្យួរទោសសាកល្បងនោះ ។ ប៉ុន្តែមានករណីមួយទៀត គឺថាបើក្នុងរយៈពេលសាកល្បងនេះ ទណ្ឌិតដែលបានទទួលការព្យួរទោសសាកល្បងហើយនោះ ហើយបានប្រព្រឹត្តនូវបទឧក្រិដ្ឋ ឬក៏បទមជ្ឈិមណាមួយថ្មីផ្សេងទៀតនោះ ដោយមិនទាន់ហួសកំណត់នូវរយៈពេលដែលបានកំណត់នោះទេ ហើយទណ្ឌិតនោះក៏ទៅប្រព្រឹត្តបទល្មើសបន្តទៅទៀត ចំណុចនេះក៏ជាមូលដ្ឋានសម្រាប់ព្រះរាជអាជ្ញាធ្វើការដាក់ពាក្យប្តឹងសុំ ដើម្បីឱ្យចៅក្រមធ្វើការដកហូតនូវការព្យួរទោសសាកល្បងពីទណ្ឌិតដែលបានប្រព្រឹត្តនូវបទល្មើសថ្មីមួយទៀតនោះដែលមិនទាន់ផុតរយៈពេលកំណត់ផងនោះ ។

### ៣.៣.ការផ្តន្ទាទោសដែលត្រូវចាត់ទុកជាអសារបង់

ចំពោះចំណុចនៃការផ្តន្ទាទោស គឺត្រូវបានចាត់ទុកថាជាអសារបង់ បើក្នុងករណីនៅមុនពេលដែលផុតរយៈពេលសាកល្បងនោះ ការផ្តន្ទាទោសនោះមិនមែនជាកម្មវត្ថុនៃពាក្យដែលសុំធ្វើការដកហូតដែលមាននៅក្នុង

[60]យោងតាមមាត្រា ១២២ (ការដកហូតការព្យួរទោសសាកល្បង) នៃក្រមព្រហ្មទណ្ឌ ឆ្នាំ២០០៩

សេចក្តីសម្រេចដកហូតទេនោះ[61]គឺបានសេចក្តីថា នៅក្នុងកំឡុងពេលនៃការសាកល្បងដែលចៅក្រមបានកំណត់នោះ ហើយទណ្ឌិតនោះក៏បានបំពេញចប់សព្វគ្រប់អស់នូវរាល់កាតព្វកិច្ច និងវិធានការត្រួតពិនិត្យទាំងអស់ដែលចៅក្រមបានដាក់ឱ្យធ្វើ ហើយទណ្ឌិតនោះក៏មិនបានប្រព្រឹត្តនូវបទល្មើសថ្មីណាមួយផ្សេងទៀតដែរ ហេតុនេះហើយ ទើបការអនុវត្តទោសនេះ ត្រូវបានធ្វើការចាត់ទុកថាជាអសារបង់ បានសេចក្តីថា ចៅក្រមគឺមិនធ្វើការយកទោសនោះទៅអនុវត្តទៅលើទណ្ឌិតនោះទៀតទេ ចំណុចនេះគឺបានន័យថា ទណ្ឌិតនោះនឹងត្រូវបានរួចខ្លួនផុតពីការផ្តន្ទាទោសរបស់ច្បាប់ទៅតាមក្រមព្រហ្មទណ្ឌទៀតហើយ ។

**<u>ឧទាហរណ៍</u>**:

ទណ្ឌិតម្នាក់ត្រូវបានចៅក្រមធ្វើការកំណត់ឱ្យទទួលរងនូវទោសដាក់ពន្ធនាគាររយៈពេល ២ (ពីរ) ឆ្នាំ ។ ហើយចៅក្រមក៏បានធ្វើការប្រកាសទោស ដោយប្រកាសថាទោសនេះត្រូវធ្វើការព្យួរទោសសាកល្បង ហេតុនេះនៅក្នុងសេចក្តីសម្រេចរបស់ចៅក្រមក៏បានកំណត់នៅក្នុងនោះមានដូចជា (១) ទាក់ទងទៅនឹងវិធានការត្រួតពិនិត្យ (២) ទាក់ទងទៅនឹងកាតព្វកិច្ចដោយឡែកមួយ ឬ ច្រើន ផងដែរ ។ ហេតុដូច្នេះ នៅក្នុងសេចក្តីសម្រេចនេះ គឺចៅក្រមក៏បានកំណត់ឱ្យបំពេញនូវកិច្ចការនេះ ដោយនៅក្នុងរយៈពេលសាកល្បងនេះមាន ១៨ (ដប់ប្រាំបី) ខែ ទៅចុះ ។ បើក្នុងករណីហួសរយៈពេល ១៨ (ដប់ប្រាំបី) ខែ ហើយទណ្ឌិតនោះបានបំពេញនូវកាតព្វកិច្ចចប់សព្វគ្រប់អស់ ហើយដោយបានធ្វើទៅតាមអ្វីដែលចៅក្រមបានកំណត់ឱ្យនោះ ដូចនេះ ទោសដែលចៅក្រមបានកំណត់នៅក្នុងរយៈពេល ២ (ពីរ) ឆ្នាំ នេះ គឺគេលែងយកមកធ្វើការអនុវត្តតទៅទៀតហើយ បានន័យថា គឺទណ្ឌិតនោះត្រូវបានរួចខ្លួនជាស្ថាពរ ។ ទាំងអស់នេះហើយ ដែលជាការបំពេញកាតព្វកិច្ច និងវិធានការត្រួតពិនិត្យ ដែល ទណ្ឌិតបានធ្វើការបំពេញទៅតាមអ្វីដែលចៅក្រមបានកំណត់ឱ្យធ្វើ ។ ហើយម្យ៉ាងវិញទៀត ទាក់ទងទៅនឹងបញ្ហានៃការផ្តន្ទាទោសដែលត្រូវទុកជាអសារបង់វិញនោះ បើក្នុងករណីផុត រយៈពេលសាកល្បងហើយនោះ ចំពោះការផ្តន្ទាទោសថ្មីវិញ គឺវាមិនមែនជាកម្មវត្ថុនៃការដាក់ពាក្យបណ្តឹងរបស់ព្រះរាជអាជ្ញានោះទេគឺបានសេចក្តីថា ពុំមានបណ្តឹងដែលបានសុំដាក់ចូលមកនោះឡើយ ដែលវាជាកម្មវត្ថុនៃការពាក់ព័ន្ធជាមួយនឹងការដកហូតនូវការព្យួរទោសសាកល្បងនោះទេ ហេតុនេះបានសេចក្តីថា ការអនុវត្តនេះក៏ត្រូវបានចាត់ទុកថាជាអសារបង់ផងដែរ

[61]យោងតាមមាត្រា ១២៣ (ការផ្តន្ទាទោសដែលត្រូវចាត់ទុកជាអសារបង់) នៃក្រមព្រហ្មទណ្ឌ ឆ្នាំ២០១១ បានចែងថា ការផ្តន្ទាទោសត្រូវចាត់ទុកជាអសារបង់ ប្រសិនបើមុនការផុតរយៈពេលសាកល្បងការផ្តន្ទាទោសមិនមែនជាកម្មវត្ថុនៃពាក្យសុំដកហូតដែលមានសេចក្តីសម្រេចដកហូតទេ ។

# សេចក្ដីសន្និដ្ឋាន

# សេចក្តីសន្និដ្ឋាន

បន្ទាប់ពីបានធ្វើការសិក្សាស្រាវជ្រាវអំពីប្រធានបទ **ការព្យួរទោស** នេះរួចមក យើងខ្ញុំបានយល់កាន់តែច្បាស់អំពីនីតិវិធីក្នុង**ការព្យួរទោស** ទៅតាមបទល្មើសនីមួយៗព្រមទាំងដំណាក់កាលនៃការផ្តន្ទាទោសដែលគួរធ្វើឡើងនៅពេលណាខ្លះ និងតាមរយៈអ្វីខ្លះ។ **ការព្យួរទោស** គឺជាវិធានមួយក្នុងការផ្តល់ឱកាសដល់ទណ្ឌិតក្នុងការកែប្រែកំហុសរបស់ខ្លួន ដោយឈប់ប្រព្រឹត្តបទល្មើសធ្វើតែអំពើល្អ នឹងជួយប្រកបមុខរបរដើម្បីជីវភាពគ្រួសារ។ ក្រៅពីនេះការអនុវត្តទោស យើងបានយល់បន្ថែមអំពីការរៀបចំ និងលក្ខខណ្ឌណាខ្លះក្នុងការព្យួរទោស ហើយនរណាខ្លះដែលមានសិទ្ធិ និងសមត្ថកិច្ចក្នុងការប្រកាសទោសទាំងនេះនៅក្នុងច្បាប់ព្រហ្មទណ្ឌ។ ការព្យួរទោសនេះ ត្រូវធ្វើឡើងយ៉ាងយកចិត្តទុកដាក់ និងឆ្លងកាត់ជាច្រើនដំណាក់កាលមុននឹងឈានដល់សេចក្តីសម្រេច។

មួយវិញទៀត ទោសដែលត្រូវអនុវត្តសម្រាប់រូបវន្តបុគ្គល គឺត្រូវបានចាត់ថ្នាក់ជាបទឧក្រិដ្ឋ បទមជ្ឈិម និងបទលហុ ទៅតាមទម្ងន់នៃបទល្មើសនីមួយៗ។ គោលបំណងក្នុងការរៀបចំចំណាត់ថ្នាក់នៃបទល្មើស គឺបង្ការកុំឲ្យមានភាពរញ៉េរញ៉ៃក្នុងការចោទប្រកាន់បទល្មើស និងក្នុងការយកទៅអនុវត្តផ្តន្ទាទោសទៀតផង។ ជាធម្មតាទោសព្រហ្មទណ្ឌ សំដៅទៅលើទោសដាក់ពន្ធនាគារ និងទោសពិន័យជាប្រាក់ ហើយគេចាត់ទុកទោសទាំងនោះជាកំហុស ឬអំពើរបស់ចារី ឬសហចារីដែលបានប្រព្រឹត្តអំពើល្មើសទាំងនោះ។ ដូច្នេះតួនាទីរបស់តុលាការ គឺត្រូវពិចារណា ស្វែងរកភាពពិត និងយុត្តិធម៌ជូនជនរងគ្រោះដោយវិធីបង្ក្រាប កែប្រែ និងបង្ការនូវអំពើល្មើសនោះកុំឲ្យកើតមានតទៅទៀត។ ស្របជាមួយគ្នានេះផងដែរ តុលាការមានសមត្ថកិច្ចក្នុងការអនុវត្តផ្តន្ទាទោសទៅលើចារីពេលដែលបានរកឃើញថាជននោះបានប្រព្រឹត្តអំពើ ឬបទល្មើសទាំងនោះមែន ប៉ុន្តែតុលាការក៏មានសិទ្ធិក្នុងការបន្ធូរបន្ថយទោស ឬព្យួរទោសក្នុងករណីទណ្ឌិតបានអនុវត្តទៅតាមលក្ខខណ្ឌនៃការព្យួរទោសបានចែង ហើយជននោះត្រូវគេមើលឃើញថាបានកែប្រែក្លាយជាមនុស្ស និងអាចជួយជាប្រយោជន៍ដល់រដ្ឋ និងសង្គមទាំងមូល។

ក្នុងនោះព្រះរាជអាជ្ញាក៏ជាអ្នកដែលមានតួនាទីពិសេសក្នុងការតាមដានរាល់ទង្វើ ឬកិច្ចការដែលទណ្ឌិតត្រូវអនុវត្ត ហើយប្រសិនបើព្រះរាជអាជ្ញាយល់ឃើញថាជននោះពិតជាបានកែប្រែខ្លួនទៅជាមនុស្សល្អពិតមែនព្រះរាជអាជ្ញានឹងធ្វើការស្នើសុំឲ្យបន្ធូរបន្ថយឬលើកលែងទោសដល់ជននោះដោយយោងទៅតាមបទប្បញ្ញត្តិដែលបានចែងជាសាធារណៈ។ ដូច្នេះប្រសិនបើទណ្ឌិតត្រូវបានលើកលែងទោសក្នុងលក្ខខណ្ឌណាមួយជននោះនឹងទទួលបានសិទ្ធិសេរីភាពក្នុងការចេញទៅរស់នៅក្នុងសង្គមសារជាថ្មី។

សរុបសេចក្តីមក នីតិវិធីក្នុង **ការព្យួរទោស** មានយន្តការ និងលក្ខខណ្ឌជាច្រើនដែលទាមទារឲ្យទណ្ឌិតគោរព និងអនុវត្តតាម ហើយវាគឺជាឱកាសមួយដ៏ល្អសម្រាប់ទណ្ឌិតក្នុងការកែប្រែ ឬសងនូវព្យសនកម្មដែលបានធ្វើឲ្យខូចខាតដល់សង្គម ឬជនរងគ្រោះជាជាងទទួលរងនូវទោសទណ្ឌផ្សេងៗ។ យន្តការទាំងនេះសុទ្ធតែមានសារៈសំខាន់ខុសៗគ្នា ដែលជាប្រយោជន៍ដល់ទណ្ឌិត និងមនុស្សនៅក្នុងសង្គមក្នុងការយល់ដឹងបន្ថែមអំពីច្បាប់ដែលមានចែងនៅក្នុងព្រះរាជាណាចក្រកម្ពុជា ដើម្បីជាប្រយោជន៍ដល់សង្គមក្នុងការកាត់បន្ថយកំណើននៃបទល្មើស និងជាពិសេសកាត់បន្ថយក្នុងការចំណាយរបស់រដ្ឋទៅលើការគ្រប់គ្រងពន្ធនាគារ និងចំណាយដទៃ

ទៀតក្នុងការអនុវត្តដំណើរការនីតិវិធីតុលាការឲ្យកាន់តែមានភាពរហ័ស និងប្រកបដោយភាពសុក្រឹត្យ និងយុត្តិធម៌ជូនប្រជាពលរដ្ឋទាំងអស់គ្នា។

# អនុសាសន៍

# អនុសាសន៍

បន្ទាប់ពីការបកស្រាយនូវប្រធានបទខាងលើនេះរួចមកយើងឃើញថាក្រមព្រហ្មទណ្ឌឆ្នាំ២០០៩ មានយន្តការច្រើនក្នុងការអនុវត្ត និងប្រកាសទោសព្រហ្មទណ្ឌ ចំពោះជនណាដែលបានប្រព្រឹត្តបទល្មើសដូចមានចែងនៅក្នុងក្រមព្រហ្មទណ្ឌ។ បន្ថែមពីនេះ ប្រភេទនៃទោសដែលក្រមព្រហ្មទណ្ឌបានចែងមាន មូលទោស ទោសបន្ថែមនិងទោសជំនួស ដែលប្រភេទនៃទោសទាំងបីនេះមានលក្ខខណ្ឌ និងនិតិវិធីក្នុងការអនុវត្តខុសៗគ្នាអាស្រ័យទៅលើទម្ងន់នៃទោសដែលជនល្មើសបានប្រព្រឹត្ត។ ក្រមព្រហ្មទណ្ឌក៏បានបញ្ញត្តិអំពីផ្សេងៗដែលអាចនាំឲ្យមានផលប៉ះពាល់ដល់ការអនុវត្តទោស ដូចជាការព្យួរទោស ការបន្ធូរបន្ថយទោស ការលើកលែងទោស និងកត្តាគតិយុត្តមួយចំនួនទៀត ដែលត្រូវបានប្បញ្ញត្តិឡើងដែលមានលក្ខណៈងាយស្រួលដល់ទណ្ឌិត។ ហេតុនេះហើយទើបយន្តការផ្សេងៗទៀតមិនសូវបានយកទៅអនុវត្ត និងនាំឲ្យមានកំណើនទណ្ឌិតនៅក្នុងពន្ធនាគារច្រើនលើសលប់ដែលនាំឲ្យមានផលពិបាកជាច្រើនដល់រដ្ឋ។ ចំពោះបញ្ហាទាំងនេះ តុលាការបានប្រើប្រាស់ទៅជំនួស (ទោសការងារសហគមន៍ និងការស្តីបន្ទោស) មកអនុវត្តដែលជួយសម្រួលដល់បញ្ហាស្ថានភាព ទីកន្លែង ពេលវេលា និងថវិកាក្នុងការជួលមនុស្សឲ្យឃ្លាំមើលជា។

ទោះបីជាការព្យួរទោសមានសារៈប្រយោជន៍សម្រាប់ទណ្ឌិត និងជួយកាត់បន្ថយបន្ទុករបស់ រដ្ឋ យ៉ាងណាក៏ដោយ ក៏មានប្រជាពលរដ្ឋមួយចំនួនធំនៅតែមិន យល់ពីការព្យួរទោសនេះ ហើយថែម ទាំង រិះគន់ទៅលើអំណាចតុលាការថា តុលាការបានធ្វើការផ្តន្ទាទោសជនល្មើសរួចរាល់ហើយ តែបែរជា ជនល្មើសអាចនៅក្រៅពន្ធនាគារបានទៅវិញ ។ បញ្ហានេះបានធ្វើឱ្យប្រជាជនមួយចំនួន មានការយល់ ច្រឡំអព្យាក្រឹត្យភាពរបស់តុលាការ ដូចនេះ ក្រុមយើងខ្ញុំនឹងលើកយកដំណោះស្រាយមួយចំនួននៅ លើបញ្ហានេះ ៖

- ក្រសួងយុត្តិធម៌ : តាងនាមឱ្យរាជរដ្ឋាភិបាលក្រសួងយុត្តិធម៌គួរតែពង្រីកនូវការ ផ្សព្វ ផ្សាយច្បាប់ឱ្យបានទៅដល់គ្រប់ទីកន្លែងដែលអាចធ្វើបាន ជាពិសេស នៅតាមតំបន់ មួយចំនួនដែលនៅឆ្ងាយពីទីក្រុង ឬទីប្រជុំជន ។
- សាកលវិទ្យាល័យ : ជាពិសេសមហាវិទ្យាល័យច្បាប់ គួរបើកវគ្គសិក្ខាសាលាស្តីអំពីការ ព្យួរទោសដល់និស្សិតឱ្យចូលរួមដោយសេរី ដើម្បីឱ្យនិស្សិតយកចំណេះដឹងដែលបាន មកពីសិក្ខាសាលាយកទៅចែកចាយបន្ត ។
- សាស្ត្រាចារ្យផ្នែកច្បាប់ : សៀវភៅគឺជាឃ្លាំងចំណេះរបស់មនុស្ស ដូចនេះសូមលោកសាស្ត្រាចារ្យផ្នែកច្បាប់ទាំងឡាយគួរនិពន្ធសៀវភៅដែលទាក់ទងនឹងការព្យួរទោសឱ្យបានច្រើន ។
- និស្សិត : ក្រៅពីក្រេបជញ្ជក់យកចំណេះហើយនោះនិស្សិតច្បាប់ទាំងឡាយគួរព្យាយាមជជែកពិភាក្សាដេញដោលគ្នា ដើម្បីបង្កើនពុទ្ធិឱ្យកាន់តែច្រើនមុននឹងយកទៅចែករំលែកបន្ត ។

- ប្រជាពលរដ្ឋ : សូមប្រជាពលរដ្ឋខ្មែរទាំងអស់ចូលរួម និងតាមដាននូវការអភិវឌ្ឍន៍ផ្នែកច្បាប់របស់ប្រទេសកម្ពុជាយើងឱ្យកាន់តែច្រើន ជាពិសេសការចូលរួមតាមសិក្ខាសាលានានាដែលពិភាក្សាគ្នាអំពីការព្យួរទោស ។

# ឯកសារយោង

# ឯកសារយោង

## ១. ច្បាប់ និងលិខិតបទដ្ឋានគតិយុត្តជាតិ និងអន្តរជាតិ

### ១.១.រដ្ឋធម្មនុញ្ញ

- រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ១៩៩៣

### ១.២.ច្បាប់

- ក្រមព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ២០០៩
- ក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី១០ ខែសីហា ឆ្នាំ២០០៧
- ក្រមនីតិរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី០៨ ខែធ្នូ ឆ្នាំ២០០៧
- ច្បាប់ស្តីពីពន្ធនាគារ ចុះថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០១១
- ច្បាប់ស្តីពីយុត្តិធម៌អនីតិជននៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី៣០ ខែឧសភា ឆ្នាំ២០១៦

### ១.៣.ព្រះរាជក្រឹត្យ

- ព្រះរាជក្រឹត្យស្តីពីការបន្ធូរបន្ថយទោស និងការលើកលែងទោសនៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី១២ ខែមករា ឆ្នាំ២០២១

### ១.៤.សារាចរ

- សារាចរ ស្តីពីការអនុវត្តបទប្បញ្ញត្តិ នៃការព្យួរទោសសាកល្បង ចុះថ្ងៃទី២២ ខែមករា ឆ្នាំ២០១៤

## ២. សៀវភៅ និងអត្ថបទផ្សេងៗ

- នីតិព្រហ្មទណ្ឌទូទៅ របស់លោកសាស្ត្រាចារ្យ **រុន ពណ្ណារិទ្ធិ** និងលោកស្រីសាស្ត្រាចារ្យ **ចាំង ស៊ីណាត** ឆ្នាំ២០២២
- សៀវភៅនីតិព្រហ្មទណ្ឌទូទៅ របស់លោកសាស្ត្រាចារ្យ **ហ៊ី សោភា**
- សៀវភៅនីតិព្រហ្មទណ្ឌទូទៅ របស់លោកសាស្ត្រាចារ្យ **សេង នាង**
- មេរៀននីតិព្រហ្មទណ្ឌទូទៅ របស់លោកសាស្ត្រាចារ្យ **ម៉ម ចាន់ណែត**
- សៀវភៅទោសព្រហ្មទណ្ឌ របស់លោកសាស្ត្រាចារ្យ **កៅ សីហា**
- មេរៀននីតិព្រហ្មទណ្ឌរៀបចំដោយផ្អែកលើអត្ថបទនៃសេចក្តីព្រាងក្រមព្រហ្មទណ្ឌ ចុះនៅខែធ្នូ ឆ្នាំ២០០៧
- វចនានុក្រមអេឡិចត្រូនិច សម្តេច **ជួន ណាត** ឆ្នាំ២០២២
- App អេឡិចត្រូនិច របស់តម្រាច្បាប់

## ៣. គេហទំព័រ និងប្រសាសន៍ផ្សេងៗ

### ៣.១.គេហទំព័រ

- https://wmc.org.kh/article (ចូលទស្សនាថ្ងៃទី២៩ ខែមេសា ឆ្នាំ២០២៤)

### ៣.២.ប្រសាសន៍ផ្សេងៗ

- ឯកឧត្តម **កើត រិទ្ធិ** (អនុប្រធានក្រុមការងារចូលរួមតាក់តែង និងការពារសេចក្តីព្រាងក្រមព្រហ្មទណ្ឌ), បទសម្ភាសន៍ដោយក្រសួងយុត្តិធម៌សហការជាមួយក្រសួងព័ត៌មានតាមរយៈទូរទស្សន៍ជាតិកម្ពុជា ចុះនៅឆ្នាំ២០១០
- ឯកឧត្តម **កើត រិទ្ធិ** ឯកឧត្តម **ប៊ុន ហុន** និងឯកឧត្តម **ផូវ សុភី** (ក្នុងកម្មវិធីផ្សព្វផ្សាយច្បាប់ស្តីពីក្រមព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា)

# ឧបសម្ព័ន្ធ

## បញ្ជីរាយនាមឧបសម្ព័ន្ធ

**ឧបសម្ព័ន្ធទី១ ៖** ក្រមព្រហ្មទណ្ឌ ឆ្នាំ២០០៩ នៃព្រះរាជាណាចក្រកម្ពុជា

**ឧបសម្ព័ន្ធទី២ ៖** សារាចរស្តីពីការអនុវត្តបទប្បញ្ញត្តិ នៃការព្យួរទោសសាកល្បង ចុះថ្ងៃទី២២ខែមករា ឆ្នាំ២០២១

**ឧបសម្ព័ន្ធទី៣ ៖** សារាចរ ស្តីពីការអនុវត្តបទប្បញ្ញត្តិ នៃការអនុវត្តទោសការងារសហគមន៍។

**ឧបសម្ព័ន្ធទី៤ ៖** សាលក្រមព្រហ្មទណ្ឌលេខៈ លេខ: ៧៣ "គ" ចុះថ្ងៃទី២៥ ខែមករា ឆ្នាំ២០២២ របស់សាលាដំបូងខេត្តកំពង់ស្ពឺ

**ឧបសម្ព័ន្ធទី៥ ៖** សាលដីកាព្រហ្មទណ្ឌលេខៈ១៦៧(ខ) ចុះថ្ងៃទី១៣ ខែមីនា ឆ្នាំ២០២៤របស់សាលាឧទ្ធរណ៍ភ្នំពេញ

**ឧបសម្ព័ន្ធទី៦ ៖** សាលដីកាព្រហ្មទណ្ឌលេខៈ៥១ "ក្រ.III.ច" ចុះថ្ងៃទី២៩ ខែមេសា ឆ្នាំ២០២៤របស់សាលាឧទ្ធរណ៍ភ្នំពេញ

**ឧបសម្ព័ន្ធទី៧ ៖** សាលក្រមព្រហ្មទណ្ឌ ចុះថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០២០របស់សាលាដំបូងរាជធានីភ្នំពេញ

**ឧបសម្ព័ន្ធទី៨ ៖** សាលដីកាព្រហ្មទណ្ឌលេខៈ៦០IV ចុះថ្ងៃទី១១ ខែមីនា ឆ្នាំ២០២០ របស់តុលាការកំពូល

**ឧបសម្ព័ន្ធទី៩ ៖** សាលដីកាព្រហ្មទណ្ឌលេខៈ៣៥១ I ចុះថ្ងៃទី២៩ ខែកក្កដា ឆ្នាំ២០២២របស់តុលាការកំពូល

# ឧបសម្ព័ន្ធទី១

**មាត្រា ៩៥.-** ទោសដាក់ពន្ធនាគារអស់មួយជីវិត និងស្ថានសម្រាលទោស

កាលណាបទល្មើសត្រូវបានផ្តន្ទាទោសដាក់ពន្ធនាគារអស់មួយជីវិត ចៅក្រមដែលផ្តល់ស្ថានសម្រាលទោស អាចប្រកាសទោសដាក់ពន្ធនាគារ ក្នុងចន្លោះរវាង ១៥ (ដប់ប្រាំ) និង ៣០ (សាមសិប) ឆ្នាំ ។

## ជំពូកទី ៣
## របបនៃការប្រកាសទោស
### ផ្នែកទី ១
### របបទូទៅ

**មាត្រា ៩៦.-** គោលការណ៍ឯកត្តកម្មនៃទោស

តុលាការប្រកាសទោសដោយផ្អែកទៅលើស្ថានទម្ងន់ និងកាលៈទេសៈនៃបទល្មើស ទៅលើបុគ្គលិកលក្ខណៈនៃជនជាប់ចោទ ទៅលើសភាពផ្លូវចិត្ត ទៅលើធនធាននិងបន្ទុក ទៅលើមូលហេតុ ព្រមទាំងទៅលើកិរិយាមារយាទរបស់ជនល្មើសក្រោយពេលប្រព្រឹត្តបទល្មើស ជាអាទិ៍ ចំពោះជនរងគ្រោះ ។

**មាត្រា ៩៧.-** ការប្រកាសមូលទោស

នៅក្នុងគ្រប់ករណីដែលបទល្មើសត្រូវបានផ្តន្ទាទោសដាក់ពន្ធនាគារផង និងពិន័យផង តុលាការអាចប្រកាស :

-ទោសដាក់ពន្ធនាគារ និងទោសពិន័យជាមួយគ្នា ឬ

-ទោសដាក់ពន្ធនាគារតែមួយមុខប៉ុណ្ណោះ ឬ

-ទោសពិន័យជាប្រាក់តែមួយមុខប៉ុណ្ណោះ ។

**មាត្រា ៩៨.-** ការប្រកាសទោសជំនួស

ទោសការងារសហគមន៍ជំនួសឱ្យមូលទោស ។ តុលាការដែលប្រកាសទោសការងារសហគមន៍នោះ មិនអាចប្រកាសទោសដាក់ពន្ធនាគារ ឬពិន័យជាប្រាក់បានទេ ។

ការស្តីបន្ទោសជំនួសឱ្យមូលទោស ។ តុលាការដែលប្រកាសការស្តីបន្ទោស មិនអាចប្រកាសទោសដាក់ពន្ធនាគារ ឬពិន័យជាប្រាក់បានទេ ។

**មាត្រា ៩៩.-** ការប្រកាសទោសបន្ថែមលើមូលទោស

កាលណាបទល្មើសមួយត្រូវផ្តន្ទាទោសដោយទោសបន្ថែមមួយឬច្រើន ទោសបន្ថែមនេះត្រូវបន្ថែមទៅលើមូលទោស លើកលែងតែបទប្បញ្ញត្តិនៃមាត្រា ១០០ (ការជំនួសមូលទោសដោយទោសបន្ថែម) នៃក្រមនេះ ចេញ ។

**មាត្រា ១០០.-** ការជំនួសមូលទោសដោយទោសបន្ថែម

តុលាការអាចសម្រេចជំនួសមូលទោសដោយទោសបន្ថែមមួយឬច្រើន នៅក្នុងករណីណាមួយដូចខាងក្រោម :

១-កាលណាជនជាប់ចោទទទួលទោសពិន័យក្នុងឋានៈជាមូលទោសតែមួយគត់ ។

២-កាលណាជនជាប់ចោទទទួលទោសដាក់ពន្ធនាគារដែលអតិបរមាស្មើ ឬតិចជាង ៣ (បី) ឆ្នាំ ។

កាលណាតុលាការសម្រេចជំនួសមូលទោសដោយទោសបន្ថែមមួយ ឬច្រើន តុលាការមិនអាចប្រកាសទោសដាក់ពន្ធនាគារ ឬទោសពិន័យជាប្រាក់បានទេ ។

**មាត្រា ១០១.-** វិធានដោយឡែកសម្រាប់ការប្រកាសទោសការងារសហគមន៍

ទោសការងារសហគមន៍នឹងអាចប្រកាសបាន លុះត្រាតែជនជាប់ចោទមានវត្តមាននៅពេលសវនាការ ហើយយល់ព្រមធ្វើការងារនេះ ។ តុលាការនៅមុនពេលប្រកាសសាលក្រម ឬសាលដីកា ត្រូវប្រាប់ជនជាប់ចោទថាសាមីខ្លួនមានសិទ្ធិប្រកែកមិនព្រមធ្វើការងារនេះ ។ ចម្លើយរបស់ជនជាប់ចោទ ត្រូវតែមានចុះនៅក្នុងសាលក្រម ឬសាលដីកា ។

**មាត្រា ១០២.-** ចិរវេលា និងអំឡុងពេលនៃការងារសហគមន៍

តុលាការដែលប្រកាសទោសការងារសហគមន៍ ត្រូវកំណត់អំពីចិរវេលានៃ

ការងារ និងរយៈពេលដែលត្រូវបំពេញ ។ រយៈពេលនេះមិនអាចលើសពី ១ (មួយ) ឆ្នាំ ទេ ។

**មាត្រា ១០៣.-** បែបបទនៃការអនុវត្តទោសការងារសហគមន៍

បែបបទនៃការអនុវត្តទោសការងារសហគមន៍ ត្រូវកំណត់ដោយព្រះរាជអាជ្ញា ។

ព្រះរាជអាជ្ញាចង្អុលប្រាប់ឈ្មោះនីតិបុគ្គល ដែលត្រូវទទួលអត្ថប្រយោជន៍ពីការងារនេះ ។

ទោសនេះត្រូវអនុវត្តនៅក្រោមការត្រួតពិនិត្យរបស់ព្រះរាជអាជ្ញា ។

## ផ្នែកទី ២

## ការព្យួរទោសធម្មតា

### កថាភាគទី ១

### បទប្បញ្ញត្តិរួម

**មាត្រា ១០៤.-** ការប្រកាសការព្យួរទោស

នៅក្នុងលក្ខខណ្ឌដែលមានចែងនៅក្នុងផ្នែកនេះ តុលាការអាចបង្គាប់ថា ត្រូវព្យួរការអនុវត្តនូវមូលទោស ។

**មាត្រា ១០៥.-** របបនៃការព្យួរទោស

ដើម្បីអនុវត្តបទប្បញ្ញត្តិស្ដីពីការព្យួរទោស ត្រូវគិតតែអំពីការផ្ដន្ទាទោសជាស្ថាពរខាងបណ្ដឹងអាជ្ញាប៉ុណ្ណោះ ។

### កថាភាគទី ២

### ការចោទប្រកាន់ចំពោះបទឧក្រិដ្ឋ ឬបទមជ្ឈិម

**មាត្រា ១០៦.-** លក្ខខណ្ឌទាក់ទងនឹងការផ្ដន្ទាទោសពីមុន

ក្នុងករណីដែលមានការចោទប្រកាន់ពីបទឧក្រិដ្ឋ ឬបទមជ្ឈិមនោះ ការព្យួរទោសធម្មតាអាចត្រូវផ្ដល់ឱ្យបាន ប្រសិនបើជនជាប់ចោទមិនទាន់មានការផ្ដន្ទាទោស

ជាស្ថាពរឱ្យជាប់ពន្ធនាគារក្នុងរយៈពេល ៥ (ប្រាំ) ឆ្នាំ មុនអំពើល្មើស ។

**មាត្រា ១០៧.-** ទោសអាចនាំឱ្យមានការព្យួរទោស

ការព្យួរទោសធម្មតា ត្រូវអនុវត្តទៅលើទោសដូចតទៅ :

១-ទោសដាក់ពន្ធនាគារ កាលបើទោសដែលប្រកាសនោះតិចជាង ឬស្មើនឹង ៥ (ប្រាំ) ឆ្នាំ ។

២-ទោសពិន័យជាប្រាក់ ។

**មាត្រា ១០៨.-** ការព្យួរទោសមួយផ្នែក

តុលាការអាចសម្រេចថា ការព្យួរទោសធម្មតានេះអាចនឹងអនុវត្តទៅលើមួយផ្នែកនៃទោសពន្ធនាគារ ដែលតុលាការជាអ្នកកំណត់ចិរវេលា ឬលើមួយផ្នែកនៃប្រាក់ពិន័យដែលតុលាការជាអ្នកកំណត់ចំនួនទឹកប្រាក់ ។

**មាត្រា ១០៩.-** ការដកហូតការព្យួរទោស

ប្រសិនបើក្នុងរយៈពេល ៥ (ប្រាំ) ឆ្នាំ បន្ទាប់ពីការផ្តន្ទាទោសជាស្ថាពរពីបទឧក្រិដ្ឋ ឬបទមជ្ឈិម ដោយមានការព្យួរទោសធម្មតា ហើយមានការផ្តន្ទាទោសថ្មីជាស្ថាពរមួយទៀតពីបទឧក្រិដ្ឋ ឬបទមជ្ឈិម ការព្យួរទោសធម្មតានេះ ត្រូវដកហូតចេញដោយពេញច្បាប់ ។

ទោសទី ១ ត្រូវអនុវត្តដោយមិនអាចស្រូបចូលជាមួយទោសទី ២ បានឡើយ ។

**មាត្រា ១១០.-** ការមិនដកហូតការព្យួរទោស

ជាបដិប្បញ្ញត្តិទៅនឹងមាត្រា ១០៩ (ការដកហូតការព្យួរទោស) នៃក្រមនេះ តុលាការអាចសម្រេចថា ការផ្តន្ទាទោសថ្មីមិននាំឱ្យមានការដកហូតនូវការព្យួរទោសធម្មតាដែលបានសម្រេចពីមុននោះទេ។ សេចក្តីសម្រេចរបស់តុលាការត្រូវតែមានសំអាងហេតុជាពិសេស ។

**មាត្រា ១១១.-** ការទុកជាអសារបង់នូវការផ្តន្ទាទោស

ប្រសិនបើរយៈពេល ៥ (ប្រាំ) ឆ្នាំ បន្ទាប់ពីការផ្តន្ទាទោសជាស្ថាពរពីបទឧក្រិដ្ឋ

ឬបទមជ្ឈិម ដោយមានការព្យួរទោសធម្មតា ហើយគ្មានការផ្តន្ទាទោសថ្មីជាស្ថាពរមួយទៀត ពីបទឧក្រិដ្ឋ ឬបទមជ្ឈិមនោះទេ ការផ្តន្ទាទោសដោយមានព្យួរនេះត្រូវចាត់ទុកថាជាអសារបង់ ។ ទោសក៏មិនអាចយកមកអនុវត្តបានទៀតឡើយ ។

កាលណាបើការព្យួរទោសត្រូវបានប្រកាសទៅលើតែផ្នែកមួយនៃទោសនោះ ការផ្តន្ទាទោសត្រូវចាត់ទុកជាអសារបង់ទាំងស្រុង ។ ទោសក៏មិនអាចយកមកអនុវត្តបានទៀតឡើយ ។

## កថាភាគទី ៣
## ការចោទប្រកាន់ចំពោះបទលហុ

**មាត្រា ១១២.-** លក្ខខណ្ឌទាក់ទងទៅនឹងការផ្តន្ទាទោសពីមុន

ក្នុងករណីចោទប្រកាន់ពីបទលហុ ការព្យួរទោសធម្មតាអាចត្រូវបានប្រកាសប្រសិនបើជនជាប់ចោទ មិនទាន់ត្រូវបានផ្តន្ទាទោសដាក់ពន្ធនាគារជាស្ថាពរនៅឡើយនៅក្នុងរយៈពេល ១ (មួយ) ឆ្នាំ មុនបទល្មើសនេះ ។

**មាត្រា ១១៣.-** ទោសអាចនាំឱ្យមានការព្យួរទោស

ក្នុងករណីចោទប្រកាន់ពីបទលហុ ការព្យួរទោសធម្មតាត្រូវអនុវត្តទៅលើទោសដូចតទៅនេះ :

១-ទោសដាក់ពន្ធនាគារ ។

២-ទោសពិន័យជាប្រាក់ ។

**មាត្រា ១១៤.-** ការដកហូតការព្យួរទោស

ប្រសិនបើក្នុងរយៈពេល ១ (មួយ) ឆ្នាំ ក្រោយការផ្តន្ទាទោសជាស្ថាពរពីបទលហុដោយមានការព្យួរទោសធម្មតាផង រួចកើតមានការផ្តន្ទាទោសថ្មីជាស្ថាពរពីបទឧក្រិដ្ឋ បទមជ្ឈិម ឬបទលហុ ការព្យួរទោសធម្មតានេះ ត្រូវដកហូតចេញដោយពេញច្បាប់។ ទោសទី ១ ត្រូវអនុវត្តដោយគ្មានស្រួបជាមួយទោសទី ២ ឡើយ ។

### មាត្រា ១១៥.- ការមិនដកហូតការព្យួរទោស

ជាបដិប្បញ្ញត្តិនៃមាត្រា ១១៤ (ការដកហូតការព្យួរទោស) នៃក្រមនេះ តុលាការអាចសម្រេចថា ការផ្តន្ទាទោសថ្មីមិនអាចនាំឱ្យមានការដកហូតនូវការព្យួរទោសធម្មតានេះដែលសម្រេចពីមុននោះទេ។ សេចក្តីសម្រេចនេះត្រូវតែមានសំអាងហេតុជាពិសេស។

### មាត្រា ១១៦.- ការចាត់ទុកជាអសារបង់នូវការផ្តន្ទាទោស

ប្រសិនបើក្នុងរយៈពេល ១ (មួយ) ឆ្នាំ បន្ទាប់ពីការផ្តន្ទាទោសជាស្ថាពរពីបទលហុដែលមានការព្យួរទោសធម្មតា គ្មានការផ្តន្ទាទោសថ្មីណាមួយបានកើតឡើងពីបទឧក្រិដ្ឋ បទមជ្ឈិម ឬបទលហុ ការផ្តន្ទាទោសដែលព្យួរនោះ ត្រូវទុកជាអសារបង់ ។ ទោសក៏មិនអាចយកមកអនុវត្តបានទៀតឡើយ ។

## ផ្នែកទី ៣
## ការព្យួរទោសសាកល្បង

### មាត្រា ១១៧.- និយមន័យ និងលក្ខខណ្ឌនៃការព្យួរទោសសាកល្បង

តុលាការអាចសម្រេចព្យួរសាកល្បងនូវទោសដែលបានសម្រេចដាក់ពន្ធនាគារដែលមានរយៈពេលពី ៦ (ប្រាំមួយ) ខែ ទៅ ៥ (ប្រាំ) ឆ្នាំ ។

ការព្យួរទោសសាកល្បង មានអានុភាពដាក់ឱ្យទណ្ឌិតស្ថិតនៅក្រោមវិធានការត្រួតពិនិត្យ និងគោរពនូវកាតព្វកិច្ចដោយឡែកមួយ ឬច្រើនក្នុងរយៈពេលសាកល្បង ។

### មាត្រា ១១៨.- រយៈពេលនៃការសាកល្បង

តុលាការកំណត់រយៈពេលនៃការសាកល្បង។ រយៈពេលនេះមិនអាចតិចជាង ១ (មួយ) ឆ្នាំ និងមិនលើសពី ៣ (បី) ឆ្នាំ ទេ ។

### មាត្រា ១១៩.- វិធានការត្រួតពិនិត្យ

វិធានការត្រួតពិនិត្យដែលតម្រូវទៅលើទណ្ឌិត មានដូចតទៅ :

១-ទណ្ឌិតត្រូវតែគោរពតាមដីកាកោះរបស់ព្រះរាជអាជ្ញា ឬរបស់បុគ្គលដែល

ព្រះរាជអាជ្ញាបានប្រគល់អំណាចឱ្យ ។

២-ទណ្ឌិតត្រូវមកទទួលនូវការមកពិនិត្យមើលរបស់បុគ្គលដែលព្រះរាជអាជ្ញាបានប្រគល់អំណាចឱ្យ ។

៣-ទណ្ឌិតត្រូវប្រគល់ដល់ព្រះរាជអាជ្ញា ឬដល់បុគ្គលដែលព្រះរាជអាជ្ញាបានប្រគល់អំណាចឱ្យ នូវគ្រប់ឯកសារសម្រាប់ធ្វើការផ្ទៀងផ្ទាត់លើការបញ្ចូលឱ្យទៅរស់នៅក្នុងសង្គមវិញ ។

៤-ទណ្ឌិតត្រូវជូនដំណឹងដល់ព្រះរាជអាជ្ញា អំពីការផ្លាស់ប្តូរអាសយដ្ឋានរបស់ខ្លួន ។

៥-ទណ្ឌិតត្រូវជូនដំណឹងដល់ព្រះរាជអាជ្ញា អំពីការផ្លាស់ប្តូរមុខរបររបស់ខ្លួន ។

៦-ទណ្ឌិតត្រូវតែមានការអនុញ្ញាតពីព្រះរាជអាជ្ញា មុនពេលធ្វើដំណើរទៅបរទេស ។

**មាត្រា ១២០.-** កាតព្វកិច្ចដោយឡែកដែលអាចដាក់ទៅលើទណ្ឌិត

កាតព្វកិច្ចដោយឡែកដែលអាចតម្រូវទៅលើទណ្ឌិតមានដូចតទៅ :

១-បំពេញសកម្មភាពខាងវិជ្ជាជីវៈ ។

២-ទទួលការបង្ហាត់បង្រៀន ឬទទួលការបណ្តុះបណ្តាលវិជ្ជាជីវៈ ។

៣-រស់នៅក្នុងទីកន្លែងណាមួយជាកំណត់ ។

៤-ទទួលឱ្យពេទ្យធ្វើការពិនិត្យ ឬការព្យាបាល ។

៥-បញ្ជាក់ថាខ្លួនរួមចំណែកក្នុងការចិញ្ចឹមបីបាច់គ្រួសារ ។

៦-ធ្វើការជួសជុលការខូចខាតដែលបណ្តាលមកពីបទល្មើស តាមលទ្ធភាពនៃធនធានរបស់ខ្លួន ។

៧-បញ្ជាក់ថាខ្លួនបានបង់ប្រាក់ជូនរដ្ឋបន្ទាប់ពីការផ្តន្ទាទោស តាមលទ្ធភាពធនធានរបស់ខ្លួន ។

៨-មិនត្រូវធ្វើសកម្មភាពខាងវិជ្ជាជីវៈឬសង្គមដែលអនុញ្ញាត ឬសម្រួលដល់ការប្រព្រឹត្តបទល្មើស។ ក្នុងករណីនេះ តុលាការបញ្ជាក់អំពីសកម្មភាពដែលហាមឃាត់ ។

៩-មិនត្រូវមានមុខនៅទីកន្លែងខ្លះ។ ក្នុងករណីនេះ តុលាការបញ្ជាក់អំពីទីកន្លែងដែលហាមឃាត់ ។

១០-មិនត្រូវសេពគប់បនល្បែង ។

១១-មិនត្រូវសេពគប់គ្រឿងភេសជ្ជៈស្រវឹង ។

១២-មិនត្រូវសេពគប់ជាមួយបុគ្គលខ្លះ ពិសេស ចារី សហចារី អ្នកផ្ដើមគំនិត អ្នកសមគំនិត ឬជនរងគ្រោះនៃបទល្មើស។ ក្នុងករណីនេះ តុលាការបញ្ជាក់អំពីបុគ្គលដែលមិនត្រូវសេពគប់ជាមួយ ។

១៣-មិនត្រូវកាន់កាប់ ឬយកតាមខ្លួននូវអាវុធ គ្រឿងផ្ទុះ និងគ្រាប់រំសេវគ្រប់ប្រភេទ ។

នៅក្នុងសេចក្ដីសម្រេចរបស់ខ្លួន តុលាការត្រូវចែងអំពីកាតព្វកិច្ចដោយឡែកដែលតម្រូវទៅលើទណ្ឌិត ។

## មាត្រា ១២១.- ការកែប្រែកាតព្វកិច្ចដោយឡែកដោយយុត្តាធិការ

នៅគ្រប់ពេលវេលា តុលាការអាចកែប្រែកាតព្វកិច្ចដោយឡែកដែលតម្រូវលើទណ្ឌិតបាន ។

តុលាការត្រូវបានទទួលបណ្ដឹងនៅក្នុងលក្ខខណ្ឌដែលបានចែងដោយក្រមនីតិវិធីព្រហ្មទណ្ឌ ។

## មាត្រា ១២២.- ការដកហូតការព្យួរទោសសាកល្បង

ការព្យួរទោសសាកល្បងអាចត្រូវដកហូតដោយតុលាការ នៅក្នុងករណីដូចខាងក្រោមនេះ :

១-ប្រសិនបើក្នុងរយៈពេលសាកល្បង ទណ្ឌិតមិនគោរពតាមវិធានការត្រួតពិនិត្យ ឬកាតព្វកិច្ចដោយឡែកទេ ។

២-ប្រសិនបើក្នុងរយៈពេលសាកល្បង ទណ្ឌិតត្រូវបានផ្ដន្ទាទោសពីបទឧក្រិដ្ឋ ឬបទមជ្ឈិមជាថ្មីទៀត ។

តុលាការអាចបង្គាប់ឱ្យដកហូតការព្យួរទោសសាកល្បងនេះទាំងមូល ឬមួយផ្នែក ។ នៅក្នុងករណីនេះ ទោសត្រូវយកមកអនុវត្តទាំងមូល ឬមួយផ្នែក ។

តុលាការត្រូវបានទទួលបណ្តឹងនៅក្នុងលក្ខខណ្ឌដែលមានចែងដោយក្រមនីតិវិធីព្រហ្មទណ្ឌ ។

**មាត្រា ១២៣.-** ការផ្តន្ទាទោសដែលត្រូវចាត់ទុកជាអសារបង់

ការផ្តន្ទាទោសត្រូវចាត់ទុកជាអសារបង់ ប្រសិនបើមុនការផុតរយៈពេលសាកល្បង ការផ្តន្ទាទោសមិនមែនជាកម្មវត្ថុនៃពាក្យសុំដកហូតដែលមានសេចក្តីសម្រេចដកហូតទេ ។

## ផ្នែកទី ៤
## ការផ្អាកការប្រកាសទោស

**មាត្រា ១២៤.-** លក្ខខណ្ឌនៃការផ្អាកការប្រកាសទោស

ក្នុងករណីចោទប្រកាន់ពីបទមជ្ឈិម តុលាការក្រោយពីបានប្រកាសថា ជនជាប់ចោទមានពិរុទ្ធ អាចផ្អាកការប្រកាសទោស ប្រសិនបើលក្ខខណ្ឌដូចតទៅនេះ ត្រូវបានបំពេញ :

-ភាពច្របូកច្របល់នៃសណ្តាប់ធ្នាប់សាធារណៈ ដែលបង្កឡើងដោយបទល្មើសត្រូវបានបញ្ឈប់

-ជនជាប់ចោទបានបង្ហាញការធានាក្នុងការចូលទៅរួមរស់នៅក្នុងសង្គមវិញ និង

-ជនជាប់ចោទសុំរយៈពេលដើម្បីជួសជុលការខូចខាត ។

**មាត្រា ១២៥.-** សេចក្តីសម្រេចនៃការផ្អាកការប្រកាសទោស

ការផ្អាកការប្រកាសទោសអាចត្រូវបង្គាប់បាន លុះត្រាតែជនជាប់ចោទមានវត្តមានក្នុងសវនាការ ។

តុលាការកំណត់នៅក្នុងសាលក្រម ឬសាលដីកានូវកាលបរិច្ឆេទដែលត្រូវសម្រេចអំពីទោស ។

សេចក្តីសម្រេចអំពីទោសត្រូវតែធ្វើឡើងយ៉ាងយូរបំផុត ១ (មួយ) ឆ្នាំ ក្រោយសេចក្តីសម្រេចផ្អាក ។

# ឧបសម្ព័ន្ធទី២

# ព្រះរាជាណាចក្រកម្ពុជា

**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងយុត្តិធម៌**

**លេខ :** ០២ កយណ.សរ/១៤

# សារាចរ
## ស្តីពី
## ការអនុវត្តបទប្បញ្ញត្តិ នៃការព្យួរទោសសាកល្បង

ក្រសួងយុត្តិធម៌បានកត់សម្គាល់ឃើញថា បទប្បញ្ញត្តិ និងគោលការណ៍ស្តីពីការអនុវត្តរបបនៃការព្យួរទោសសាកល្បង ដែលមានចែងនៅក្នុងក្រមព្រហ្មទណ្ឌចាប់ពីមាត្រា ១១៧ ដល់ មាត្រា ១២៣ និងមាត្រា ១៦៥ មិនទាន់អនុវត្តឲ្យបានគ្រប់ជ្រុងជ្រោយនៅឡើយ ដែលជាហេតុធ្វើឲ្យការអនុវត្តនៃការព្យួរទោសសាកល្បង មិនទាន់បានល្អប្រសើរ។

ដើម្បីអនុវត្តបទប្បញ្ញត្តិ និងគោលការណ៍ទាំងនេះឲ្យមានប្រសិទ្ធភាព ក្រសួងយុត្តិធម៌សូមធ្វើការណែនាំដូចខាងក្រោម ៖

### ក-ចៅក្រមជំនុំជម្រះ

១-យោងតាមមាត្រា ១១៧ នៃក្រមព្រហ្មទណ្ឌ ចៅក្រមគប្បីត្រូវពិចារណាសម្រេចព្យួរសាកល្បងនៃទោស ឲ្យបានជាអតិបរិមានូវទោស ដែលបានសម្រេចដាក់ពន្ធនាគារ ក្នុងបទល្មើសមជ្ឈិម។

២-តុលាការត្រូវចេញសម្រង់សាលក្រមស្លារពរចំនួនបីច្បាប់។ ចំនួនពីរច្បាប់ប្រគល់ជូនព្រះរាជអាជ្ញា និងមួយច្បាប់ទៀតប្រគល់ឲ្យទៅទណ្ឌិតដើម្បីអនុវត្ត។

### ខ-ព្រះរាជអាជ្ញា

១-ត្រូវដឹកនាំសម្របសម្រួល ការអនុវត្តសេចក្តីសម្រេចព្យួរទោសសាកល្បងរបស់តុលាការគ្រប់ជាន់ថ្នាក់ ឲ្យមានប្រសិទ្ធភាព។

២-ត្រូវចាត់តាំងបុគ្គលនៅក្នុងមូលដ្ឋានដែលទណ្ឌិតរស់នៅ ឬ បំពេញកាតព្វកិច្ច ឲ្យតាមដានសកម្មភាពរបស់ទណ្ឌិត។ បុគ្គលដែលគប្បីចាត់តាំង ដូចជានគរបាលប៉ុស្តិ៍រដ្ឋបាល សមាជិកក្រុមប្រឹក្សាឃុំ-សង្កាត់ មន្ត្រីទទួលបន្ទុកអប់រំ និងស្មារនីតិសម្បទា...។

៣-ត្រូវបង្គាប់ណែនាំដល់ទណ្ឌិត ឲ្យទៅបង្ហាញខ្លួននៅចំពោះមុខបុគ្គលដែលត្រូវបានចាត់តាំងឲ្យតាមដាន។

៤-ត្រូវប្រគល់សម្រង់សាលក្រម ឬ សម្រង់សាលដីកាស្ថាពរដល់បុគ្គលដែលត្រូវបាន ចាត់តាំងឲ្យតាមដានទណ្ឌិត និងធ្វើការដឹកនាំសម្របសម្រួលការអនុវត្ត។

៥-ក្នុងករណីចាំបាច់ ត្រូវបង្គាប់ទៅអង្គភាពនគរបាលយុត្តិធម៌ ឲ្យចាត់វិធានការជួយតាមដានរាល់សកម្មភាពរបស់ទណ្ឌិត និងត្រូវធ្វើរបាយការណ៍តាមការកំណត់ ពីការកត់សម្គាល់ឃើញរបស់ខ្លួនចំពោះសកម្មភាពរបស់ទណ្ឌិតជូនទៅព្រះរាជអាជ្ញា ដើម្បីស្នើសុំយោបល់ ឬ ចាត់វិធានការ។

សូមលោក លោកស្រី ជាចៅក្រម ព្រះរាជអាជ្ញា គ្រប់ស្ថាប័នតុលាការ និងអយ្យការ ត្រូវអនុវត្តសារាចរនេះឲ្យមានប្រសិទ្ធភាព ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ។

រាជធានីភ្នំពេញ, ថ្ងៃទី..២២...ខែមករា.. ឆ្នាំ..២០១៤...

**រដ្ឋមន្ត្រី**

អង្គ វង្សវឌ្ឍនា

ចម្លងជូន ៖
- ទីស្ដីការគណៈរដ្ឋមន្ត្រី
- ក្រសួងមហាផ្ទៃ
- ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា
- ខុទ្ទកាល័យនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី
- តុលាការ និងមហាអយ្យការអមតុលាការកំពូល
- សាលាឧទ្ធរណ៍ និងមហាអយ្យការអមសាលាឧទ្ធរណ៍
- សាលាដំបូង និងអយ្យការអមសាលាដំបូងរាជធានី-ខេត្ត
- ឯកសារ-កាលប្បវត្តិ

# ឧបសម្ព័ន្ធទី៣

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងយុត្តិធម៌**

លេខ : ០៣ កយ.សរ./១៤

**សារាចរ**

**ស្តីពី**

**ការអនុវត្តបទប្បញ្ញត្តិនៃ ការអនុវត្តទោសការងារសហគមន៍**

ក្រសួងយុត្តិធម៌បានកត់សម្គាល់ឃើញថា បទប្បញ្ញត្តិ និងគោលការណ៍ស្តីពីការអនុវត្តទោសការងារសហគមន៍ ដែលមានចែងនៅក្នុងក្រមព្រហ្មទណ្ឌចាប់ពីមាត្រា ៧២ ដល់មាត្រា ៧៥ មាត្រា ៩៨ មាត្រា ១០១ ដល់ ១០៣ និងមាត្រា ១៦២ មិនទាន់អនុវត្តបានគ្រប់ជ្រុងជ្រោយនៅឡើយ ដែលជាហេតុធ្វើឲ្យការអនុវត្តទោសការងារសហគមន៍ មិនទាន់មានប្រសិទ្ធិភាព និងមិនទាន់មានភាពរលូន។

ដើម្បីធានាការអនុវត្តបទប្បញ្ញត្តិ និងគោលការណ៍ទាំងនេះឲ្យមានប្រសិទ្ធភាព ក្រសួងយុត្តិធម៌សូមធ្វើការណែនាំដូចខាងក្រោម ៖

**ក-ចៅក្រមជំនុំជម្រះ**

១-គប្បីធានាឲ្យបាននូវការអនុវត្តតាមបទប្បញ្ញត្តិ និងគោលការណ៍ដែលមានចែងក្នុងក្រមព្រហ្មទណ្ឌស្តីពីទោសការងារសហគមន៍ ចំពោះទណ្ឌិតណាដែលតុលាការប្រកាសទោសដាក់ពន្ធនាគារតិចជាង ឬស្មើ ៣ (បី) ឆ្នាំ ។

២-តុលាការត្រូវប្រគល់សម្រង់សាលក្រម ជូនព្រះរាជអាជ្ញាមួយច្បាប់ និងប្រគល់ឲ្យទៅទណ្ឌិតមួយច្បាប់។

**ខ-ព្រះរាជអាជ្ញា**

១-ត្រូវសហការជាមួយអង្គការរដ្ឋ សមាគមន៍ ឬអង្គការមិនមែនរដ្ឋាភិបាល ដើម្បីកសាង និងធ្វើបច្ចុប្បន្នភាពបញ្ជីឈ្មោះនីតិបុគ្គល និងប្រភេទការងារ ដែលមានតម្រូវការផ្តល់ការងារឲ្យទណ្ឌិតធ្វើ។ បញ្ជីនេះត្រូវដាក់បង្ហាញជូនតុលាការដើម្បីជ្រើសរើសការងារ ឲ្យទណ្ឌិតដែលយល់ព្រមទទួលយក។

២-ការផ្តល់ការងារសហគមន៍ដល់អនីតិជន ត្រូវពិភាក្សាបន្ថែមជាមួយមន្ត្រីសង្គមកិច្ចអំពីការងារដែលមានលក្ខណៈជាការងារបណ្តុះបណ្តាល និងសម្រួលដល់ការបញ្ចូលខ្លួនទៅរស់នៅក្នុងសង្គមវិញ។

៣-ត្រូវរៀបចំបែបបទនៃការអនុវត្តទោសការងារសហគមន៍ សម្រាប់នីតិបុគ្គលដែលទទួលទណ្ឌិតឲ្យធ្វើការងារ ដោយឲ្យនីតិបុគ្គលនោះ បំពេញនូវកាតព្វកិច្ចដូចតទៅ ៖

-ណែនាំដល់ទណ្ឌិតអំពីការបំពេញកាតព្វកិច្ច និងអប់រំទណ្ឌិតឲ្យយកចិត្តទុកដាក់ក្នុងការកសាងខ្លួនចូលក្នុងសង្គមវិញ

-គ្រប់គ្រងតាមដានសកម្មភាពរបស់ទណ្ឌិត ក្នុងពេលបំពេញកាតព្វកិច្ច

-ធ្វើរបាយការណ៍អំពីសកម្មភាពរបស់ទណ្ឌិតជូនដល់ព្រះរាជអាជ្ញា

-ត្រូវចុះហត្ថលេខាលើកំណត់ហេតុទទួលស្គាល់ អំពីការអនុវត្តការងាររបស់ទណ្ឌិត

៤-ត្រូវយកចិត្តទុកដាក់តាមដានត្រួតពិនិត្យការអនុវត្តការងាររបស់ទណ្ឌិតដែលមានដូចខាងក្រោម ៖

-គ្រប់គ្រង តាមដាន រក្សាទុករបាយការណ៍ កំណត់ហេតុអំពីការអនុវត្តការងារសហគមន៍

-តាមដានការអនុវត្តរបស់ទណ្ឌិតទៅតាមលក្ខខណ្ឌរបស់សាលក្រម

-ណែនាំទណ្ឌិតអំពីការអនុវត្តការងារសហគមន៍ និងកាតព្វកិច្ចដែលត្រូវអនុវត្ត

-ណែនាំដល់នីតិបុគ្គលដែលទទួលទណ្ឌិត អំពីបែបបទអនុវត្តការងារគ្រប់គ្រង

-ចេញដីកាសម្រេចបញ្ចប់ការអនុវត្តទោសរបស់ទណ្ឌិត ដែលបានអនុវត្តទោសការងារសហគមន៍ដោយជោគជ័យ។

សូមលោក លោកស្រី ជាចៅក្រម ព្រះរាជអាជ្ញា គ្រប់ស្ថាប័នតុលាការ និងអយ្យការ ត្រូវអនុវត្តសារាចរនេះឲ្យមានប្រសិទ្ធភាព ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ។

រាជធានីភ្នំពេញ, ថ្ងៃទី...២៧...ខែមករា.. ឆ្នាំ...២០១៤

**រដ្ឋមន្ត្រី**

អង្គ វង្សវឌ្ឍនៈ

<u>ចម្លងជូន</u> ៖

-ទីស្តីការគណៈរដ្ឋមន្ត្រី

-ក្រសួងមហាផ្ទៃ

-ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា

-ខុទ្ទកាល័យនាយករដ្ឋមន្ត្រី

ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី

-តុលាការ និងមហាអយ្យការអមតុលាការកំពូល

-សាលាឧទ្ធរណ៍ និងមហាអយ្យការអមសាលាឧទ្ធរណ៍

-សាលាដំបូង និងអយ្យការអមសាលាដំបូងរាជធានី-ខេត្ត

-ឯកសារ-កាលប្បវត្តិ

# ឧបសម្ព័ន្ធទី៤

38/8

# ព្រះរាជាណាចក្រកម្ពុជា

## ជាតិ សាសនា ព្រះមហាក្សត្រ

សាលាដំបូងខេត្តកំពង់ស្ពឺ
សំណុំរឿងព្រហ្មទណ្ឌលេខ ៣៣២
ចុះថ្ងៃទី ១២ ខែ មីនា ឆ្នាំ ២០២១
សាលក្រមព្រហ្មទណ្ឌលេខ ៧៣ "គ"
ចុះថ្ងៃទី ២៥ ខែ មករា ឆ្នាំ ២០២២

## គោចនាមប្រជារាស្ត្រខ្មែរ

## សាលាដំបូងខេត្តកំពង់ស្ពឺ

បានបើកសវនាការជាសាធារណៈ នៅសាលាដំបូងខេត្តកំពង់ស្ពឺ ។
កាលបរិច្ឆេទបើកសវនាការ ថ្ងៃទី២០ ខែធ្នូ ឆ្នាំ២០២១ ពេលព្រឹក ។
កាលបរិច្ឆេទប្រកាសសាលក្រម ថ្ងៃទី២៥ ខែមករា ឆ្នាំ២០២២ ពេលរសៀល ។

### ចៅក្រមជំនុំជម្រះ

លោក អនុប្រធាន និង ជាក្រមសាលាដំបូងខេត្តកំពង់ស្ពឺ

### តំណាងអយ្យការ

លោក ព្រះរាជអាជ្ញារង នៃអយ្យការសាលាដំបូងខេត្តកំពង់ស្ពឺ

### ក្រឡាបញ្ជីសវនាការ

លោក ក្រឡាបញ្ជីសាលាដំបូងខេត្តកំពង់ស្ពឺ

### ដើម្បីជំនុំជម្រះ

លើសំណុំរឿងព្រហ្មទណ្ឌលេខ ៣៣២ ចុះថ្ងៃទី១២ ខែមីនា ឆ្នាំ២០២១ ដែលមានជនជាប់ចោទ៖

-ឈ្មោះ ភេទប្រុស អាយុ ៣៣ឆ្នាំ ជាតិខ្មែរ កើតនៅភូមិភ្នំលន្ទះ ឃុំអង្គប្រាសាទ ស្រុកគិរីវង្ស ខេត្តតាកែវ អាសយដ្ឋានបច្ចុប្បន្ននៅភូមិភ្នំលន្ទះ ឃុំអង្គប្រាសាទ ស្រុកគិរីវង្ស ខេត្តតាកែវ ឪពុកឈ្មោះ "រស់" ម្តាយឈ្មោះ "ស្លាប់" នៅលីវ ទោសពីមុនគ្មាន ។

ជាប់ចោទពីបទ បើកបរដោយធ្វេសប្រហែស ខ្ជីខ្ជា មិនប្រុងប្រយ័ត្នបណ្តាលឱ្យរបួសអ្នកដទៃ តាមមាត្រា ៨៣ នៃច្បាប់ស្តីពីចរាចរណ៍ផ្លូវគោក ប្រព្រឹត្តនៅភូមិចំបក់ ឃុំវល្លិស ស្រុកសំរោងទង ខេត្តកំពង់ស្ពឺ កាលពីថ្ងៃទី១២ ខែកុម្ភៈ ឆ្នាំ២០២១ ។

### ដើមបណ្តឹងរដ្ឋប្បវេណី

១-ឈ្មោះ ភេទប្រុស អាយុ ៥៧ឆ្នាំ ជនជាតិ អាឡឺម៉ង់ អាសយដ្ឋានបច្ចុប្បន្ននៅអគារមេគង្គវិយូ២ សង្កាត់ជ្រោយចង្វារ ខណ្ឌជ្រោយចង្វារ រាជធានីភ្នំពេញ ។

មានលោក សេង ឡាយ អត្តលេខ ៧២០ និងលោក សាន សំរួល អត្តលេខ ១៦៥៦ ជាមេធាវីការពារសិទ្ធិ ។

២-ឈ្មោះ ភេទប្រុស អាយុ ៣៩ឆ្នាំ ជាតិខ្មែរ អាសយដ្ឋានបច្ចុប្បន្ននៅភូមិត្បែស ឃុំវល្លិស ស្រុកសំរោងទង ខេត្តកំពង់ស្ពឺ ។

### អ្នកទទួលខុសត្រូវរដ្ឋប្បវេណី

-ឈ្មោះ ភេទស្រី អាយុ ៣៩ឆ្នាំ ជាតិខ្មែរ ម្ចាស់រថយន្តម៉ាក FUSO ពណ៌[illegible] ពាក់ផ្លាកលេខ ភ្នំពេញ 3E-3936 សណ្តោងរ៉ឺម៉ក អាសយដ្ឋានបច្ចុប្បន្ននៅភូមិភូមិ៣ សង្កាត់ទួលទំពូងទី[illegible] ខណ្ឌចំការមន រាជធានីភ្នំពេញ ។

មានលោក សាយ មុន្នី អត្តលេខ ១៨៩៧ និងលោកស្រី តេនៈ មុន្នីនាថ ជាមេធាវីការពារសិទ្ធិ ។

-បានឃើញ របាយការណ៍សំយោគលេខ ៦៧/២១ ចុះថ្ងៃទី០៥ ខែមីនា ឆ្នាំ២០២១ របស់ការិយាល័យនគរបាលចរាចរណ៍ផ្លូវគោក នៃស្នងការដ្ឋាននគរបាលខេត្តកំពង់ស្ពឺ ។

-បានឃើញ ដីកាសន្និដ្ឋានស្ថាពរលេខ ៨២៦៩ ចុះថ្ងៃទី១៤ ខែកញ្ញា ឆ្នាំ២០២១ របស់តំណាងអយ្យការអមសាលាដំបូងខេត្តកំពង់ស្ពឺ ។

-បានឃើញ ដីកាដំណោះស្រាយលេខ ៦២៨ ចុះថ្ងៃទី១៦ ខែកញ្ញា ឆ្នាំ២០២១ របស់ចៅក្រមស៊ើបសួរនៃសាលាដំបូងខេត្តកំពង់ស្ពឺ ។

-បានឃើញ ការផ្តល់ និងការជូនដំណឹងអំពីកាលបរិច្ឆេទ នៃសវនាការដែលធ្វើឡើងដោយអនុលោមតាមមាត្រា ២៩២ និងមាត្រាពាក់ព័ន្ធនៃក្រមនីតិវិធីព្រហ្មទណ្ឌ ។

**អង្គហេតុកើតឡើងមានដូចតទៅ**

កាលពីថ្ងៃទី១២ ខែកុម្ភៈ ឆ្នាំ២០២១ វេលាម៉ោង ៤ និង២០នាទី នៅលើផ្លូវជាតិលេខ៤ ចន្លោះគីឡូម៉ែត្រលេខ៤២-៤៣ ត្រង់ចំណុចភូមិចំបក់ ឃុំវល្លិស ស្រុកសំរោងទង ខេត្តកំពង់ស្ពឺ មានករណីគ្រោះថ្នាក់ចរាចរណ៍មួយបានកើតឡើង ។ ដោយមុនពេលកើតហេតុមានរថយន្តមួយគ្រឿងម៉ាក MITSUBISHI FUSO ពណ៌បៃតង ពាក់ផ្លាកលេខ ភ្នំពេញ 3E-3936 បើកបរដោយឈ្មោះ ភេទប្រុស អាយុ ៣៣ឆ្នាំ ក្នុងទិសដៅពីលិចទៅកើតមកដល់ចំណុចកើតហេតុខាងលើ បានបើកចូលចំណែកផ្លូវម្ខាងទៀត ខុសនឹងច្បាប់ស្តីពីចរាចរណ៍ផ្លូវគោក ជ្រុលទៅបុករថយន្តមួយគ្រឿងម៉ាក TUNDRA ពណ៌ស ពាក់ផ្លាកលេខ 2AJ-7909 បើកបរដោយឈ្មោះ JOSEF ភេទប្រុស អាយុ ៥៨ឆ្នាំ មានអ្នករួមដំណើរម្នាក់ឈ្មោះ ភេទស្រី អាយុ ២៦ឆ្នាំ ដែលកំពុងបើកបញ្ច្រាសទិសគ្នា បន្ទាប់មករថយន្តម៉ាក MITSUBISHI FUSO បានជ្រុលទៅបុកបង្គោលភ្លើងចំនួន ០១ដើម និងផ្ទះមួយខ្នងរបស់ឈ្មោះ ភេទប្រុស អាយុ ៣៩ឆ្នាំ ។ ក្នុងគ្រោះថ្នាក់ចរាចរណ៍នេះបណ្តាលឱ្យឈ្មោះ BAUER THOMAS JOSEF រងរបួសធ្ងន់ ឈ្មោះ រងរបួសស្រាល និងធ្វើឱ្យខូចខាតរថយន្ត ០២គ្រឿង បង្គោលភ្លើងមួយដើម ផ្ទះមួយខ្នង និងសម្ភារៈក្នុងផ្ទះមួយចំនួន ។

**នាពេលសវនាការ**

១-ដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ បានឆ្លើយថា នៅថ្ងៃកើតហេតុខ្លួនបើកឡានពីភ្នំពេញ ទៅកំពង់សោម បើកក្នុងល្បឿន Maximum ៤០គីឡូម៉ែត្រ ក្នុងមួយម៉ោង ដល់កន្លែងកើតហេតុ មានរថយន្តមួយគ្រឿងបើកចូលគន្លងផ្លូវមិនមានស៊ីញ៉ូទេ បុកឡានខ្ញុំពេញទំហឹង ។ ខ្ញុំសូមទាមទារថ្លៃព្យាបាល និងសំណង ១០០.០០០ (ដប់ម៉ឺន) ដុល្លារអាមេរិក ។

២-ដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ បានឆ្លើយថា នៅថ្ងៃកើតហេតុមានឡានកុងទីន័រ បុកចូលផ្ទះខ្ញុំតែម្តង ខ្ញុំមិនដឹងថា ឡានកុងទីន័រ ឬឡាន TUNDRA ជាអ្នកមានកំហុសនោះទេ ។ ឡាននោះបុកចូលបណ្តាលឱ្យខូចខាតកន្លែង WING របស់ខ្ញុំ និងសម្ភារៈក្នុងផ្ទះមួយចំនួនផងដែរ ។

៣-លោក **សាន សំរួល** មេធាវីការពារសិទ្ធិឱ្យដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ បានធ្វើសេចក្តីសន្និដ្ឋានថា តាមរបាយការណ៍សំយោគលេខ ២៤៧/២១ ចុះថ្ងៃទី០៩ ខែមីនា ឆ្នាំ២០២១ របស់ស្នងការនគរបាលខេត្តកំពង់ស្ពឺថា នាទីទាបភ្លឺនៅលើផ្លូវជាតិលេខ៤ ចន្លោះគីឡូម៉ែត្រលេខ៤២-៤៣ ត្រង់ចំណុចភូមិចំបក់ ឃុំវល្លិស ស្រុកសំរោងទង ខេត្តកំពង់ស្ពឺ មានរថយន្តមួយគ្រឿងម៉ាក MITSUBISHI FUSO ពណ៌បៃតង ពាក់ផ្លាកលេខភ្នំពេញ 3E-3936 សណ្តោងស៊ីមីរ៉ឺម៉ក ពណ៌លឿងទុំ ពាក់ផ្លាកលេខ ភ្នំពេញ 3A-5074 អ្នកបើកបរឈ្មោះ ភេទប្រុស អាយុ៣៣ឆ្នាំ រស់នៅភូមិភ្នំលន្ទះ ឃុំអង្គប្រាសាទ ស្រុក[illegible] ខេត្ត[illegible] បើកបរពីទិសខាងលិច ទៅទិសខាងកើត លុះមកដល់ចំណុចដូចខាងលើ បានបើកទៅបុករថយន្តមួយគ្រឿង ម៉ាក

38/16

TUNDRA ពណ៌ស ពាក់ផ្លាកលេខ ភ្នំពេញ 2AJ-7909 អ្នកបើកបរឈ្មោះ ភេទប្រុស អាយុ៥៨ឆ្នាំ ជនជាតិ អាឡឺម៉ង់ និងអ្នករួមដំណើរម្នាក់ ឈ្មោះ ភេទស្រី អាយុ២៦ឆ្នាំ ដែលកំពុងតែបើកបរ បញ្ច្រាសទិសគ្នា បន្ទាប់មករថយន្ត MITSUBISHI FUSO បានជ្រុលទៅបុកបង្គោលភ្លើង០១ដើម និងផ្ទះមួយខ្នង របស់ឈ្មោះ ភេទប្រុស អាយុ ៣៩ឆ្នាំ ឆ្នាំរស់នៅភូមិចំបក់ ឃុំល្អើសរ ស្រុកសំរោងទង ខេត្តកំពង់ស្ពឺ បណ្តាលឱ្យគ្រោះថ្នាក់មនុស្ស និងខូចខាតសម្ភារៈដូចខាងក្រោម៖

-របួសធ្ងន់ ០១នាក់ប្រុស ជនជាតិអាឡឺម៉ង់ (ឈ្មោះ )

-របួសស្រាល ០១នាក់ស្រី (ឈ្មោះ )

-ខូចរថយន្ត ០២គ្រឿង (ធ្ងន់០១គ្រឿងម៉ាក TUNDRA)

-ខូចបង្គោលភ្លើង ០១ដើម

-ខូចផ្ទះ ០១ខ្នង (ផ្ទះរឹងរលុយ) និងសម្ភារៈក្នុងផ្ទះមួយចំនួនទៀត ។

ដោយយោងតាមការវាស់វែងទីកន្លែងកើតហេតុ និងផ្អែកតាមកំណត់ហេតុត្រួតពិនិត្យ កន្លែងកើតហេតុនាំឱ្យសមត្ថកិច្ចសន្និដ្ឋាន គឺអ្នកបើកបររថយន្តម៉ាក MITSUBISHI FUSO ពណ៌បៃតង ពាក់ផ្លាកលេខភ្នំពេញ 3E-3936 សណ្តោងស៊ីមីរ៉ឺម៉ក ពណ៌លឿងទុំ ពាក់ផ្លាកលេខភ្នំពេញ 4A-5074 បើកបរខ្វះការប្រុងប្រយ័ត្ន បានបើកចូលចំណែកផ្លូវម្ខាងទៀតទៅបុករថយន្ត០១គ្រឿង ដែលកំពុងបើកបរបញ្ច្រាសទិសគ្នា រួចជ្រុលទៅបុកបង្គោលភ្លើង ០១ដើម និងផ្ទះមួយខ្នងទៀត បង្កឡើងនូវការគ្រោះថ្នាក់បណ្តាលឱ្យរបួស និងខូចខាតទ្រព្យសម្បត្តិអ្នកដទៃ ខុសនឹងច្បាប់ស្តីពីចរាចរណ៍ផ្លូវគោក ។ តាមគេហទំព័ររបស់ស្នងការនគរបាលខេត្តកំពង់ស្ពឺ ដែលភ្ជាប់មកក្នុងបណ្តឹងរបស់ខ្លួនបានបញ្ជាក់ថា អ្នកបើកបរឈ្មោះ នេះបានគេចខ្លួនក្រោយកើតហេតុ ។

ក្នុងអង្គហេតុនេះ បណ្តាលអោយកូនក្តីយើងខ្ញុំ រងរបួសបាក់ជើងទាំងសងខាង និងបាក់ដៃ យ៉ាងធ្ងន់ធ្ងរ ហើយកំពុងបន្តសម្រាកព្យាបាលរបួសរហូតមកទល់សព្វថ្ងៃ រីឯរថយន្តម៉ាក TUNDRA បានរងការខូចខាតស្ទើរទាំងស្រុង រួមនឹងការបាត់បង់សម្ភារៈផ្ទាល់ខ្លួនមួយចំនួនថែមទៀត ។ តាមការឱ្យដឹងពីកូនក្តីខ្លួនថា ការសម្រាកព្យាបាលអស់រយៈពេលជាច្រើនខែកន្លងមកនេះ ស្ថានភាពរបួសបាក់ជើងរបស់គាត់ពុំមានសញ្ញាណល្អប្រសើរឡើយ ផ្ទុយមកវិញស្ថានភាពរបួសនេះ បានវិវឌ្ឍន៍កាន់តែអាក្រក់ទៅៗ ។ រហូតមកដល់ពេលចុងក្រោយនេះ ដោយមានមតិយោបល់ណែនាំពីលោកវេជ្ជបណ្ឌិត កូនក្តីខ្លួនគាត់បានសម្រេចចិត្តឱ្យលោកវេជ្ជបណ្ឌិត ជួយកាត់ជើងបាក់របួសដែលរ៉ាំរ៉ៃនោះចោលតែម្តង ដើម្បីការពារអាយុជីវិតគាត់ ។ ហើយចាប់ពេលពេលនោះមក គាត់ប្រហែលជាត្រូវធ្លាក់ខ្លួនជាជនពិការលើរទេះរុញអស់មួយជីវិតតែម្តង ។ ផ្អែកលើទំហំព្យសនកម្ម ការខូចខាតឡានម៉ាក TUNDRA ស្ទើរតែទាំងស្រុង ដែលគាត់បានទិញក្នុងតម្លៃ $៣០.០០០ (បីម៉ឺន) ដុល្លាអាមេរិក និងទំហំព្យសនកម្មផ្លូវកាយ ការរងរបួសធ្ងន់ធ្ងររហូតដល់បាក់ជើង បាក់ដៃ និងរហូតដល់បាត់បង់ជើងម្ខាងទៀតពេលនេះ និងការឈឺចាប់ផ្លូវចិត្តយ៉ាងធំធេងនេះ ការស្នើសុំទាមទារសំណងចំនួនតែ ១០០.០០០$ (ដប់ម៉ឺន) ដុល្លាអាមេរិក ដូចក្នុងពាក្យបណ្តឹង វាហាក់ដូចជានៅមិនទាន់ធួនល្មមនឹងទំហំព្យសនកម្មនៅឡើយទេ ត្បិតការព្យាបាលបានចំណាយប្រាក់អស់យ៉ាងច្រើនសន្ធឹកសន្ធាប់រហូតមកដល់ថ្ងៃសវនាការនេះ ហើយបាន និងកំពុងព្យាបាលបន្តក្នុងពេលអនាគតបន្តទៀត ។

តាមឯកសារប័ណ្ណសម្គាល់យានយន្តដែលមានក្នុងសំណុំរឿងជាប្រភេទរថយន្តណ្តោងក្បាលទំនិញ ម៉ាក FUSO ក្បាលពណ៌បៃតង ពាក់ផ្លាកលេខភ្នំពេញ 3E-3936 សណ្តោងសីមីរ៉ឺម៉កពណ៌លឿង ពាក់ផ្លាកលេខភ្នំពេញ 4A-5074 និងមានលិខិតអនុញ្ញាតឱ្យយានយន្តធ្វើអាជីវកម្មដឹកជញ្ជូនទំនិញលេខ [illegible] ចេញដោយអគ្គនាយកដ្ឋានដឹកជញ្ជូនផ្លូវគោក កាលបរិច្ឆេទចេញ ១៤-០៩-២០២០ មានកម្មសិទ្ធិករ និងជាម្ចាស់អាជីវកម្មឈ្មោះ ភេទស្រី ថ្ងៃខែឆ្នាំកំណើត ០៣-១០-១៩៨២ កាន់អត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរលេខ

០១១០២៩៧៧០ អាសយដ្ឋានផ្ទះលេខ ៥០E1 ផ្លូវលេខ៤៣២ ភូមិ៣ សង្កាត់ទួលទំពូងទី១ ខណ្ឌចំការមន រាជធានីភ្នំពេញ ជាអ្នកទទួលខុសត្រូវរដ្ឋប្បវេណី ។

គិតចាប់តាំងពីពេលកើតហេតុ ពោលពីថ្ងៃទី១២ ខែកុម្ភៈ ឆ្នាំ២០២១ រហូតមកដល់បច្ចុប្បន្ននេះ ឈ្មោះ ជាកម្មសិទ្ធិករនៃយានយន្ត និងជាម្ចាស់អាជីវកម្មដឹកជញ្ជូនទំនិញ ដែលជាអ្នកទទួលខុសត្រូវរដ្ឋប្បវេណី ពុំបានបង្ហាញឆន្ទៈ ដើម្បីធ្វើការដោះស្រាយសំណងផ្នែករដ្ឋប្បវេណីជូនកូនក្តីខ្លួនឡើយ ។ ទង្វើពុំទទួលខុសត្រូវនេះ គឺផ្ទុយទាំងស្រុងទៅនឹងកាតព្វកិច្ចតាមផ្លូវច្បាប់សម្រាប់ម្ចាស់ ឬកម្មសិទ្ធិករ នៃយានយន្តធ្វើអាជីវកម្មដឹកជញ្ជូនទំនិញ ដែលត្រូវដោះស្រាយសំណងដល់ជនរងគ្រោះ ឱ្យបានឆាប់រហ័សបន្ទាប់ពីការបង្កគ្រោះថ្នាក់ ស្របតាមច្បាប់ស្តីពីធានារ៉ាប់រង និងច្បាប់ស្តីពីចរាចរណ៍ផ្លូវគោក ។

តាមរបាយការណ៍របស់សមត្ថកិច្ច ចម្លើយរបស់ដើមបណ្តឹងរដ្ឋប្បវេណី ចម្លើយសាក្សីឃើញថា មានភស្តុតាងបញ្ជាក់បានថា ជនជាប់ចោទឈ្មោះ ពិតជាបើកបរខ្វះការប្រុងប្រយ័ត្ន បានបើកចូលចំណែកផ្លូវម្ខាងទៀតទៅបុករថយន្តកូនក្តីខ្លួន ដែលកំពុងបើកបរបញ្ច្រាសទិសគ្នាពិតប្រាកដមែន រួចជ្រុលទៅបុកបង្គោលភ្លើងមួយដើម និងផ្ទះមួយខ្នងទៀត បង្កគ្រោះថ្នាក់បណ្តាលឱ្យកូនក្តីខ្លួនរបួសយ៉ាងធ្ងន់ធ្ងរ និងពិការជើងជាអចិន្ត្រៃយ៍ ព្រមទាំងបណ្តាលឱ្យខូចខាតទ្រព្យសម្បត្តិឡានរបស់គាត់ស្ទើរទាំងស្រុង ។

ដូច្នេះឈ្មោះ នេះត្រូវទទួលខុសត្រូវផ្នែកព្រហ្មទណ្ឌតាមបញ្ញត្តិមាត្រា ៨៣ នៃច្បាប់ស្តីពីចរាចរណ៍ផ្លូវគោក ពីការបើកបរដោយធ្វេសប្រហែស ខ្ជីខ្ជា មិនប្រុងប្រយ័ត្ន ឬមិនគោរពកាតព្វកិច្ចដែលបទប្បញ្ញត្តិស្តីពីចរាចរណ៍ផ្លូវគោកតម្រូវ ។

ចំណែកឯឈ្មោះ ជាកម្មសិទ្ធិករនៃយានយន្ត និងជាម្ចាស់អាជីវកម្មដឹកជញ្ជូនទំនិញ ត្រូវទទួលខុសត្រូវរដ្ឋប្បវេណី និងជួសជុលសំណងខូចខាត ឱ្យកូនក្តីយើងខ្ញុំតាមបញ្ញត្តិមាត្រា ៧២ នៃច្បាប់ស្តីពីចរាចរណ៍ផ្លូវគោក ដែលបញ្ញត្តិថា អ្នកគ្រប់គ្រង ឬម្ចាស់កម្មសិទ្ធិករត្រូវទទួលខុសត្រូវផ្នែករដ្ឋប្បវេណី ក្នុងករណីយានជំនិះរបស់ខ្លួនបង្កគ្រោះថ្នាក់ដល់អ្នកដទៃ ។

ខ្លួនជាមេធាវីការពារសិទ្ធិឱ្យកូនក្តីឈ្មោះ ជាដើមបណ្តឹងរដ្ឋប្បវេណី ប្តឹងសុំឱ្យតុលាការ៖

ក/.ផ្តន្ទាទោសឈ្មោះ ភេទប្រុស អាយុ៣៣ឆ្នាំ រស់នៅភូមិភ្នំលន្ទះ ឃុំអង្គប្រាសាទ ស្រុកគិរីវង្ស ខេត្តតាកែវ ដាក់ពន្ធនាគារឱ្យបានតឹងរ៉ឹងបំផុតតាមបញ្ញត្តិមាត្រា ៨៣ នៃច្បាប់ស្តីពីចរាចរណ៍ផ្លូវគោក ដើម្បីផ្តល់យុត្តិធម៌ដល់ជនរងគ្រោះ ក៏ដូចជាបង្ហាញឱ្យឃើញការអនុវត្តច្បាប់ចរាចរណ៍ឱ្យបានម៉ឺងម៉ាត់ ចំពោះជនបង្កគ្រោះថ្នាក់ចរាចរណ៍ទាំងបំពាន ដោយសុំឱ្យតុលាការអនុវត្តតាមបញ្ញត្តិមាត្រា ៣៥៣ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ដោយចេញដីកាបង្គាប់ឱ្យឃុំខ្លួន និងដីកាបង្គាប់ឱ្យចាប់ខ្លួនឈ្មោះ នេះ ដើម្បីយកមកផ្តន្ទាទោសទៅតាមផ្លូវច្បាប់ ។

ខ/.សុំឱ្យតុលាការសម្រេចអំពីផលប្រយោជន៍ផ្នែករដ្ឋប្បវេណី តាមការទាមទាររបស់កូនក្តីយើងខ្ញុំ ជាសំណងលើព្យសនកម្មដ៏ធំធេងដែលកូនក្តីខ្ញុំទទួលរង ចំនួន ១០០.០០០$ (ដប់ម៉ឺន) ដុល្លារអាមេរិក ពីអ្នកទទួលខុសត្រូវរដ្ឋប្បវេណីឈ្មោះ ភេទស្រី ថ្ងៃខែឆ្នាំកំណើត ០៣-១០-១៩៨២ កាន់អត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរលេខ ០១១០២៩៧៧០ អាសយដ្ឋានផ្ទះលេខ ៥០E1 ផ្លូវលេខ៤៣២ ភូមិ៣ សង្កាត់ទួលទំពូងទី១ ខណ្ឌចំការមន រាជធានីភ្នំពេញ ជាកម្មសិទ្ធិករ និងជាម្ចាស់អាជីវកម្ម រថយន្តល្ហោងកុងទីន័រដឹកជញ្ជូនទំនិញម៉ាក F-650 ពណ៌បៃតង ពាក់ផ្លាកលេខភ្នំពេញ 3E-3936 សណ្តោងស៊ីមីរ៉ឺម៉ក ពណ៌លឿងទុំ ពាក់ផ្លាកលេខភ្នំពេញ 4A-5074 ។

38/4

គ/.ក្នុងករណីឈ្មោះ                    កេខស្រី ថ្ងៃខែឆ្នាំកំណើត ០៣-១០-១៩៨២ មិនព្រមសងសំណង ជាសាច់ប្រាក់ទេ សុំឱ្យតុលាការអនុញ្ញាតឱ្យកូនក្តីខ្ញុំ មានសិទ្ធិស្នើសុំលក់ឡាយឡុងយានយន្តបង្កគ្រោះថ្នាក់ ម៉ាក FUSO ក្បាលពណ៌បៃតង ពាក់ផ្លាកលេខភ្នំពេញ 3E-3936 និងកន្ទុយសណ្តោង ពណ៌លឿងទុំ ពាក់ផ្លាកលេខ ភ្នំពេញ 4A-5074 និងទ្រព្យសម្បត្តិផ្សេងទៀតរបស់ឈ្មោះ សម ណារុន ដើម្បីសងសំណងឱ្យគ្រប់ចំនួន ។

ឃ/.ប្រគល់ឡានម៉ាក TUNDRA ពណ៌ស ដែលខូចខាតស្ទើរទាំងស្រុង និងដែលរក្សាទុកនៅប៉ុស្តិ៍រដ្ឋបាល ឃុំវល្លិ៍ស មកឱ្យកូនខ្លួនវិញ ។

៤-លោក សាយ មុន្នី មេធាវីការពារសិទ្ធិឱ្យអ្នកទទួលខុសត្រូវរដ្ឋប្បវេណីឈ្មោះ                    បានធ្វើ សេចក្តីសន្និដ្ឋានថា ខ្ញុំសូមបដិសេធកំណត់ហេតុវាស់វែងគំនូស និងរបាយការណ៍សំយោគរបស់ស្នងការនគរបាល ខេត្តកំពង់ស្ពឺ ព្រោះការវាស់វែងធ្វើឡើងនៅពេលយប់ ដូច្នេះតើភាពត្រឹមត្រូវធ្វើបានត្រឹមកម្រិតណា? ថ្លៃព្យាបាល របស់ឈ្មោះ BAUER THOMAS JOSEF មានតែវិក័យបត្រឯកជនប៉ុណ្ណោះ ចំពោះថ្លៃព្យាបាលសូមឱ្យធ្វើការវាយតម្លៃ តាមពេទ្យរដ្ឋវិញ ។ កូនក្តីខ្ញុំសូមជូនសំណងឱ្យឈ្មោះ                    ចំនួន ១៤.០០០$ (មួយម៉ឺនបួនពាន់) ដុល្លារអាមេរិក និងឈ្មោះ                    ចំនួន ១.០០០$ (មួយពាន់) ដុល្លារអាមេរិក ។

## សេចក្តីសន្និដ្ឋានប្តឹងសុំរបស់តំណាងអយ្យការ

តំណាងអយ្យការបានធ្វើសេចក្តីសន្និដ្ឋានថា ក្រោយពីបានស្តាប់ចម្លើយ និងកស្តុតាងឯកសារពាក់ព័ន្ធក្នុង សំណុំរឿងឃើញថា ជនជាប់ចោទឈ្មោះ                    ពិតជាបានប្រព្រឹត្តអំពើ បើកបរដោយធ្វេសប្រហែស ខ្ជីខ្ជា មិនប្រុងប្រយ័ត្នបណ្តាលឱ្យរបួសអ្នកដទៃ តាមមាត្រា ៨៣ នៃច្បាប់ស្តីពីចរាចរណ៍ផ្លូវគោក ប្រព្រឹត្តនៅភូមិចំបក់ ឃុំវល្លិ៍ស ស្រុកសំរោងទង ខេត្តកំពង់ស្ពឺ កាលពីថ្ងៃទី១២ ខែកុម្ភៈ ឆ្នាំ២០២១ ។ ហេតុនេះ តំណាងអយ្យការសូម តម្កល់ការចោទប្រកាន់ទុកជាបានការដដែល និងប្តឹងសុំឱ្យតុលាការផ្តន្ទាទោសជនជាប់ចោទតាមច្បាប់ ។

-ក្រោយពីបានស្តាប់អំណានចម្លើយជនជាប់ចោទ ។

-ក្រោយពីបានស្តាប់ចម្លើយដើមបណ្តឹងរដ្ឋប្បវេណី ។

-ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានប្តឹងសុំរបស់តំណាងអយ្យការ ។

-ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានរបស់មេធាវីការពារសិទ្ធិរបស់ភាគី ។

-ក្រោយពីបានពិនិត្យលើឯកសារ កស្តុតាងនានា ។

-ក្រោយពីបានពិចារណាត្រឹមត្រូវតាមច្បាប់ហើយ ។

## សំអាងហេតុ

១-កាលពីថ្ងៃទី១២ ខែកុម្ភៈ ឆ្នាំ២០២១ នៅភូមិចំបក់ ឃុំវល្លិ៍ស ស្រុកសំរោងទង ខេត្តកំពង់ស្ពឺ ពិតជាមាន អង្គហេតុ បើកបរដោយធ្វេសប្រហែស ខ្ជីខ្ជា មិនប្រុងប្រយ័ត្នបណ្តាលឱ្យរបួសអ្នកដទៃ ប្រាកដមែន ។

២-ជនជាប់ចោទឈ្មោះ                    បានឆ្លើយនៅចំពោះមុខចៅក្រមស៊ើបសួរថា កាលពីថ្ងៃទី១១ ខែកុម្ភៈ ឆ្នាំ២០២១ វេលាម៉ោង៤ និង ២០នាទីទាបភ្លឺ ខ្លួនបើករថយន្តកុងទីន័រម៉ាក FUSO ក្បាលពណ៌បៃតង ផ្លាកលេខ 3E-3936 បើកបរក្នុងទិសដៅពីលិច ទៅកើត (ពីកំពង់សោម ទៅរាជធានីភ្នំពេញ) ពេលដល់ចំណុចកើតហេតុ ស្ថិតនៅម្តុំមុខសាលារៀនចំបក់ ស្រាប់តែមានរថយន្តមួយគ្រឿងម៉ាក TUNDRA ពណ៌ទឹកប្រាក់ [illegible] ជិះបញ្ច្រាសទិសគ្នា ពីកើតទៅលិច បានរេចង្កូតមកខាងចំណែករថយន្តផ្លូវខាងខ្លួន ហើយរថយន្តនោះបាន[illegible] ទៅវិញ ប៉ុន្តែមិនផុត ក៏ប៉ះនឹងរថយន្តរបស់ខ្លួនផ្នែកខាងមុខឆ្វេង បណ្តាលឱ្យរថយន្តរបស់ខ្លួន[illegible] ខាងឆ្វេងដៃទៅបុកផ្ទះរឹងវរលុយ ធ្វើឱ្យខូចខាតដំបូលផ្ទះគាត់ ។ បន្ទាប់ពីគ្រោះថ្នាក់ហើយ[illegible]មិនបាន រត់គេចទៅណាទេ គឺខ្លួននៅជួយគាស់គាត់ចេញពីក្នុងរថយន្តរហូតរួចរាល់ ហើយខាងក្រុមហ៊ុនបានយករថយន្ត

មកផ្ទះអើរ៉ាន់អស់ ហើយបន្ទាប់ពីយករថយន្តទៅរក្សាទុកនៅប៉ុស្ដិ៍ហើយទើបខ្លួនត្រឡប់ទៅភ្នំពេញវិញ ។ ខ្លួនមានប័ណ្ណបើកបររថយន្តត្រឹមត្រូវតាមច្បាប់ ហើយក្នុងថ្ងៃកើតហេតុនោះ ខ្លួនមិនបានសេពគ្រឿងស្រវឹងទេ ហើយគ្រឿងញៀនក៏ខ្លួនមិនដែលប្រើប្រាស់ដែរ ។ ចំណែកឯម្ចាស់រថយន្តរងគ្រោះវិញ ពេលខ្លួនទៅជួយយកគាត់ចេញពីក្នុងឡាន មានជំក្លិនស្រាទៀតផង ។ ខ្លួនមានភស្តុតាងដែលអាចបញ្ជាក់បានថា ខ្លួនមិនបានរេចង្កូតរថយន្តចូលចំណែកផ្លូវម្ខាងទៀតនោះទេ គឺរថយន្តមួយទៀតរេចង្កូតចូលចំណែកផ្លូវរបស់ខ្លួន ខ្លួនមានឧបករណ៍ GPS សម្រាប់តាមដានរថយន្តដែលខ្លួនបើកបរ ហើយខ្លួននឹងដាក់ជូនតុលាការពិនិត្យនៅពេលក្រោយ ។ គប្បីតុលាការពិចារណា និងសម្រេចតាមច្បាប់ ។

២-ដើមបណ្ដឹងរដ្ឋប្បវេណីឈ្មោះ បានឆ្លើយថា នៅថ្ងៃកើតហេតុខ្លួនបើកឡានពីភ្នំពេញ ទៅកំពង់សោម បើកក្នុងល្បឿន Maximum ៤០គីឡូម៉ែត្រ ក្នុងមួយម៉ោង ដល់កន្លែងកើតហេតុ មានរថយន្តមួយគ្រឿងបើកចូលគន្លងផ្លូវមិនមានស៊ីញ៉ូទេ បុកឡានខ្លួនពេញទំហឹង ។ ខ្លួនសូមទាមទារសំណង ១០០.០០០ (ដប់ម៉ឺន) ដុល្លារអាមេរិក ។ គប្បីតុលាការពិចារណា និងសម្រេចតាមច្បាប់ ។

៣-ដើមបណ្ដឹងរដ្ឋប្បវេណីឈ្មោះ បានឆ្លើយថា នៅថ្ងៃកើតហេតុមានឡានកុងទីន័រ បុកចូលផ្ទះខ្ញុំតែម្ដង ខ្ញុំមិនដឹងថា ឡានកុងទីន័រ ឬឡាន TUNDRA ជាអ្នកមានកំហុសនោះទេ ។ ឡាននោះបុកចូលបណ្ដាលឱ្យខូចខាតកន្លែង WING របស់ខ្ញុំ និងសម្ភារៈក្នុងផ្ទះមួយចំនួនផងដែរ ។ ខ្លួនសុំទាមទារសំណងចំនួន ១០.១៣៧,៨$ (មួយម៉ឺន មួយរយសាមសិបប្រាំពីរ ក្បៀសប្រាំបី) ដុល្លារអាមេរិក គប្បីតុលាការពិចារណា និងសម្រេចតាមច្បាប់ ។

៤-តាមរបាយការណ៍សំណុំរឿងលេខ ៦៧/២១ ចុះថ្ងៃទី០៥ ខែមីនា ឆ្នាំ២០២១ របស់ការិយាល័យនគរបាលចរាចរណ៍ផ្លូវគោក នៃស្នងការដ្ឋាននគរបាលខេត្តកំពង់ស្ពឺបានបញ្ជាក់ថា យោងតាមការវាស់វែងទីកន្លែងកើតហេតុ និងផ្អែកតាមកំណត់ហេតុត្រួតពិនិត្យកន្លែងកើតហេតុ នាំឱ្យសមត្ថកិច្ចសន្និដ្ឋានបានថា អ្នកបើកបររថយន្តម៉ាក MITSUBISHI FUSO ពណ៌បៃតង ពាក់ផ្លាកលេខ ភ្នំពេញ 3E-3936 សណ្ដោងរ៉ឺម៉ក ពណ៌លឿងទុំ ពាក់ផ្លាកលេខ ភ្នំពេញ 4A-5074 បើកបរខ្វះការប្រុងប្រយ័ត្ន បានបើកចូលចំណែកផ្លូវម្ខាងទៀត ទៅបុករថយន្តមួយគ្រឿងដែលកំពុងតែបើកបរបញ្ច្រាសទិសគ្នា រួចជ្រុលទៅបុកបង្គោលភ្លើងមួយដើម និងផ្ទះមួយខ្នង បង្កឡើងនូវគ្រោះថ្នាក់បណ្ដាលឱ្យរបួស និងខូចខាតទ្រព្យសម្បត្តិអ្នកដទៃ ខុសនឹងច្បាប់ចរាចរណ៍ផ្លូវគោក ។ របាយការណ៍នេះមានមូលដ្ឋានគ្រប់ជ្រុងជ្រោយ អាចឱ្យតុលាការជឿបាន និងពិចារណាសម្រេចតាមច្បាប់ ។

៥-សេចក្ដីសន្និដ្ឋានរបស់តំណាងអយ្យការមានមូលហេតុ និងមូលដ្ឋានគ្រប់គ្រាន់ ដែលអាចឱ្យតុលាការជឿបានថា ជនជាប់ចោទឈ្មោះ ពិតជាបានប្រព្រឹត្តអំពើ បើកបរដោយធ្វេសប្រហែស ខ្ជីខ្ជា មិនប្រុងប្រយ័ត្នបណ្ដាលឱ្យរបួសអ្នកដទៃ តាមមាត្រា ៨៣ នៃច្បាប់ស្ដីពីចរាចរណ៍ផ្លូវគោក ប្រព្រឹត្តនៅភូមិចំបក់ ឃុំវល្លិស ស្រុកសំរោងទង ខេត្តកំពង់ស្ពឺ កាលពីថ្ងៃទី១២ ខែកុម្ភៈ ឆ្នាំ២០២១ ។

៦-អំពើប្រព្រឹត្តរបស់ជនជាប់ចោទឈ្មោះ មានធាតុផ្សំគ្រប់គ្រាន់ជាបទល្មើស បើកបរដោយធ្វេសប្រហែស ខ្ជីខ្ជា មិនប្រុងប្រយ័ត្នបណ្ដាលឱ្យរបួសអ្នកដទៃ តាមមាត្រា ៨៣ នៃច្បាប់ស្ដីពីចរាចរណ៍ផ្លូវគោក ប្រព្រឹត្តនៅភូមិចំបក់ ឃុំវល្លិស ស្រុកសំរោងទង ខេត្តកំពង់ស្ពឺ កាលពីថ្ងៃទី១២ ខែកុម្ភៈ ឆ្នាំ២០២១ ។

៧-ក្នុងពេលប្រព្រឹត្តបទល្មើស ជនជាប់ចោទមានសតិស្មារតីគ្រប់គ្រាន់ ពោលគឺពុំមែនជាជនវិកលចរិត ។ ដូច្នេះគប្បីតុលាការផ្ដន្ទាទោសលើជនជាប់ចោទឈ្មោះ ឱ្យបានសមទៅនឹងអំពើប្រព្រឹត្តរបស់ខ្លួន ។

៨-មានភស្តុតាង និងពិរុទ្ធភាពគ្រប់គ្រាន់លើជនជាប់ចោទឈ្មោះ ពីបទ បើកបរដោយធ្វេសប្រហែស ខ្ជីខ្ជា មិនប្រុងប្រយ័ត្នបណ្តាលឱ្យរបួសអ្នកដទៃ តាមមាត្រា ៨៣ នៃច្បាប់ស្តីពីចរាចរណ៍ផ្លូវគោក ប្រព្រឹត្តនៅភូមិចំបក់ ឃុំវល្លិស ស្រុកសំរោងទង ខេត្តកំពង់ស្ពឺ កាលពីថ្ងៃទី១២ ខែកុម្ភៈ ឆ្នាំ២០២១ ។

៩-ជនជាប់ចោទឈ្មោះ ត្រូវបានចៅក្រមស៊ើបសួរដាក់ឱ្យស្ថិតនៅក្រោមការត្រួតពិនិត្យតាមផ្លូវតុលាការ ហើយជននេះពុំធ្លាប់មានប្រវត្តិផ្តន្ទាទោសពីពេលកន្លងមកទេ គប្បីតុលាការប្រកាសទោសព្យួរតាមមាត្រា ១០៦ និងមាត្រា ១០៧ នៃក្រមព្រហ្មទណ្ឌ ។

១០-វត្ថុចាប់យកមាន៖

១០.១-រថយន្តមួយគ្រឿងម៉ាក TUNDRA ពណ៌ស ពាក់ផ្លាកលេខ ភ្នំពេញ 2AJ-7909 កម្មសិទ្ធិករឈ្មោះ សុខ គាក អាសយដ្ឋាននៅផ្ទះលេខ៤១១ ផ្លូវជាតិ៥ សង្កាត់ច្រាំងចំរេះ១ ខណ្ឌឫស្សីកែវ រាជធានីភ្នំពេញ ។

១០.២-រថយន្តមួយគ្រឿងម៉ាក FUSO ពណ៌បៃតង ពាក់ផ្លាកលេខ ភ្នំពេញ 3E-3936 សណ្តោងរ៉ឺម៉កពាក់ផ្លាកលេខ ភ្នំពេញ 4A-5074 កម្មសិទ្ធិករឈ្មោះ សម ណារុន អាសយដ្ឋាននៅផ្ទះលេខ ៥០អឺ១ ផ្លូវ៤៣២ ភូមិ៣ សង្កាត់ទួលទំពូង ខណ្ឌចំការមន រាជធានីភ្នំពេញ ។

១១-ជនជាប់ចោទ និងអ្នកទទួលខុសត្រូវរដ្ឋប្បវេណី មិនចូលបង្ហាញខ្លួននៅពេលសវនាការទេ ហើយគ្មានភស្តុតាងបង្ហាញឱ្យឃើញថា សាមីខ្លួនបានដឹងអំពីការកោះហៅនោះដែរ គប្បីតុលាការប្រកាសាលក្រមដោយកំបាំងមុខ ។

## ហេតុដូច្នេះសម្រេច

១-ផ្តន្ទាទោសលើជនជាប់ចោទឈ្មោះ ភេទប្រុស អាយុ ៣៣ឆ្នាំ ជាតិខ្មែរ មានអត្តសញ្ញាណដូចខាងលើ ដាក់ពន្ធនាគារកំណត់ ០១ (មួយ) ឆ្នាំ និង ០៦ (ប្រាំមួយ) ខែ ពីបទ បើកបរដោយធ្វេសប្រហែស ខ្ជីខ្ជា មិនប្រុងប្រយ័ត្នបណ្តាលឱ្យរបួសអ្នកដទៃ តាមមាត្រា ៨៣ នៃច្បាប់ស្តីពីចរាចរណ៍ផ្លូវគោក ប្រព្រឹត្តនៅភូមិចំបក់ ឃុំវល្លិស ស្រុកសំរោងទង ខេត្តកំពង់ស្ពឺ កាលពីថ្ងៃទី១២ ខែកុម្ភៈ ឆ្នាំ២០២១ តែទោសនេះត្រូវព្យួរធម្មតា តាមមាត្រា ១០៦ និងមាត្រា ១០៧ នៃក្រមព្រហ្មទណ្ឌ ។

២-បង្គាប់ឱ្យអ្នកទទួលខុសត្រូវរដ្ឋប្បវេណីឈ្មោះ ភេទស្រី អាយុ ៤០ឆ្នាំ កាន់អត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរលេខ ០១១០២៩៧៧០ អាសយដ្ឋានផ្ទះលេខ៥០E1 ផ្លូវលេខ៤៣២ ភូមិ៣ សង្កាត់ទួលទំពូងទី១ ខណ្ឌចំការមន រាជធានីភ្នំពេញ សងសំណងការខូចខាត និងជម្ងឺចិត្តជាប្រាក់ ចំនួន ៦០.០០០$ (ប្រាំមួយម៉ឺន) ដុល្លារអាមេរិក ទៅឱ្យដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ BAUER THOMAS JOSEF ភេទប្រុស អាយុ ៥៧ឆ្នាំ ជនជាតិអាល្លឺម៉ង់ អាសយដ្ឋានបច្ចុប្បន្ននៅអគារមេគង្គវីយូ២ សង្កាត់ជ្រោយចង្វារ ខណ្ឌជ្រោយចង្វារ រាជធានីភ្នំពេញ ការទាមទារលើសពីនេះ បដិសេធចោល ។

៣-បង្គាប់ឱ្យអ្នកទទួលខុសត្រូវរដ្ឋប្បវេណីឈ្មោះ ភេទស្រី អាយុ ៤០ឆ្នាំ កាន់អត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរលេខ ០១១០២៩៧៧០ អាសយដ្ឋានផ្ទះលេខ៥០E1 ផ្លូវលេខ៤៣២ ភូមិ៣ សង្កាត់ទួលទំពូងទី១ ខណ្ឌចំការមន រាជធានីភ្នំពេញ សងសំណងការខូចខាត និងជម្ងឺចិត្តជាប្រាក់ ចំនួន ៧.០០០$ (ប្រាំពីរពាន់) ដុល្លារអាមេរិក ទៅឱ្យដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ ភេទប្រុស អាយុ ៣៩ឆ្នាំ ជាតិខ្មែរ អាសយដ្ឋានបច្ចុប្បន្ននៅភូមិត្បែស ឃុំវល្លិស ស្រុកសំរោងទង ខេត្តកំពង់ស្ពឺ ការទាមទារលើសពីនេះ បដិសេធចោល ។

៤-វត្ថុចាប់យកមាន៖

៤.១-រថយន្តមួយគ្រឿងម៉ាកTUNDRA ពណ៌ស ពាក់ផ្លាកលេខ ភ្នំពេញ 2AJ-7909 ប្រគល់ឱ្យម្ចាស់ដើមវិញ ។

៤.២-រថយន្តមួយគ្រឿងម៉ាក FUSO ពណ៌បៃតង ពាក់ផ្លាកលេខ ភ្នំពេញ 3E-3936 សណ្តោងរ៉ឺម៉ក ពាក់ផ្លាកលេខ ភ្នំពេញ 4A-5074 ប្រគល់ឱ្យម្ចាស់ដើមវិញ ។

សាលក្រមនេះជំនុំជម្រះជាសាធារណៈនៅថ្ងៃទី២០ ខែធ្នូ ឆ្នាំ២០២១ និងប្រកាសជាសាធារណៈ នៅថ្ងៃទី២៥ ខែមករា ឆ្នាំ២០២២ ចំពោះមុខដើមបណ្តឹងរដ្ឋប្បវេណី កំបាំងមុខជនជាប់ចោទ និងអ្នកទទួលខុសត្រូវរដ្ឋប្បវេណី ។

ទុកសិទ្ធិប្តឹងទាស់ និងប្តឹងឧទ្ធរណ៍ក្នុងរយៈពេលដែលច្បាប់កំណត់ ។

ក្រឡាបញ្ជីអង្គសវនាការ

ចៅក្រមជំនុំជម្រះ

# ឧបសម្ព័ន្ធទី៥

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

សាលាឧទ្ធរណ៍បាត់ដំបង

# ក្នុងនាមប្រជារាស្ត្រខ្មែរ
# សាលាឧទ្ធរណ៍បាត់ដំបង

សំណុំរឿងព្រហ្មទណ្ឌ
លេខ: ៦៣២
ចុះថ្ងៃទី១២ ខែធ្នូ ឆ្នាំ២០២៣
សាលដីកា
លេខ: ១៦៧ (ខ)
ចុះថ្ងៃទី១៣ ខែមីនា ឆ្នាំ២០២៤

បង្កើតឡើងតាមច្បាប់ស្តីពីការរៀបចំអង្គការតុលាការ ដែលប្រកាសឱ្យប្រើតាមព្រះរាជក្រមលេខ នស០១៥/០៧១៤/រកម/ ចុះថ្ងៃទី១៦ ខែកក្កដា ឆ្នាំ២០១៤ និង ព្រះរាជក្រឹត្យលេខ នស/រកត/០២២០/១៩៨ ចុះថ្ងៃទី១៩ ខែកុម្ភៈ ឆ្នាំ២០២០ ស្តីពីការដាក់ឱ្យដំណើរការសាលាឧទ្ធរណ៍តំបន់ បានបើកសវនាការជាសាធារណៈ នៅសាលសវនាការនៃសាលាឧទ្ធរណ៍បាត់ដំបង នាថ្ងៃទី១៥ ខែកុម្ភៈ ឆ្នាំ២០២៤ ដោយមានសមាសភាពដូចតទៅ៖

## ក្រុមប្រឹក្សាជំនុំជម្រះ

ឯកឧត្តម ប្រធានក្រុមប្រឹក្សា

ឯកឧត្តម ចៅក្រមប្រឹក្សា

លោក ចៅក្រមប្រឹក្សា

## តំណាងមហាអយ្យការ

ឯកឧត្តម អគ្គព្រះរាជអាជ្ញារង

## ក្រឡាបញ្ជីសវនាការ

លោក

ដើម្បីពិភាក្សាដេញដោលលើសំណុំរឿងព្រហ្មទណ្ឌលេខ ៦៣២ ចុះថ្ងៃទី១២ ខែធ្នូ ឆ្នាំ២០២៣ ដែលមាន៖

-ជនជាប់ចោទឈ្មោះ ភេទប្រុស អាយុ ៣៣ឆ្នាំ សញ្ជាតិខ្មែរ មុខរបរមិនប្រាកដ ទីកន្លែងកំណើតនៅភូមិត្រពាំងលើ ឃុំប្រាំបីមុំ ស្រុកទ្រាំង ខេត្តតាកែវ ទីលំនៅបច្ចុប្បន្នភូមិដីក្រហម សង្កាត់អូរតាវ៉ៅ ក្រុងប៉ៃលិន ខេត្តប៉ៃលិន នៅលីវ ឪពុកឈ្មោះ (រ៉ី) ម្តាយឈ្មោះ (រ) ទោសពីមុន គ្មាន ។ (ក្នុងឃុំ) (ប្តឹងឧទ្ធរណ៍)



ផ្លូវលេខ៥៧ ភូមិចំការឫស្សី សង្កាត់ព្រែកព្រះស្តេច ក្រុងបាត់ដំបង ខេត្តបាត់ដំបង

ឃុំខ្លួនដីកាបង្គាប់ឱ្យឃុំខ្លួនលេខ ២៣២ ថ្ងៃទី១៥ ខែឧសភា ឆ្នាំ២០២៣ របស់ចៅក្រមស៊ើបសួរ សាលាដំបូងខេត្តប៉ៃលិន ។

<u>ជាប់ចោទពីបទ៖</u> ជួញដូរ និងប្រើប្រាស់ដោយខុសច្បាប់នូវសារធាតុញៀន ប្រព្រឹត្តនៅភូមិដីក្រហម សង្កាត់អូរតាវៅ ក្រុងប៉ៃលិន ខេត្តប៉ៃលិន កាលពីថ្ងៃទី ១៣ ខែឧសភា ឆ្នាំ២០២៣ បទល្មើសព្រហ្មទណ្ឌដែលមានចែង និងបញ្ញត្តិឱ្យផ្តន្ទាទោស តាមមាត្រា ៤០, មាត្រា ៤៥ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន។

## <u>**រឿងហេតុមានដូចតទៅ**</u>

កាលពីថ្ងៃទី១៣ ខែឧសភា ឆ្នាំ២០២៣ កម្លាំងប្រឆាំងគ្រឿងញៀន នៃអធិការនគរបាលក្រុងប៉ៃលិនបានចុះបង្ក្រាបករណីជាក់ស្តែង ជួញដូរ និងប្រើប្រាស់ដោយខុសច្បាស់នូវសារធាតុញៀន ស្ថិតនៅភូមិដីក្រហម សង្កាត់អូរតាវៅ ក្រុងប៉ៃលិន ខេត្តប៉ៃលិន ដោយបានឃាត់ខ្លួនជនសង្ស័យឈ្មោះ កែម ចាន់ណា ព្រមទាំងបានដកហូតម្សៅក្រាមពណ៌សថ្លាចំនួន ០២កញ្ចប់តូច ទម្ងន់ ២,២៥ ក្រាម,ជញ្ជីងថ្លឹងថ្នាំញៀន ចំនួន ០១ និងទូរស័ព្ទចំនួន ០១គ្រឿង។ ក្រោយពីបានសាកសួរជនសង្ស័យរួច សមត្ថកិច្ចបានកសាងសំណុំរឿងបញ្ជូនទៅអយ្យការអមសាលាដំបូងខេត្តប៉ៃលិន ដើម្បីចាត់ការតាមនីតិវិធី។

**-បានឃើញ សាលក្រមលេខ: ៨៣ "ខ" ចុះថ្ងៃទី៦ ខែតុលា ឆ្នាំ២០២៣ របស់សាលាដំបូងខេត្តប៉ៃលិន ដែលមានខ្លឹមសារនៃសេចក្តីសម្រេចដូចតទៅ៖**

១-ផ្តន្ទាទោសលើឈ្មោះ ភេទប្រុស អាយុ ៣៣ឆ្នាំ ជនជាតិខ្មែរ ដាក់ពន្ធនាគារកំណត់ ០២(ពីរ)ឆ្នាំ ពីបទ ជួញដូរ និងប្រើប្រាស់ដោយខុសច្បាប់នូវសារធាតុញៀន ប្រព្រឹត្តនៅភូមិដីក្រហម សង្កាត់អូរតាវៅ ក្រុងប៉ៃលិន ខេត្តប៉ៃលិន កាលពីថ្ងៃទី ១៣ ខែឧសភា ឆ្នាំ២០២៣ បទល្មើសព្រហ្មទណ្ឌដែលមានចែង និងបញ្ញត្តិឱ្យផ្តន្ទាទោស តាមមាត្រា ៤០ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន។

២-វត្ថុចាប់យករួមមាន ៖ មានម្សៅក្រាមពណ៌សថ្លាចំនួន ២,២៧ក្រាម, ទូរស័ព្ទម៉ាក IPHONE 6 ពណ៌ទឹកប្រាក់ចំនួន ០១គ្រឿង, សម្រេចរឹបអូសបំផ្លាញចោល លើកលែងតែទូរស័ព្ទម៉ាក IPHONE 6 ពណ៌ទឹកប្រាក់ ០១គ្រឿងសម្រេចប្រគល់ឱ្យម្ចាស់ដើមវិញ។

សាលក្រមនេះជំនុំជម្រះជាសាធារណៈ នៅថ្ងៃទី១៣ ខែកញ្ញា ឆ្នាំ២០២៣ និងប្រកាសជាសាធារណៈនៅថ្ងៃទី០៦ ខែតុលា ឆ្នាំ ២០២៣ ចំពោះមុខជនជាប់ចោទឈ្មោះ ។

ទុកសិទ្ធិប្តឹងឧទ្ធរណ៍ក្នុងរយៈពេល ដែលច្បាប់បានកំណត់ ។

-បានឃើញ ពាក្យបណ្តឹងឧទ្ធរណ៍ចុះថ្ងៃទី១៦ ខែតុលា ឆ្នាំ២០២៣ របស់ជនជាប់ចោទ ឈ្មោះ កែម ចាន់ណា ប្តឹងឧទ្ធរណ៍នឹងសាលក្រមលេខ ៨៣ "ខ" ចុះថ្ងៃទី០៦ ខែតុលា ឆ្នាំ២០២៣ របស់សាលាដំបូងខេត្តប៉ៃលិន ក្រង់ចំណុច ទាំងមូលនៃសេចក្តីសម្រេច ។

-បានឃើញ របាយការណ៍រឿងរបស់ចៅក្រមរបាយការណ៍ ចុះថ្ងៃទី [illegible] ឆ្នាំ២០២៣។

-បានឃើញ សេចក្ដីសន្និដ្ឋានរបស់តំណាងមហាអយ្យការ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ២០២៤ ។

<u>**នាពេលសវនាការ**</u>

-ជនជាប់ចោទឈ្មោះ (វត្តមាន)

-ប្រធានក្រុមប្រឹក្សាជំនុំជម្រះសង្ខេបរបាយការណ៍រឿង

-ប្រធានក្រុមប្រឹក្សាជំនុំជម្រះ សុំឱ្យតំណាងមហាអយ្យការ ធ្វើការកត់សម្គាល់ ចំពោះកិច្ចពិភាក្សាដេញដោល ។

-ក្រឡាបញ្ជី អានចម្លើយជនជាប់ចោទឈ្មោះ ដែលបានឆ្លើយនៅនីតិវិធីសាលាដំបូងខេត្តប៉ៃលិន ។

-ជនជាប់ចោទឈ្មោះ បានឆ្លើយថា ខ្លួនពិតជាបានប្រព្រឹត្តដូចការចោទប្រកាន់មែន ។ ខ្លួនប្ដឹងឧទ្ធរណ៍មក ដោយសារសាលាដំបូងខេត្តប៉ៃលិន ដាក់ទោសច្រើន ។ ខ្លួនធ្លាប់លក់គ្រឿងញៀនឱ្យគេ ។ ថ្ងៃកើតហេតុខ្លួនយកទិញគ្រឿងញៀន ទៅប្រើប្រាស់ ក៏ប៉ូលីសចាប់តែម្ដង ។ ខ្លួនស្នើសុំឱ្យសាលាឧទ្ធរណ៍បាត់ដំបង ជួយបន្ធូរបន្ថយទោសដល់ខ្លួនផង ខ្លួនដឹងកំហុសហើយ ។ ខ្លួនមានម្ដាយ ឪពុកចាស់ត្រូវមើលថែរក្សា ហើយពួកគាត់សល់តែខ្លួនម្នាក់ ចឹងខ្លួនចង់ឆាប់បានចេញទៅមើលម្ដាយ ឪពុក ។

-តំណាងមហាអយ្យការ បានធ្វើសេចក្ដីសន្និដ្ឋានថា បណ្ដឹងឧទ្ធរណ៍របស់ជនជាប់ចោទ ធ្វើឡើងតាមកំណត់ច្បាប់ ។ សាលក្រមព្រហ្មទណ្ឌលេខ ៨៣ "ខ" ចុះថ្ងៃទី០៦ ខែតុលា ឆ្នាំ២០២៣ របស់សាលាដំបូងខេត្តប៉ៃលិន សម្រេចមានលក្ខណៈត្រឹមត្រូវតាមច្បាប់ តំណាងអយ្យការស្នើសុំតម្កល់ទុកជាបានការដដែល ។

-ក្រោយពីបានស្ដាប់ចម្លើយរបស់ជនជាប់ចោទ

-ក្រោយពីបានស្ដាប់សេចក្ដីសន្និដ្ឋានរបស់តំណាងមហាអយ្យការ

-ក្រោយពីបានពិនិត្យឯកសារក្នុងសំណុំរឿងហើយ

-ក្រោយពីបានពិភាក្សា និងពិចារណាត្រឹមត្រូវតាមច្បាប់ហើយ

<u>**សភាព្រហ្មទណ្ឌនៃសាលាឧទ្ធរណ៍បាត់ដំបង**</u>

<u>**យល់ឃើញថា**</u>

១.ពាក្យបណ្ដឹងឧទ្ធរណ៍ចុះថ្ងៃទី១៧ ខែតុលា ឆ្នាំ២០២៣ របស់ឈ្មោះ ធ្វើឡើងតាមកំណត់ច្បាប់ សាលាឧទ្ធរណ៍បាត់ដំបង ទទួលជំនុំជម្រះបានយោងតាមបញ្ញត្តិមាត្រា ៣៨២ថ្មី នៃច្បាប់ស្ដីពីវិសោធនកម្មមាត្រា ២៤៧ មាត្រា ៣៦៨ មាត្រា ៣៧២ និងមាត្រា ៣៨២ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ។

២.កាលពីថ្ងៃទី១៣ ខែឧសភា ឆ្នាំ២០២៣ កម្លាំងប្រឆាំងគ្រឿងញៀននៃអធិការដ្ឋាននគរបាលក្រុងប៉ៃលិន បានបង្ក្រាបករណីគ្រឿងញៀនដោយបានឃាត់ខ្លួន ឈ្មោះ ហើយបានឆែកឆេរ ដកហូតបានគ្រឿងញៀន ចំនួន ២ (ពីរ)កញ្ចប់តូច មានទម្ងន់ ២.២៥ (ពីរក្បៀសម្ភៃប្រាំ)ក្រាម ជញ្ជីងថ្លឹងគ្រឿងញៀនចំនួន ១ (មួយ) និងទូរស័ព្ទ ១ (មួយ)គ្រឿង ។

៣.ជនជាប់ចោទឈ្មោះ កែម ចាន់ណា បានឆ្លើយទទួលស្គាល់នូវអង្គហេតុដែលចោទប្រកាន់មកលើខ្លួន ដោយបានបញ្ជាក់ថា នៅថ្ងៃទី១៣ ខែឧសភា ឆ្នាំ២០២៣ ខ្លួនបានទិញគ្រឿងញៀនចំនួន ២(ពីរ)កញ្ចប់ ហើយបានយកថ្នាំញៀននោះទៅប្រើប្រាស់ ពេលកំពុងប្រើប្រាស់ក៏ត្រូវសមត្ថកិច្ចឃាត់ខ្លួនតែម្តង ។ ខ្លួនធ្លាប់ប្រើប្រាស់ ។ ខ្លួនធ្លាប់ប្រើប្រាស់គ្រឿងញៀន ជិតមួយខែមកហើយ ពេលខ្លះខ្លួនប្រើប្រាស់គ្រឿងញៀនជាមួយអ្នកដែលទិញថ្នាំញៀនពីខ្លួន ។ ខ្លួនបានលក់ថ្នាំញៀនឱ្យគេជិតមួយខែមកហើយ លក់ម្តងៗក្នុងតម្លៃ ៣០.០០០ (បីម៉ឺន)រៀលទៅ ១០០.០០០ (ដប់ម៉ឺន)រៀល ។

៤.តាមចម្លើយរបស់ជនជាប់ចោទ និងតាមភស្តុតាងក្នុងសំណុំរឿង បានបញ្ជាក់ឱ្យ ឃើញថា ជនជាប់ចោទឈ្មោះ ពិតជាបានប្រព្រឹត្តអំពើជួញដូរ និងរក្សាទុកដោយខុសច្បាប់នូវសារធាតុញៀន ប្រាកដមែន ។

៥.មានភស្តុតាង និងពិរុទ្ធភាពគ្រប់គ្រាន់លើឈ្មោះ កែម ចាន់ណា ពីបទៈ ជួញដូរ និងរក្សាទុកដោយខុសច្បាប់នូវសារធាតុញៀន ប្រព្រឹត្តនៅភូមិដីក្រហម សង្កាត់អូរតាវ៉ៅ ក្រុងប៉ៃលិន ខេត្តប៉ៃលិន កាលពីថ្ងៃទី១៣ ខែឧសភា ឆ្នាំ២០២៣ បទល្មើសព្រហ្មទណ្ឌ ដែលមានចែងឱ្យផ្តន្ទាទោសតាមបញ្ញត្តិមាត្រា ៤០ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន ។

៦.រឿងក្តីនេះ សាលាដំបូងខេត្តប៉ៃលិន បានធ្វើការអង្កេត និងលើកយកភស្តុតាងមកសំអាងជូនសព្វគ្រប់ហើយ សាលាឧទ្ធរណ៍បាត់ដំបងឯកភាពនឹងសំអាងហេតុនេះ ដូច្នេះសាលាឧទ្ធរណ៍បាត់ដំបង ពុំចាំបាច់លើកយកសំអាងហេតុដដែលនេះ មកបញ្ជាក់ជាថ្មីទៀតទេ ។

៧.តំណាងមហាអយ្យការអមសាលាឧទ្ធរណ៍បាត់ដំបង បានធ្វើសេចក្តីសន្និដ្ឋានថា បណ្តឹងឧទ្ធរណ៍របស់ជនជាប់ចោទ ធ្វើឡើងតាមកំណត់ច្បាប់ ។ សាលក្រមព្រហ្មទណ្ឌលេខ ៨៣ "ខ" ចុះថ្ងៃទី០៦ ខែតុលា ឆ្នាំ២០២៣ របស់សាលាដំបូងខេត្តប៉ៃលិន សម្រេចមានលក្ខណៈត្រឹមត្រូវតាមច្បាប់ តំណាងអយការស្នើសុំតម្កល់ទុកជាបានការដដែល ។

៨.ការដែលជនជាប់ចោទឈ្មោះ ស្នើសុំបន្ធូរបន្ថយទោស នោះ សាលាឧទ្ធរណ៍យល់ឃើញថា មានលក្ខណៈសមរម្យ ព្រោះជនជាប់ចោទ បានសហការជាមួយសមត្ថកិច្ច មិនបង្កការលំបាកដល់នីតិវិធីតុលាការ មានសារភាពទទួលស្គាល់កំហុស និងមានការសោកស្តាយចំពោះកំហុសដែលបានធ្វើខុសកន្លងមក ដូច្នេះគប្បីសាលាឧទ្ធរណ៍បាត់ដំបង ពិចារណា ផ្តល់នូវការអនុវត្តព្យួរទោសមួយផ្នែកដល់ជនជាប់ចោទ តាមបញ្ញត្តិមាត្រា ១០៧ និងមាត្រា ១០៨ នៃក្រមព្រហ្មទណ្ឌ ។

៩.សាលក្រមព្រហ្មទណ្ឌលេខ ៨៣ "ខ" ចុះថ្ងៃទី០៦ ខែតុលា ឆ្នាំ២០២៣ របស់សាលាដំបូងខេត្តប៉ៃលិន ទុកជាបានការដដែល ដោយគ្រាន់តែកែប្រែការផ្តន្ទាទោសលើជនជាប់ចោទ ស្របតាមការយល់ឃើញខាងលើ ។

<u>ហេតុដូច្នេះ</u>

<u>វិនិច្ឆ័យសេចក្ដី</u>

១.ទទួលពាក្យបណ្ដឹងឧទ្ធរណ៍ចុះថ្ងៃទី១៧ ខែតុលា ឆ្នាំ២០២៣ របស់ឈ្មោះ ទុកជាត្រឹមត្រូវតាមទម្រង់ច្បាប់ ។

២.តម្កល់ សាលក្រមព្រហ្មទណ្ឌលេខ ៨៣ "ខ" ចុះថ្ងៃទី០៦ ខែតុលា ឆ្នាំ២០២៣ របស់សាលាដំបូងខេត្តប៉ៃលិន ទុកជាបានការដដែល ដោយគ្រាន់តែកែប្រែរយៈពេលនៃការផ្ដន្ទាទោសលើឈ្មោះ ក្នុងចំណុចទី១ នៃសេចក្ដីសម្រេច ពីទោសដាក់ពន្ធនាគារកំណត់ ២(ពីរ)ឆ្នាំ មកជា ទោសដាក់ពន្ធនាគារកំណត់ ២(ពីរ)ឆ្នាំ តែត្រូវអនុវត្តក្នុងពន្ធនាគារកំណត់ចំនួន ១(មួយ)ឆ្នាំ ទោសសល់ពីនេះ ត្រូវព្យួរធម្មតា វិញ ។

ចំណុចក្រៅពីនេះ រក្សាទុកជាបានការដដែល ។

៣.សាលដីកានេះ ប្រកាសជាសាធារណៈ នាថ្ងៃទី១៣ ខែមីនា ឆ្នាំ២០២៤ ចំពោះមុខជនជាប់ចោទ ។ បើកផ្លូវប្ដឹងសាទុក្ខតាមកំណត់ច្បាប់ ។

| ក្រឡាបញ្ជី | ចៅក្រមប្រឹក្សា | ប្រធានក្រុមប្រឹក្សាជំនុំជម្រះ |
|---|---|---|
| ហត្ថលេខា៖ | ហត្ថលេខា៖ | ហត្ថលេខា៖ |

បានចម្លងត្រឹមត្រូវតាមច្បាប់ដើម

ថ្ងៃពុធ ៤កើត ខែផល្គុន ឆ្នាំថោះ បញ្ចស័ក ព.ស២៥៦៧

ត្រូវនឹងថ្ងៃទី១៣ ខែមីនា ឆ្នាំ២០២៤

ប្រធានក្រុមប្រឹក្សាជំនុំជម្រះ

ក្រឡាបញ្ជី

# ឧបសម្ព័ន្ធទី៦

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

សាលាឧទ្ធរណ៍ភ្នំពេញ

សំណុំរឿងព្រហ្មទណ្ឌ
លេខ៖ ៤៦
ចុះថ្ងៃទី១៣-០១-២០២៣

**សាលដីកា**

លេខ៖ ៥១ "ក្រ.III.ច"
ចុះថ្ងៃទី២៩-០៤-២០២៤

# តាមនាមប្រជារាស្ត្រខ្មែរ
## សាលាឧទ្ធរណ៍ ភ្នំពេញ

បង្កើតតាមច្បាប់ស្តីពីការរៀបចំអង្គការតុលាការ ប្រកាសឱ្យប្រើតាមព្រះរាជក្រម លេខ:នស/រកម/០៧១៤/០១៥ ចុះថ្ងៃទី១៦-០៧-២០១៤ បានបើកសវនាការជាសាធារណៈនៅសាលាឧទ្ធរណ៍ភ្នំពេញ ថ្ងៃទី០៤-០៤-២០២៤ ដោយមានសមាសភាពដូចតទៅ:

**សមាសភាពក្រុមប្រឹក្សាជំនុំជំរះ**

| | |
|---|---|
| លោកស្រី | ជាប្រធានក្រុមប្រឹក្សា |
| ឯកឧត្តម | ជាចៅក្រមប្រឹក្សា |
| លោក | ជាចៅក្រមប្រឹក្សា |

**តំណាងមហាអយ្យការ**

| | |
|---|---|
| លោក | ជាព្រះរាជអាជ្ញា |

**ក្រឡាបញ្ជី**

លោក

ដើម្បីជំនុំជំរះលើបណ្តឹងឧទ្ធរណ៍នៃរឿងព្រហ្មទណ្ឌលេខ ៤៦ ចុះថ្ងៃទី១៣ ខែមករា ឆ្នាំ២០២៣ ដោយមាន៖

១-ជនជាប់ចោទ ឈ្មោះ ភេទស្រី អាយុ៦៥ឆ្នាំ សញ្ជាតិខ្មែរ មុខរបរអាជីវកម្ម ទីកន្លែងកំណើតនៅភូមិព្រៃតាព្រីក ឃុំស្តេចគង់ខាងលិច ស្រុកបន្ទាយមាស ខេត្តកំពត និងមានទីលំនៅបច្ចុប្បន្នស្នាក់នៅភូមិអូរត្រជាក់ចិត្ត ឃុំសំរុង ស្រុកព្រៃនប់ ខេត្តព្រះសីហនុ ឪពុកឈ្មោះ "ស" ម្តាយឈ្មោះ "ស" ប្តីឈ្មោះ "រ" មានកូន០៣ នាក់ ជានិតិជន ប្រវត្តិនៃការផ្តន្ទាទោសពីមុនគ្មាន ។

-<u>ជាប់ចោទពីបទ:</u> "ឆបោក និងមិនបំពេញកាតព្វកិច្ចចំពោះឧបករណ៍អាចជួញដូរបាន" ប្រព្រឹត្តនៅរាជធានីភ្នំពេញ កាលពីអំឡុងឆ្នាំ២០១៩ ដល់ឆ្នាំ២០២០ បទល្មើសព្រហ្មទណ្ឌដែលមានបញ្ញត្តិឱ្យផ្តន្ទាទោសតាមបញ្ញត្តិមាត្រា ៣៧៧ មាត្រា៣៧៨ នៃក្រមព្រហ្មទណ្ឌ និងមាត្រា២៣១ នៃច្បាប់ស្តីពីឧបករណ៍អាចជួញដូរបាន និងប្រតិបត្តិការទូទាត់ប្រាក់ ។

២-ជនជាប់ចោទ ឈ្មោះ ភេទស្រី អាយុ ៤០ឆ្នាំ សញ្ជាតិខ្មែរ មុខរបរលក់ឥវ៉ាន់ ទីកន្លែង

កំណើតនៅភូមិព្រៃតាព្រីក ឃុំស្ដេចគង់ខាងលិច ស្រុកបន្ទាយមាស ខេត្តកំពត ទីលំនៅបច្ចុប្បន្នស្នាក់នៅភូមិអូរត្រជាក់ចិត្ត ឃុំសំរុង ស្រុកព្រៃនប់ ខេត្តព្រះសីហនុ ឪពុកឈ្មោះ "រ" ម្ដាយឈ្មោះ "រ" នៅលីវ ជានីតិជន ប្រវត្តិនៃការផ្ដន្ទាទោសពីមុនគ្មាន ។

**៣-ជនជាប់ចោទ** ឈ្មោះ ភេទប្រុស អាយុ៣៨ឆ្នាំ សញ្ជាតិខ្មែរ មុខរបររកស៊ី មានទីកន្លែងកំណើតនៅភូមិព្រៃតាព្រីក ឃុំស្ដេចគង់ខាងលិច ស្រុកបន្ទាយមាស ខេត្តកំពត និងមានទីលំនៅបច្ចុប្បន្នស្នាក់នៅភូមិអូរត្រជាក់ចិត្ត ឃុំសំរុង ស្រុកព្រៃនប់ ខេត្តព្រះសីហនុ ឪពុកឈ្មោះ "រ" ម្ដាយឈ្មោះ "រ" នៅលីវ ជានីតិជន ប្រវត្តិនៃការផ្ដន្ទាទោសពីមុនគ្មាន ។

**៤-ជនជាប់ចោទ** ឈ្មោះ ភេទស្រី អាយុ៣៣ឆ្នាំ សញ្ជាតិខ្មែរ មុខរបររកស៊ី មានទីកន្លែងកំណើតនៅភូមិព្រៃតាព្រីក ឃុំស្ដេចគង់ខាងលិច ស្រុកបន្ទាយមាស ខេត្តកំពត និងមានទីលំនៅបច្ចុប្បន្នស្នាក់នៅភូមិអូរត្រជាក់ចិត្ត ឃុំសំរុង ស្រុកព្រៃនប់ ខេត្តព្រះសីហនុ ឪពុកឈ្មោះ "រ" ម្ដាយឈ្មោះ "រ" នៅលីវ ជានីតិជន ប្រវត្តិនៃការផ្ដន្ទាទោសពីមុនគ្មាន ។

-មានមេធាវីការពារសិទ្ធិឱ្យជនជាប់ចោទដោយមេធាវី ។

-<u>ជាប់ចោទពីបទ:</u> "ឆបោក" ប្រព្រឹត្តនៅរាជធានីភ្នំពេញ កាលពីអំឡុងឆ្នាំ២០១៩ ដល់ឆ្នាំ២០២០ បទល្មើសព្រហ្មទណ្ឌដែលមានបញ្ញត្តិឱ្យ ផ្ដន្ទាទោសតាមបញ្ញត្តិមាត្រា ៣៧៧ និងមាត្រា៣៧៨ នៃក្រមព្រហ្មទណ្ឌ ។

-ដើមបណ្ដឹងរដ្ឋប្បវេណី ឈ្មោះ ភេទប្រុស អាយុ៣៩ ឆ្នាំ សញ្ជាតិខ្មែរ មានអាសយដ្ឋាន នៅផ្ទះលេខ ៧៧ ផ្លូវលេខ៧៧ បេតេ ភូមិចំរើនផលទី១ សង្កាត់បឹងទំពន់ទី១ ខណ្ឌមានជ័យ រាជធានីភ្នំពេញ ។

-មានមេធាវីការពារសិទ្ធិដោយមេធាវី ។

### ៦រឿងហេតុមានដូចតទៅៈ

កាលពីអំឡុងឆ្នាំ២០១៩ ដល់ឆ្នាំ២០២០ ឈ្មោះ ភេទស្រី អាយុ៦៤ឆ្នាំ ឈ្មោះ ភេទស្រីអាយុ៤០ឆ្នាំ ឈ្មោះ ភេទប្រុស អាយុ៣៨ឆ្នាំ និងឈ្មោះ ភេទស្រីអាយុ ៣៣ឆ្នាំ បានសុំខ្ចីប្រាក់ពីឈ្មោះ ភេទប្រុស អាយុ៣៩ឆ្នាំ ដើម្បីយកទៅរកស៊ីទិញដី នៅខេត្តព្រះសីហនុ ទិញគ្រឿងចក្រ និងឡានដឹកខ្សាច់ ដោយមានការជឿជាក់ឈ្មោះ លី ពុទ្ធី ក៏បានប្រគល់ប្រាក់ជាបន្តបន្ទាប់សរុបចំនួន ១៤៣,៥០០$ (ដប់បួនម៉ឺនបីពាន់ប្រាំរយដុល្លារអាមេរិក) ដោយឈ្មោះ ឈ្មោះ ឈ្មោះ ឈ្មោះ បានដាក់ធានា កាតគ្រីឡានដឹកដី លិខិតស្នាមពាក់ព័ន្ធដីធ្លីមួយចំនួន លុះដល់ថ្ងៃកំណត់ទូទាត់ប្រាក់ជំពាក់ឈ្មោះ បានចេញមូលប្បទានប័ត្រចំនួន៤សន្លឹក ដែលមានលេខ ២៧២៩៧៩ , លេខ២៧២៩៨០ លេខ២៧២៩៨១ ,លេខ២៧២៩៨២ របស់ធនាគារវិនិយោគ និងអភិវឌ្ឍន៍កម្ពុជា ភីអិលស៊ី ប្រគល់ឱ្យឈ្មោះ ប៉ុន្តែពេលឈ្មោះ យកទៅបើកប្រាក់ត្រូវធនាគារបង្វិលត្រឡប់ ព្រោះមិនមានសាច់ប្រាក់ក្នុងគណនី។ ក្រោយមកឈ្មោះ បានធ្វើការស៊ើបសួរទើបដឹងថា កាតគ្រីឡានដឹកដី លិខិតស្នាមពាក់ព័ន្ធដីធ្លី ដែលពួកគេបានដាក់ធានានោះ មិនមែនជាកម្មសិទ្ធរបស់ឈ្មោះ ឈ្មោះ ឈ្មោះ និងឈ្មោះ

-បានឃើញ សាលក្រមព្រហ្មទណ្ឌលេខ ៣៤៧២ "ត" ចុះថ្ងៃទី១៥ ខែវិច្ឆិកា ឆ្នាំ២០២២ របស់សាលាដំបូងរាជធានីភ្នំពេញដែលមានខ្លឹមសារនៃសេចក្តីសម្រេចដូចតទៅ:

-ឱ្យរួចខ្លួនពីបទចោទលើ

១-ឈ្មោះ ភេទស្រី អាយុ៦៥ឆ្នាំ សញ្ជាតិខ្មែរ

ពីបទ "ឆបោក និងមិនបំពេញកាតព្វកិច្ចចំពោះឧបករណ៍ដែលអាចជួញដូរបាន" ប្រព្រឹត្តនៅរាជធានីភ្នំពេញ កាលពីអំឡុងឆ្នាំ២០១៩ ដល់ឆ្នាំ២០២០ បទល្មើសព្រហ្មទណ្ឌដែលមានបញ្ញត្តិឱ្យ ផ្តន្ទាទោសតាមបញ្ញត្តិមាត្រា ៣៧៧ មាត្រា៣៧៨ នៃក្រមព្រហ្មទណ្ឌ និងមាត្រា២៣១ នៃច្បាប់ស្តីពីឧបករណ៍អាចជួញដូរបាន និងប្រតិបត្តិការទូទាត់ប្រាក់ ។

២-ឈ្មោះ ភេទស្រីអាយុ៤០ ឆ្នាំ សញ្ជាតិខ្មែរ

៣-ឈ្មោះ ភេទប្រុស អាយុ៣៨ឆ្នាំ សញ្ជាតិខ្មែរ

៤-ឈ្មោះ ភេទស្រី អាយុ៣៣ ឆ្នាំ សញ្ជាតិខ្មែរ

ពីបទ "ឆបោក" ប្រព្រឹត្តនៅរាជធានីភ្នំពេញ កាលពីអំឡុងឆ្នាំ២០១៩ ដល់ឆ្នាំ២០២០ បទល្មើសព្រហ្មទណ្ឌដែលមានបញ្ញត្តិឱ្យផ្តន្ទាទោសតាមបញ្ញត្តិមាត្រា ៣៧៧ និងមាត្រា៣៧៨ នៃក្រមព្រហ្មទណ្ឌ។

-សាលក្រមនេះជំនុំជម្រះនៅថ្ងៃទី២៥ ខែតុលា ឆ្នាំ២០២២ ចំពោះមុខជនជាប់ចោទឈ្មោះ , និង និងចាត់ទុកចំពោះមុខ ចំពោះមុខដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ និងប្រកាសជាសាធារណៈនៅថ្ងៃទី១៥ ខែវិច្ឆិកា ឆ្នាំ២០២២ ។

-បានឃើញ សេចក្តីសុំប្តឹងឧទ្ធរណ៍លេខ ០៧ ចុះថ្ងៃទី១៤ ខែកុម្ភៈ ឆ្នាំ២០២៣ របស់អគ្គព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍ភ្នំពេញ សុំប្តឹងឧទ្ធរណ៍នឹងសាលក្រមព្រហ្មទណ្ឌលេខ ៣៤៧២ "ត" ចុះថ្ងៃទី១៥ ខែវិច្ឆិកា ឆ្នាំ២០២២ ត្រង់ចំណុចទី១,២,៣ និង៤ នៃសេចក្តីសម្រេច ។

-បានឃើញ សេចក្តីចម្លងបណ្តឹងឧទ្ធរណ៍លេខ ១៣១៦ ចុះថ្ងៃទី១៣ ខែធ្នូ ឆ្នាំ២០២២ របស់ដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ សុំប្តឹងឧទ្ធរណ៍នឹងសាលក្រមព្រហ្មទណ្ឌលេខ ៣៤៧២ "ត" ចុះថ្ងៃទី១៥ ខែវិច្ឆិកា ឆ្នាំ២០២២ ត្រង់ចំណុចនៃសេចក្តីសម្រេចទាំងមូល ។

-បានឃើញ របាយការណ៍រឿងព្រហ្មទណ្ឌរបស់ចៅក្រមរបាយការណ៍សភាព្រហ្មទណ្ឌ នៃសាលាឧទ្ធរណ៍។

-បានឃើញ សេចក្តីសន្និដ្ឋានរបស់តំណាងមហាអយ្យការអមសាលាឧទ្ធរណ៍ ។

## នាពេលសវនាការ

**ប្រធានក្រុមប្រឹក្សាជំនុំជំរះ បានអានរបាយការណ៍សង្ខេបនៃរឿង**

-ជនជាប់ចោទឈ្មោះ , ឈ្មោះ , ឈ្មោះ (អវត្តមាន) ។

-ដើមបណ្ដឹងរដ្ឋប្បវេណីឈ្មោះ (អវត្តមាន) ។

## តំណាងមហាអយ្យការធ្វើសេចក្ដីសន្និដ្ឋាន

បណ្ដឹងឧទ្ធរណ៍របស់អគ្គព្រះរាជអាជ្ញា និងដើមបណ្ដឹងរដ្ឋប្បវេណី មានលក្ខណៈត្រឹមត្រូវតាមទម្រង់ច្បាប់ យោងតាមមាត្រា ៣៧៥ , ៣៨១ , ៤០២ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ។ តាមការសួរដេញដោលនៅពេលសវនាការ និងពិនិត្យទៅលើឯកសារមួយចំនួន តំណាងមហាអយ្យការយល់ឃើញថា សាលក្រមរបស់សាលាដំបូងសម្រេចឲ្យជនជាប់ចោទរួចផុតពីបទចោទប្រកាន់ ពីបទ ឆបោក និងមិនបំពេញកាតព្វកិច្ចចំពោះឧបករណ៍ដែលអាចជួញដូរបាន ជាការមិនត្រឹមត្រូវទេ ព្រោះថា ជនជាប់ចោទបានមកខ្ចីប្រាក់ដើមបណ្ដឹងរដ្ឋប្បវេណី ០៣ លើក សរុបចំនួន ១៤៣.៥០០ (ដប់បួនម៉ឺនបីពាន់ប្រាំរយ) ដុល្លារអាមេរិក មានកិច្ចសន្យាត្រឹមត្រូវបានដាក់បញ្ចាំដី តែឯកសារបញ្ចាំដីនោះ មិនមែនជាដីរបស់ជនជាប់ចោទទេ ។ ដីខ្លះជាដីរបស់រដ្ឋ ម្យ៉ាងទៀតជនជាប់ចោទបានចេញមូលប្បទានបត្រមួយចំនួនឱ្យទៅដើមបណ្ដឹងរដ្ឋប្បវេណី ទៅបើកប្រាក់ពីធនាគារ តែដល់ថ្ងៃកំណត់ ដើមបណ្ដឹងរដ្ឋប្បវេណីទៅបើក ខាងធនាគារបញ្ជាក់ថា ពុំមានសាច់ប្រាក់ទេ ។ ដូច្នេះការប្ដឹងឧទ្ធរណ៍របស់អគ្គព្រះរាជ្ញាមានលក្ខណៈត្រឹមត្រូវតាមច្បាប់ ។ សុំឱ្យក្រុមប្រឹក្សាពិចារណាទៅលើបណ្ដឹងឧទ្ធរណ៍របស់អគ្គព្រះរាជ្ញា ។

## <u>សេចក្ដីសន្និដ្ឋានមេធាវីការពារសិទ្ធិឲ្យដើមបណ្ដឹងរដ្ឋប្បវេណី</u>

កាលពីក្នុងឆ្នាំ២០១៩ ,២០២០ ឈ្មោះ ព្រមទាំងឈ្មោះ ,ឈ្មោះ និង ឈ្មោះ ហ៊ីម សុធាវ៉ា បានមានទំនាក់ទំនងការងាររកស៊ី ទិញលក់-ដី និងខ្ចីចងការប្រាក់ជាមួយកូនក្ដីខ្លួនលោក ដោយជនទាំងអស់នេះបានជំពាក់ប្រាក់កូនក្ដីខ្លួនជាបន្តបន្ទាប់ចំនួន ៣ លើកសរុបចំនួន ១៤៣,៥០០ $ (ដប់បួនម៉ឺនបីពាន់ប្រាំរយ) ដុល្លាអាមេរិក ដូចមានលិខិតប្រគល់-ទទួលប្រាក់ ចុះថ្ងៃទី១៥ ខែកុម្ភៈ ឆ្នាំ២០១៩ ,លិខិតប្រគល់-ទទួលប្រាក់ ចុះថ្ងៃទី១២ ខែមេសា ឆ្នាំ២០១៩ និងលិខិតប្រគល់-ទទួលប្រាក់ ចុះថ្ងៃទី២៨ ខែសីហា ឆ្នាំ ២០១៩ (ឯកសារថតចំលងលេខ១/៧) ។ ប្រាក់ជំពាក់ទាំងអស់នេះ ឈ្មោះ ,ឈ្មោះ ,ឈ្មោះ និងឈ្មោះ បានយកលុយទៅបង្វិលរកស៊ីទិញ-លក់ដីនៅខេត្តព្រះសីហនុ, យកទៅដោះបំណុលសង ធនាគារ , យកទៅទិញគ្រឿងចក្រ (អាម៉ិច) ឡានដឹកខ្សាច់ ដើម្បីបំរើការក្នុងអាជីវកម្មបូមខ្សាច់របស់ខ្លួននៅខេត្តកំពតជាដើម ។ ការមកយកលុយមួយលើកៗជនទាំងអស់នេះ ដើម្បីឱ្យកូនក្ដីខ្លួនលោក មានការជឿទុកចិត្ត ជនទាំងអស់នេះបានបង្ហាញ និងដាក់ឯកសារតម្កល់ធានាដូចជា កាតគ្រីឡានដឹកដី២គ្រឿង ,លិខិតស្នាមពាក់ព័ន្ធដីធ្លីមួយចំនួន(ឯកសារក្តី) ដោយបាន និយាយអះអាងថា សុទ្ធតែជាកម្មសិទ្ធិឯកជនស្របច្បាប់របស់ខ្លួនទាំងអស់ មិនមានការពាក់ព័ន្ធការហាមឃាត់ ការលក់ដូរផ្ទេរ សិទ្ធិ ជួលបញ្ចាំ ដាក់ធានា ហ៊ីប៉ូតែក ធ្វើអំណោយ មរតក មានទំនាស់ជាមួយនិងជនណាមួយ ឬតតិយជន ឬពាក់ព័ន្ធនិងបញ្ហាដីរដ្ឋអ្វីដែរ ដោយបានអះអាងថា ខ្លួនមានមុខរបររកស៊ីត្រឹមត្រូវ ដូចជាអាជីវកម្មបូមខ្សាច់នៅខេត្តកំពតស្រុកឈូក, មានឡានដឹកដី និងខ្សាច់ជាច្រើនគ្រឿង និងមិនតែប៉ុណ្ណោះជនទាំងអស់នេះបានបញ្ជាក់ថា ខ្លួនមានក្រុមហ៊ុនអាជីវកម្មធ្វើការ សម្ងួតកាកស្រាបៀរ សម្រាប់លក់ជាចំអីជ្រកឱ្យក្រុមហ៊ុនចិញ្ចឹមជ្រូកជារៀងរាល់ខែដែលមានច្បាប់អនុញ្ញាតឱ្យធ្វើអាជីវកម្ម ហើយទទួលបានចំណូលរាល់ខែរាប់ពាន់ដុល្លារអាមេរិកមិនឱ្យកូន

ក្តីខ្ញុំមានការបារម្ភពីការគ្មានប្រាក់សងទាំងដើមទាំងការឡើយ ។ ទន្ទឹមនឹងនេះពួកខ្លួន មានដីធ្លីច្រើនកន្លែងទៀតផង ដូចមាន ឯកសារប្លង់កម្មសិទ្ធិបានបង្ហាញ និងថតភ្ជាប់ជូនដាក់ធានារួចហើយក្នុងកិច្ចសន្យាខ្ចីប្រាក់ដាក់ធានាមួយលើកៗនោះ និងមានកូនស្រីរបស់ឈ្មោះ គឺឈ្មោះ ចេះភាសាចិន និងមានប្តីជនជាតិចិន តៃវ៉ាន់ ស្រាប់មានម៉ូយ និងទំនាក់ទំនងល្អជាមួយចិនៗច្រើនក្នុងការរកស៊ីដីធ្លីនៅស្រុកខ្មែរ។ លុះក្រោយមកឈ្មោះ ព្រមទាំងឈ្មោះ ,ឈ្មោះ និងឈ្មោះ បានចេញមូលប្បទានប័ត្រចំនួន៤សន្លឹក លេខ ២៧២៩៧៨,២៧២៩៨០,២៧២៩៨១ និងលេខ២៧២៩៨២ ប្រគល់ឱ្យកូនក្តីខ្ញុំលោក ទុកទៅបើកប្រាក់នៅធនាគារតាម ការកំណត់នីមួយៗ និងនៅពេលណាក៏បាន ដោយមិនទាន់ចុះកាលបរិច្ឆេទលើសន្លឹកមូលប្បទានប័ត្រនីមួយៗនោះទេ ព្រោះជនទាំងនេះបានអះអាងប្រាប់កូនក្តីខ្លួនចាំដល់ថ្ងៃកំណត់ប្រគល់ប្រាក់តាមកិច្ចសន្យាពួកខ្លួននឹងសរសេរចុះកាលបរិច្ឆេទលើសន្លឹកមូលប្បទានប័ត្រទាំងអស់នេះតាមក្រោយហើយខ្លួននឹងបញ្ចូលទឹកប្រាក់ឬដាក់លុយទៅក្នុងគណនីរបស់ខ្លួនតែម្តង ហើយពេលនោះនឹងឱ្យកូនក្តីខ្លួនលោក កាន់មូលប្បទានប័ត្រទៅបើកយកលុយដែលខ្លួនជំពាក់នេះទៅ(ឯកសារថតចំលងលេខ ២/២) ។ នៅពេលដល់ថ្ងៃកំណត់ប្រគល់ប្រាក់ទាំង៣លើក និងដល់ពេលកំណត់ប្រគល់ប្រាក់តាមការសុំពន្យាពេលជាច្រើនលើកតាំងពីឆ្នាំ២០១៩រហូតដល់ឆ្នាំ២០២០ ឈ្មោះ ,ឈ្មោះ ,ឈ្មោះ និងឈ្មោះ មិនបានមកជួបលោក ដើម្បីសរសេរចុះកាលបរិច្ឆេទលើសន្លឹកមូលប្បទានប័ត្រឱ្យកូនក្តីខ្លួនលោក កាន់ទៅដកប្រាក់ ទេ ដោយពួកជនទាំងអស់នេះគេចវេស ហើយយកលេសជាប់រវល់មិនចេះចប់ ដោយលួងលោមឱ្យកូនក្តីខ្ញុំបាទពន្យាពេលឱ្យពួកគាត់រហូត និងសន្យាថាចាំលក់ដីនៅកន្លែងនេះ រឺរងចាំធនាគារទម្លាក់លុយកម្ចីឱ្យបានលុយសិន ពួកខ្លួននឹងយកមកប្រគល់ឱ្យទាំងដើមទាំងការមិនឱ្យខ្វះឡើយ ជួនកាលភូតភរកុហកថា ចិនបានទិញដីខ្លួននៅចំណុចគីឡូម៉ែត្រលេខ១៩៤ ផ្លូវជាតិលេខ៤ និងបានកក់លុយហើយៗ ពេលចិនទូរទាត់លុយឱ្យចាំសង និងឱ្យកូនក្តីខ្ញុំកាន់មូលប្បទានប័ត្រយកទៅដកប្រាក់ទៅ ឬជួនកាលប្រាប់ថា ចិនទៅស្រុកមិនទាន់មកខ្មែរវិញ ឬធ្វើផ្លូវចូលទៅដីលក់ឱ្យចិនមិនទាន់ហើយៗចិនមិនទាន់ទម្លាក់លុយឱ្យឬពេលខ្លះធ្វើ ផ្លូវឱ្យចិនហើយតែមិនទាន់ឱ្យប្រាក់ និងចុងក្រោយ ច្បាប់បិទហ្គេមអនឡាញចិនឈប់ទិញដីគាត់វិញ និងចុងក្រោយអត់អី និយាយដោះសារជាមួយម្ចាស់បំណុលទៀត ក៏និយាយលួងលោមបញ្ចុះបញ្ចូលឱ្យកូនក្តីខ្ញុំលោក

ជួយរកម៉ូយមកទិញដី របស់ខ្លួនទៅវិញ ។ រាល់លើកដែលជនទាំងអស់នេះប្រាប់ថា ប្រគល់ប្រាក់ទាំងអស់មកឱ្យកូនក្តីខ្លួនដែលមាននៅក្នុងមូលប្បទានប័ត្រទាំង ៤សន្លឹក នេះ គឺកូនក្តីខ្ញុំលោក តែងតែកាន់សន្លឹកមូលប្បទានប័ត្រទាំង ៤សន្លឹក ទៅបើកនៅធនាគារតាមការកំណត់ និងបានសួរធនាគារថា តើមូលប្បទានប័ត្រហ្នឹងមានប្រាក់ រឺទេ តែធនាគារឆ្លើយថាគ្មានលុយរហូត (ឯកសារថតចំលងលេខ៣/៣) ។ ដោយសារមានការយោគយល់ធ្លាប់មានទំនាក់ទំនងការងាររកស៊ីជាមួយគ្នាកន្លងមកទើបកូនក្តីខ្លួន អនុគ្រោះពន្យាពេលទុកឱ្យរហូតតាំងពីឆ្នាំ២០១៩ រហូតដល់ឆ្នាំ២០២០ អស់រយៈពេល២ឆ្នាំ ។ ដោយឡែកចំពោះដីធ្លីទាំងប៉ុន្មានដែលជននេះបានយកប័ណ្ណសារឬឯកសារ មកអះអាងបញ្ជាក់ ឬបង្ហាញប្រាប់ និងដាក់ធានាឱ្យកូនក្តីខ្លួនជឿទុកចិត្ត និងទទួលទុកកន្លងមក គឺសុទ្ធតែមិនមែនជាកម្មសិទ្ធិឯកជនស្របច្បាប់របស់គាត់ដែលបានទិញគេ ហើយមិនទាន់កាត់ឈ្មោះទេ តែដាក់កម្មសិទ្ធិឯកជនអ្នកដទៃសុទ្ធ

សាធ (ឯកសារថតចំលងលេខ៤/៥) ។ រីឯដីធ្លីផ្សេងៗទៀតដែល ពួកគាត់បានអះអាងថា ជាដីចំការភោគៈកម្មសិទ្ធិឯកជនរបស់ពួកគាត់ដូចជា ដីចំការទំហំ១៨ហិចតា (ដីអត់ប្លង់រឹង) មានទីតាំង ស្ថិតនៅភូមិអូរត្រជាក់ចិត្ត ឃុំសំរុង ស្រុកព្រៃនប់ ខេត្តព្រះសីហនុ ដែលពួកគាត់បានយកមកបង្ហាញដាក់តម្កល់ធានា ដោយមិនមានឯកសារនោះ គឺជាដីព្រៃ រឺដីភ្នំសាធារណៈរបស់រដ្ឋទាំងស្រុង មិនមែនជាដីចំការភោគៈឯកជនស្របច្បាប់របស់ពួកគាត់អីនោះទេ (រដ្ឋមិនចេញកម្មសិទ្ធិឯកជនឱ្យឡើយ) ហើយពួកគាត់ក៏មិនមានឯកសារអ្វីត្រឹមត្រូវច្បាស់លាស់នោះដែរ ។ ជាក់ស្តែងចំពោះដីព្រៃ ឬដីភ្នំសាធារណៈរបស់រដ្ឋទំហំ១៨ហិកតានេះទៀតសោត គឺមានការពាក់ព័ន្ធទំនាស់ជាមួយម្ចាស់ផ្សេងទៀតកំពុងកាន់កាប់ គ្រប់គ្រងរាល់ថ្ងៃដែរ ហើយពួកគាត់បានលក់ និងផ្ទេរសិទ្ធិដីនេះឱ្យគេកន្លងមកតាំងពីរចុងឆ្នាំ២០១៥មកម្ល៉េះ និងដីនេះក៏កំពុងមាន ការជាប់ពាក់ព័ន្ធទំនាស់ជាន់គ្នាជាមួយអ្នកដីទៃៗផ្សេងទៀតផងដែរ (ឯកសារថតចំលងលេខ៥/១១) ។ ដោយឡែកចំពោះឡានដឹកដី២គ្រឿង ដែលជនទាំងនេះបានយកកាតគ្រីថតចម្លងមកបង្ហាញធានាតម្កល់នោះ គឺគ្មានទេ ហើយក៏មិនដឹងឡាននៅទីណាដែររកមិនឃើញឡើយបានលក់ដូរឱ្យគេយូរហើយ រីឯអាជីវកម្មបូមខ្សាច់នៅខេត្តកំពត និងសម្ងួតកាកស្រាបៀរលក់ចំណីឱ្យគ យកទៅចិញ្ចឹមសត្វជ្រូកដែលពួកគាត់បានអះអាងប្រាប់កូនក្តីខ្ញុំលោក . កន្លងមកថា ពួកខ្លួនជាម្ចាស់ និងមានច្បាប់អនុញ្ញាតត្រឹមត្រូវ និងកំពុងដំណើរការអាជីវកម្មរាល់ថ្ងៃនោះ គឺមិនពិតទេជាការភូតភរកុហកទាំងស្រុង ដោយអាជីវកម្មទាំងនេះ បានបិទយូរហើយមិនដំណើរការទេ ហើយឥឡូវក៏ឈប់ផងដែរ ឯច្បាប់អនុញ្ញាតក៏លែងមានសុពលភាពទៀត ។ដោយឡែក ចំពោះការអះអាងរបស់មេធាវីការពារឱ្យជនជាប់ចោទ និងជនជាប់ចោទទាំងអស់បានលើកឡើងថា ពួកខ្លួនពុំមានការពាក់ព័ន្ធ យកលុយកាក់ទាំងរស់នេះពីកូនក្តីខ្លួនលោក និងឬមិនដែលស្គាល់កូនក្តីខ្លួនលោក . ព្រមទាំងពួកខ្លួនពុំចេះមើលអានសរសេរអក្សរខ្មែរ គឺមិនពិតទេ ជាភូតភរកុហក ដើម្បីគេចពីការទទួលខុសត្រូវចំពោះមុខច្បាប់ និងកូនក្តីខ្លួនលោក ទាំងស្រុង ដូចមានភស្តុតាងភ្ជាប់ជូនជាមួយស្រាប់ (ឯកសារថតចំលងលេខ៦/១៥) ។អំពើរបស់ជនទាំងអស់នេះគឺបង្ហាញឱ្យឃើញពីធាតុផ្សំនៃបទល្មើសគ្រប់គ្រាន់ក្នុងការឆបោកប្រាក់ និងចេញមូលប្បទានប័ត្រគ្មានសាច់ប្រាក់ដែលប្រព្រឹត្តដោយឈ្មោះ , ឈ្មោះ ,ឈ្មោះ និងឈ្មោះ មកលើកូនក្តីខ្លួនលោក . ជាជនរងគ្រោះបណ្តាលឱ្យកូនក្តី ខ្ញុំទទួលរងនូវព្យសនកម្មបាត់បង់ប្រាក់អស់សរុបចំនួន ១៤៣, ៥០០ $ ( ដប់បួនម៉ឺនបីពាន់ប្រាំរយ ) ដុល្លាអាមេរិក ។

ដោយឈរលើគោលការណ៍ច្បាប់ ក្រមព្រហ្មទណ្ឌ ក្រមនីតិវិធីព្រហ្មទណ្ឌ និងដើម្បីធានាការពារឱ្យបាននូវសិទ្ធិ និងផល ប្រយោជន៍ស្របច្បាប់ និងរកនូវភាពយុត្តិធម៌ឱ្យកូនក្តីខ្ញុំបាទៗសូមសំណូមពរឱ្យតុលាការសម្រេចផ្តន្ទាទោសលើជនជាប់ចោទទាំងអស់តាមផ្លូវច្បាប់ និងបង្គាប់ឱ្យជាប់ចោទទាំងអស់សងប្រាក់ដើមសរុបចំនួន ១៤៣, ៥០០$( ដប់បួនម៉ឺនបីពាន់ប្រាំរយ ) ដុល្លាអាមេរិក និងសំណងជំងឺចិត្តចំនួន ៦០,០០០$( ប្រាំមួយម៉ឺន) ដុល្លាអាមេរិក ប្រគល់មកឱ្យកូនក្តីខ្លួនលោក ។

អាស្រ័យហេតុដូចបានជំរាបជូននូវអង្គហេតុ អង្គច្បាប់ និងសំណូមពរខាងលើ សូមក្រុមប្រឹក្សាជំនុំជម្រះពិនិត្យពិចារណា និងសម្រេចតាមការស្នើសុំដូចមានក្នុងកម្មវត្ថុ និងសំណូមពរ តាមនីតិវិធីច្បាប់ ដោយក្តីអនុគ្រោះ

## សេចក្តីសន្និដ្ឋានមេធាវីការពារសិទ្ធិឲ្យជនជាប់ចោទ

កូនក្តីខ្លួនបានទទួលដំណឹងពីថ្លៃសវនាការទាំងអស់គ្នាហើយ តែមិនបានចូលរួមសវនាការទេ ដោយកូនក្តីខ្លួនរវល់ ។ កូនក្តីខ្លួនបានលក់ដីឱ្យទៅដើមបណ្តឹងរដ្ឋប្បវេណី បានទទួលប្រាក់ចំនួន ១៤៣.៥០០ (ដប់បួនម៉ឺនបីពាន់ប្រាំរយ) ដុល្លារអាមេរិក ហើយ តែដើមបណ្តឹងរដ្ឋប្បវេណីមិនប្រគល់លុយឱ្យគ្រប់ចំនួនមកឱ្យកូនក្តីខ្លួនទៀតទេ ទើបគាត់ឈប់លក់ឱ្យវិញ ដោយព្រមសងប្រាក់ចំនួន ១៤៣.៥០០ (ដប់បួនម៉ឺនបីពាន់ប្រាំរយ) ដុល្លារអាមេរិក ទៅឲ្យដើមបណ្តឹងរដ្ឋប្បវេណីវិញ ។

## តុលាការថយទៅពិភាក្សា

ក្រោយពីបានពិនិត្យឯកសារក្នុងសំណុំរឿងហើយ

ក្រោយពីបានស្តាប់អំណានរបាយការណ៍

ក្រោយពីបានស្តាប់ចម្លើយរបស់ជនជាប់ចោទ

ក្រោយពីបានស្តាប់តំណាងមហាអយ្យការធ្វើសន្និដ្ឋាន

ក្រោយពីបានស្តាប់មេធាវីការពារសិទ្ធិឱ្យជនជាប់ចោទធ្វើសន្និដ្ឋាន

ក្រោយពីបានពិភាក្សាត្រឹមត្រូវហើយ។

## <u>សាលាឧទ្ធរណ៍</u>

### <u>យល់ឃើញថា:</u>

១-សេចក្តីសុំប្តឹងឧទ្ធរណ៍លេខ ០៧ ចុះថ្ងៃទី១៧ ខែកុម្ភៈ ឆ្នាំ២០២៣ របស់អគ្គព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍ភ្នំពេញ សុំប្តឹងឧទ្ធរណ៍នឹងសាលក្រមព្រហ្មទណ្ឌលេខ ៣៤៧២ "ត" ចុះថ្ងៃទី១៥ ខែវិច្ឆិកា ឆ្នាំ២០២២ របស់សាលាដំបូងរាជធានីភ្នំពេញ ធ្វើឡើងក្នុងកំណត់ច្បាប់ សាលាឧទ្ធរណ៍ទទួលជំនុំជម្រះបានយោងតាមមាត្រា ៣៧៥ , ៣៨១ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ។

២-សេចក្តីចម្លងបណ្តឹងឧទ្ធរណ៍លេខ ១៣១៦ ចុះថ្ងៃទី១៣ ខែធ្នូ ឆ្នាំ២០២២ របស់ដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ លី ពុទ្ធី សុំប្តឹងឧទ្ធរណ៍នឹងសាលក្រមព្រហ្មទណ្ឌលេខ ៣៤៧២ "ត" ចុះថ្ងៃទី១៥ ខែវិច្ឆិកា ឆ្នាំ២០២២ របស់សាលាដំបូងរាជធានីភ្នំពេញ ធ្វើឡើងក្នុងកំណត់ច្បាប់ សាលាឧទ្ធរណ៍ទទួលជំនុំជម្រះបានយោងតាមមាត្រា ៣៧៥ , ៣៨២ (ថ្មី) ៤០២ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ។

៣-តាមចម្លើយជនជាប់ចោទឈ្មោះ បានឆ្លើយបដិសេធថា មូលហេតុដែលខ្លួនចេញមូលប្បទានប័ត្រនោះ ដោយសារតែដីនោះមិនទាន់បានចេញដោយភូមិឃុំទើប អោយខ្លួនខ្ចីលុយប្អូនគាត់សិន ហើយពេលនោះគឺខ្ចីលុយ និងអោយខ្លួនចេញមូលប្បទានបត្រនោះដើម្បីធានា ហើយមានកិច្ចសន្យាខ្ចីលុយជាង ១៤០.០០០ (ដប់បួនម៉ឺន) ដុល្លារអាមេរិក ។

៤-តាមចម្លើយជនជាប់ចោទឈ្មោះ បានឆ្លើយបដិសេធថា ខ្លួនពុំបានប្រព្រឹត្ត[illegible]ទេ ។ ខ្លួនបានដឹងថាឈ្មោះ លក់ដីឱ្យ និងខ្លួនធ្វើជាសាក្សីមិនដឹងរឿង[illegible] រឿងចេញមូលប្បទានបត្រខ្លួនមិនបានដឹងនោះទេ ។

៥-តាមចម្លើយជនជាប់ចោទឈ្មោះ បានឆ្លើយបដិសេធថា ខ្លួនពុំបានប្រព្រឹត្តអំពើ ឆបោក ទេ ។ ខ្លួនមិនបានខ្ចីប្រាក់នោះទេ ខ្លួនមិនបានពាក់ព័ន្ធនឹងរឿងទិញលក់នោះទេ គ្រាន់តែដឹងថាម្ដាយខ្លួនលក់ដីឱ្យគាត់ និងគេបង់ប្រាក់ឱ្យមិនគ្រប់ ។ ខ្លួនមិនបានដឹងអំពីការចេញមូលប្បទានបត្រ រឺរឿងខ្ចីលុយនោះទេ ។

៦-តាមចម្លើយជនជាប់ចោទឈ្មោះ ហ៊ឹម សុធារី បានឆ្លើយបដិសេធថា ខ្លួនពុំបានប្រព្រឹត្តអំពើ ឆបោក ទេ ។ ខ្លួនសុំឱ្យតុលាការស៊ើបសួរការពិតផ្ដល់យុត្តិធម៌ជូនខ្លួន ។

៧-តាមចម្លើយដើមបណ្ដឹងរដ្ឋប្បវេណីឈ្មោះ បានឆ្លើយថា ឈ្មោះ ព្រមទាំងកូនៗរបស់ខ្លួនឈ្មោះ ,ឈ្មោះ , ឈ្មោះ បានមកសុំខ្ចីលុយខ្លួនចំនួន ០៣ លើកសរុប ១៤៣,៥០០ (ដប់បួនម៉ឺនបីពាន់ប្រាំរយ) ដុល្លារអាមេរិក ។ ដើម្បីឱ្យមកការជឿទុកចិត្ត ជនទាំងនេះបានបង្ហាញ និងដាក់ឯកសារតម្កល់ធានាដូចជា កាតគ្រីឡានដឹកដីចំនួន២គ្រឿង លិខិតស្នាមពាក់ព័ន្ធដីធ្លីមួយចំនួន និងបានចេញមូលប្បទានបត្រចំនួន ៤ សន្លឹក ប្រគល់ឱ្យខ្លួនបានទុកទៅបើកប្រាក់នៅធនាគារ ដោយមិនទាន់ចុះការបរិច្ឆេទលើសន្លឹកមូលប្បទានបត្រ ខ្លួនតែងតែកាន់សន្លឹកមូលប្បទានបត្រទាំង ៤ សន្លឹកទៅបើកនៅធនាគារតាមការកំណត់ និងបានសួរធនាគារថា តើមូលប្បទានប័ត្រហ្នឹងមានប្រាក់ឬទេ តែធនាគារឆ្លើយថា គ្មានលុយរហូត។

៨-តំណាងមហាអយ្យការបានសន្និដ្ឋានថា បណ្ដឹងឧទ្ធរណ៍របស់អគ្គព្រះរាជអាជ្ញា និងដើមបណ្ដឹងរដ្ឋប្បវេណី ធ្វើឡើងក្នុងកំណត់ច្បាប់ សាលាឧទ្ធរណ៍អាចទទួលជំនុំជម្រះបានយោងតាមមាត្រា ៣៧៥ , ៣៨១ , ៤០២ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ។ តាមការសួរដេញដោលនៅពេលសវនាការ និងពិនិត្យទៅលើឯកសារមួយចំនួន តំណាងមហាអយ្យការយល់ឃើញថា សាលក្រមរបស់សាលាដំបូងសម្រេចឱ្យជនជាប់ចោទរួចផុតពីបទចោទប្រកាន់ ពីបទឆបោក និងមិនបំពេញកាតព្វកិច្ចចំពោះឧបករណ៍ដែលអាចជួញដូរបាន ជាការមិនត្រឹមត្រូវទេ ព្រោះថា ជនជាប់ចោទបានមកខ្ចីប្រាក់ដើមបណ្ដឹងរដ្ឋប្បវេណី ៣ លើក សរុបចំនួន ១៤៣.៥០០ (ដប់បួនម៉ឺនបីពាន់ប្រាំរយ) ដុល្លារអាមេរិកមានកិច្ចសន្យាត្រឹមត្រូវបានដាក់បញ្ចាំដី តែឯកសារបញ្ចាំដីនោះ មិនមែនជាដីរបស់ជនជាប់ចោទទេ ។ ដីខ្លះជាដីរបស់រដ្ឋ ម្យ៉ាងទៀតជនជាប់ចោទបានចេញមូលប្បទានបត្រមួយចំនួនឱ្យទៅដើមបណ្ដឹងរដ្ឋប្បវេណី ទៅបើកប្រាក់ពីធនាគារ តែដល់ថ្ងៃកំណត់ ដើមបណ្ដឹងរដ្ឋប្បវេណីទៅបើក ខាងធនាគារបញ្ជាក់ថា ពុំមានសាច់ប្រាក់ទេ ។ ដូច្នេះការប្ដឹងឧទ្ធរណ៍របស់អគ្គព្រះរាជអាជ្ញាត្រង់ចំណុចចេញមូលប្បទានបត្រគ្មានសាច់ប្រាក់មានលក្ខណៈត្រឹមត្រូវតាមច្បាប់ ។ សុំឱ្យក្រុមប្រឹក្សាពិចារណាទៅលើបណ្ដឹងឧទ្ធរណ៍របស់អគ្គព្រះរាជអាជ្ញា ។

៩-ការសន្និដ្ឋានរបស់តំណាងមហាអយ្យការ ពិចារណាទៅលើបណ្ដឹងឧទ្ធរណ៍របស់អគ្គព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍ភ្នំពេញ សាលាឧទ្ធរណ៍យល់ឃើញថា ការសន្និដ្ឋានរបស់តំណាងមហាអយ្យការទៅលើចំណុចការចោទប្រកាន់ពីបទ មិនបំពេញកាតព្វកិច្ចចំពោះឧបករណ៍ដែលអាចជួញដូរបាន សាលាឧទ្ធរណ៍យល់ឃើញថា មានលក្ខណៈត្រឹមត្រូវ សាលាឧទ្ធរណ៍នឹងពិនិត្យពិចារណាតាមច្បាប់ ។ ចំណែកសុំឱ្យក្រុមប្រឹក្សាពិចារណាចោទប្រកាន់លើជនជាប់ចោទពីបទ ឆបោក សាលាឧទ្ធរណ៍ឃើញថា ពុំត្រឹមត្រូវឡើយ ។

១០-មេធាវីការពារសិទ្ធិឱ្យដើមបណ្ដឹងរដ្ឋប្បវេណីសន្និដ្ឋានថា ជនជាប់ចោទទាំងអស់នេះ គ្មានមកខ្ចីប្រាក់ពី

70/3

កូនក្តីខ្លួនសរុបចំនួន ៣ លើក សរុបចំនួន ១៤៣.៥០០ (ដប់បួនម៉ឺនបីពាន់ប្រាំរយ) ដុល្លារអាមេរិក ដែលមានកិច្ចសន្យាប្រគល់ទទួលចុះថ្ងៃទី១២ ខែមេសា ឆ្នាំ២០១៩ ។ ដើម្បីឱ្យកូនក្តីខ្លួនទុកចិត្ត ក៏បានយកកាតគ្រីឡានដឹកដី២គ្រឿង , លិខិតស្នាមពាក់ព័ន្ធដីធ្លីមួយចំនួន និងចេញមូលប្បទានបត្រមួយចំនួនឱ្យកូនក្តីខ្លួនទៅបើកពីធនាគារ តែដល់ថ្ងៃកំណត់ត្រូវទៅបើកពីធនាគារ១បានបញ្ជាក់ថា មូលប្បទានបត្រពុំមានសាច់ប្រាក់ទេ ។ ចំពោះដីដាក់បញ្ចាំនេះមិនមែនជាដីរបស់ជនជាប់ចោទទេ ដីខ្លះជារបស់រដ្ឋ និងខ្លះទៀតជារបស់អ្នកផ្សេង ។ ខ្លួនឯកភាពតាមការសន្និដ្ឋានរបស់តំណាងមហាអយ្យការ ។ សុំក្រុមប្រឹក្សាពិចារណាបដិសេធសាលក្រមរបស់សាលាដំបូង ហើយផ្តន្ទាទោសជនជាប់ចោទតាមច្បាប់ និងទាមទារប្រាក់ដើម និងសំណងជម្ងឺចិត្តចំនួន ៦០.០០០ (ប្រាំមួយម៉ឺន) ដុល្លារអាមេរិក ។

១១-តាមការសន្និដ្ឋានរបស់មេធាវីការពារសិទ្ធិឱ្យដើមបណ្តឹងរដ្ឋប្បវេណី ស្នើសុំឱ្យក្រុមប្រឹក្សាពិចារណាផ្តន្ទាទោសជនជាប់ចោទ សាលាឧទ្ធរណ៍យល់ឃើញថា ការសន្និដ្ឋានរបស់មេធាវីបានតែទៅផលប្រយោជន៍រដ្ឋប្បវេណីតែប៉ុណ្ណោះ ។ តែចំពោះការស្នើសុំទៅលើសំណងរដ្ឋប្បវេណី អាចឱ្យក្រុមប្រឹក្សាលើកមកពិចារណាតាមស្នើសុំបាន សាលាឧទ្ធរណ៍នឹងពិចារណាតែទៅតាមចំនួនទឹកប្រាក់ក្នុងមូលប្បទានបត្រ និងសំណងជម្ងឺចិត្តតាមច្បាប់ ។

១២-មេធាវីការពារសិទ្ធិឱ្យជនជាប់ចោទសន្និដ្ឋានថា កូនក្តីខ្លួនបានទទួលដំណឹងពីថ្ងៃសវនាការទាំងអស់គ្នាហើយ តែមិនបានចូលរួមសវនាការទេ ដោយកូនក្តីខ្លួនរវល់ ។ កូនក្តីខ្លួនបានលក់ដីឱ្យទៅដើមបណ្តឹងរដ្ឋប្បវេណី បានទទួលប្រាក់ចំនួន ១៤៣.៥០០ (ដប់បួនម៉ឺនបីពាន់ប្រាំរយ) ដុល្លារអាមេរិក ហើយ តែដើមបណ្តឹងរដ្ឋប្បវេណីមិនប្រគល់លុយឱ្យគ្រប់ចំនួនមកឱ្យកូនក្តីខ្លួនទៀតទេ ទើបគាត់ឈប់លក់ឱ្យវិញ ដោយព្រមសងប្រាក់ចំនួន ១៤៣.៥០០ (ដប់បួនម៉ឺនបីពាន់ប្រាំរយ) ដុល្លារអាមេរិក ទៅឱ្យដើមបណ្តឹងរដ្ឋប្បវេណីវិញ ។ សំណូមពរសុំក្រុមប្រឹក្សាពិចារណាតម្កល់សាលក្រមទុកជាបានការដដែល ។ សាលាឧទ្ធរណ៍នឹងពិនិត្យពិចារណាសម្រេចតាមច្បាប់ ។

១៣-ផ្អែកតាមចម្លើយរបស់ជនជាប់ចោទ និងចម្លើយដើមបណ្តឹងរដ្ឋប្បវេណី ព្រមទាំងឯកសារជាភស្តុតាងនៅក្នុងសំណុំរឿងឃើញថា ជនជាប់ចោទទទួលស្គាល់ថា បានខ្ចីប្រាក់ពីដើមបណ្តឹងរដ្ឋប្បវេណីដែលមានកិច្ចសន្យាខ្ចីប្រាក់ដោយការដាក់ធានា ចំនួន ៣ លើក ១.ចុះថ្ងៃទី១៥ ខែកុម្ភៈ ឆ្នាំ២០១៩ ២.ចុះថ្ងៃទី១២ ខែមេសា ឆ្នាំ២០១៩ ៣.ចុះថ្ងៃទី២៨ ខែសីហា ឆ្នាំ២០១៩ សាលាឧទ្ធរណ៍យល់ឃើញថា នេះជាវិវាទក្នុងរឿងរដ្ឋប្បវេណី ដែលត្រូវដោះស្រាយដោយតុលាការរដ្ឋប្បវេណី ។ ហើយនៅក្នុងកិច្ចសន្យាខ្ចីប្រាក់ទាំងនេះ គឺធ្វើតែរវាងឈ្មោះ និងដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ តែប៉ុណ្ណោះ មិនមានការចូលរួមពីឈ្មោះ , ឈ្មោះ , និងឈ្មោះ នោះទេ ។

១៤-ចំពោះការចេញមូលប្បទានបត្ររបស់ជនជាប់ចោទឈ្មោះ ចំនួន ០៤ សន្លឹក មាន ១.លេខ ២៧២៩៧៩ ២.លេខ ២៧២៩៨០ ៣.លេខ ២៧២៩៨១ ៤.លេខ ២៧២៩៨២ របស់ធនាគារវិនិយោគ និងអភិវឌ្ឍន៍កម្ពុជា ដែលជនជាប់ចោទបានបញ្ជាក់ច្បាស់ថា គ្មានសាច់ប្រាក់ គឺជាបទល្មើស។

១៥-គ្មានពិរុទ្ធភាព និងភស្តុតាងគ្រប់គ្រាន់លើជនជាប់ចោទឈ្មោះ , ឈ្មោះ , ឈ្មោះ និងឈ្មោះ ពីបទ "ឆបោក" ប្រព្រឹត្តនៅរាជធានីភ្នំពេញ ក្នុង[illegible]

70/2

ឆ្នាំ២០២០ បទល្មើសព្រហ្មទណ្ឌដែលមានបញ្ញត្តិឱ្យផ្តន្ទាទោសតាមបញ្ញត្តិមាត្រា ៣៧៧ និងមាត្រា៣៧៨ នៃក្រមព្រហ្មទណ្ឌ។

១៦-មានពិរុទ្ធភាព និងភស្តុតាងគ្រប់គ្រាន់លើជនជាប់ចោទឈ្មោះ ពីបទ "មិនបំពេញកាតព្វកិច្ចចំពោះឧបករណ៍ដែលអាចជួញដូរបាន" ប្រព្រឹត្តនៅរាជធានីភ្នំពេញ កាលពីអំឡុងឆ្នាំ២០១៩ ដល់ឆ្នាំ២០២០ បទល្មើសព្រហ្មទណ្ឌដែលមានបញ្ញាត្តិឱ្យផ្តន្ទាទោសតាមបញ្ញាត្តិមាត្រា ២៣១ នៃច្បាប់ស្តីពីឧបករណ៍អាចជួញដូរបាន និងប្រត្តិបត្តិការទូទាត់ប្រាក់ ។

១៧-សាលក្រមព្រហ្មទណ្ឌលេខ ៣៤៧២ "ត" ចុះថ្ងៃទី១៥ ខែវិច្ឆិកា ឆ្នាំ២០២២ របស់សាលាដំបូងរាជធានីភ្នំពេញ បានសម្រេចឱ្យជនជាប់ចោទឈ្មោះ , ឈ្មោះ , ឈ្មោះ និងឈ្មោះ រួចផុតពីបទ ឆបោក គឺជាការត្រឹមត្រូវ ចំណែកឯការសម្រេចឱ្យជនជាប់ចោទឈ្មោះ រួចផុតបទ មិនបំពេញកាតព្វកិច្ចចំពោះឧបករណ៍ដែលអាចជួញដូរបាន ជាការមិនត្រឹមត្រូវឡើយ គប្បីសាលាឧទ្ធរណ៍ភ្នំពេញពិចារណា បដិសេធសាលក្រមត្រង់ចំណុចខ្លះនៃសេចក្តីសម្រេច ហើយសម្រេចជាថ្មី ឱ្យជនជាប់ចោទឈ្មោះ ជាប់ចោទពីបទ មិនបំពេញកាតព្វកិច្ចចំពោះឧបករណ៍ដែលអាចជួញដូរបាន ប្រព្រឹត្តនៅរាជធានីភ្នំពេញ កាលពីអំឡុងឆ្នាំ២០១៩ ដល់ឆ្នាំ២០២០ បទល្មើសព្រហ្មទណ្ឌដែលមានបញ្ញាត្តិឱ្យផ្តន្ទាទោសតាមបញ្ញាត្តិមាត្រា ២៣១ នៃច្បាប់ស្តីពីឧបករណ៍អាចជួញដូរបាន និងប្រត្តិបត្តិការទូទាត់ប្រាក់ ។

១៨-ជនជាប់ចោទឈ្មោះ ជាស្ត្រីមានវ័យចំណាស់ គួរគប្បីសាលាឧទ្ធរណ៍ពិចារណាអំពីទោសព្យួរដល់ជនជាប់ចោទ តាមមាត្រា ១០៧ នៃក្រមព្រហ្មទណ្ឌ ។

## ហេតុដូច្នេះ

## វិនិច្ឆ័យសេចក្តី

១)ក.ទទួលសេចក្តីសុំប្តឹងឧទ្ធរណ៍លេខ ០៧ ចុះថ្ងៃទី១៤ ខែកុម្ភៈ ឆ្នាំ២០២៣ របស់តំណាងមហាអយ្យការអមសាលាឧទ្ធរណ៍ ទុកជាត្រឹមត្រូវតាមច្បាប់ ។

ខ.ទទួលសេចក្តីចម្លងបណ្តឹងឧទ្ធរណ៍លេខ ១៣១៦ ចុះថ្ងៃទី១៣ ខែធ្នូ ឆ្នាំ២០២២ របស់ដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ ទុកជាត្រឹមត្រូវតាមច្បាប់ ។

២).តម្កល់សាលក្រមព្រហ្មទណ្ឌលេខ ៣៤៧២ "ត" ចុះថ្ងៃទី១៥ ខែវិច្ឆិកា ឆ្នាំ២០២២ របស់សាលាដំបូងរាជធានីភ្នំពេញ ទុកជាបានការ លើកលែងចំណុចទី១ នៃសេចក្តីសម្រេចត្រូវបដិសេធចោល ដោយសម្រេចជាថ្មី ៖

-ផ្តន្ទាទោសលើឈ្មោះ ភេទស្រី អាយុ៦៥ឆ្នាំ ដាក់ពន្ធនាគារកំណត់ ០២ (ពីរ) ឆ្នាំ តែទោសនេះត្រូវអនុវត្តទោសព្យួរធម្មតា ពីបទ មិនបំពេញកាតព្វកិច្ចចំពោះឧបករណ៍ដែលអាចជួញដូរបាន ប្រព្រឹត្តនៅរាជធានីភ្នំពេញ កាលពីអំឡុងឆ្នាំ២០១៩ ដល់ឆ្នាំ២០២០ បទល្មើសព្រហ្មទណ្ឌដែលមានបញ្ញាត្តិឱ្យផ្តន្ទាទោសតាមបញ្ញាត្តិមាត្រា ២៣១ នៃច្បាប់ស្តីពីឧបករណ៍អាចជួញដូរបាន និងប្រត្តិបត្តិការទូទាត់ប្រាក់ និងមាត្រា ១០៧ នៃក្រមព្រហ្មទណ្ឌ ។

៣).បង្គាប់ឱ្យឈ្មោះ សងប្រាក់សរុបចំនួន ១០១.៥០០ (ដប់ម៉ឺនមួយពាន់ប្រាំរយ) ដុល្លារអាមេរិក និងសំណងជម្ងឺចិត្តចំនួន ៥.០០០.០០០ (ប្រាំលាន) រៀល ទៅឱ្យដើមបណ្ដឹងរដ្ឋប្បវេណីឈ្មោះ ។

-ការទាមទារលើសពីនេះត្រូវច្រានចោល ។

សាលដីកានេះជំនុំជម្រះជាសាធារណៈនៅថ្ងៃទី០៤ ខែមេសា ឆ្នាំ២០២៤ កំបាំងមុខជនជាប់ចោទតែចាត់ទុកជាចំពោះមុខ ចំពោះមេធាវីការពារសិទ្ធិជនជាប់ចោទ មេធាវីការពារឱ្យដើមបណ្ដឹងរដ្ឋប្បវេណី និងប្រកាសជាសាធារណៈនៅថ្ងៃទី២៩ ខែមេសា ឆ្នាំ២០២៤ បើកសិទ្ធិប្ដឹងសាទុក្ខតាមកំណត់ច្បាប់ ។

| ក្រឡាបញ្ជី | ចៅក្រមប្រឹក្សា | ប្រធានក្រុមប្រឹក្សាជំនុំជំរះ |
|---|---|---|
| ហត្ថលេខា: | ហត្ថលេខា: | ហត្ថលេខា: |

---

បានចំលងត្រឹមត្រូវតាមច្បាប់ដើម

ថ្ងៃ...[illegible]...ខែចេត្រ ឆ្នាំរោង ឆស័ក ព.ស.២៥៦៧

បានឃើញ

ប្រធានក្រុមប្រឹក្សាជំនុំជំរះ

សាលាឧទ្ធរណ៍ភ្នំពេញ ថ្ងៃទី..[illegible]..ខែ.មេសា.ឆ្នាំ២០២៤

ក្រឡាបញ្ជី

# ឧបសម្ព័ន្ធទី៨

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

តុលាការកំពូល

សាលាព្រហ្មទណ្ឌ
សំណុំរឿងព្រហ្មទណ្ឌ
លេខ ១៥៧
ចុះថ្ងៃទី១៦ ខែកក្កដា ឆ្នាំ២០១៩

សាលដីកា
លេខ ២០ IV
ចុះថ្ងៃទី១១ ខែមីនា ឆ្នាំ២០២០

## សាលដីកា
## នាមប្រជារាស្ត្រខ្មែរ
## តុលាការកំពូល

បានបើកសវនាការជាសាធារណៈ នៅថ្ងៃទី០៤ ខែមីនា ឆ្នាំ២០២០
ដោយមានសមាសភាពក្រុមប្រឹក្សាជំនុំជម្រះដូចខាងក្រោម៖

១.ឯកឧត្តម ជាប្រធានក្រុមប្រឹក្សាជំនុំជម្រះ
២.លោក ជាចៅក្រមរបាយការណ៍
៣.លោក ជាចៅក្រម
៤.លោក ជាចៅក្រម
៥.លោកស្រី ជាចៅក្រម

**ក្រឡាបញ្ជីសវនាការ**

-កញ្ញា

**តំណាងមហាអយ្យការ**

-លោក ជាព្រះរាជអាជ្ញា

**ដើម្បីជំនុំជម្រះ**

លើបណ្តឹងសាទុក្ខលេខ ១៥៩ ចុះថ្ងៃទី២៤ ខែមិថុនា ឆ្នាំ២០១៩ របស់ជនជាប់ចោទ ឈ្មោះ ចំពោះសាលដីកាព្រហ្មទណ្ឌលេខ ៥៣ "ក្រ.សរ" ចុះថ្ងៃទី២៤ ខែ ភា ឆ្នាំ២០១៩ របស់សភាព្រហ្មទណ្ឌនៃសាលាឧទ្ធរណ៍ ដែលមាន៖

ជនជាប់ចោទឈ្មោះ ភេទប្រុស អាយុ ៦០ ឆ្នាំ សញ្ជាតិខ្មែរ មុខរបរ ប្រធានក្រុមហ៊ុន PL ទីកន្លែងកំណើតនៅភូ ខេត្តព្រៃវែង ទីលំនៅបច្ចុប្បន្ននៅភូមិ ខេត្តព្រៃវែង ឪពុកឈ្មោះ ម្តាយឈ្មោះ ពន្ធឈ្មោះ មានកូន ០៦ នាក់ ទោសពីមុនគ្មានៗ (អ្នកប្តឹងសាទុក្ខ)

**ជាប់ចោទពីបទ** មិនបំពេញកាតព្វកិច្ចចំពោះឧបករណ៍អាចជួញដូរបាន នៅពេលដល់កាលប្រតិទានដោយបំណង និងមានចេតនាធ្វើឱ្យខូចខាតប្រយោជន៍អ្នកដទៃ ប្រព្រឹត្តនៅភូមិក្រាំងទ្រា ឃុំនិពាន្ធ ស្រុកគងពិសី ខេត្តកំពង់ស្ពឺ កាលពីថ្ងៃទីមិនចាំ ខែមិថុនា ឆ្នាំ២០១៥ បទល្មើសព្រហ្មទណ្ឌមានចែង និងផ្តន្ទាទោសតាមមាត្រា ២៣១ នៃច្បាប់ស្តីពីឧបករណ៍អាចជួញដូរបាន និងប្រតិបត្តិការទូទាត់សងប្រាក់។

**ដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ** ភេទប្រុស អាយុ ៣០ ឆ្នាំ សញ្ជាតិខ្មែរ មុខរបរអាជីវកម្ម មានទីលំនៅបច្ចុប្បន្ននៅភូមិព្រៃចំការខាងជើង ឃុំស្វាយជ្រុំ ស្រុកមេសាង ខេត្តព្រៃវែង។

**អំពីអង្គហេតុ**

កាលពីថ្ងៃទីមិនចាំ ខែមិថុនា ឆ្នាំ២០១៥ ស្ថិតនៅភូមិក្រាំងទ្រា ឃុំនិពាន្ធ ស្រុកគងពិសី ខេត្តកំពង់ស្ពឺ មានករណី មិនបំពេញកាតព្វកិច្ចចំពោះឧបករណ៍អាចជួញដូរបាននៅដល់ពេលកាលប្រតិទានដោយបំណង និងដោយមានចេតនាធ្វើឱ្យខូចខាតប្រយោជន៍អ្នកដទៃមួយបានកើតឡើង ដែលបង្កឡើងដោយឈ្មោះ ពិតប្រាកដមែន។

-បានឃើញសាលក្រមព្រហ្មទណ្ឌលេខ ១៦១ "ខ" ចុះថ្ងៃទី១០ ខែឧសភា ឆ្នាំ២០១៨ របស់សាលាដំបូងខេត្តកំពង់ស្ពឺ ដែលមានខ្លឹមសារនៃសេចក្តីសម្រេចដូចតទៅ៖

១.ផ្តន្ទាទោសជនជាប់ចោទឈ្មោះ ភេទប្រុស អាយុ ៦០ ឆ្នាំ (ដែលមានសញ្ជាតិជួចខាងលើ) ដាក់ពន្ធនាគារកំណត់រយៈពេល ០១ ឆ្នាំ តែទោសនេះត្រូវព្យួរសាកល្បងរយៈពេល ០៣ ឆ្នាំ ពីបទ មិនបំពេញកាតព្វកិច្ច ចំពោះឧបករណ៍អាចជួញដូរបាន នៅពេលដល់កាលប្រតិទានដោយបំណង និងដោយមានចេតនាធ្វើឱ្យខូចខាតប្រយោជន៍អ្នកដទៃ ប្រព្រឹត្តនៅភូមិក្រាំងទ្រា ឃុំព្រះនិពាន្ធ ស្រុកគងពិសី ខេត្តកំពង់ស្ពឺ កាលពីអំឡុងខែមិថុនា ឆ្នាំ២០១៧ បទល្មើសព្រហ្មទណ្ឌដែលមានចែងឱ្យផ្តន្ទាទោសតាមបញ្ញត្តិមាត្រា ២៣១ នៃច្បាប់ស្តីពីឧបករណ៍អាចជួញដូរបាន និងប្រតិ។ត្តិការទូទាត់សងប្រាក់។

២.បង្គាប់ឱ្យជនជាប់ចោទឈ្មោះ សងប្រាក់ចំនួន ៨ ០០០ (ប្រាំបីពាន់ដុល្លារ) ទៅដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ ។

សាលក្រមនេះជំនុំជម្រះ នៅថ្ងៃទី១៩ ខែមេសា ឆ្នាំ២០១៨ តែងប្រកាសជាសាធារណៈ នៅថ្ងៃទី១០ ខែឧសភា ឆ្នាំ២០១៨ ចំពោះមុខជនជាប់ចោទឈ្មោះ និងចំពោះមុខដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ បើកសិទ្ធិប្តឹងឧទ្ធរណ៍តាមកំណត់ច្បាប់។

-បានឃើញបណ្តឹង។ទ្ធរណ៍លេខ ៤៩ ចុះថ្ងៃទី២២ ខែឧសភា ឆ្នាំ២០១៨ របស់ដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ ប្តឹងមិនសុខចិត្តទៅនឹងសាលក្រមព្រហ្មទណ្ឌលេខ ១៦១ "ខ" ចុះថ្ងៃទី១០ ខែឧសភា ឆ្នាំ២០១៨ របស់សាលាដំបូងខេត្តកំពង់ស្ពឺ ត្រង់ចំណុចទាំងមូលនៃសេចក្តីសម្រេច។

-បានឃើញបណ្តឹងឧទ្ធរណ៍លេខ៥៤ ចុះថ្ងៃទី០៦ ខែមិថុនា ឆ្នាំ២០១៨ របស់ជនជាប់ចោទ ឈ្មោះ                ប្តឹងមិនសុខចិត្តទៅនឹងសាលក្រមព្រហ្មទណ្ឌលេខ ១៦១ "ខ" ចុះថ្ងៃទី១០ ខែឧសភា ឆ្នាំ២០១៨ របស់សាលាដំបូងខេត្តកំពង់ស្ពឺ ត្រង់ចំណុចទាំងមូលនៃសេចក្តីសម្រេច។

-បានឃើញសាលដីកាព្រហ្មទណ្ឌលេខ ៥៣"ក្រ.សព ចុះថ្ងៃទី២៤ ខែឧសភា ឆ្នាំ២០១៩ របស់សាលាឧទ្ធរណ៍ ដែលមានខ្លឹមសារនៃសេចក្តីសម្រេចដូចតទៅ៖

១.ទទួលបណ្តឹងឧទ្ធរណ៍លេខ ៤៩ ចុះថ្ងៃទី២៤ ខែឧសភា ឆ្នាំ២០១៧ របស់ដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ                និងបណ្តឹងឧទ្ធរណ៍លេខ ៥៤ ចុះថ្ងៃទី០៦ ខែមិថុនា ឆ្នាំ២០១៨ របស់ជនជាប់ចោទឈ្មោះ                ទុកជាត្រឹមត្រូវតាមទម្រង់ច្បាប់ តែបដិសេធចោលដោយខាស់គតិច្បាប់។

២.តម្កល់សាលក្រមព្រហ្មទណ្ឌលេខ ១៦១ "ខ" ចុះថ្ងៃទី១០ ខែឧសភា ឆ្នាំ២០១៨ របស់សាលាដំបូងខេត្តកំពង់ស្ពឺ ទុកជាបានការ។

សាលដីកានេះ ជំនុំជម្រះថ្ងៃទី០៩ ខែឧសភា ឆ្នាំ២០១៩ និងប្រកាសជាសាធារណៈថ្ងៃទី២៤ ខែឧសភា ឆ្នាំ២០១៩ ចំពោះមុខជនជាប់ចោទ និងកំបាំងមុខដើមបណ្តឹងរដ្ឋប្បវេណី។

បើកសិទ្ធិប្តឹងតាមក្នុងកំណត់ច្បាប់។

-បានឃើញបណ្តឹងសាទុក្ខលេខ ១៥៩ ចុះថ្ងៃទី២៤ ខែមិថុនា ឆ្នាំ២០១៩ របស់ជនជាប់ចោទឈ្មោះ                ប្តឹងមិនសុខចិត្តនឹងសាលដីកាព្រហ្មទណ្ឌលេខ ៥៣"ក្រ.សព ចុះថ្ងៃទី២៤ ខែឧសភា ឆ្នាំ២០១៩ របស់សាលាឧទ្ធរណ៍ ត្រង់ចំណុចទាំងមូលនៃសេចក្តីសម្រេច។

**នាពេលសវនាការ**

-បានស្តាប់របាយការណ៍របស់ចៅក្រមរបាយការណ៍

-តំណាងមហាអយ្យការអមតុលាការកំពូលសន្និដ្ឋានថា ជនជាប់ចោទ បានសារភាពថាពិតជាបានចេញសែកដែលបានលើកឡើងថា មុនទៅដកប្រាក់មួយថ្ងៃឱ្យប្រាប់ទៅផង ព្រោះមិនទាន់មានប្រាក់ក្នុងសែកនោះទេ តែដុយទៅវិញខ្លួនមិនបានយកប្រាក់ទៅដាក់នៅពេលដែលដើមបណ្តឹងរដ្ឋប្បវេណីទៅដក ក៏គ្មានប្រាក់ដមែន ហេតុដូច្នេះសែកនោះ គឺពិតជាបានចេញថ្ងៃកក់ដីតែគ្មានប្រាក់ទេ។

ហេតុដូច្នេះ តំណាងមហាអយ្យការប្តឹងសុំចំពោះតុលាការកំពូលឱ្យ:

១.បណ្តឹងសាទុក្ខលេខ ១៥៩ ចុះថ្ងៃទី២៤ ខែមិថុនា ឆ្នាំ២០១៩ របស់ឈ្មោះ                ទុកជាត្រឹមត្រូវតាមទម្រង់ច្បាប់ តែបដិសេធចោលដោយ ខុសទៅនឹងគតិច្បាប់។

២.តម្កល់ សាលដីកាព្រហ្មទណ្ឌលេខ ៥៣"ក្រ.សព ចុះថ្ងៃទី២៤ ខែឧសភា ឆ្នាំ២០១៩ របស់សាលាឧទ្ធរណ៍ ទុកជាបានការដដែល។

-ក្រឡាបញ្ជីអានសារណាការពាររបស់ជនជាប់ចោទឈ្មោះ ។

-ដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ បានឆ្លើយថា ពាក់ព័ន្ធនឹងប្រាក់ជនជាប់ចោទបានសន្យាថា នឹងឱ្យមកខ្ញុំនវើបខ្ញុំនព្រមធ្វើការឱ្យ។ ជនជាប់ចោទជំពាក់ប្រាក់ខ្ញុំនជាង ៣០ ០០០ (បីម៉ឺន) ដុល្លារអាមេរិក ជនជាប់ចោទបានឱ្យសែកមកខ្ញុំនតែសែកនោះគ្មានសាច់ប្រាក់ទេ ហើយសន្យាថា និងសងខ្ញុំនបណ្តើរ។ ប៉ុន្តែគាត់មិនបានធ្វើតាមសន្យានោះទេ ទើបខ្ញុំនប្តឹងមកតុលាការតែម្តង។ នៅសាលាដំបូងគាត់ក៏បានទទួលស្គាល់ដែលថា គាត់ជំពាក់ប្រាក់ខ្ញុំនពិតប្រាកដមែន, ខ្ញុំនសុខចិត្តយកប្រាក់ចំនួន ៨ ០០០ (ប្រាំបីពាន់) ដុល្លារអាមេរិក ដើម្បីបញ្ចប់រឿង តែជនជាប់ចោទនៅតែមិនព្រម។ ខ្ញុំនសំណូមពរ សុំឱ្យតុលាការកំពូលមេត្តាសម្រេចតាមច្បាប់ និងសុំឱ្យចាប់ខ្ញុំនជនជាប់ចោទ ដើម្បីឱ្យជនជាប់ចោទសងប្រាក់ខ្ញុំន។

-ក្រោយពីបានស្តាប់របាយការណ៍ របស់ចៅក្រមរបាយការណ៍

-ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានរបស់តំណាងមហាអយ្យការ

-ក្រោយពីបានស្តាប់មូលហេតុនៃបណ្តឹងសាទុក្ខរបស់ជនជាប់ចោទ និងចម្លើយដើមបណ្តឹងរដ្ឋប្បវេណី

-ក្រោយពីបានពិភាក្សាត្រឹមត្រូវតាមច្បាប់ហើយ

**សំអាងហេតុ**

១.យល់ឃើញថា បណ្តឹងសាទុក្ខលេខ ១៥៩ ចុះថ្ងៃទី២៤ ខែមិថុនា ឆ្នាំ២០១៩ របស់ជនជាប់ចោទ ធ្វើឡើងក្នុងកំណត់ច្បាប់ តុលាការកំពូលអាចលើករឿងនេះមកជំនុំជម្រះបាន តាមមាត្រា ៦៤ នៃច្បាប់ស្តីពីការរៀបចំអង្គការតុលាការ មាត្រា ៤១៧ និងមាត្រា ៤២០ នៃក្រមនីតិវិធីព្រហ្មទណ្ឌ។

២.យល់ឃើញថា តាមសារណាបញ្ជាក់អំពីមូលហេតុនៃបណ្តឹងសាទុក្ខរបស់ជនជាប់ចោទ បានសុំឱ្យតុលាការកំពូល ផ្តល់យុត្តិធម៌ដល់រូបខ្ញុំន ដោយលើកយកមូលហេតុថា ខ្ញុំនពុំបានតាំងចិត្តធ្វើឱ្យខូចខាតផលប្រយោជន៍របស់ដើមបណ្តឹងរដ្ឋប្បវេណីនោះទេ ការចេញមូលប្បទានប័ត្រគ្មានសាច់ប្រាក់នេះ ដោយសារដើមបណ្តឹងរដ្ឋប្បវេណីជាអ្នកស្នើសុំឱ្យចេញឱ្យគាត់ដើម្បីដាក់ធានា និងបញ្ជាក់ថា ខ្ញុំនជំពាក់ប្រាក់គាត់ ហើយក្រោយមកបន្ទាប់ពីបានឯកភាពគ្នា ខ្ញុំនបានសងប្រាក់ទៅគាត់បានពីរដងចំនួន ១៤ ០០០ ដុល្លារ ទើបដឹងថា គាត់ដាក់ពាក្យប្តឹង នោះ តុលាការកំពូលពិនិត្យឃើញថា អំពើរបស់ជនជាប់ចោទ ដែលបានដឹងថាគណនីរបស់ខ្ញុំនគ្មានទឹកប្រាក់គ្រប់គ្រាន់នៅតែចេញមូលប្បទានប័ត្រ ដែលគ្មានសាច់ប្រាក់ទៅឱ្យដើមបណ្តឹងរដ្ឋប្បវេណី បានបង្ហាញពីចេតនាទុច្ចរិតធ្វើឱ្យដើមបណ្តឹងរដ្ឋប្បវេណី ទទួលរងនូវការខូចខាតប្រយោជន៍ ដែលជាធាតុផ្សំនៃបទ មិនបំពេញកាតព្វកិច្ចចំពោះឧបករណ៍អាចជួញដូរបាន នៅពេលដល់ឥណប្រតិទានដោយបំណង និងដោយមានចេតនាធ្វើឱ្យខូចខាត

ប្រយោជន៍អ្នកដទៃ បទល្មើសព្រហ្មទណ្ឌមានចែង និង ផ្តន្ទាទោសតាមមាត្រា ២៣១ នៃច្បាប់ស្តីពីឧបករណ៍អាចជួញដូរបាន និង ប្រតិបត្តិការទូទាត់សងប្រាក់។ ចំណែក ការសម្រេចផ្តន្ទាទោស ០១ ឆ្នាំព្យួរសាកល្បង ៣ ឆ្នាំ ស្ថិតក្នុងកម្រិតអប្បបរមា ជាការផ្តល់ស្ថានសម្រាលទោសដល់ជនជាប់ចោទហើយ ឃើញថា បណ្តឹងសាទុក្ខរបស់ជនជាប់ចោទ មានមូលហេតុមិនត្រូវនឹងចំណុចណាមួយដូចមានកំណត់ក្នុងមាត្រា ៤១៩ នៃក្រមនីតិវិធីព្រហ្មទណ្ឌឡើយ។

៣.យល់ឃើញថា សាលដីកាព្រហ្មទណ្ឌលេខ ៥៣ "ក្រ.សរ" ចុះថ្ងៃទី២៤ ខែឧសភា ឆ្នាំ២០១៩ របស់សភាព្រហ្មទណ្ឌសាលាឧទ្ធរណ៍ភ្នំពេញ ដែលបានសម្រេចសេចក្តីមកនេះ ត្រឹមត្រូវតាមច្បាប់។

**ហេតុដូច្នេះ**

**សម្រេច**

**១.បដិសេធ** បណ្តឹងសាទុក្ខលេខ ១៥៩ ចុះថ្ងៃទី២៤ ខែមិថុនា ឆ្នាំ២០១៩ របស់ជនជាប់ចោទ ។

**២.តម្កល់** សាលដីកាព្រហ្មទណ្ឌលេខ ៥៣ "ក្រ.សរ" ចុះថ្ងៃទី២៤ ខែឧសភា ឆ្នាំ២០១៩ របស់សភាព្រហ្មទណ្ឌសាលាឧទ្ធរណ៍ភ្នំពេញ ទាំងមូល។

សាលដីកានេះ បានជំនុំជម្រះជាសាធារណៈ នៅថ្ងៃទី០៤ ខែមីនា ឆ្នាំ២០២០ និង ប្រកាសនាសវនាការជាសាធារណៈ នៅថ្ងៃទី១១ ខែមីនា ឆ្នាំ២០២០។

# ឧបសម្ព័ន្ធទី៩

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

តុលាការកំពូល

## សាលដីកា

## នាមប្រជារាស្ត្រខ្មែរ

## តុលាការកំពូល

សភាព្រហ្មទណ្ឌ

សំណុំរឿងព្រហ្មទណ្ឌ

លេខ ៣៥៨

ចុះថ្ងៃទី១៤ ខែធ្នូ ឆ្នាំ២០២១

សាលដីកា

លេខ ៣៥១ I

ចុះថ្ងៃទី២៩ ខែកក្កដា ឆ្នាំ២០២២

**បានបើកសវនាការជាសាធារណៈ នៅថ្ងៃទី២២ ខែកក្កដា ឆ្នាំ២០២២**

**ដោយមានសមាសភាពអង្គជំនុំជម្រះដូចខាងក្រោម៖**

**១-ឯកឧត្តម** **ជាប្រធាន**

**២-ឯកឧត្តម** **ជាចៅក្រម**

**៣-ឯកឧត្តម** **ជាចៅក្រម**

**៤-លោកជំទាវ** **ជាចៅក្រម**

**៥-ឯកឧត្តម** **ជាចៅក្រម**

**ចៅក្រមរបាយការណ៍**

**ឯកឧត្តម**

**ក្រឡាបញ្ជីសវនាការ**

**លោក**

**តំណាងមហាអយ្យការ**

**ឯកឧត្តម** **ឋានៈជាព្រះរាជអាជ្ញា**

**ដើម្បីជំនុំជម្រះ**

**លើបណ្តឹងសាទុក្ខលេខ ៣៧៥ ចុះថ្ងៃទី០៣ ខែធ្នូ ឆ្នាំ២០២១** របស់ឯកឧត្តមអគ្គព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍ភ្នំពេញ, **បណ្តឹងសាទុក្ខលេខ ៣៩៥ ចុះថ្ងៃទី១០ ខែធ្នូ ឆ្នាំ២០២១** របស់ឯកឧត្តមអគ្គព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍ភ្នំពេញ, **បណ្តឹងសាទុក្ខលេខ ៣៧១ ចុះថ្ងៃទី០៣ ខែធ្នូ ឆ្នាំ២០២១** របស់ជនជាប់ចោទឈ្មោះ និងឈ្មោះ **និងលើបណ្តឹងសាទុក្ខលេខ ៣៩៤ ចុះថ្ងៃទី០៨ ខែធ្នូ ឆ្នាំ២០២១** របស់លោក ជាមេធាវីទទួលសិទ្ធិតំណាងក្នុងការប្តឹងសាទុក្ខឱ្យជនជាប់ចោទឈ្មោះ ឈ្មោះ និងឈ្មោះ ចំពោះសាលដីកាលេខ ១១០ ក្រ V "វ" ចុះថ្ងៃទី១២ ខែវិច្ឆិកា ឆ្នាំ២០២១ របស់សភាព្រហ្មទណ្ឌនៃសាលាឧទ្ធរណ៍ភ្នំពេញដែលមាន៖

**-បុគ្គលប្តឹងសាទុក្ខ ៖**

១-ឯកឧត្តមអគ្គព្រះរាជអាជ្ញានៃមហាអយ្យការអមសាលាឧទ្ធរណ៍ភ្នំពេញ ។

២-ឈ្មោះ ភេទប្រុស កើតនៅថ្ងៃទី១៥ ខែកក្កដា ឆ្នាំ១៩៦៩ កាន់អត្តសញ្ញាណប័ណ្ណខ្មែរលេខ០២០ ២៥៩១១៨ សាសនាព្រះពុទ្ធ មុខរបរប្រធានសហភាពសហជីព និងជាទីប្រឹក្សាសមាគមគ្រូបង្រៀនឯករាជ្យ ទីកន្លែងកំណើតនៅភូមិចុងកោះតូច ឃុំតាលន់ ស្រុកស្អាង ខេត្តកណ្តាល មានលំនៅបច្ចុប្បន្នផ្ទះលេខ៨៨ ផ្លូវលេខ៩ ភូមិទួលរការ សង្កាត់ចាក់អង្រែក្រោម ខណ្ឌមានជ័យ រាជធានីភ្នំពេញ ។ ឪពុកឈ្មោះ ម្តាយឈ្មោះ (ស) ។ នៅលីវ។ ប្រវត្តិផ្តន្ទាទោសដោយតុលាការគ្មាន។

-ឃុំខ្លួនថ្ងៃទី០១ ខែសីហា ឆ្នាំ២០២០ នៅមន្ទីរអប់រំកែប្រែទី១ (ម-១ ព្រៃស) ។

**-មេធាវីការពារសិទ្ធិ ៖ លោក** ។

៣-ឈ្មោះ ភេទស្រី កើតនៅថ្ងៃទី០៧ ខែវិច្ឆិកា ឆ្នាំ១៩៨៣ កាន់អត្តសញ្ញាណប័ណ្ណខ្មែរលេខ ០២១០៦៣៨៨ សាសនាព្រះពុទ្ធ មុខរបរលក់ដូរ កម្រិតវប្បធម៌រៀនថ្នាក់ទី៦ ទីកន្លែងកំណើតនៅភូមិតាខ្នង ឃុំព្រែកតាខ្នង ស្រុកកោះសូទិន ខេត្តកំពង់ចាម មានលំនៅបច្ចុប្បន្នផ្ទះលេខ១៦១E1C ផ្លូវលេខ២០៣ ភូមិតាខ្មៅ១ សង្កាត់តាខ្មៅ ក្រុងតាខ្មៅ ខេត្តកណ្តាល។ ឪពុកឈ្មោះ ម្តាយឈ្មោះ ប្រវត្តិផ្តន្ទាទោសដោយតុលាការគ្មាន។

-ឃុំខ្លួនថ្ងៃទី០៧ ខែសីហា ឆ្នាំ២០២០ នៅមន្ទីរអប់រំកែប្រែទី១ (ម-២ ព្រៃស) ។

**-មេធាវីការពារសិទ្ធិ ៖ លោក** ។

៤-ឈ្មោះ កើតនៅថ្ងៃទី០៧ ខែឧសភា ឆ្នាំ១៩៨១ ជនជាតិខ្មែរ សាសនាព្រះពុទ្ធ មុខរបររត់កង់បី កម្រិតវប្បធម៌រៀនថ្នាក់ទី៧ ទីកន្លែងកំណើតនៅភូមិកោះថ្មី ឃុំខ្ពប ស្រុកស្អាង ខេត្តកណ្តាល មានលំនៅបច្ចុប្បន្ននៅភូមិព្រែកតាពៅ សង្កាត់ដើមមៀន ក្រុងតាខ្មៅ ខេត្តកណ្តាល។ ឪពុកឈ្មោះ ម្តាយឈ្មោះ (រ) ប្រពន្ធឈ្មោះ មានកូន ០៣ នាក់ ប្រវត្តិផ្តន្ទាទោសដោយតុលាការគ្មាន ។

-ឃុំខ្លួនថ្ងៃទី១៨ ខែសីហា ឆ្នាំ២០២១ នៅមន្ទីរអប់រំកែប្រែទី១ (ម-១ ព្រៃស) ។

**ជាប់ចោទពីបទញុះញង់បង្កឱ្យមានភាពវឹកវរធ្ងន់ធ្ងរដល់សន្តិសុខសង្គម** ប្រព្រឹត្តនៅប្រទេសកម្ពុជា កាលពីថ្ងៃទី២០ និងថ្ងៃទី២១ ដល់ថ្ងៃទី៣១ ខែកក្កដា ឆ្នាំ២០២០ បទល្មើសដែលមានចែងនិងឱ្យផ្តន្ទាទោសតាមមាត្រា ៤៩៤ និងមាត្រា ៤៩៥ នៃក្រមព្រហ្មទណ្ឌ។

**ដើមបណ្តឹងរដ្ឋប្បវេណី ៖ គណៈកម្មាធិការចម្រុះកិច្ចការព្រំដែន** មានការិយាល័យស្ថិតនៅអគារទីស្តីការគណៈរដ្ឋមន្ត្រី ផ្លូវសហព័ន្ធរុស្ស៊ី សង្កាត់មិត្តភាព ខណ្ឌ៧មករា រាជធានីភ្នំពេញ។

មានមេធាវី និងមេធាវី ជាតំណាង ។

**-អំពីអង្គហេតុ**

កាលពីថ្ងៃទី២០ ខែកក្កដា ឆ្នាំ២០២០ ឈ្មោះ និងបក្ខពួកបានចុះទៅភូមិត្រពាំងផ្លុង ឃុំត្រពាំងផ្លុង ស្រុកពញាក្រែក ខេត្តត្បូងឃ្មុំ ជួបជាមួយប្រជាពលរដ្ឋចំនួន ១០គ្រួសារ និងធ្វើការពិនិត្យលើបង្គោលព្រំដែនប្រទេសកម្ពុជា-វៀតណាម នៅបង្គោលលេខ១១៤ ដល់បង្គោលលេខ១១៩ ដែលដាំនៅចន្លោះដីទំហំ ៦០ ហិកតា។ បន្ទាប់មកឈ្មោះ បានចេញសេចក្តីថ្លែងការណ៍ចុះថ្ងៃទី២១ ខែកក្កដា ឆ្នាំ២០២០ ដែលមានខ្លឹមសារបំផុសបំផុលនិងញុះញង់ឱ្យប្រជាពលរដ្ឋខ្មែរមានភាពច្របូកច្របល់ បង្កចលាចល និងភាពវឹកវរធ្ងន់ធ្ងរដល់សន្តិសុខសង្គមនិងសណ្តាប់ធ្នាប់

សាធារណៈ ដែលបានធ្វើការបំផ្លើសខុសពីការពិត និងមានការគាំទ្រពីឈ្មោះ និងឈ្មោះ ផង ដែរ សកម្មភាពរបស់ជនជាប់ចោទទាំងនេះបានធ្វើការផ្សព្វផ្សាយតាមរយៈគេហទំព័ររបស់ឈ្មោះ ដែលមានខ្លឹមសារសំខាន់ៗដូចខាងក្រោមនេះ៖

"កាលពីថ្ងៃទី២០ ខែកក្កដា ឆ្នាំ២០២០ តំណាងក្រុមប្រឹក្សាឃ្លាំមើលបានដឹកនាំក្រុមការងារចុះទៅពិនិត្យផ្ទាល់កន្លែងដីមានទំនាស់របស់ប្រជាពលរដ្ឋនិងបង្គោលព្រំដែនលេខ១១៤ ដល់បង្គោលលេខ១១៩ ស្ថិតនៅភូមិត្រពាំងផ្លុង ឃុំត្រពាំងផ្លុង ស្រុកពញាក្រែក ខេត្តត្បូងឃ្មុំ ហើយក៏បានជួបសំណេះសំណាលជាមួយតំណាងប្រជាពលរដ្ឋដែលរងគ្រោះប្រមាណជា ១០៦ គ្រួសារ..." ។

"ក្រុមប្រឹក្សាឃ្លាំមើលកម្ពុជាយល់ឃើញថា ប្រជាពលរដ្ឋរងគ្រោះដែលបាត់បង់ដីធ្លីជាច្រើនទៅភាគីយួន បន្ទាប់ពីបោះបង្គោលព្រំដែនរួច នៅសល់ដីតិចតួច គួរត្រូវបានរាជរដ្ឋាភិបាលកម្ពុជាផ្តល់សិទ្ធិឱ្យពួកគាត់អាស្រ័យផលនៅលើដីនោះ ។ លើសពីនេះ ចំពោះទង្វើរបស់អាជ្ញាធរយួនដែលរុញច្រានប្រជាពលរដ្ឋខ្មែរប្រមាណជា ២០០ ម៉ែត្រក្នុងទឹកដីខ្មែរ គឺជាការរំលោភបំពានមកលើអធិបតេយ្យភាពនៃកម្ពុជា ។ ក្រុមប្រឹក្សាឃ្លាំមើលកម្ពុជាសូមឱ្យរាជរដ្ឋាភិបាលកម្ពុជាពង្រឹងនូវកម្លាំងការពារតាមខ្សែបន្ទាត់ព្រំដែនកុំឱ្យកម្លាំងអាជ្ញាធរប្រទេសជិតខាងចូលមកក្នុងដែនអធិបតេយ្យ-ភាពនៃកម្ពុជាយើងបន្តទៀត និងត្រូវផ្តល់ដីប្រមាណជា ៦០ ហិកតា ដែលកំពុងមានជម្លោះជូនប្រជាពលរដ្ឋធ្វើស្រែចម្ការនិងផ្តល់កម្មសិទ្ធិជូនពួកគាត់វិញ" ។

យោងតាមភស្តុតាងជាសកម្មភាពនិងខ្លឹមសារដែលដកស្រង់ចេញពីគេហទំព័រ RONG CHHUN បានបញ្ជាក់ឱ្យឃើញថា ឈ្មោះ បានធ្វើសកម្មភាពដែលបានប្រើឈ្មោះជាតំណាងក្រុមប្រឹក្សាឃ្លាំមើលកម្ពុជាដោយខុសច្បាប់នោះ គឺធ្វើឡើងដើម្បីបង្កឱ្យមានភាពអសន្តិសុខ ហើយត្រូវបានបដិសេធនិងទាត់ចោលទាំងស្រុងនូវការផ្សាយព័ត៌មានមិនពិត បំផ្លើសការពិត របស់ឈ្មោះ តាមសេចក្តីថ្លែងការណ៍លេខពិសេស ៤ អ.ជ.ព.ដ ចុះថ្ងៃទី៣១ ខែកក្កដា ឆ្នាំ២០២០ របស់គណៈកម្មាធិការចម្រុះកិច្ចការព្រំដែន។

**-បានឃើញ សាលក្រមព្រហ្មទណ្ឌលេខ ២៥៦៣ "រ" ចុះថ្ងៃទី១៨ ខែសីហា ឆ្នាំ២០២១ របស់សាលាដំបូងរាជធានីភ្នំពេញ ដែលមានខ្លឹមសារនៃសេចក្តីសម្រេចដូចតទៅ៖**

១-ផ្តន្ទាទោសលើជនជាប់ចោទ៖

១.១-ឈ្មោះ ភេទប្រុស កើតនៅថ្ងៃទី១៥ ខែកក្កដា ឆ្នាំ១៩៦៩ ជនជាតិខ្មែរ មានអត្តសញ្ញាណខាងលើដាក់ពន្ធនាគារកំណត់រយៈពេល ២ (ពីរ) ឆ្នាំ និងពិន័យជាប្រាក់ចំនួន ២.០០០.០០០ (ពីរលាន) រៀល។

១.២-ឈ្មោះ ភេទស្រី កើតនៅថ្ងៃទី០៧ ខែវិច្ឆិកា ឆ្នាំ១៩៨៣ ជនជាតិខ្មែរ មានអត្តសញ្ញាណខាងលើដាក់ពន្ធនាគារកំណត់រយៈពេល ២០ (ម្ភៃ) ខែ និងពិន័យជាប្រាក់ចំនួន ២.០០០.០០០ (ពីរលាន) រៀល។

១.៣-ឈ្មោះ ភេទប្រុស កើតនៅថ្ងៃទី០៧ ខែឧសភា ឆ្នាំ១៩៨១ ជនជាតិខ្មែរ មានអត្តសញ្ញាណខាងលើដាក់ពន្ធនាគារកំណត់រយៈពេល ២០ (ម្ភៃ) ខែ និងពិន័យជាប្រាក់ចំនួន ២.០០០.០០០ (ពីរលាន) រៀល។

ពីបទ**ញុះញង់បង្កឱ្យមានភាពវឹកវរធ្ងន់ធ្ងរដល់សន្តិសុខសង្គម** ប្រព្រឹត្តនៅប្រទេសកម្ពុជា កាលពីថ្ងៃទី២០ និងថ្ងៃទី២១ ដល់ថ្ងៃទី៣១ ខែកក្កដា ឆ្នាំ២០២០ បទល្មើសដែលមានចែងនិងផ្តន្ទាទោសតាមមាត្រា ៤៩៤ និងមាត្រា ៤៩៥ នៃក្រមព្រហ្មទណ្ឌ។

២-បង្គាប់ឱ្យឃុំខ្លួនលើជនជាប់ចោទឈ្មោះ ភេទប្រុស កើតនៅឆ្នាំ១៩៨២ ជនជាតិខ្មែរ មានអត្តសញ្ញាណដូចខាងលើ ។

៣-បង្គាប់ឱ្យជនជាប់ចោទឈ្មោះ ឈ្មោះ និងឈ្មោះ រួមគ្នាសងសំណងការខូចខាតចំនួន ៤០០.០០០.០០០ (បួនរយលាន) រៀល ទៅឱ្យគណៈកម្មាធិការចម្រុះកិច្ចការព្រំដែន ។ ការទាមទារលើសពីនេះច្រានចោល។

សាលក្រមនេះជំនុំជម្រះជាសាធារណៈ នៅថ្ងៃទី១៥ ខែមករា ឆ្នាំ២០២១, ថ្ងៃទី០៣ ខែកុម្ភៈ ឆ្នាំ២០២១, ថ្ងៃទី១៧ ខែកុម្ភៈ ឆ្នាំ២០២១ និងថ្ងៃទី៣០ ខែកក្កដា ឆ្នាំ២០២១ ចំពោះមុខជនជាប់ចោទ និងប្រកាសជាសាធារណៈនៅថ្ងៃទី១៨ ខែសីហា ឆ្នាំ២០២១ ។ ទុកសិទ្ធិប្តឹងឧទ្ធរណ៍តាមកំណត់ច្បាប់។

**-បានឃើញ ពាក្យបណ្តឹងឧទ្ធរណ៍លេខ ៦៣៧ ចុះថ្ងៃទី២៥ ខែសីហា ឆ្នាំ២០២១ របស់លោក ជាមេធាវីការពារសិទ្ធិឱ្យជនជាប់ចោទឈ្មោះ , ឈ្មោះ និងឈ្មោះ ក្នុងការប្តឹងឧទ្ធរណ៍ ដែលប្តឹងមិនសុខចិត្តនឹងសាលក្រមព្រហ្មទណ្ឌលេខ ២៥៦៣ "រ" ចុះថ្ងៃទី១៨ ខែសីហា ឆ្នាំ២០២០ របស់សាលាដំបូងរាជធានីភ្នំពេញ គ្រប់ចំណុចនៃសេចក្តីសម្រេចទាំងមូល។**

**-បានឃើញ ពាក្យបណ្តឹងឧទ្ធរណ៍លេខ ៦៥៣ ចុះថ្ងៃទី៣០ ខែសីហា ឆ្នាំ២០២១ របស់លោក ជាមេធាវីការពារសិទ្ធិឱ្យជនជាប់ចោទឈ្មោះ ក្នុងការប្តឹងឧទ្ធរណ៍ ដែលប្តឹងមិនសុខចិត្តនឹងសាលក្រមព្រហ្មទណ្ឌលេខ ២៥៦៣ "រ" ចុះថ្ងៃទី១៨ ខែសីហា ឆ្នាំ២០២០ របស់សាលាដំបូងរាជធានីភ្នំពេញ គ្រប់ចំណុចនៃសេចក្តីសម្រេចទាំងមូល។**

**-បានឃើញ សាលដីកាព្រហ្មទណ្ឌលេខ ១១០ ក្រV "រ" ចុះថ្ងៃទី១២ ខែវិច្ឆិកា ឆ្នាំ២០២១ របស់សាលាឧទ្ធរណ៍ភ្នំពេញដែលមានខ្លឹមសារនៃសេចក្តីសម្រេចដូចតទៅ៖**

១-ទទួលបណ្តឹងឧទ្ធរណ៍លេខ **៦៣៧** ចុះថ្ងៃទី២៥ ខែសីហា ឆ្នាំ២០២១ របស់លោក ជាមេធាវីការពារសិទ្ធិឱ្យជនជាប់ចោទឈ្មោះ ឈ្មោះ ឈ្មោះ និងបណ្តឹងឧទ្ធរណ៍លេខ **៦៥៣** ចុះថ្ងៃទី៣០ ខែសីហា ឆ្នាំ២០២១ របស់លោក ជាមេធាវីការពារសិទ្ធិឱ្យជនជាប់ចោទឈ្មោះ ឈ្មោះ **ស គណិការ** ទុកជាត្រឹមត្រូវបានច្បាប់។

២-តម្កល់សាលក្រមព្រហ្មទណ្ឌលេខ **២៥៦៣ "រ"** ចុះថ្ងៃទី១៨ ខែសីហា ឆ្នាំ២០២១ របស់សាលាដំបូងរាជធានីភ្នំពេញទុកជាបានការ លើកលែងតែ៖

ក.ចំណុចទី១-១ ដែលផ្តន្ទាទោសលើជនជាប់ចោទឈ្មោះ ដាក់ពន្ធនាគារកំណត់រយៈពេល ០២ (ពីរ) ឆ្នាំ ត្រូវកែប្រែមកជាទោសនេះត្រូវអនុវត្តក្នុងពន្ធនាគារកំណត់រយៈពេល ០១ (មួយ) ឆ្នាំ ០៣ (បី) ខែ ១១ (ដប់មួយ) ថ្ងៃ ។ ទោសដែលនៅសល់ត្រូវព្យួរទោសសាកល្បងដោយកំណត់រយៈពេល ០៣ (បី) ឆ្នាំ ។

ខ.ចំណុចទី១-២ ដែលផ្តន្ទាទោសលើជនជាប់ចោទឈ្មោះ ដាក់ពន្ធនាគារកំណត់រយៈពេល ២០ (ម្ភៃ) ខែ ត្រូវកែប្រែមកជាទោសនេះត្រូវអនុវត្តក្នុងពន្ធនាគារកំណត់រយៈពេល ០១ (មួយ) ឆ្នាំ ០៣ (បី) ខែ ០៥ (ប្រាំ) ថ្ងៃ ។ ទោសដែលនៅសល់ត្រូវព្យួរទោសសាកល្បងដោយកំណត់រយៈពេល ០៣ (បី) ឆ្នាំ។

គ.ចំណុចទី១-៣ ដែលផ្តន្ទាទោសលើជនជាប់ចោទឈ្មោះ ដាក់ពន្ធនាគារកំណត់រយៈពេល ២០ (ម្ភៃ) ខែ ត្រូវកែប្រែមកជាទោសនេះត្រូវអនុវត្តក្នុងពន្ធនាគារកំនត់រយៈពេល ០២ (ពីរ) ខែ ២៤ (ម្ភៃបួន) ថ្ងៃ ។ ទោសដែលនៅសល់ត្រូវព្យួរទោសសាកល្បងដោយកំណត់រយៈពេល ០៣ (បី) ឆ្នាំ ។

-ចំណុចផ្សេងក្រៅពីនេះត្រូវរក្សាទុកនៅដដែល ។

៣-ទណ្ឌិតត្រូវអនុវត្តវិធានការត្រួតពិនិត្យដូចតទៅ៖

ក.ទណ្ឌិតត្រូវតែគោរពតាមដីកាកោះរបស់ព្រះរាជអាជ្ញាឬរបស់បុគ្គលដែលព្រះរាជអាជ្ញាបានប្រគល់អំណាចឱ្យ។

ខ.ទណ្ឌិតត្រូវមកទទួលនូវការមកពិនិត្យមើលរបស់បុគ្គលដែលព្រះរាជអាជ្ញាបានប្រគល់អំណាចឱ្យ។

គ.ទណ្ឌិតត្រូវប្រគល់ដល់ព្រះរាជអាជ្ញាឬដល់បុគ្គលដែលព្រះរាជអាជ្ញាបានប្រគល់អំណាចឱ្យ នូវគ្រប់ឯកសារសម្រាប់ធ្វើការផ្ទៀងផ្ទាត់លើការបញ្ចូលឱ្យទៅរស់នៅក្នុងសង្គមវិញ។

ឃ.ទណ្ឌិតត្រូវជូនដំណឹងដល់ព្រះរាជអាជ្ញាអំពីការផ្លាស់ប្តូរអាសយដ្ឋាននិងមុខរបររបស់ខ្លួន ។

ង.ទណ្ឌិតត្រូវតែមានការអនុញ្ញាតពីព្រះរាជអាជ្ញា មុនពេលធ្វើដំណើរទៅបរទេស ។

៤-ទណ្ឌិតត្រូវអនុវត្តកាតព្វកិច្ចដោយឡែកដូចតទៅ៖

-មិនត្រូវសេពគប់ជាមួយបុគ្គលដែលបានផ្តើមគំនិតក្នុងអំពើដែលខ្លួនបានប្រព្រឹត្តខាងលើ ។

៥-សាលដីកានេះជំនុំជម្រះជាសាធារណៈនៅថ្ងៃទី២៥ ខែតុលា ឆ្នាំ២០២១ ចំពោះមុខជនជាប់ចោទ , មេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី និងប្រកាសជាសាធារណៈនៅថ្ងៃទី១២ ខែវិច្ឆិកា ឆ្នាំ២០២១ ។

ទុកសិទ្ធិប្តឹងសាទុក្ខតាមកំណត់ច្បាប់។

**-បានឃើញ ពាក្យបណ្តឹងសាទុក្ខលេខ ៣៧៥ ចុះថ្ងៃទី០៣ ខែធ្នូ ឆ្នាំ២០២១ របស់ឯកឧត្តមអគ្គព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍ភ្នំពេញក្នុងការប្តឹងសាទុក្ខ បានប្តឹងមិនសុខចិត្តនឹងសាលដីកាព្រហ្មទណ្ឌលេខ ១១០ ក្រ V "វ" ចុះថ្ងៃទី១២ ខែវិច្ឆិកា ឆ្នាំ២០២១ របស់សាលាឧទ្ធរណ៍ភ្នំពេញ ត្រង់ចំណុចទី២.ក និងចំណុចទី២.ខ លើឈ្មោះ និងឈ្មោះ ដោយហេតុថា សាលាឧទ្ធរណ៍ភ្នំពេញសម្រេចទោសស្រាលពេក ។**

**-បានឃើញ ពាក្យបណ្តឹងសាទុក្ខលេខ ៣៩៥ ចុះថ្ងៃទី១០ ខែធ្នូ ឆ្នាំ២០២១ របស់ឯកឧត្តមអគ្គព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍ភ្នំពេញក្នុងការប្តឹងសាទុក្ខ បានប្តឹងមិនសុខចិត្តនឹងសាលដីកាព្រហ្មទណ្ឌលេខ ១១០ ក្រ V "វ" ចុះថ្ងៃទី១២ ខែវិច្ឆិកា ឆ្នាំ២០២១ របស់សាលាឧទ្ធរណ៍ភ្នំពេញ ត្រង់ចំណុចនៃសេចក្តីសម្រេចលើឈ្មោះ ដោយហេតុថា សាលាឧទ្ធរណ៍ភ្នំពេញសម្រេចទោសស្រាលពេក ។**

**-បានឃើញ ពាក្យបណ្តឹងសាទុក្ខលេខ ៣៧១ ចុះថ្ងៃទី០៣ ខែធ្នូ ឆ្នាំ២០២១ របស់ជនជាប់ចោទឈ្មោះ វ៉ង ឈុន និងឈ្មោះ ក្នុងការប្តឹងសាទុក្ខ បានប្តឹងមិនសុខចិត្តនឹងសាលដីកាព្រហ្មទណ្ឌលេខ ១១០ ក្រ V "វ" ចុះថ្ងៃទី១២ ខែវិច្ឆិកា ឆ្នាំ២០២១ របស់សាលាឧទ្ធរណ៍ភ្នំពេញ ត្រង់ចំណុចនៃសេចក្តីសម្រេចទាំងមូល។**

**-បានឃើញ ពាក្យបណ្តឹងសាទុក្ខលេខ ៣៩៤ ចុះថ្ងៃទី០៨ ខែធ្នូ ឆ្នាំ២០២១ របស់លោក ជាមេធាវីទទួលសិទ្ធិតំណាងឱ្យជនជាប់ចោទឈ្មោះ ឈ្មោះ និងឈ្មោះ ក្នុងការប្តឹងសាទុក្ខ បានប្តឹងមិនសុខចិត្តនឹងសាលដីកាព្រហ្មទណ្ឌលេខ ១១០ ក្រ V "វ" ចុះថ្ងៃទី១២ ខែវិច្ឆិកា ឆ្នាំ២០២១ របស់សាលាឧទ្ធរណ៍ភ្នំពេញ ត្រង់ចំណុចនៃសេចក្តីសម្រេចទាំងមូល។**

**នាពេលសវនាការ**

**-ចៅក្រមរបាយការណ៍ឡើងធ្វើសេចក្តីរាយការណ៍។**

**-សេចក្តីសន្និដ្ឋានរបស់តំណាងមហាអយ្យការអមតុលាការកំពូលបានលើកឡើងថា៖** តាមសារណារបស់អគ្គព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍ភ្នំពេញមិនសុខចិត្តនឹងការសម្រេចរបស់សាលាឧទ្ធរណ៍ ចំពោះទោសស្រាលពេក។ មហាអយ្យការអមសាលាឧទ្ធរណ៍បានធ្វើសេចក្តីសន្និដ្ឋានជាលាយល័ក្ខអក្សរ និងផ្ទាល់មាត់នាពេលសវនាការ ប៉ុន្តែសាលាឧទ្ធរណ៍មិនបានសម្រេចលើពាក្យប្តឹងសុំរបស់អយ្យការដែលយល់ឃើញក្នុងសាលដីកា ពុំស្របតាមមាត្រា៤១៩ ចំណុច៦ នៃក្រមនីតិវិធីព្រហ្មទណ្ឌ។ សារណាការពារបណ្តឹងសាទុក្ខរបស់ជនជាប់ចោទឈ្មោះ និងឈ្មោះ មិនមានចូលក្នុងបញ្ហាណាមួយក្នុងមាត្រា ៤១៩ នៃក្រមនីតិវិធីព្រហ្មទណ្ឌទេ។ សាលដីកាព្រហ្មទណ្ឌលេខ **១១០ ក្រ V "វ"** ចុះថ្ងៃទី១២ ខែវិច្ឆិកា ឆ្នាំ២០២១ របស់សាលាឧទ្ធរណ៍ភ្នំពេញសម្រេចមិនត្រឹមត្រូវតាមគតិច្បាប់ទេ គប្បីបដិសេធចោល។ បដិសេធសាលដីកាព្រហ្មទណ្ឌ **១១០ ក្រ V "វ"** ចុះថ្ងៃទី១២ ខែវិច្ឆិកា ឆ្នាំ២០២១ របស់សាលាឧទ្ធរណ៍ភ្នំពេញចោលជាអាសាបង់ និងបង្វិលសំណុំរឿងនេះទៅសាលាឧទ្ធរណ៍ដើម្បីជំនុំជម្រះឡើងវិញ។

-ក្រឡាបញ្ជីអានសារណាការពាររបស់ជនជាប់ចោទឈ្មោះ ចុះថ្ងៃទី២០ ខែធ្នូ ឆ្នាំ២០២១។

-ក្រឡាបញ្ជីអានសារណាការពាររបស់ជនជាប់ចោទឈ្មោះ ចុះថ្ងៃទី១៨ ខែធ្នូ ឆ្នាំ២០២១។

-ក្រឡាបញ្ជីអានសេចក្តីសន្និដ្ឋានការពាររបស់លោក ជាមេធាវីការពារសិទ្ធិឱ្យជនជាប់ចោទឈ្មោះ ចុះថ្ងៃទី១៣ ខែឧសភា ឆ្នាំ២០២២។

-ក្រឡាបញ្ជីអានសារណាឆ្លើយតបរបស់លោក និងលោក តំណាងដោយអាណត្តិ និងផលប្រយោជន៍របស់គណៈកម្មាធិការចម្រុះកិច្ចការព្រំដែន ចុះថ្ងៃទី២១ ខែកុម្ភៈ ឆ្នាំ២០២២។

**- ក្រោយពីបានស្តាប់សេចក្តីរាយការណ៍របស់ចៅក្រមរបាយការណ៍**

**- ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានរបស់តំណាងមហាអយ្យការ**

**- ក្រោយពីបានស្តាប់អំណានសារណាការពារខ្លួនរបស់ជនជាប់ចោទ និងសេចក្តីសន្និដ្ឋានរបស់មេធាវីការពារឱ្យជនជាប់ចោទ**

**- ក្រោយពីបានពិនិត្យ ពិចារណា ពិភាក្សាត្រឹមត្រូវតាមច្បាប់ហើយ ។**

## សំអាងហេតុ

## តុលាការកំពូល

**១-យល់ឃើញថា** បណ្តឹងសាទុក្ខលេខ **៣៧៥** ចុះថ្ងៃទី០៣ ខែធ្នូ ឆ្នាំ២០២១ និងលេខ **៣៩៥** ចុះថ្ងៃទី១០ ខែធ្នូ ឆ្នាំ២០២១ របស់អគ្គព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍ភ្នំពេញ , បណ្តឹងសាទុក្ខលេខ **៣៧១** ចុះថ្ងៃទី០៣ ខែធ្នូ ឆ្នាំ២០២១ របស់ជនជាប់ចោទឈ្មោះ និងឈ្មោះ និងបណ្តឹងសាទុក្ខលេខ **៣៩៤** ចុះថ្ងៃទី០៩ ខែធ្នូ ឆ្នាំ២០២១ របស់លោក ជាមេធាវីទទួលសិទ្ធិតំណាងក្នុងការប្តឹងសាទុក្ខឱ្យជនជាប់ចោទឈ្មោះ , ឈ្មោះ និងឈ្មោះ ធ្វើឡើងក្នុងកំណត់ច្បាប់ តុលាការកំពូលអាចលើករឿងនេះមកជំនុំជម្រះបាន តាមបទប្បញ្ញត្តិមាត្រា ៦៤ ច្បាប់ស្តីពីការរៀបចំអង្គការតុលាការនិងមាត្រា ៤១៧, មាត្រា ៤១៨ ,មាត្រា ៤២០ និងមាត្រា ៤២២ កថាខណ្ឌទី២ វាក្យខណ្ឌទី១ និងទី២ ក្រមនីតិវិធីព្រហ្មទណ្ឌ។

**២-យល់ឃើញថា** តាមសេចក្តីសុំប្តឹងសាទុក្ខចុះថ្ងៃទី០៣ ខែធ្នូ ឆ្នាំ២០១២១ របស់ឯកឧត្តមអគ្គព្រះរាជអាជ្ញាអម សាលាឧទ្ធរណ៍ភ្នំពេញ ធ្វើឡើងប្រឆាំងនឹងសាលដីកាព្រហ្មទណ្ឌរបស់ សាលាឧទ្ធរណ៍ភ្នំពេញ ត្រង់ចំណុចទី២-ក និង ចំណុច ២-ខ លើជនជាប់ចោទឈ្មោះ ឈ្មោះ និងតាមសេចក្តីសុំប្តឹងសាទុក្ខចុះថ្ងៃទី១០ ខែធ្នូ ឆ្នាំ ២០២១ លើជនជាប់ចោទឈ្មោះ ដោយលើកឡើងថា ការប្រកាសទោសលើជនជាប់ចោទទាំង ៣ នាក់ ស្ថិតក្នុងកម្រិតស្រាលនោះ តុលាការកំពូលពិនិត្យពិចារណាឃើញថា តាមសំអាងហេតុទី៨ កថាខណ្ឌ៤ នៃសាលដីកា សាលាឧទ្ធរណ៍បានបង្ហាញច្បាស់លាស់ហើយ តុលាការកំពូល ឯកភាពនឹងសំអាងហេតុនេះ ។ លើសពីនេះទៀត បណ្តឹងសាទុក្ខរបស់អគ្គព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍ភ្នំពេញ ធ្វើឡើងមិនមានមូលហេតុនៃបណ្តឹងសាទុក្ខស្របតាមបញ្ញត្តិមាត្រា ៤១៩ នៃក្រមនីតិវិធីព្រហ្មទណ្ឌឡើយ។

**៣-យល់ឃើញថា** បុគ្គលប្តឹងសាទុក្ខជាជនជាប់ចោទ ៣ នាក់ ឈ្មោះ ,ឈ្មោះ និងឈ្មោះ ប៉ុន្តែក្នុងនីតិវិធីនៃការដាក់សារណាការពារតាមផ្លូវច្បាប់ បុគ្គល ប្តឹងសាទុក្ខជនជាប់ចោទឈ្មោះ តុន និមល មិនបានដាក់សារណាការពារឡើយ។ ដូច្នេះ តាម បញ្ញត្តិមាត្រា ៤១៩ (មូលហេតុនៃបណ្តឹងសាទុក្ខ) និងមាត្រា ៤៣៦ (សេចក្តីសម្រេចលើបញ្ហា គតិយុត្ត) នៃក្រមនីតិវិធីព្រហ្មទណ្ឌ បណ្តឹងសាទុក្ខរបស់ឈ្មោះ គឺគ្មានមូលហេតុនៃ បណ្តឹងសាទុក្ខឡើយ ដែលគប្បីតុលាការកំពូលបដិសេធចោល ។

**៤-យល់ឃើញថា** ការដែលជនជាប់ចោទឈ្មោះ អះអាងតាមសារណាការពារ ក្នុងនីតិវិធីនៃបណ្តឹងសាទុក្ខរបស់ខ្លួនថារឿងរ៉ាវកន្លងមកនាថ្ងៃទី២០ ខែកក្កដា ឆ្នាំ២០២០ ខ្លួនគ្រាន់តែចុះទៅដល់ទីតាំងដីទំនាស់របស់ ប្រជាពលរដ្ឋនិងបង្គោលព្រំដែន ដោយជួបសំណេះសំណាលជាមួយតំណាងប្រជាពលរដ្ឋរងគ្រោះប្រមាណ ១០៦ គ្រួសារ ។ នៅថ្ងៃទី២១ ខែកក្កដា ឆ្នាំ២០២០ ខ្លួនបានធ្វើសេចក្តីថ្លែងការណ៍អំពីហេតុការណ៍ដែលជួបជាមួយប្រជាពលរដ្ឋ ដូចជាការបាត់បង់ទឹកដី និងផ្នែកបញ្ចប់នៃសេចក្តីថ្លែងការណ៍ គឺខ្លួនគ្រាន់តែបានស្នើសុំទៅអាជ្ញាធរឱ្យ ពង្រឹងកងកម្លាំងការពារព្រំដែនតាមខ្សែបន្ទាត់ព្រំដែនកុំឱ្យប្រទេសជិតខាង ចូលមកក្នុងដែន អធិបតេយ្យកម្ពុជា ដែលសកម្មភាពរបស់ខ្លួននេះមិនមែនជាការប្រព្រឹត្តអំពើញុះញង់បង្កឱ្យមានភាពវឹកវរធ្ងន់ធ្ងរ ដល់សន្តិសុខសង្គម ដូចការប្រកាន់តុលាការអង្គហេតុទេ ហើយ ខ្លួនក៏មិនបាន ចោទប្រកាន់ថា គណៈកម្មាធិការចម្រុះកិច្ចការព្រំដែន ឬ រាជរដ្ឋាភិបាលធ្វើឱ្យមានការបាត់ដី ឬក៏ ធ្វើឱ្យខ្សែបន្ទាត់ព្រំដែនរំកិលចូលមកទឹកដីកម្ពុជាទេ ហេតុនេះ ខ្លួនស្នើសុំរួចខ្លួនពីបទចោទប្រកាន់ នោះជាការមិនត្រឹមត្រូវទេ ព្រោះថា តាមភស្តុតាងនានា ជាពិសេសគឺសេចក្តីថ្លែងការណ៍របស់ ជនជាប់ចោទផ្ទាល់ ចុះថ្ងៃទី២១ ខែកក្កដា ឆ្នាំ២០២០ ដោយភ្ជាប់ជាមួយខ្លឹមសារថា "*ការបោះ បង្គោលព្រំដែនពីលេខ ១១៥ ដល់លេខ ១១៩ មានភាពមិនប្រក្រតីច្រើន ដែលធ្វើឱ្យប្រជាពលរដ្ឋ បាត់បង់ដីអាស្រ័យផលទៅភាគីយួនជាច្រើនរយហិកតា ហើយគិតពីបន្ទាត់ព្រំដែនចាស់ មកដល់ ការបោះបង្គោលឡាក់និងបង្គោលរណបថ្មីបានចូលមកប្រហែល ៥០០ ម៉ែត្រក្នុងទឹកដីកម្ពុជា ខ្សែ បន្ទាត់ព្រំដែនចេះតែរំកិលបន្តិចម្តងៗចូលមកក្នុងទឹកដីកម្ពុជាប្រមាណជា ៣ គីឡូម៉ែត្រ។ លើស ពីនេះអាជ្ញាធរយួនក៏បានមកចូលរួមបណ្តេញ និងរុញច្រានប្រជាពលរដ្ឋខ្មែរដែលរងគ្រោះពីដីធ្លី ចូលប្រមាណជាង ២០០ម៉ែត្រក្នុងដីខ្មែរ ដែលអាជ្ញាធរមិនបានទប់ស្កាត់ចំពោះទង្វើអាជ្ញាធរយួន ធ្វើមកលើពលរដ្ឋរងគ្រោះនៅឃុំត្រពាំងផ្លុង ស្រុកពញាក្រែក ខេត្តត្បូងឃ្មុំ...*"។ ដោយមានការ ចូលរួមសហការណ៍ក្នុងការចែករំលែកនូវខ្លឹមសារនៃសេចក្តីថ្លែងការណ៍ ដូចជាការបង្ហោះតាមបណ្តាញសង្គម គឺមានចរិតជាការញុះញង់ ក៏ដូចជាផ្សព្វផ្សាយនូវពត៌មានបំផ្លើសការពិត ក្នុង

គោលបំណងបំភ័ន្តសាធារណៈមតិជាតិនិងអន្តរជាតិ ។ សកម្មភាពរបស់ជនជាប់ចោទឈ្មោះ គឺជាសញ្ញាណរួមផ្សំបង្កើតបានជាបទល្មើសដូចការកំណត់របស់តុលាការអង្គហេតុ លើសពីនេះទៀត សំអាងហេតុទី២ កថាខណ្ឌ២, ទី៤ នៃសាលដីការបស់សាលាឧទ្ធរណ៍ និងសំអាង ហេតុទី២៣ នៃសាលក្រមរបស់សាលាដំបូងរាជធានីភ្នំពេញ ក៏បានបញ្ជាក់ច្បាស់លាស់អំពី អត្ថិភាពនៃធាតុចេតនា និងបទល្មើសដែលប្រព្រឹត្តឡើងដោយជនជាប់ចោទឈ្មោះ ។

**៥-យល់ឃើញថា** ការដែលបុគ្គលប្តឹងសាទុក្ខជនជាប់ចោទឈ្មោះ បានអះអាង តាមសារណាការពារ ក៏ដូចជាតាមសេចក្តីសន្និដ្ឋានការពារក្តីរបស់មេធាវីការពារសិទ្ធិ បានបញ្ជាក់ថា សាលាដំបូងរាជធានីភ្នំពេញ ក៏ដូចជាសាលាឧទ្ធរណ៍ភ្នំពេញ បានសម្រេចផ្តន្ទាទោសភាគីខ្លួនដោយមិនមានភស្តុតាង មិនមានសាក្សី ដែលបញ្ជាក់ថាជនជាប់ចោទឈ្មោះ មាន ការពាក់ព័ន្ធនឹងហេតុការណ៍ ថ្ងៃទី២០,២១ ខែកក្កដា ឆ្នាំ២០២០ ជាមួយឈ្មោះ ទេ។ ពីថ្ងៃទី២១ ខែកក្កដា ឆ្នាំ២០២០ រហូតដល់ថ្ងៃទី៣១ ខែកក្កដា ឆ្នាំ២០២០ ភាគីខ្លួនក៏មិនបាន ប្រព្រឹត្តអំពើអ្វីពាក់ព័ន្ធនឹងព្រំដែនដែរ សូម្បីតែសេចក្តីថ្លែងការណ៍ ចុះថ្ងៃទី៣១ ខែកក្កដា ឆ្នាំ ២០២០ របស់គណៈកម្មាធិការចម្រុះកិច្ចការព្រំដែន ក៏មិនមានបង្ហាញថា ឈ្មោះ មានការពាក់ព័ន្ធនឹងរឿងព្រំដែនដែរ ហើយក៏មិនមានជាប់ពាក់ព័ន្ធនឹងសេចក្តីថ្លែងការណ៍របស់ លោក ចេញនៅថ្ងៃទី២១ ខែកក្កដា ឆ្នាំ២០២០ ដែរ ហេតុនេះ ស្នើសុំរួចផុតពីបទចោទប្រកាន់ នោះជាការមិនត្រឹមត្រូវទេ ព្រោះថាតាមភស្តុតាងនានាដូចជា សាក្សីជានគរបាល យុត្តិធម៌ ឈ្មោះ ការធ្វើកោសលវិច័យលើទិន្នន័យក្នុងទូរស័ព្ទដៃរបស់ឈ្មោះ រួមនឹងការការសហការបង្ហោះតាមបណ្តាញសង្គម ចែករំលែកនូវខ្លឹមសារនៃសេចក្តី ថ្លែងការណ៍របស់ជនជាប់ចោទឈ្មោះ នោះគឺជាភស្តុតាង ហើយភស្តុតាងទាំងនេះ មានភាពស៊ីចង្វាក់គ្នា មានតម្លៃនិងទម្ងន់នៃភស្តុតាងដាក់បន្ទុកគ្រប់គ្រាន់ល្មមកំណត់បាននូវអត្ថិភាព នៃបទល្មើសនិងធាតុចេតនារបស់ជនជាប់ចោទឈ្មោះ ដូចការកំណត់ពិរុទ្ធភាពនិង ទោសរបស់តុលាការអង្គហេតុ ។ លើសពីនេះទៀត សំអាងហេតុទី៣,ទី៤ នៃសាលដីការបស់ សាលាឧទ្ធរណ៍, សំអាងហេតុទី១៤ នៃសាលក្រមរបស់សាលាដំបូងក៏បានបញ្ជាក់អំពីអត្ថិភាព នៃបទល្មើសប្រព្រឹត្តដោយជនជាប់ចោទឈ្មោះ **ស គណិការ** ដែរ តុលាការកំពូលឯកភាពចំពោះ សំអាងហេតុទាំងនោះ។

**៦-យល់ឃើញថា** តាមសំអាងហេតុខាងលើនេះ បណ្តឹងសាទុក្ខរបស់បុគ្គលប្តឹងសាទុក្ខ ធ្វើឡើងពុំមានមូលហេតុនៃបណ្តឹងសាទុក្ខសមស្របតាមបញ្ញត្តិមាត្រា ៤១៩ នៃក្រមនីតិវិធីព្រហ្មទណ្ឌឡើយ ។

**៧-យល់ឃើញថា** តាមសេចក្តីសន្និដ្ឋានរបស់តំណាងមហាអយ្យការនៅក្នុងកិច្ចពិភាក្សាដេញដោលនាពេលសវនាការបានលើកឡើងថា តាមសារណាការពាររបស់អគ្គព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍ភ្នំពេញមិនសុខចិត្តនឹងការសម្រេចរបស់សាលាឧទ្ធរណ៍ភ្នំពេញ ចំពោះទោសស្រាលពេកនោះឃើញថា មានលក្ខណៈត្រឹមត្រូវហើយ ចំពោះសារណាការពារបណ្តឹងសាទុក្ខ របស់សហជនជាប់ចោទក៏មិនចូលក្នុងចំណុចណាមួយក្នុងមាត្រា ៤១៩ ក្រមនីតិវិធីព្រហ្មទណ្ឌទេ ហេតុនេះស្នើសុំតុលាការកំពូលពិចារណានិងសម្រេចតាមច្បាប់ នោះតុលាការពិចារណា ឃើញថាសេចក្តីសន្និដ្ឋាននេះមានលក្ខណៈត្រឹមត្រូវផ្នែកខ្លះ និងមិនមានមូលដ្ឋានផ្នែកខ្លះ ឯការដែលត្រឹមត្រូវ ដូចតុលាការកំពូលបានលើកនូវសំអាងហេតុដូចមានខាងលើនេះរួចហើយ។

**៨-យល់ឃើញថា** តាមសារណាតបរបស់មេធាវីតំណាងឱ្យដើមបណ្តឹងរដ្ឋប្បវេណី គណៈកម្មាធិការចម្រុះកិច្ចការព្រំដែន បានស្នើសុំក្រុមប្រឹក្សាជំនុំជម្រះសម្រេចតម្កល់សាលដីកាព្រហ្មទណ្ឌលេខ **១១០ ក្រV "រ"** ចុះថ្ងៃទី១២ ខែ

វិច្ឆិកា ឆ្នាំ២០២១ របស់សាលាឧទ្ធរណ៍ភ្នំពេញ ទុកជាបានការពេញទាំងមូល នោះតុលាការកំពូលពិនិត្យឃើញថា មានលក្ខណៈត្រឹមត្រូវដូចការ ដែលតុលាការកំពូលបានពិចារណាដូចសំអាងហេតុខាងលើនេះហើយ។

**៩-យល់ឃើញថា** សាលដីកាព្រហ្មទណ្ឌលេខ ១១០ ក្រV "រ" ចុះថ្ងៃទី១២ ខែវិច្ឆិកា ឆ្នាំ២០២១ របស់សាលាឧទ្ធរណ៍ភ្នំពេញដែលបានសម្រេចសេចក្តីមកនេះត្រឹមត្រូវតាមគតិច្បាប់ហើយ ។

## ហេតុដូច្នេះ

## សម្រេចសេចក្តី

១-បដិសេធបណ្តឹងសាទុក្ខលេខ **៣៧៥** ចុះថ្ងៃទី០៣ ខែធ្នូ ឆ្នាំ២០២១ និងលេខ ៣៩៥ ចុះថ្ងៃទី១០ ខែធ្នូ ឆ្នាំ២០២១ របស់អគ្គព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍ភ្នំពេញ។

២-បដិសេធបណ្តឹងសាទុក្ខលេខ **៣៧១** ចុះថ្ងៃទី០៣ ខែធ្នូ ឆ្នាំ២០២១ របស់ជនជាប់ចោទ ឈ្មោះ និង ឈ្មោះ និងបណ្តឹងសាទុក្ខលេខ **៣៩៤** ចុះថ្ងៃទី០៩ ខែធ្នូ ឆ្នាំ ២០២១ របស់លោក ជាមេធាវីទទួលសិទ្ធិតំណាងក្នុងការប្តឹងសាទុក្ខឱ្យជនជាប់ចោទ ឈ្មោះ ,ឈ្មោះ និងឈ្មោះ ។

៣-តម្កល់សាលដីកាព្រហ្មទណ្ឌលេខ **១១០** ក្រV "រ" ចុះថ្ងៃទី១២ ខែវិច្ឆិកា ឆ្នាំ២០២១ របស់សាលាឧទ្ធរណ៍ភ្នំពេញ។

សាលដីកានេះជំនុំជម្រះជាសាធារណៈនៅថ្ងៃទី២២ ខែកក្កដា ឆ្នាំ២០២២ និងប្រកាសនាសវនាការជាសាធារណៈនៅថ្ងៃទី២៩ ខែកក្កដា ឆ្នាំ២០២២ ។

-ឯកឧត្តម ជាប្រធាន

-ឯកឧត្តម ជាចៅក្រម

-ឯកឧត្តម ជាចៅក្រម

-លោកជំទាវ ជាចៅក្រម

-ឯកឧត្តម ជាចៅក្រម

-លោក ជាក្រឡាបញ្ជី

**បានឃើញ**

ថ្ងៃ[illegible] ខែស្រាពណ៍ ឆ្នាំខាល ចត្វាស័ក ព.ស.២៥៦៦

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី០២ ខែសីហា ឆ្នាំ ២០២២

**ប្រធានអង្គជំនុំជម្រះ**

**បានចម្លងត្រឹមត្រូវតាមច្បាប់ដើម។**

ថ្ងៃ[illegible] ខែស្រាពណ៍ ឆ្នាំខាល ចត្វាស័ក ព.ស.២៥៦៦

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី០២ ខែសីហា ឆ្នាំ២០២២

**ក្រឡាបញ្ជី**